# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ អបទាន
# តតិយភាគ
# ៧៤



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## KHUDDAKANIKĀYA

## APADĀNA

## TATIYABHĀGA

## 74

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិញ្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្កឹកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ  អបទាន

## តតិយភាគ

៧៤

ព.  ស.  ២៤០៦

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស អបទានំ

# តតិយោ ភាគោ

---

## ឯកត្តឹសតិមោ បទុមកេសរិយវគ្គោ

### បឋមំ បទុមកេសរិយត្ថេរាបទានំ

[១] ឥសិសង្ឃេ អហំ បុព្វេ　　អាសឹ មាតង្គវារណោ
មហេសីនំ បសាទេន　　បទុមកេសរមោកិរឹ ។
បច្ចេកជិនសេដ្ឋេសុ　　ធុតរាគេសុ តាទិសុ
តេសុ ចិត្តំ បសាទេត្វា　　កប្បំ សគ្គម្ហិ មោទហំ ។
ឯកនវុតេ ឥតោ កប្បេ　　កេសរំ ឱកិរឹ តទា
ទុគ្គតឹ នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនំ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ អបទាន

# តតិយភាគ

---

## បទុមកេសរិយវគ្គ ទី ៣១

## បទុមកេសរិយត្ថេរាបទាន ទី ១

[១] *ក្នុងភពមុន ខ្ញុំកើតជាដំរីឈ្មោះមាតង្គៈ នៅជិតពួកឥសី បានរោយរាយកេសរផ្កាឈូក ដោយចិត្តជ្រះថ្លា ថ្វាយចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ដែលទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាចំពោះព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់ឈ្នះមារដ៏ប្រសើរ ទ្រង់មានរាគៈកម្ចាត់បង់ហើយ ប្រកបដោយតាទិគុណ ហើយបានរីករាយ ក្នុងឋានសួគ៌អស់ ១ កប្ប ។ ក្នុងកប្ប ទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានរោយកេសរផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

ឥត្ថំ សុទំ អាយស្មា បទុមកេសរិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមកេសរិយត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ សព្វគន្ធិយត្ថេរាបទានំ

[២] គន្ធមាលំ មយា ទិន្នំ វិបស្សិស្ស មហេសិនោ
អទាសឹ ឧជុភូតស្ស កោសេយ្យវត្ថមុត្តមំ ។
ឯកនវុតេ ឥតោ កប្បេ យំ គន្ធមទទឹ តទា[១]
ទុគ្គតឹ នាភិជានាមិ គន្ធទានស្សិទំ ផលំ ។
ឥតោ បណ្ណរសេ កប្បេ សុចេឡោ នាម ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. យំ វត្ថមទទឹ បុរេតិ ទិស្សតិ ។

បានឮថា ព្រះបទុមកេសរិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមកេសរិយត្ថេរាបទាន ។

# សព្វគន្ធិយត្ថេរាបទាន ទី ២

[២] ខ្ញុំបានថ្វាយគ្រឿងក្រអូបនិងកម្រងផ្កា ដល់ព្រះពុទ្ធព្រះនាមវិបស្សី ទ្រង់ស្វែងរកគុណដ៏ធំ ទាំងបានថ្វាយសំពត់កោសេយ្យពស្ត្រដ៏ឧត្តម ដល់ព្រះពុទ្ធទ្រង់មានព្រះសន្តានដ៏ត្រង់ ។ ក្នុងកប្ប ទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយគ្រឿងក្រអូបនិងកម្រងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយគ្រឿងក្រអូប ។ ក្នុងកប្បទី ១៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុវេលៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំបានប្រតិបត្តិហើយ ។

៣

តតិយំ បរមន្នទាយកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា សព្វគន្ធិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សព្វគន្ធិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ បរមន្នទាយកត្ថេរាបទានំ

[៣] កណិការំវ ជោតន្តំ    ឧទយន្តំវ ភាណុមំ
វិបស្សឹ អទ្ទសំ ពុទ្ធំ    លោកជេដ្ឋំ នរាសភំ ។
អញ្ជលឹ បគ្គហេត្វាន    អភិនេសឹ សកំ ឃរំ
អភិនេត្វាន សម្ពុទ្ធំ    បរមន្នមទាសហំ ។
ឯកនវុតេ ឥតោ កប្បេ    បរមន្នមទំ តទា
ទុគ្គតឹ នាភិជានាមិ    បរមន្នស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បរមន្នទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បរមន្នទាយកត្ថេរស្ស អបទានំ សមត្តំ ។

បានឮថា ព្រះសព្វគន្ធិយត្ថេរ មានអាយុ សម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សព្វគន្ធិយត្ថេរាបទាន ។

# បរមន្នទាយកត្ថេរាបទាន ទី ៣

[៣] ខ្ញុំបានឃើញព្រះពុទ្ធព្រះនាមវិបស្សី ទ្រង់ជាឆ្នើមក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់រុងរឿងដូចផ្កាកណិការ ឬក៏ដូចព្រះអាទិត្យដែលទើបនឹងរះ ។ ខ្ញុំផ្គងអញ្ជលី និមន្តឲ្យស្តេចទៅផ្ទះរបស់ខ្លួន លុះនាំព្រះសម្ពុទ្ធទៅហើយ ក៏បានថ្វាយនូវបាយាសដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយបាយាសដ៏ប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយបាយាសដ៏ប្រសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបរមន្នទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បរមន្នទាយកត្ថេរាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ចតុត្ថំ ធម្មសញ្ញកត្ថេរាបទានំ

[៤] វិបស្សិនោ ភគវតោ មហាពោធិមហោ អហុ
រុក្ខដ្ឋស្សេវ សម្ពុទ្ធោ លោកជេដ្ឋោ នរាសភោ ។
ភគវា តម្ហិ សមយេ ភិក្ខុសង្ឃបុរក្ខតោ
ចតុសច្ចំ បកាសេតិ វាចាសភិមុទីរយំ ។
សង្ខិត្តេន ច ទេសេន្តោ វិត្ថារេន ច ទេសយិ
វិវដច្ឆទោ សម្ពុទ្ធោ និព្វាបេសិ មហាជនំ ។
តស្សាហំ ធម្មំ សុត្វាន លោកជេដ្ឋស្ស តាទិនោ
វន្ទិត្វា សត្ថុនោ បាទេ បក្កាមិ ឧត្តរាមុខោ ។
ឯកនវុតេ ឥតោ កប្បេ យំ ធម្មមសុណឹ តទា
ទុគ្គតឹ នាភិជានាមិ ធម្មស្សវនស្សិទំ ផលំ ។
តេត្តឹសម្ហិ ឥតោ កប្បេ ឯកោ អាសិ មហីបតិ
សុតវា នាម នាមេន ចក្កវត្តិ មហព្វលោ ។

# ធម្មសញ្ញកត្ថេរាបទាន ទី ៩

[៤] មានពិធីឆ្លងមហាពោធិព្រឹក្ស របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ឯព្រះសម្ពុទ្ធជាច្បងក្នុងលោក ប្រសើរជាងនរៈ ទ្រង់ឋិតនៅទៀបដើមពោធិព្រឹក្ស ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ ទ្រង់មានភិក្ខុសង្ឃចោមរោម ទ្រង់ប្រកាសសច្ចៈ ៤ ទ្រង់បន្លឺឡើងនូវវាចាដ៏អង់អាច ។ ព្រះសម្ពុទ្ធមានកិលេសជាគ្រឿងបិទបើកហើយ ទ្រង់សម្តែងធម៌ដោយបម្រួញផង ដោយពិស្តារផង ទ្រង់ញ៉ាំងមហាជនឲ្យរលត់ទុក្ខ ។ ខ្ញុំបានស្តាប់ធម៌ របស់ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ជាធ្មេមក្នុងលោក ប្រកបដោយតាទិគុណ ហើយថ្វាយបង្គំព្រះបាទា របស់ព្រះសាស្តា រួចឈមមុខទៅកាន់ឧត្តរទិស ហើយចៀសចេញទៅ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានស្តាប់ធម៌ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្តាប់ធម៌ ។ ក្នុងកប្បទី ៣៣ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គព្រះនាមសុតវា ជាម្ចាស់ផែនដី ទ្រង់មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ធម្មសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ ផលទាយកត្ថេរាបទានំ

[៤] ភាគីរសីនទីតីរេ    អហោសិ អស្សមោ តទា
តមហំ អស្សមាគញ្ឆឹ    ផលហត្ថោ អសេខវា[១] ។
វិបស្សឹ តត្ថ អទ្ទក្ខឹ    បីតរំសីវ ភាណុមំ
យំ មេ អត្ថិ ផលំ សព្វំ    អទាសឹ សត្ថុនោ អហំ ។
ឯកនវុតេ ឥតោ កប្បេ    យំ ផលំ មទទឹ តទា
ទុគ្គតឹ នាភិជានាមិ    ផលទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ម. អបេក្ខវា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មសញ្ញកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មសញ្ញកត្ថេរាបទាន ។

# ផលទាយកត្ថេរាបទាន ទី ៥

[៥] កាលនោះ មានអាស្រមនៅទៀបឆ្នេរស្ទឹង ឈ្មោះភាគីរសី ខ្ញុំជាអ្នកមិនបានសិក្សា កាន់យកផ្លែឈើដើរតម្រង់មកអាស្រមនោះ ខ្ញុំបានឃើញព្រះវិបស្សី គង់ក្នុងអាស្រមនោះ ទ្រង់មានរស្មីលឿងដូចព្រះអាទិត្យ ខ្ញុំក៏បានថ្វាយផ្លែឈើទាំងអស់របស់ខ្ញុំ ដល់ព្រះសាស្ដា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែឈើ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែឈើ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

៦

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ឥត្ថំ សុទំ អាយស្មា ផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ សម្បសាទកត្ថេរាបទានំ

[៦] នមោ តេ ពុទ្ធវីរត្ថុ វិប្បមុត្តោសិ សព្វធិ
ព្យសនម្ហិ អនុប្បត្តោ តស្ស មេ សរណំ ភវ ។
សិទ្ធត្ថោ តស្ស ព្យាកាសិ លោកេ អប្បដិបុគ្គលោ
មហោទធិសមោ សង្ឃោ អប្បមេយ្យោ អនុត្តរោ ។
តត្ថ ត្វំ វិរជេ ខេត្តេ អនន្តផលទាយកេ
សង្ឃេ ចិត្តំ បសាទេហិ សុវីជំ វាបិ រោបយ ។
ឥទំ វត្វាន សព្វញ្ញូ លោកជេដ្ឋោ នរាសភោ
មមេវំ អនុសាសិត្វា វេហាសតលមុគ្គមិ ។

*បានឮថា ព្រះផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ ផលទាយកត្ថេរាបទាន ។

# សម្បសាទិកត្ថេរាបទាន ទី ៦

[៦] *បពិត្រព្រះពុទ្ធមានព្យាយាម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ព្រះអង្គផុតស្រឡះហើយ ចាកកិលេសទាំងពួង ខ្ញុំព្រះអង្គដល់ហើយនូវសេចក្តីវិនាស សូមព្រះអង្គជាទីពឹងរបស់ខ្ញុំនោះ ។ ព្រះសិទ្ធត្ថ ទ្រង់មិនមានបុគ្គលប្រៀបផ្ទឹម ក្នុងលោក ទ្រង់សម្តែងប្រាប់ខ្ញុំថា ព្រះសង្ឃស្មើដោយមហាសមុទ្រ ប្រមាណមិនបាន ប្រសើរបំផុត អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ទាំងចូរបណ្តុះនូវពូជដ៏ល្អ ក្នុងព្រះសង្ឃដែលទុកជាស្រែមិនមានធូលីគឺរាគៈ ជាស្រែប្រគល់ឲ្យផល ឥតមានទីបំផុត ។ ព្រះសព្វញ្ញូ ជាឆ្នើមក្នុងលោក ព្រះអង្គប្រសើរជាងពួកនរៈ លុះទ្រង់សម្តែងនូវពាក្យនេះ ទ្រង់ប្រៀនប្រដៅខ្ញុំយ៉ាងនេះហើយ ក៏ស្តេចហោះឡើងទៅឯផ្ទៃអាកាស ។*

៧

ឆដ្ឋំ សម្បសាទិកត្ថេរាបទានំ

អចិរំ កតមត្តម្ហិ    សព្វញ្ញុម្ហិ នរាសភេ
មរណំ សមនុប្បត្តោ    តុសិតំ ឧបបជ្ជហំ ។
តទាហំ វិរជេ ខេត្តេ    អនន្តផលទាយកោ
សង្ឃេ ចិត្តំ បសាទេត្វា    កប្បំ សគ្គម្ហិ មោទហំ ។
ចតុន្នវុតេ ឥតោ កប្បេ    បសាទមលភឹ តទា
ទុគ្គតឹ នាភិជានាមិ    បសាទស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សម្បសាទិកោ ថេរោ ឥមា កាថាយោ អភាសិត្ថាតិ ។

សម្បសាទិកត្ថេរស្ស អបទានំ សមត្តំ ។

## សម្បសាទិកត្ថេរាបទាន ទី ៦

កាលដែលព្រះសព្វញ្ញូ ប្រសើរជាងពួកនរៈ ស្តេចពុទ្ធដំណើរ ទៅហើយ មិនយូរប៉ុន្មាន ខ្ញុំក៏ដល់នូវមរណៈ ហើយបាន ទៅកើតក្នុងឋានតុសិត ។ ក្នុងកាលនោះ ខ្ញុំបានញ៉ាំងចិត្ត ឲ្យជ្រះថ្លាក្នុងព្រះសង្ឃ ដែលជាស្រែមិនមានធូលី ជាស្រែ ប្រគល់ឲ្យផលឥតមានទីបំផុត ខ្ញុំបានរីករាយហើយ ក្នុងឋាន សួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុង កាលនោះ ព្រោះហេតុដែលខ្ញុំមានសេចក្តីជ្រះថ្លា ខ្ញុំមិនដែល ស្គាល់ទុគ្គតិ នេះជាផលនៃសេចក្តីជ្រះថ្លា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសម្បសាទិកត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សម្បសាទិកត្ថេរាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# សត្តមំ អារាមទាយកត្ថេរាបទានំ

[៧] សិទ្ធត្ថស្ស ភគវតោ　　អារាមោ រោបិតោ មម
សីតច្ឆាយេសុ រុក្ខេសុ　　ឧបាសន្តេសុ បក្ខិសុ ។
អទ្ទសំ វិរជំ ពុទ្ធំ　　អាហុតីនំ បដិគ្គហំ
អារាមំ អភិនាមេសឹ　　លោកជេដ្ឋំ នរាសភំ ។
ហដ្ឋោ ហដ្ឋេន ចិត្តេន　　ផលំ បុប្ផញ្ចទាសហំ
តតោ ជាតប្បសាទោ ច　　តំ ទានំ បរិណាមយឹ ។
ពុទ្ធស្ស យមិទំ ទាសឹ　　វិប្បសន្នេន ចេតសា
ភវេ និព្វត្តមានម្ហិ　　និព្វត្តតិ ផលំ មម ។
ចតុន្នវុតេ ឥតោ កប្បេ　　យំ អារាមមទំ តទា
ទុគ្គតឹ នាភិជានាមិ　　អារាមស្ស ឥទំ ផលំ ។
សត្តត្តឹសេ ឥតោ កប្បេ　　សត្តាសុំ មុទុសីតលា
សត្តរតនសម្បន្នា　　ចក្កវត្តី មហព្វលា ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# អារាមទាយកត្ថេរាបទាន ទី ៧

[៧] ខ្ញុំបានដាំសួនច្បារ ថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថ ពួកបក្សីចូលទៅអាស្រ័យ ឰដ៏ដើមឈើទាំងឡាយ ដែលមានម្លប់ត្រជាក់ ។ ខ្ញុំបានឃើញព្រះពុទ្ធ ទ្រង់មិនមានធូលី គឺកិលេស ទ្រង់គួរទទួលនូវគ្រឿងបូជា ទើបនាំព្រះសម្ពុទ្ធ ជាលោកជេដ្ឋ ប្រសើរជាងពួកនរៈ ទៅក្នុងសួនច្បារ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ បានថ្វាយផ្លែឈើនិងផ្កាឈើ ទាំងមានសេចក្តីជ្រះថ្លាខ្លាំង កើតឡើងក្នុងលំដាប់នោះ ហើយបង្អោនថ្វាយ នូវទាននោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយទានណា ដល់ព្រះពុទ្ធ ផលរមែងកើតសម្រាប់ខ្ញុំ ក្នុងភពដែលខ្ញុំកើតហើយ (ព្រោះការថ្វាយទាននោះ) ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយសួនច្បារ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសួនច្បារ ។ ក្នុងកប្បទី ៣៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមមុទុសីតលៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

៩

អដ្ឋមំ អនុលេបទាយកត្ថេរាបទានំ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អារាមទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អារាមទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ អនុលេបទាយកត្ថេរាបទានំ

[៨] អត្ថទស្សិស្ស មុនិនោ អទ្ទសំ សាវកំ អហំ
នវកម្មំ ករោន្តស្ស សីមាយ ឧបគញ្ឆហំ ។
និដ្ឋិតេ នវកម្មេ ច អនុលេបំ អទាសហំ
បសន្នចិត្តោ សុមនោ បុញ្ញក្ខេត្តេ អនុត្តរេ ។
អដ្ឋារសេ កប្បសតេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ អនុលេបស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អនុលេបទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អនុលេបទាយកត្ថេរស្ស អបទានំ សមត្តំ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំ បានប្រតិបត្តិហើយ ។

បានឮថា ព្រះអារាមទាយកត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អារាមទាយកត្ថេរាបទាន ។

# អនុលេបទាយកត្ថេរាបទាន ទី ៨

[៨] ខ្ញុំបានឃើញសាវ័ករបស់ព្រះមុនី ព្រះនាមអត្ថទស្សី កំពុងធ្វើនវកម្ម ខ្ញុំក៏ដើរចូលទៅក្នុងដែន ។ កាលដែលនវ-កម្មរួចស្រេច ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ ក៏បានថ្វាយ ថ្នាំលាបដល់សាវ័ក ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ក្នុងកប្បទី ១.៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃថ្នាំលាប ។ បដិស-ម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុលេបទាយកត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អនុលេបទាយកត្ថេរាបទាន ។

# នវមំ ពុទ្ធសញ្ញិកត្ថេរាបទានំ

[៩] ឧទេន្តំ សតរំសឹវ បីតរំសឹវ ភាណុមំ
វនន្តរគតំ សន្តំ លោកជេដ្ឋំ នរាសភំ
អទ្ទសំ សុបិនន្តេន សិទ្ធត្ថំ លោកនាយកំ
តត្ថ ចិត្តំ បសាទេត្វា សុគតឹ ឧបបជ្ជហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ពុទ្ធសញ្ញិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពុទ្ធសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# ពុទ្ធសញ្ញិកត្ថេរាបទាន ទី ៩

[៩] ខ្ញុំបានយល់សប្តិឃើញថា ព្រះសិទ្ធត្ថ ជាលោកនាយក ទ្រង់ជាធ្មើមក្នុងត្រៃលោក ទ្រង់ប្រសើរជាងពួកនរៈ ទ្រង់មានឥន្ទ្រិយស្ងប់រម្ងាប់ ស្តេចពុទ្ធដំណើរទៅ ក្នុងចន្លោះព្រៃ ទ្រង់មានរស្មីដូចព្រះអាទិត្យដែលទើបនឹងរះ ឬដូចព្រះអាទិត្យដែលមានរស្មីលឿង ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គនោះហើយ បានទៅកើតក្នុងសុគតិ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះពុទ្ធសញ្ញិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពុទ្ធសញ្ញិកត្ថេរាបទាន ។

១១

# ទសមំ បព្ភារទាយកត្ថេរាបទានំ

[១០] បិយទស្សិនោ ភគវតោ    បព្ភារោ សោធិតោ មយា
ឃដកញ្ច ឧបដ្ឋាសឹ    បរិភោគាយ តាទិនោ ។
តំ មេ ពុទ្ធោ វិយាកាសិ    បិយទស្សី មហាមុនិ
សហស្សកណ្ឌោ សតភេណ្ឌុ    ធជាលុ ហរិតាមយោ
និព្វត្តិស្សតិ សោ យូបោ    រតនញ្ច អនប្បកំ
បព្ភារទានំ ទត្វាន    កប្បំ សគ្គម្ហិ មោទហំ ។
ឥតោ ពត្តឹសកប្បម្ហិ    សុពុទ្ធោ នាម[១] ខត្តិយោ
សត្តរតនសម្បន្នោ    ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. សុសុទ្ធោ នាម ។

# បញ្ញារទាយកត្ថេរាបទាន ទី ១០

[១០] ខ្ញុំបានសម្អាតញកថ្វាយព្រះមានព្រះភាគ ព្រះនាមបិយទស្សី ព្រះអង្គប្រកបដោយតាទិគុណ ទាំងបានតម្កល់ទុកនូវក្អមទឹក សម្រាប់ប្រើប្រាស់ ។ ព្រះពុទ្ធជាមហាមុនី ព្រះនាមបិយទស្សី ទ្រង់ព្យាករឿងនោះ ប្រាប់ខ្ញុំថា ប្រាសាទជាវិការៈនៃកែវមណីខៀវ មានកម្ពស់មួយពាន់សង្កាត់ព្រួញ[១] មានជាន់ច្រើន បរិបូណ៌ដោយទង់នោះផង រតនៈដ៏ច្រើនផង នឹងកើតឡើងសម្រាប់អ្នក ខ្ញុំបានថ្វាយញកជាទាន ហើយខ្ញុំបានរីករាយក្នុងឋានសួគ៌អស់មួយកប្ប ។ ក្នុងកប្បទី ៣២ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសុពុទ្ធៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

---

១ ព្រួញដែលបាញ់ឡើងទៅអស់សន្ទុះ ហើយធ្លាក់ចុះមកវិញ ហៅថាមួយសង្កាត់ព្រួញ ។ អដ្ឋកថា ។

១២

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ឥត្ថំ សុទំ អាយស្មា បដ្ដារទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បដ្ដារទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ឧទ្ទានំ

កេសរំ គន្ធមន្ទញ្ច    ជម្ពុសញ្ញាជលេង ច
បសាទារាមទាយី ច    លេបកោ ពុទ្ធសញ្ញិកោ
បដ្ដារោ ច គាថាយោ    ឯកបញ្ញាស កត្តិតា ។

បទុមកេសរិយវគ្គោ ឯកត្តឹសតិមោ ។

---

បានឮថា ព្រះបញ្ញារទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ញារទាយកត្ថេរាបទាន ។

# ឧទ្ទាន

បទុមកេសរិយត្ថេរាបទាន ១ សព្វគន្ធិយត្ថេរាបទាន ១

បរមន្នទាយកត្ថេរាបទាន ១ ធម្មសញ្ញិកត្ថេរាបទាន ១

ផលទាយកត្ថេរាបទាន ១ សម្បសាទិកត្ថេរាបទាន ១

អារាមទាយកត្ថេរាបទាន ១ អនុលេបទាយកត្ថេរាបទាន ១

ពុទ្ធសញ្ញិកត្ថេរាបទាន ១ បញ្ញារទាយកត្ថេរាបទាន ១

មានគាថា ៥១ ដែលអ្នកប្រាជ្ញទាំងឡាយ បានគណនាហើយ ។

ចប់ បទុមកេសរិយវគ្គ ទី ៣១ ។

# ពត្តឹសោ អារក្ខទាយកវគ្គោ

## បឋមំ អារក្ខទាយកត្ថេរាបទានំ

[១១] ធម្មទស្សិស្ស មុនិនោ　　វតិ ការាបិតា មយា
អារក្ខោ ច មយា ទិន្នោ　　និបនិទ្ធស្ស តាទិនោ ។
អដ្ឋារសេ កប្បសតេ　　យំ កម្មមករឹ តទា
តេន កម្មាវសេសេន　　បត្តោ មេ អាសវក្ខយោ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អារក្ខទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អារក្ខទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អារក្ខទាយកវគ្គ ទី ៣២

## អារក្ខទាយកត្ថេរាបទាន ទី ១

[១១] ខ្ញុំបានឲ្យគេធ្វើរបង់ផង ខ្ញុំបានថ្វាយជនអ្នករក្សាផង ដល់ព្រះមុនីព្រះនាមធម្មទស្សី ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ១.៨០០ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ ខ្ញុំបានដល់នូវការអស់ទៅនៃអាសវៈដោយសេសសល់នៃកម្មនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអារក្ខទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អារក្ខទាយកត្ថេរាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ទុតិយំ ភោជនទាយកត្ថេរាបទានំ

[១២] សុជាតោ សាលលដ្ឋីវ សោភញ្ជនំ ឥវុគ្គតោ
ឥន្ទលដ្ឋីវាកាសេ វិរោចតិ សទា ជិនោ ។
តស្ស ទេវាតិទេវស្ស វេស្សភុស្ស មហេសិនោ
អទាសឹ ភោជនមហំ វិប្បសន្នេន ចេតសា ។
តំ មេ ពុទ្ធោ អនុមោទិ សយម្ភូ អបរាជិតោ
ភវេ និព្វត្តមានម្ហិ ផលំ និព្វត្តតុ តវ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ភោជនស្ស ឥទំ ផលំ ។
បញ្ចវីសេ ឥតោ កប្បេ ឯកោ អាសឹ អមិត្តកោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

# ភោជនទាយកត្ថេរាបទាន ទី ២

[១២] ព្រះជិនស្រី ទ្រង់មានព្រះជាតិដ៏ល្អដូចលំពង់សាលព្រឹក្ស ទ្រង់មានកម្ពស់សមដូចដើមម្រុំ ទ្រង់រុងរឿងសព្វកាល ដូចលំពង់ឥន្ទព្រឹក្សព្វដ៏អាកាស ។ ខ្ញុំមានចិត្តជ្រះថ្លាបានថ្វាយភោជន ដល់ព្រះវេស្សភូអង្គនោះ ដែលជាទេវតាក្រៃលែងជាងទេវតា ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះពុទ្ធជាសយម្ភូ ទ្រង់ឈ្នះមារ ទ្រង់អនុមោទនាភោជនទាន របស់ខ្ញុំនោះថា ផលចូរសម្រេចដល់អ្នក ក្នុងភពដែលអ្នកកើតចុះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភោជនទាន ។ ក្នុងកប្បទី ២៩ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមអមិត្តកៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ភោជនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភោជនទាយកត្ថេរស្ស អបទានំ សមត្តំ ។

# តតិយំ គតសញ្ញកត្ថេរាបទានំ

[១៣] អាកាសេវ បទំ នត្ថិ អម្ពរេ អនិលញ្ជសេ
សិទ្ធត្ថំ ជិនមទ្ទក្ខឹ គច្ឆន្តំ តិទិវង្គណំ[១] ។
អនិលេនេរិតំ ទិស្វា សម្មាសម្ពុទ្ធចីវរំ
វិត្តិ មេ ចាហុនា តាវ ទិស្វាន គមនំ មុនេ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា គតសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គតសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. តិទិវង្គតំ ។

បានឮថា ព្រះភោជនទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភោជនទាយកត្ថេរាបទាន ។

# គតសញ្ញកត្ថេរាបទាន ទី ៣

[១៣] ខ្ញុំបានឃើញព្រះជិនស្រី ព្រះនាមសិទ្ធត្ថ ស្ដេចពុទ្ធដំណើរទៅកាន់ឋានសួគ៌ឮដ៏អាកាស ដែលមិនមានស្នាមជើង ខ្ញុំបានឃើញនូវចីវរព្រះសម្មាសម្ពុទ្ធដែលខ្យល់បក់ត្រូវហើយ សេចក្ដីត្រេកអររបស់ខ្ញុំ ទុកជាគ្រឿងបូជា ព្រោះឃើញដំណើរព្រះមុនី ក្នុងខណៈនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះគតសញ្ញកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គតសញ្ញកត្ថេរាបទាន ។

១៦

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ចតុត្ថំ សត្តបទុមិយត្ថេរាបទានំ

[១៤] នទីកូលេ វសាមហំ　　នេសាទោ នាម ព្រាហ្មណោ
សត្តបត្តេហិ បុប្ផេហិ　　សម្បជ្ជិត្វាន អស្សមំ ។
សុវណ្ណវណ្ណំ សម្ពុទ្ធំ　　សិទ្ធត្ថំ លោកនាយកំ
ទិស្វា វនេន គច្ឆន្តំ　　ហាសោ មេ ឧបបជ្ជថ ។
បច្ចុគ្គន្ត្វាន សម្ពុទ្ធំ　　លោកជេដ្ឋំ នរាសភំ
អស្សមំ អតិនាមេត្វា　　ជលជគ្គេហិ ឱកិរឹ ។
ចតុន្នវុតេ ឥតោ កប្បេ　　យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។
ឥតោ តេ សត្តមេ កប្បេ　　ចតុរោ ថានថារា
សត្តរតនសម្បន្នា　　ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

# សត្តបទុមិយត្ថេរាបទាន ទី ៤

[១៤] ខ្ញុំជាព្រាហ្មណ៍ឈ្មោះនេសាទ នៅទៀបឆ្នេរស្ទឹង បានបោសសម្អាតអាស្រមដោយផ្កាឈូក ។ ខ្ញុំមានសេចក្តីរីករាយកើតឡើង ព្រោះឃើញព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ជាលោកនាយក ទ្រង់មានសម្បុរដូចមាស កាលដែលទ្រង់ពុទ្ធដំណើរទៅតាមព្រៃ ។ ខ្ញុំបានក្រាកទទួលព្រះសម្ពុទ្ធ ទ្រង់ជាឆ្នើមក្នុងលោក ប្រសើរជាងពួកនរៈ ហើយនាំទៅឯអាស្រម រួចរោយរាយដោយផ្កាឈូក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៤ ជាតិ ព្រះនាមបាទបាវរៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

១៧

បញ្ចមំ បុប្ផាសនទាយកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា សត្តបទុមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តបទុមិយត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ បុប្ផាសនទាយកត្ថេរាបទានំ

[១៨] សុវណ្ណវណ្ណំ សម្ពុទ្ធំ សតរំសីវ[១] ភាណុមំ
អវិទូរេ គច្ឆន្តំ សិទ្ធត្ថំ អបរាជិតំ ។
តស្ស បច្ចុគ្គមិត្វាន បវេសេត្វាន អស្សមំ
បុប្ផាសនំ មយា ទិន្នំ វិប្បសន្នេន ចេតសា ។
អញ្ជលឹ បគ្គហេត្វាន វេទជាតោ តទា អហំ
ពុទ្ធេ ចិត្តំ បសាទេត្វា កម្មន្តំ បរិណាមយឹ ។
យំ មេ អត្ថិ កតំ បុញ្ញំ សយម្ភុំ អបរាជិតំ
សព្វេន តេន កុសលេន វិមលោ ហោមិ សាសនេ ។
ចតុន្នវុតេ ឥតោ កប្បេ បុប្ផាសនមទំ តទា
ទុគ្គតឹ នាភិជានាមិ បុប្ផាសនស្សិទំ ផលំ ។

១ ម. បិតរំសឹវ ។

បុប្ផាសនទាយកត្ថេរាបទាន ទី ៥

*បានឮថា ព្រះសត្តបទុមិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ សត្តបទុមិយត្ថេរាបទាន ។

# បុប្ផាសនទាយកត្ថេរាបទាន ទី ៥

*[១៥] (ខ្ញុំបានឃើញ) នូវព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ទ្រង់ឈ្នះមារ ទ្រង់មានសម្បុរដូចមាស ឬដូចព្រះអាទិត្យមានរស្មីច្រើន ដែលស្តេចយាងក្នុងទីជិតខ្ញុំ ។ ខ្ញុំមានចិត្តជ្រះថ្លាបានក្រោកទទួលព្រះសម្ពុទ្ធអង្គនោះ ហើយនិមន្តឲ្យស្តេចចូលទៅឯអាស្រម ហើយថ្វាយអាសនៈផ្កា ។ កាលនោះ ខ្ញុំមានសេចក្តីរីករាយកើតឡើង ទើបផ្គងអញ្ជលី ធ្វើចិត្តឲ្យជ្រះ-ថ្លាចំពោះព្រះពុទ្ធ ហើយបង្អោនចិត្តទៅរកអំពើនោះថា បុណ្យណា ដែលខ្ញុំបានធ្វើហើយ ចំពោះព្រះសយម្ភូ ទ្រង់ឈ្នះមារ ខ្ញុំសូមឲ្យជាអ្នកប្រាសចាកមន្ទិល ក្នុងព្រះពុទ្ធសាសនាដោយកុសលកម្មទាំងអស់នោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយអាសនៈផ្កា ។*

បដិសម្ភិទា ចតស្សោ		វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា		កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុប្ផាសនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផាសនទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ អាសនត្ថវិកត្ថេរាបទានំ

[១៦] ចេតិយំ ឧត្តមំ នាម		សិខិនោ លោកពន្ធុនោ
អរញ្ញេ ឥរិណេ វិនេ[១]		អន្ធាហិណ្ឌាមហំ តទា ។
បវនា និក្ខមន្តេន		ទិដ្ឋំ សីហាសនំ មយា
ឯកំសំ អញ្ជលឹ កត្វា		សន្ថវឹ លោកនាយកំ ។
ទិវសភាគំ ថវិត្វាន		ពុទ្ធំ លោកគ្គនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន		ឥមំ វាចមុទីរយឹ ។

១ ម. វនេ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផាសនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផាសនទាយកត្ថេរាបទាន ។

# អាសនត្ថវិកត្ថេរាបទាន ទី ៦

[១៦] កាលនោះ ខ្ញុំដើរសំដៅទៅឯឧត្តមចេតិយ នៃព្រះលោកពន្ធុព្រះនាមសិខី ដែលនៅក្នុងព្រៃធំ ។ កាលខ្ញុំដើរចេញមកអំពីព្រៃវិញ ក៏បានឃើញព្រះពុទ្ធគង់លើសីហាសនៈ ខ្ញុំធ្វើសំពត់ឆៀងស្មាម្ខាង ហើយធ្វើអញ្ជលីសរសើរព្រះលោកនាយក ។ លុះខ្ញុំសរសើរព្រះសម្ពុទ្ធអគ្គនាយកក្នុងលោក អស់ចំណែកមួយថ្ងៃ ជាអ្នកមានចិត្តរីករាយ បានពោលវាចានេះថា

១៩

ឆដ្ឋំ អាសនត្ថវិកត្ថេរាបទានំ

នមោ តេ បុរិសាជញ្ញ   នមោ តេ បុរិសុត្តម
សព្វញ្ញូសិ មហាវីរ   លោកជេដ្ឋ នរាសភ ។
អភិត្ថវិត្វា សិខិនំ   និមិត្តករណេនហំ
អាសនំ អភិរោបេត្វា   បក្កាមឹ ឧត្តរាមុខោ ។
ឯកត្តឹសេ ឥតោ កប្បេ   យំ ថវឹ វទតំ វរំ
ទុគ្គតឹ នាភិជានាមិ   ថោមនាយ ឥទំ ផលំ ។
សត្តវីសេ ឥតោ កប្បេ   អតុល្យា[១]សត្ត អាសុ តេ[២]
សត្តរតនសម្បន្នា   ចក្កវត្តី មហព្វលា ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា អាសនត្ថវិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អាសនត្ថវិកត្ថេរស្ស អបទានំ សមត្តំ ។

១ ម. អតុលា ។ ២ ម. អាសុំ តេ ។

អាសនត្ថវិកត្ថេរាបទាន ទី ៦

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គមានព្យាយាមធំ ជាចម្បងក្នុងលោក ទ្រង់ប្រសើរជាងពួកនរៈ ព្រះអង្គជាសព្វញ្ញុពុទ្ធ ។ លុះខ្ញុំបានសរសើរព្រះសម្ពុទ្ធព្រះនាមសិខី ដោយការធ្វើនិមិត្តហើយ ក៏ថ្វាយបង្គំព្រះអង្គ ដែលទ្រង់កំពុងគង់នៅ រួចដើរចេញទៅ ឈមមុខទៅកាន់ឧត្តរទិស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំ បានសរសើរព្រះពុទ្ធ ទ្រង់ប្រសើរជាងពួកអ្នកប្រាជ្ញ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការសរសើរ ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៧ ជាតិ ព្រះនាមអតុល្យៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះអាសនត្ថវិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អាសនត្ថវិកត្ថេរាបទាន ។

# សត្តមំ សទ្ទសញ្ញកត្ថេរាបទានំ

[១៧] សុជស្សិតោ មហាវីរោ ទេសេតិ អមតំ បទំ
បរិវុតោ សាវកេហិ វសតិ ឃរមុត្តមេ ។
តាយ វាចាយ មធុរាយ សង្គណ្ហាតិ[១] មហាជនំ
ឃោសោ ច វិបុលោ អាសិ អាសិ សោ ទេវមានុសេ ។
និគ្ឃោសសទ្ទំ សុត្វាន សិទ្ធត្ថស្ស មហេសិនោ
សទ្ទេ ចិត្តំ បសាទេត្វា អវន្ទឹ លោកនាយកំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សទ្ទសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សទ្ទសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សង្គណ្ហន្តំ ។

# សទ្ទសញ្ញកត្ថេរាបទាន ទី ៧

[១៧] ព្រះពុទ្ធព្រះនាមសុទស្សនៈ មានព្យាយាមធំ ទ្រង់សម្តែងនូវអមតបទ មានពួកសាវ័កចោមរោម ទ្រង់គង់នៅក្នុងផ្ទះដ៏ប្រសើរ ទ្រង់សង្គ្រោះមហាជន ដោយព្រះវាចាដ៏ពីរោះ សំឡេងសរសើរព្រះពុទ្ធផ្សាយទៅ ពេញទេវលោកនិងមនុស្សលោក ។ ខ្ញុំបានស្តាប់ពាក្យឃោសនាហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងសំឡេងសរសើរព្រះមហេសី ទ្រង់ញុំាងប្រយោជន៍ឲ្យសម្រេច ទើបខ្ញុំថ្វាយបង្គំព្រះលោកនាយក ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសទ្ទសញ្ញកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សទ្ទសញ្ញកត្ថេរាបទាន ។

២១

# អដ្ឋមំ តិរំសិយត្ថេរាបទានំ

[១៨] កេសរឹ អភិជាតំវ អគ្គិក្ខន្ធំវ បព្វតេ
ឱភាសេន្តំ ទិសា សិន្នំ[១] សិទ្ធត្ថំ បព្វតន្តរេ ។
សុរិយស្ស ច អាលោកំ ចន្ទាលោកំ តថេវ ច
ពុទ្ធាលោកញ្ច ទិស្វាន បីតិ មេ ឧបបជ្ជថ ។
តយោ អាលោកេ ទិស្វាន ទិស្វាន សាវកុត្តមំ
ឯកំសំ អជិនំ កត្វា សន្ថវឹ លោកនាយកំ ។
តយោ ហិ អាលោកករា លោកេ លោកតមោនុទា
ចន្ទោ ច សុរិយោ ចាបិ ពុទ្ធោ ច លោកនាយកោ។
ឧបមំ ឧបទស្សេត្វា កិត្តិតោ មេ មហាមុនិ
ពុទ្ធស្ស វណ្ណំ កិត្តេត្វា កប្បំ សគ្គម្ហិ មោទហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ពុទ្ធមភិកិត្តយឹ
ទុគ្គតឹ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។
ឯកសដ្ឋិម្ហិតោ កប្បេ ឯកោ ញាណវរោ[២] អហុ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។

---

១ ម. និភាសេន្តំ ។ ២ ម. ញាណធរោ ។

# តិរំសិយត្ថេរាបទាន ទី ៨

[១៨] (ខ្ញុំបានឃើញ) នូវព្រះសិទ្ធត្ថ ទ្រង់ញុំាងទិសទាំងឡាយឲ្យភ្លឺ គង់នៅត្រង់ចន្លោះភ្នំ ជាអភិជាតិ ទ្រង់មានរស្មីរុងរឿង ដូចកេសររាជសីហ៍ ឬដូចគំនរភ្លើងលើភ្នំ ។ ខ្ញុំមានបីតិកើតឡើង ព្រោះឃើញពន្លឺព្រះអាទិត្យផង ពន្លឺព្រះចន្ទ្រផង ពន្លឺព្រះពុទ្ធផង មានសភាពដូចគ្នា ។ ខ្ញុំឃើញពន្លឺទាំង ៣ ឃើញសាវ័កដ៏ឧត្តម ហើយធ្វើស្បែកខ្លាឃ្មុំឆៀងស្មាម្ខាង រួចសរសើរព្រះលោកនាយក ។ សេចក្តីពិតថា ពន្លឺដ៏វិសេស ៣ យ៉ាង ក្នុងលោក គឺព្រះចន្ទ្រ ១ ព្រះអាទិត្យ ១ ព្រះពុទ្ធជាលោកនាយក ១ ជាពន្លឺកម្ចាត់បង់នូវងងឹត ក្នុងលោក ។ ខ្ញុំបានអាងឧបមា ហើយសរសើរព្រះមហាមុនី ព្រោះខ្ញុំបានសរសើរព្រះពុទ្ធ ក៏រីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានសរសើរពុទ្ធគុណ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ ក្នុងកប្បទី ៦១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមញាណវរៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា ចតស្សោ      វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា      កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិវំសិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិវំសិយត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ នាលិបុប្ផិយត្ថេរាបទានំ

[១៩] សិន្ធុយា នទិយា តីរេ      អហោសឹ កស្សកោ តទា
បរកម្មាយនេ យុត្តោ      បរភត្តំ អបស្សិតោ ។
សិន្ធុំ អនុចរន្តោហំ      សិទ្ធត្ថំ ជិនមទ្ទសំ
សមាធិនា និសិន្នំ ច      សតបត្តំវ បុប្ផិតំ ។
សត្តកំ នាលិបុប្ផានិ      វណ្ដេ ឆេត្វានហន្តទា
មត្ថកេ អភិរោបេសឹ      ពុទ្ធស្សាទិច្ចពន្ធុនោ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះតិរំសិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិរំសិយត្ថេរាបទាន ។

# នាលិបុប្ផិយត្ថេរាបទាន ទី ៩

[១៩] កាលនោះ ខ្ញុំបានកើតជាអ្នកក្ដួររាស់ នៅក្បែរត្រើយទន្លេសិន្ធុ បានប្រកបក្នុងការងាររបស់ជនដទៃ ចិញ្ចឹមជីវិតដោយថ្លៃឈ្នួល របស់ជនដទៃ ។ កាលខ្ញុំដើរទៅតាមទន្លេសិន្ធុ ក៏បានឃើញព្រះជិនស្រី ព្រះនាមសិទ្ធត្ថ ទ្រង់គង់នៅដោយសមាធិ ទ្រង់មានរស្មីរុងរឿង ដូចផ្កាឈូករីក ។ កាលនោះ ខ្ញុំបានកាត់ផ្កាឈូក ៧ ទាំងទង ដាក់ប្រទូលលើក្បាល នាំយកទៅបូជាព្រះសម្ពុទ្ធ ជាព្រះអាទិច្ចពន្ធុ ។

២៣

ទសមំ កុមុទមាលិយត្ថេរាបទានំ

សុវណ្ណវណ្ណំ សម្ពុទ្ធំ អនុព្យញ្ជនសម្បន្នំ សមាហិតំ
តិជាប្បភិន្នំ មាតង្គំ កុញ្ជរំវ ទុរាសទំ ។
តមហំ ឧបគន្ត្វាន និបកំ ភាវិតិន្ទ្រិយំ
អញ្ជលី បគ្គហេត្វាន អវន្ទឹ សត្ថុនោ អហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ ជាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ជាលិបុប្ផិយោ[១] ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

នាលិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ កុមុទមាលិយត្ថេរាបទានំ

[២០] ឧសភំ បវរំ វីរំ មហេសឹ វិជិតាជិនំ
វិបស្សិនំ មហាវីរំ អភិជាតំវ កេសរឹ ។
រថិយំ បដិបជ្ជន្តំ អាហុតីនំ បដិគ្គហំ
គហេត្វា កុមុទំ មាលំ ពុទ្ធសេដ្ឋំ សមោកិរឹ ។

១ ម. កន្ទលិបុប្ផិយោ ។

ខ្ញុំបានចូលទៅជិតព្រះសម្ពុទ្ធ ដែលទ្រង់មានសម្បុរដូចមាស ទ្រង់គង់ស្ងឹងស្ងាធីនៅជិតត្រើយទន្លេ ព្រះអង្គដូចដំរីមាតង្គៈ ចុះប្រេង ៣ អន្លើ ដែលគ្របសង្កត់បានដោយកម្រ ទ្រង់មានបញ្ញាចាស់ មានឥន្ទ្រិយអប់រំហើយ ទើបខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តាជាម្ចាស់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះនាលិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាលិបុប្ផិយត្ថេរាបទាន ។

# កុមុទមាលិយត្ថេរាបទាន ទី១០

[២០] ខ្ញុំយកកម្រងផ្កាកុមុទ ទៅបូជាព្រះពុទ្ធដ៏ប្រសើរ ព្រះនាមវិបស្សី ជាឧសភៈដ៏ប្រសើរ ទ្រង់មានព្យាយាម ជាអ្នកស្វែងរកនូវគុណដ៏ធំ ទ្រង់ឈ្នះមារ ជាមហាវីរបុរសដូចរាជសីហ៍ ជាអភិជាតិ ទ្រង់គួរទទួលគ្រឿងបូជា កំពុងពុទ្ធដំណើរក្នុងច្រក ។

ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ ណាភិជាណាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កុមុទមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កុមុទមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

អារក្ខទោ ភោជនទោ គតសញ្ញី បទុមិកោ
បុប្ផាសនិ សន្ថវិកោ សទ្ទសញ្ញី តិរំសិយោ ។
ណាលិកោ កុមុទី ចេវ សត្តបញ្ញាស គាថកា ។

អារក្ខទាយកវគ្គោ ពត្តឹសោ ។

*ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះកុមុទមាលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ កុមុទមាលិយត្ថេរាបទាន ។

## ឧទ្ទាន

*អារក្ខទាយកត្ថេរាបទាន ១ ភោជនទាយកត្ថេរាបទាន ១ គតសញ្ញកត្ថេរាបទាន ១ បទុមិយត្ថេរាបទាន ១ បុប្ផាសនទាយកត្ថេរាបទាន ១ អាសនត្ថវិកត្ថេរាបទាន ១ សទ្ទសញ្ញកត្ថេរាបទាន ១ តិរំសិយត្ថេរាបទាន ១ នាលិបុប្ផិយត្ថេរាបទាន ១ កុមុទមាលិយត្ថេរាបទាន ១ មានគាថា ៥៧ ។*

ចប់ អារក្ខទាយកវគ្គ ទី ៣២ ។

---

# តេត្តឹសោ ឧម្មាបុប្ផិយវគ្គោ

## បឋមំ ឧម្មាបុប្ផិយត្ថេរាបទានំ

[២១] សមាហិតំ សមាបន្នំ សិទ្ធត្ថមបរាជិតំ
សមាធិនា ឧបវិដ្ឋំ អទ្ទសាសឹ នរុត្តមំ ។
ឧម្មាបុប្ផំ គហេត្វាន ពុទ្ធស្ស អភិបូជយឹ
សព្វេ បុប្ផា ឯកសីសា ឧទ្ធំវណ្ដា អធោមុខា ។
សុចិត្តា វិយ តិដ្ឋន្តេ អាកាសេ បុប្ផសន្ថរា
តេន ចិត្តប្បសាទេន តុសិតំ ឧបបជ្ជហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បញ្ចបញ្ញាសិតោ កប្បេ ឯកោ អាសឹ មហីបតិ
សមន្តច្ឆទនោ នាម ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧម្មាបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧម្មាបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# ឧម្មាបុប្ផិយវគ្គ ទី ៣៣

# ឧម្មាបុប្ផិយត្ថេរាបទាន ទី ១

[២១] *ខ្ញុំបានឃើញព្រះសិទ្ធត្ថប្រសើរជាងពួកនរៈ ទ្រង់មានព្រះទ័យតម្កល់មាំខ្ជាប់ខ្ជួន ទ្រង់ឈ្នះមារ ទ្រង់ចូលសមាធិ ។ ខ្ញុំកាន់យកផ្កាត្រកៀតបូជាព្រះពុទ្ធ ផ្កាទាំងអស់មានក្បាលតែមួយ មានទងឡើងលើ មានមុខចុះក្រោម វិចិត្រល្អដូចជាកម្រាលផ្កា ប្រតិស្ឋានឰដ៏អាកាស ខ្ញុំបានកើតក្នុងឋានតុសិត ដោយចិត្តជ្រះថ្លានោះ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ៥៥ អំពីកប្បនេះ ក្នុងកាលនោះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយអង្គ ព្រះនាមសមន្តច្ឆទនៈ ជាធំលើផែនដី ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះឧម្មាបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ ឧម្មាបុប្ផិយត្ថេរាបទាន ។

២៦



# ទុតិយំ បុឡិនបូជកត្ថេរាបទានំ

[២២] កកុធំ វិលសន្តំវ និសភាជានិយំ យថា
ឱសធីវ វិរោចន្តំ ឱភាសន្តំ នរាសភំ ។
អញ្ជលឹ បគ្គហេត្វាន អវន្ទឹ សត្ថុនោ អហំ
សត្ថារំ បរិវណ្ណេសឹ សកកម្មេន តោសយឹ ។
សុសុទ្ធំ បុឡិនំ គយ្ហំ គតមគ្គេ សមោកិរឹ
ឧច្ឆង្គេន គហេត្វាន វិបស្សិស្ស មហេសិនោ ។
តតោ ឧបឌ្ឍបុឡិនំ វិប្បសន្នេន ចេតសា
ទិវាវិហារេ ឱសិញ្ចឹ ទិបទិន្ទស្ស តាទិនោ ។
ឯកនវុតេ ឥតោ កប្បេ បុឡិនំ យំ អសិញ្ចហំ
ទុគ្គតឹ នាភិជានាមិ បុឡិនស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុឡិនបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុឡិនបូជកត្ថេរស្ស អបទានំ សមត្តំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# បុឡិនបូជកត្ថេរាបទាន ទី ២

[២២] ខ្ញុំបានឃើញព្រះពុទ្ធ ប្រសើរជាងនរៈ ទ្រង់យាង-យាសដូចលំពង់ថ្វាន់ ឬដូចនិសភអាជានេយ្យ ទ្រង់រុងរឿងភ្លឺស្វាង ដូចផ្កាយព្រឹក ។ ខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសាស្តា ហើយសរសើរព្រះសាស្តា ខ្ញុំរីករាយដោយកុសលកម្ម របស់ខ្លួន ។ ខ្ញុំបានកើបខ្សាច់ដ៏ស្អាត ដក់មួយថ្នក់យកទៅពោយរាយត្រង់ផ្លូវដែលព្រះមហេសី ព្រះនាមវិបស្សី ស្តេចយាងទៅ ។ លំដាប់នោះ ខ្ញុំមានចិត្តជ្រះថ្លា បានចាក់ខ្សាច់ពាក់កណ្តាលត្រង់បង្អារសម្រាប់សម្រាកក្នុងវេលាថ្ងៃ នៃព្រះពុទ្ធ ទ្រង់ជាធំជាងសត្វជើងពីរ ប្រកបដោយតាទិគុណ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានពោយរាយខ្សាច់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការពោយរាយខ្សាច់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុឡិនបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុឡិនបូជកត្ថេរាបទាន ។

២៧

# តតិយំ ហាសជនកត្ថេរាបទានំ

[២៣] ទុមគ្គេ បំសុកូលិកំ លគ្គំ ទិស្វាន សត្ថុនោ
អញ្ជលឹ បគ្គហេត្វាន ភិយ្យោ ឧច្ចារិតំ មយា ។
ទូរតោ បដិទិស្វាន ហាសោ មេ ឧបបជ្ជថ
អញ្ជលឹ បគ្គហេត្វាន ភិយ្យោ ចិត្តំ បសាទយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ហាសជនកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ហាសជនកត្ថេរស្ស អបទានំ សមត្តំ ។

# ហាសជនកត្ថេរាបទាន ទី ៣

[២៣] ខ្ញុំបានឃើញបំសុកូលិកចីវរ របស់ព្រះសាស្តា ដែលព្យួរលើចុងឈើ ហើយផ្គងអញ្ជលីបន្ទឹវាចាឡើងយ៉ាងខ្លាំង ។ សេចក្តីរីករាយក៏កើតមានដល់ខ្ញុំ ព្រោះបានឃើញអំពីចម្ងាយ ទើបខ្ញុំផ្គងអញ្ជលីញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះហាសជនកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ហាសជនកត្ថេរាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ចតុត្ថំ យញ្ញសាមិកត្ថេរាបទានំ

[២៤] ជាតិយា សត្តវស្សោហំ អហោសឹ មន្តបារគូ
កុលវំសំ[១] អធារេសឹ យញ្ញោ ឧស្សាបិតោ មយា ។
ចុល្លាសីតិសហស្សានិ បសូ ហញ្ញន្តិ មេ តទា
សារស្មឹ[២] ហិ ឧបនីតានិ យញ្ញត្ថាយ ឧបដ្ឋិតា ។
ឧក្កាមុខេ បហដ្ឋោវ ខទិរង្គារសន្និភោ
ឧទយន្តោវ សុរិយោ បុណ្ណមាយេវ ចន្ទិមា ។
សិទ្ធត្ថោ សព្វសិទ្ធត្ថោ តិលោកមហិតោហិតោ
ឧបគន្ត្វាន សម្ពុទ្ធោ ឥទំ វចនមព្រវិ ។
អហឹសា សព្វបាណានំ កុមារ មម រុច្ចតិ
ថេយ្យា ច អតិចារា ច មជ្ជបានា ច អារតិ ។
រតិ ច សមចរិយាយ ពាហុសច្ចំ កតញ្ញុតា
ទិដ្ឋេ ធម្មេ បរត្ថ ច ធម្មា ឯតេ បសំសិយា ។

---

១ ម. កុលវត្តំ ។ ២ ម. តារស្មឹ ។

# យញ្ញសាមិកត្ថេរាបទាន ទី ៤

[២៤] ខ្ញុំមានអាយុ ៧ ឆ្នាំ រាប់អំពីឆ្នាំកំណើត បានចេះចប់មន្ត្ត បានទ្រទ្រង់វង្សត្រកូល ខ្ញុំបានលើកតម្កើងយញ្ញវិធី ។ កាលនោះ ខ្ញុំនាំយកសត្វចិញ្ចឹម ៨ ម៉ឺន ៤ ពាន់ មកចង ក្រៀកនឹងសសរខ្ទឹម បម្រុងទុកនឹងសម្លាប់បូជាយញ្ញ ។ ព្រះសម្ពុទ្ធ ព្រះនាមសិទ្ធត្ថ ទ្រង់ញុំាងប្រយោជន៍ទាំងអស់ឲ្យសម្រេច ទ្រង់ទម្លាក់ចោលនូវរបស់មិនជាប្រយោជន៍ ក្នុងត្រៃលោក ទ្រង់ដូចជាមុខគប់ភ្លើងត្រូវខ្យល់បក់ ឬដូចរងើកឧសគគីរ ពុំនោះសោត ដូចព្រះអាទិត្យដែលទើបនឹងរះឡើង ឬដូចព្រះចន្ទពេញវង់ ទ្រង់ចូលមកជិតខ្ញុំ ហើយត្រាស់ព្រះពុទ្ធដីកានេះថា នែកុមារ ការមិនបៀតបៀនសត្វទាំងអស់ រមែងពេញចិត្តតថាគត ការវៀរចាកការលួច ការប្រព្រឹត្តកន្លង (បរទារកកម្ម) និងការផឹកទឹកស្រវឹង ១ សេចក្តីត្រេកអរចំពោះការប្រព្រឹត្តស្មើ ១ ភាពជាពហុស្សូត ១ កតញ្ញូតា ១ ធម៌ទាំងនេះ បណ្ឌិតសរសើរក្នុងបច្ចុប្បន្ន ទាំងបរលោក ។

២៩

ចតុត្ថំ យញ្ញសាមិកត្ថេរាបទានំ

ឯតេ ជម្ពេ ភាវយិត្វា សព្វសត្តហិតេ រតោ
ពុទ្ធេ ចិត្តំ បសាទេត្វា ភាវេហិ មគ្គមុត្តមំ ។
ឥទំ វត្វាន សព្វញ្ញូ លោកជេដ្ឋោ នរាសភោ
មមេវំ អនុសាសិត្វា វេហាសំ ឧគ្គតោ គតោ ។
បុព្វេ ចិត្តំ វិសោធេត្វា បច្ឆា ចិត្តំ បសាទយឹ
តេន ចិត្តប្បសាទេន តុសិតំ ឧបបជ្ជហំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ចិត្តំ បសាទយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា យញ្ញសាមិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យញ្ញសាមិកត្ថេរស្ស អបទានំ សមត្តំ ។

## យញ្ញសាមិកត្ថេរាបទាន ទី ៤

*អ្នកចូរអប់រំធម៌ទាំងនេះ ហើយត្រេកអរ នឹងប្រយោជន៍សព្វសត្វ ចូរញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធ ហើយអប់រំនូវមគ្គដ៏ប្រសើរ ។ លុះព្រះសព្វញ្ញូជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់ត្រាស់នូវភាសិត ប្រៀនប្រដៅ ខ្ញុំយ៉ាងនេះហើយ ទើបស្ដេចពុទ្ធដំណើរទៅ កាន់អាកាសទៅ ។ ខ្ញុំបានជម្រះចិត្ត ក្នុងកាលមុន ហើយញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងកាលជាខាងក្រោយ ក៏បានចូលទៅកើត ក្នុងឋានតុសិត ដោយការធ្វើចិត្តឲ្យជ្រះថ្លានោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានញ៉ាំងចិត្តឲ្យជ្រះថ្លា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះយញ្ញសាមិកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ យញ្ញសាមិកត្ថេរាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# បញ្ចមំ និមិត្តសញ្ញកត្ថេរាបទានំ

[២៤] ចន្ទភាគានទីតីរេ វសាមិ អស្សមេ អហំ
សុវណ្ណមិគមទ្ទក្ខឹ ចរន្តំ វិបិនេ អហំ ។
មិគេ ចិត្តំ បសាទេត្វា លោកជេដ្ឋំ អនុស្សរឹ
តេន ចិត្តប្បសាទេន អញ្ញេ ពុទ្ធេ អនុស្សរឹ ។
អតីតា ច យេ ពុទ្ធា វត្តមានា អនាគតា
ឯវមេវ វិរោចន្តិ មិគរាជាវ តេ តយោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ សញ្ញមលភឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធសញ្ញាយិទំ ផលំ ។
សត្តវីសេ ឥតោ កប្បេ ឯកោ អាសិ មហីបតិ
អរញ្ញសត្ថោ(១)នាមេន ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ម. អរញ្ញសត្ថោ ។

# និមិត្តសញ្ញកត្ថេរាបទាន ទី ៥

[២៥] ខ្ញុំនៅក្នុងអាស្រម ទៀបឆ្នេរស្ទឹងចន្ទភាគា បានក្រឡេកឃើញម្រឹគមានសម្បុរដូចមាស ដែលកំពុងត្រាច់ក្នុងព្រៃធំ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាចំពោះម្រឹគ ហើយនឹកដល់ព្រះសម្ពុទ្ធជាច្បងក្នុងលោក ទាំងនឹកដល់ព្រះពុទ្ធដទៃ ៗ ទៀត ដោយចិត្តជ្រះថ្លានោះថា ព្រះពុទ្ធទាំងឡាយណា ដែលកន្លងទៅហើយក្តី ដែលកំពុងត្រាស់ដឹងក្នុងបច្ចុប្បន្ននេះក្តី ដែលនឹងមកត្រាស់ដឹងក្នុងអនាគតកាលក្តី ព្រះពុទ្ធទាំង ៣ ពួកនោះរុងរឿងដូចជាស្តេចម្រឹគ យ៉ាងនេះឯង ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាននូវសញ្ញា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធសញ្ញា ។ ក្នុងកប្បទី ២៧ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិមួយព្រះអង្គ ព្រះនាមអរញ្ញសត្ត ជាម្ចាស់ផែនដី ទ្រង់មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

៣១

ឆដ្ឋំ អន្នសំសាវកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា និមិត្តសញ្ញកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

និមិត្តសញ្ញកត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ អន្នសំសាវកត្ថេរាបទានំ

[២៦] សុវណ្ណវណ្ណំ សម្ពុទ្ធំ    គច្ឆន្តំ អន្តរាបណេ
កញ្ចនគ្ឃិយសង្កាសំ    ពត្តឹសវរលក្ខណំ ។
សិទ្ធត្ថំ សព្វសិទ្ធត្ថំ    អនេជំ អបរាជិតំ
សម្ពុទ្ធំ អតិនាមេត្វា    ភោជយឹ តំ មហាមុនឹ ។
មុនិ ការុណិកោ លោកេ    ឱភាសយិ មមំ តទា
ពុទ្ធេ ចិត្តំ បសាទេត្វា    កប្បំ សគ្គម្ហិ មោទហំ ។
ចតុន្នវុតេ ឥតោ កប្បេ    យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ    ភិក្ខាទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

បានឮថា ព្រះនិមិត្តសញ្ញកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ និមិត្តសញ្ញកត្ថេរាបទាន ។

# អន្នសំសាវកត្ថេរាបទាន ទី ៦

[២៦] ខ្ញុំបានឃើញ នូវព្រះសម្ពុទ្ធ មានវណ្ណៈដូចមាសប្រាកដស្មើគ្រឿងបូជាមាស មានលក្ខណៈ ៣២ ប្រការដែលកំពុងទ្រង់ពុទ្ធដំណើរទៅត្រង់រានផ្សារ ។ ខ្ញុំនាំព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ទ្រង់ញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេច មិនញាប់ញ័រដោយកិលេស ទ្រង់ឈ្នះមារ ហើយខ្ញុំញ៉ាំងព្រះមហាមុនីអង្គនោះឲ្យសោយចង្ហាន់ ។ កាលនោះ ព្រះមុនីទ្រង់ប្រកបដោយករុណា ទ្រង់ញ៉ាំងខ្ញុំឲ្យភ្លឺស្វាង ក្នុងលោកខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធ ហើយបានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយចង្ហាន់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ឥត្ថំ សុទំ អាយស្មា អន្ធសំសារកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អន្ធសំសារកត្ថេរស្ស អបទានំ សមត្តំ ។

# សត្តមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ

[២៧] យទា ទេវោ ទេវកាយា ចវតិ អាយុសង្ខយា
តយោ សទ្ទា និច្ឆរន្តិ ទេវានំ អនុមោទតំ ។
ឥតោ ភោ សុគតឹ គច្ឆ មនុស្សានំ សហព្យតំ
មនុស្សភូតោ សទ្ធម្មេ លភ សទ្ធំ អនុត្តរំ ។
សា តេ សទ្ធា និវិដ្ឋស្ស មូលជាតា បតិដ្ឋិតា
យាវជីវំ អសំហិរា សទ្ធម្មេ សុបវេទិតេ ។
កាយេន កុសលំ កត្វា វាចាយ កុសលំ ពហុំ
មនសា កុសលំ កត្វា អព្យាបជ្ឈំ និរូបធឹ ។

បានឮថា ព្រះអន្ទសំសាវកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អន្ទសំសាវកត្ថេរាបទាន ។

# និគ្គុណ្ឋិបុប្ផិយត្ថេរាបទាន ទី ៧

[២៧] កាលណា ទេវតានឹងច្យុតចាកពួកទេវតា ដោយអស់អាយុ សំឡេង ៣ យ៉ាង របស់ពួកទេវតាអ្នករីករាយតាមតែងលាន់ឮឡើងថា ម្នាលអ្នកដ៏ចម្រើន បើអ្នកចុះចាកទេវលោកនេះ ចូរទៅកាន់សុគតិ កើតជាមួយនឹងពួកមនុស្សចុះ លុះអ្នកបានកើតជាមនុស្សហើយ ចូរបាននូវសទ្ធាដ៏ប្រសើរ ចំពោះព្រះសទ្ធម្ម សទ្ធានោះដែលអ្នកតម្កល់មាំហើយ នឹងកើតជាឫសខ្ជាប់ខ្ជួន មិនកម្រើកក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគទ្រង់សម្តែងល្អហើយ ដរាបដល់អស់ជីវិត ។ អ្នកចូរធ្វើនូវកុសលដោយកាយ ចូរធ្វើកុសលដោយវាចាឲ្យច្រើន ចូរធ្វើកុសលដោយចិត្ត មិនមានព្យាបាទ មិនមានឧបធិ ។

៣៣

សត្តមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ

តតោ ឱបជិតំ បុញ្ញំ កត្វា នាតេន តំ ពហុំ
អញ្ញេ បរេ[១] សទ្ធម្មេ ព្រហ្មចរិយេ និវេសយ ។
ឥមាយ អនុកម្បាយ ទេវទេវំ យថា វិទូ
ចរន្តំ អនុមោទន្តិ ឯហិ ទេវ បុនប្បុនំ ។
សំវិគ្គោហំ តទា អាសឹ ទេវសង្ឃេ សមាគតេ
កំសុ នាម អហំ យោនឹ គមិស្សាមិ ឥតោ ចុតោ ។
មម សំវេគមញ្ញាយ សមណោ ភាវិតិន្ទ្រិយោ
មមុទ្ធរិតុកាមោ សោ អាគច្ឆិ មម សន្តិកំ ។
សុមនោ នាម នាមេន បទុមុត្តរសាវកោ
អត្ថធម្មានុសាសិត្វា សំវេជេសិ មមន្តទា ។

ទ្វាទសមំ ភាណវារំ ។

តស្សាហំ វចនំ សុត្វា ពុទ្ធេ ចិត្តំ បសាទយឹ
តំ ធីរំ អភិវាទេត្វា តត្ថ កាលំ កតោ អហំ ។

---

១ ម. អញ្ញេបិ មច្ចេតិ ទិស្សតិ ។

និគ្គុណ្ឋិបុប្ផិយត្ថេរាបទាន ទី ៧

អ្នកចូរធ្វើបុណ្យឲ្យច្រើនជាងនោះ គឺធ្វើបុណ្យនោះឲ្យច្រើន ដោយការបរិច្ចាគទាន ហើយតាំងនៅក្នុងព្រហ្មចរិយៈ គឺព្រះសទ្ធម្មដ៏ប្រសើរដទៃទៀតចុះ ។ ម្នាលទេវតា អ្នកចូរមក (កាន់ទេវលោក) នេះវិញឲ្យរឿយ ៗ ដោយសេចក្តីអនុគ្រោះនេះ ដូចពួកអ្នកប្រាជ្ញ តែងត្រេកអររកទេវតាដ៏ប្រសើរដែលច្យុត ។ កាលនោះ ខ្ញុំមានសេចក្តីតក់ស្លុត ក្នុងទីប្រជុំពួកទេវតាថា អាត្មាអញច្យុតចាកទេវលោកនេះ នឹងទៅកាន់កំណើតណាអេះ ។ ស្រាប់តែមានសមណៈ មានឥន្ទ្រិយអប់រំហើយ ជ្រាបសេចក្តីសង្វេគរបស់ខ្ញុំ សមណៈនោះមានសេចក្តីប្រាថ្នានឹងស្រង់ខ្ញុំ បានមកកាន់សម្នាក់ខ្ញុំ ។ កាលនោះ សាវ័ករបស់ព្រះបទុមុត្តរៈ ព្រះនាមសុមនៈ បានប្រៀនប្រដៅនូវអត្ថនិងធម៌ ហើយញ៉ាំងខ្ញុំឲ្យសង្វេគ ។

ចប់ ភាណវារៈ ទី ១២ ។

ខ្ញុំបានស្តាប់ពាក្យ នៃព្រះថេរៈនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ ខ្ញុំថ្វាយបង្គំព្រះថេរៈ ជាអ្នកប្រាជ្ញអង្គនោះ មិនយូរប៉ុន្មាន ខ្ញុំក៏ធ្វើមរណកាលក្នុងទីនោះ ។

៣៤



ឧបបជ្ជឹ ស តត្ថេវ សុក្កមូលេន ចោទិតោ
វសន្តោ មាតុកុច្ឆិម្ហិ បុន ធារេតុ មាតុយា ។
តម្ហា កាយា ចវិត្វាន តិទសេ ឧបបជ្ជហំ
ឆឡន្តរេ ន បស្សាមិ ទោមនស្សំ អហំ តទា ។
តាវត្តឹសា ចវិត្វាន មាតុកុច្ឆឹ សមោក្កមឹ
និក្ខមិត្វាន កុច្ឆិម្ហា កិញ្ចិ ទុក្ខំ អជានិហំ ។
ជាតិយា សត្តវស្សេន អារាមំ ចារិសឹ អហំ
គោតមស្ស ភគវតោ សក្យបុត្តស្ស តាទិនោ ។
វិត្ថារិកេ ចាវចេ ពាហុជញ្ញម្ហិ សាសនេ
អទ្ទសំ សាសនំ ការេ ភិក្ខវោ តត្ថ សត្ថុនោ ។
សាវត្ថិ នាម នគរំ រាជា តត្ថាសិ កោសលោ
រថេន នាគយុត្តេន ឧបេសិ ពោធិមុត្តមំ ។
តស្សាហំ នាគំ ទិស្វាន បុព្វកម្មំ អនុស្សរឹ
អញ្ជលឹ បគ្គហេត្វាន សមយំ អគមាសហំ ។

ខ្ញុំនោះត្រូវកុសលមូលដាស់តឿន ក៏បានទៅកើតក្នុងទីនោះដដែល កាលខ្ញុំនៅក្នុងផ្ទៃមាតា កុសលក៏ទ្រទ្រង់ខ្ញុំក្នុងផ្ទៃនៃមាតាទៀត ។ លុះខ្ញុំច្យុតចាកកាយនោះ ក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស កាលនោះ ខ្ញុំមិនបានឃើញទោមនស្សក្នុងរវាងនោះសោះ ។ ខ្ញុំច្យុតចាកឋានតាវត្តិង្សវិញ បានចុះមកកាន់ផ្ទៃមាតា លុះចេញចាកផ្ទៃហើយ ខ្ញុំបានស្គាល់សេចក្តីទុក្ខតែបន្តិចបន្តួច ។ ខ្ញុំមានអាយុ ៧ ឆ្នាំ បានចូលទៅកាន់អារាម របស់ព្រះមានព្រះភាគ ព្រះនាមគោត្តមជាសក្យបុត្រ ព្រះអង្គប្រកបដោយតាទិគុណ ។ ខ្ញុំបានឃើញពួកភិក្ខុ ក្នុងអារាមនោះ លោកអ្នកធ្វើតាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ក្នុងពុទ្ធដីកាជាប្រធាន គឺសាសនាដែលទូលំទូលាយមានជនចុះចូលច្រើន ។ ក្នុងពេលនោះ ព្រះរាជាក្នុងក្រុងសាវត្ថី ព្រះនាមកោសល ស្តេចធ្វើរាជដំណើរទៅកាន់ដើមពោធិព្រឹក្សដ៏ឧត្តម ដោយរាជរថដែលទឹមដំរីដ៏ប្រសើរ ។ លុះខ្ញុំឃើញដំរីដ៏ប្រសើរ នៃព្រះរាជាអង្គនោះ ក៏នឹកឃើញបុព្វកម្មរបស់ខ្លួន បានផ្គងអញ្ជលី ដើរទៅក្នុងសម័យនោះដែរ ។

៣៨

សត្តមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ

ជាតិយា សត្តវស្សោវ បព្វជឹ អនគារិយំ
យោ សោ ពុទ្ធំ ឧបដ្ឋាសិ អានន្ទោ នាម សាវកោ ។
គតិមា ធីតិមា ចេវ សតិមា ច ពហុស្សុតោ
រញ្ញោ ចិត្តំ បសាទេន្តោ និយ្យាទេសិ មហាជុតិ ។
តស្សាហំ ធម្មំ សុត្វាន បុព្វកម្មំ អនុស្សរឹ
តត្ថេវ ឋិតកោ សន្តោ អរហត្តំ អបាបុណឹ ។
ឯកំសំ ចីវរំ កត្វា សិរេ កត្វាន អញ្ជលឹ
សម្ពុទ្ធំ អភិវាទេត្វា ឥមំ វាចំ ឧទីរយឹ ។
បទុមុត្តរពុទ្ធស្ស ទ្វិបទិន្ទស្ស តាទិនោ
និគ្គុណ្ឌិបុប្ផំ បគ្គយ្ហ សីហាសនេ ឋបេសហំ ។
តេន កម្មេន ទ្វិបទិន្ទ លោកជេដ្ឋ នរាសភ
បត្តោម្ហិ អចលំ ឋានំ ហិត្វា ជយបរាជយំ ។
បញ្ចវីសសហស្សម្ហិ កប្បានំ មនុជាធិបា
អព្ពុទនិរព្ពុទានិ អដ្ឋដ្ឋាសីសុ ខត្តិយា ។

## និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ទី ៧

ខ្ញុំមានអាយុ ៧ ឆ្នាំ ក៏បានចូលទៅកាន់ផ្នួសក្នុងសាសនា ឯព្រះអានន្ទជាសាវក អ្នកមានគតិល្អ មានប្រាជ្ញាខ្ជាប់ខ្ជួន មានស្មារតីជាពហុស្សូត មានសេចក្តីរុងរឿង តែងបម្រើព្រះសម្ពុទ្ធ លោកញ៉ាំងព្រះទ័យព្រះរាជាឲ្យជ្រះថ្លា ហើយញ៉ាំងព្រះរាជាឲ្យប្រគល់កាយថ្វាយខ្លួន (ជាឧបាសកក្នុងពុទ្ធសាសនា) ។ ខ្ញុំបានស្តាប់ធម៌ព្រះអានន្ទត្ថេរនោះ ហើយក៏រលឹកឃើញបុព្វកម្ម ខ្ញុំបានសម្រេចព្រះអរហត្ត ទាំងកំពុងឈរក្នុងទីនោះឯង ។ បន្ទាប់មក ខ្ញុំធ្វើចីវរឆៀងស្មាម្ខាង ធ្វើអញ្ជលីលើសិរ្ស: ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយបន្លឺវាចានេះថា បពិត្រព្រះនរាសភ: ជាច្បងក្នុងលោក ជាធំជាងសត្វជើងពីរ ក្នុងភពមុន ខ្ញុំបានយកផ្កានិគ្គុណ្ឌិព្រឹក្ស ទៅតម្កល់ទុកហើយលើអាសនៈដ៏ប្រសើរ ថ្វាយព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរ: ជាធំជាងសត្វជើងពីរ ព្រះអង្គប្រកបដោយតាទិគុណ ឥឡូវនេះ ខ្ញុំលះបង់នូវការឈ្នះនិងការចាញ់ បានដល់នូវអចលដ្ឋាន គឺព្រះនិព្វាន ដោយកុសលកម្មនោះ ។ ក្នុងកប្បទី ២៥.០០០ ខ្ញុំបានកើតជាស្តេច ជាអធិបតីលើមនុស្ស បិតនៅអស់ ៨ អព្វុទ:[១] និងនិរព្វុទ:[២] ។

---

១ អព្វុទ:មួយ ៗ មាន ៥៦ ពិន្ទុ ។ ២. និរព្វុទ:មួយ ៗ មាន ៦៣ ពិន្ទុ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា និគ្គុណ្ឌិបុប្ផិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

និគ្គុណ្ឌិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ សុមនាវេឡិយត្ថេរាបទានំ

[២៨] វេស្សភុស្ស ភគវតោ លោកជេដ្ឋស្ស តាទិនោ
សព្វេ ជនា សមាគម្ម មហាបូជំ ករោន្តិ តេ ។
សុធាយ បិណ្ឌំ កត្វាន អាវេឡំ សុមនាយហំ
សីហាសនស្ស បុរតោ អភិរោបេសហំ តទា ។
សព្វេ ជនា សមាគម្ម បេក្ខន្តិ បុប្ផមុត្តមំ
កេនិទំ បូជិតំ បុប្ផំ ពុទ្ធសេដ្ឋស្ស តាទិនោ ។
តេន ចិត្តប្បសាទេន និម្មានំ ឧបបជ្ជហំ
អនុភោមិ សកំ កម្មំ បុព្វេ សុកតមត្តនោ ។
យំ យំ យោនូបបជ្ជាមិ ទេវត្តំ អថ មានុសំ
សព្វេសានំ បិយោ ហោមិ បុប្ផបូជាយិទំ ផលំ ។

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះនិគ្គុណ្ឌិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ។

# សុមនាវេឡិយត្ថេរាបទាន ទី ៨

[២៨] *ជនទាំងពួងមកប្រជុំគ្នា ធ្វើមហាបូជាចំពោះព្រះមានព្រះភាគព្រះនាមវេស្សភូ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ ។ កាលនោះ ខ្ញុំយកដុំបាយអ ធ្វើជាភួងផ្កាម្លិះដាក់បូជាពីមុខអាសនៈដ៏ប្រសើរ ។ ជនទាំងអស់មកប្រជុំគ្នា ក្រឡេកមើលផ្កាដ៏ប្រសើរនោះ ហើយគិតគ្នាថា អ្នកណាបានបូជាផ្កានេះ ចំពោះព្រះពុទ្ធដ៏ប្រសើរ ប្រកបដោយតាទិគុណ ។ ហេតុតែចិត្តជ្រះថ្លានោះ ខ្ញុំបានទៅកើតឯឋាននិម្មានរតី ទទួលរងកុសលរបស់ខ្លួន ដែលខ្លួនធ្វើទុកល្អហើយ ក្នុងកាលមុន ។ ខ្ញុំទៅយកកំណើតណា ៗ ទោះបីជាទេវតាឬជាមនុស្ស រមែងជាទីស្រឡាញ់របស់ជនទាំងពួង នេះជាផលនៃការបូជាផ្កា ។*

៣៧

អដ្ឋមំ សុមនាវេឡិយត្ថេរាបទានំ

ជាតិជាតិ កាយេន វាចាយ ឧទ ចេតសា
សំយតានំ តបស្សីនំ កតំ ឧបដ្ឋាហិតំ[១] មយា ។
តេន សុចរិតេនាហំ ចិត្តស្ស បណិធីហិ ច
សព្វេសំ បូជិតោ ហោមិ អនក្កោសស្សិទំ ផលំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
ឥតោ ឯកាទសេ កប្បេ សហស្សារាសិ ខត្តិយោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុមនាវេឡិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុមនាវេឡិយត្ថេរស្ស អបទានំ សមត្តំ ។

១ ម. អក្កោសិតំ ។

សុមនាវេឡិយត្ថេរាបទាន ទី ៨

ខ្ញុំពុំស្គាល់នូវការតិះដៀល ចំពោះពួកលោក ដែលមានសេចក្តីសង្រួមនិងមានតបធម៌ ដែលខ្ញុំធ្វើហើយ ដោយកាយវាចាឬដោយចិត្តឡើយ ។ ដោយសុចរិតនោះផង ដោយការតម្កល់ទុកនូវចិត្តនោះផង ខ្ញុំក៏ត្រូវអ្នកទាំងពួងបូជាហើយ នេះជាផលនៃការមិនតិះដៀល ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ក្នុងកប្បទី ១១ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ព្រះនាមសហស្សារៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនាវេឡិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនាវេឡិយត្ថេរាបទាន ។

# នវមំ បុប្ផច្ឆត្តិយត្ថេរាបទានំ

[២៩] សិទ្ធត្ថស្ស ភគវតោ    លោកជេដ្ឋស្ស តាទិនោ
សច្ចំ បកាសយន្តស្ស    និព្វាបេន្តស្ស បាណិនោ ។
ជលជំ អាហរិត្វាន    សតបត្តំ មនោរមំ
បុប្ផស្ស ឆត្តំ កត្វាន    ពុទ្ធស្ស អភិរោបយឹ ។
សិទ្ធត្ថោ ច លោកវិទូ    អាហុតីនំ បដិគ្គហោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា    ឥមំ គាថំ អភាសថ ។
យោ មេ ចិត្តំ បសាទេត្វា    បុប្ផច្ឆត្តំ អធារយិ
តេន ចិត្តប្បសាទេន    ទុគ្គតឹ សោ ន គច្ឆតិ ។
ឥទំ វត្វាន សម្ពុទ្ធោ    សិទ្ធត្ថោ លោកនាយកោ
ឧយ្យោជេត្វាន បរិសំ    វេហាសំ នភមុគ្គមិ ។
ឧដ្ឋិតេ នរទេវម្ហិ    សេតច្ឆត្តំបិ វុដ្ឋហិ
បុរតោ ពុទ្ធសេដ្ឋស្ស    គច្ឆតិ ឆត្តមុត្តមំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# បុប្ផច្ឆត្តិយត្ថេរាបទាន ទី ៩

[២៩] កាលព្រះមានព្រះភាគព្រះនាមសិទ្ធត្ថ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ ទ្រង់ប្រកាសនូវសច្ចៈ ញុំាងពួកសត្វឲ្យរំលត់ទុក្ខ ខ្ញុំបានយកផ្កាឈូកដែលដុះក្នុងទឹក ជាទីរីករាយនៃចិត្តធ្វើជាឆត្រផ្កា ហើយបូជាព្រះសម្ពុទ្ធ ។ ឯព្រះព្រះសាស្តា ព្រះនាមសិទ្ធត្ថ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់ឋិតនៅក្នុងពួកភិក្ខុ ហើយសម្តែងនូវគាថាទាំងនេះថា បុគ្គលណា ញុំាងចិត្តឲ្យជ្រះថ្លាបានបាំងឆត្រផ្កាថ្វាយតថាគត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយចិត្តជ្រះថ្លានោះឡើយ ។ លុះព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថ ជាលោកនាយក ទ្រង់ត្រាស់គាថានេះហើយ ទ្រង់បញ្ជូនបរិស័ទទៅ រួចហើយស្តេចពុទ្ធដំណើរទៅកាន់អាកាសដែលជាទីរីករាយនៃសត្វស្វាប ។ កាលព្រះសម្ពុទ្ធជាទេវតារបស់មនុស្ស ទ្រង់ក្រោកឡើង សេតច្ឆត្រក៏អណ្តែតឡើងឆត្រដ៏ឧត្តម បានអណ្តែតទៅពីខាងមុខព្រះសម្ពុទ្ធដ៏ប្រសើរ ។

៣៩

ទសមំ សបរិវារច្ឆត្តទាយកត្ថេរាបទានំ

ចតុន្នវុតេ ឥតោ កប្បេ យំ ឆត្តំ អភិរោបយឹ
ទុគ្គតឹ នាភិជានាមិ បុប្ផច្ឆត្តស្សិទំ ផលំ ។
ចតុសត្តតិកប្បម្ហិ អដ្ឋ ជលសិខា អហុ
សត្តរតនសម្បន្នា ចក្កវត្តី មហព្ពលា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុប្ផច្ឆត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុប្ផច្ឆត្តិយត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ សបរិវារច្ឆត្តទាយកត្ថេរាបទានំ

[៣០] បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
អាកាសេ ជលវុដ្ឋីវ វស្សតេ ធម្មវុដ្ឋិយា ។
តមទ្ទសាសឹ សម្ពុទ្ធំ ទេសេន្តំ អមតំ បទំ
សកំ ចិត្តំ បសាទេត្វា អគមាសឹ សកំ ឃរំ ។

ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាឆត្រ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយឆត្រផ្កា ។ ក្នុងកប្បទី ៧៤ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៨ ជាតិ មានព្រះនាមជលសិខៈ ទ្រង់បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុប្ផច្ឆត្តិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុប្ផច្ឆត្តិយត្ថេរាបទាន ។

# សបរិវារច្ឆត្តទាយកត្ថេរាបទាន ទី ១០

[៣០] ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវគ្រឿងបូជា ទ្រង់បង្អុរនូវភ្លៀងគឺធម៌ ដូចជាទឹកភ្លៀងបង្អុរចុះអំពីអាកាស ។ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធអង្គនោះ កំពុងសម្តែងអមតបទ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយបានទៅកាន់ផ្ទះរបស់ខ្លួនវិញ ។

ឆត្តំ អលង្កតំ គយ្ហ ឧបគញ្ឆឹ នរុត្តមំ
ហដ្ឋោ ហដ្ឋេន ចិត្តេន អាកាសេ ឧក្ខិបឹ អហំ ។
សុសង្គហិតយានំវ ទន្តោវ សាវកុត្តមោ
ឧបគន្ត្វាន សម្ពុទ្ធំ មត្ថកេ សម្បតិដ្ឋហិ ។
អនុកម្បកោ ការុណិកោ ពុទ្ធោ លោកគ្គនាយកោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យេន ឆត្តមិទំ ទិន្នំ អលង្កតំ មនោរមំ
តេន ចិត្តប្បសាទេន ទុគ្គតឹ សោ ន គច្ឆតិ ។
សត្តក្ខត្តុំ ច ទេវេសុ ទេវរជ្ជំ ករិស្សតិ
ទ្វត្តឹសក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិ នាសវោ ។

ខ្ញុំកាន់ឆត្រដែលស្អិតស្អាងហើយ ដើរចូលទៅរកព្រះសម្ពុទ្ធ ដ៏ប្រសើរជាងពួកនរៈ ខ្ញុំជាអ្នកមានចិត្តរីករាយ បានលើកឡើង (នូវឆត្រ) ទៅឰដ៏អាកាស ។ (ឆត្រនោះមានលម្អ) ដូចជាយាន ដែលជាងផ្ចុំស្រួលហើយ ឬដូចសារ័កជាឆ្មើម ដែលមានឥន្ទ្រិយទូន្មានល្អហើយ អណ្តែតទៅរកព្រះសម្ពុទ្ធ ហើយប្រតិស្ឋាននៅលើព្រះសិរ្សៈ ។ ព្រះពុទ្ធអគ្គនាយកក្នុងលោក ទ្រង់មានសេចក្តីអនុគ្រោះ ប្រកបដោយសេចក្តីករុណា ទ្រង់គង់នៅក្នុងពួកភិក្ខុ ហើយសម្តែង នូវគាថាទាំងនេះថា បុគ្គលណាបានថ្វាយឆ័ត្រនេះ ដែលតាក់តែងគួរជាទីរីករាយនៃចិត្ត បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ ដោយចិត្តជ្រះថ្លានោះឡើយ ។ បុគ្គលនោះនឹងបានជាទេវរាជ ក្នុងទេវលោក អស់វារៈ ៧ ដង នឹងបានជាស្តេចចក្រពត្តិ ៣២ ដង ។ នៅមួយសែនកប្បទៀត នឹងមានព្រះសាស្តា ព្រះនាមគោតមៈ កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងមកត្រាស់ដឹងក្នុងលោក បុគ្គលនោះនឹងបានជាធម្មទាយាទ ជាឱរស ជាធម្មនិម្មិតរបស់ព្រះគោតមនោះ នឹងកំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ហើយនឹងបរិនិព្វាន ។

៤១

ទសមំ  សបរិវារច្ឆត្តទាយកត្ថេរាបទានំ

ពុទ្ធស្ស តិរមញ្ញាយ    វាចាសភិ មុទីរិតំ
បសន្នចិត្តោ សុមនោ    ភិយ្យោ ហាសំ ជនេសហំ ។
ជហិត្វា មានុសំ យោនឹ    ទិព្វយោនឹ សមជ្ឈគំ
វិមានមុត្តមំ មយ្ហំ    អព្ភុគ្គតំ មនោរមំ ។
វិមានា និក្ខមន្តស្ស    សេតច្ឆត្តំ ធរីយតិ
តទា សញ្ញំ បដិលភាមិ    បុព្វកម្មស្សិទំ ផលំ ។
ទេវលោកា ចវិត្វាន    មនុស្សត្តញ្ច អាគមឹ
ឆត្តឹសក្ខត្តុំ ចក្កវត្តិ    សត្តកប្បសតម្ហិតោ ។
តម្ហា កាយា ចវិត្វាន    អាគច្ឆឹ តិទសំ បុរំ
សំសរិត្វានុបុព្វេន    មានុសំ បុនរាគមឹ ។
ឱក្កន្តំ មាតុកុច្ឆឹ មំ    សេតច្ឆត្តំ អធារយុំ
ជាតិយា សត្តវស្សោហំ    បព្វជឹ អនគារិយំ ។
សុនន្ទោ នាម នាមេន    ព្រាហ្មណោ មន្តចារគូ
ផលិកំ ឆត្តមាទាយ    សាវកគ្គស្ស សោ អទា ។
អនុមោទិ មហាវីរោ    សារីបុត្តោ មហាកថី
សុត្វានុមោទនំ តស្ស    បុព្វកម្មំ អនុស្សរឹ ។

សបរិវារច្ឆត្តទាយកត្ថេរាបទាន ទី ១០

ខ្ញុំដឹង នូវព្រះវាចាដ៏អង់អាច ដែលព្រះសម្ពុទ្ធសម្តែងហើយ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើសេចក្តីរីករាយឲ្យកើតឡើងយ៉ាងខ្លាំង ។ ខ្ញុំលះបង់កំណើតមនុស្សហើយ ក៏បានទៅកាន់កំណើតជាទិព្វ វិមានរបស់ខ្ញុំ ឧត្តមខ្ពស់ត្រដែត ជាទីរីករាយនៃចិត្ត ។ កាលខ្ញុំចេញពីវិមាន គេរមែងបាំងស្វេតច្ឆ-ត្រឲ្យ ខ្ញុំបានសញ្ញាក្នុងកាលនោះ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ៧០០ អំពីកប្បនេះ ខ្ញុំច្យុតចាកទេវលោកមកកើតជាមនុស្ស បានជាស្តេចចក្រពត្តិ ៣៦ ជាតិ ។ ខ្ញុំច្យុតចាកកាយនោះ មកកាន់បុរីឈ្មោះតាវត្តិង្ស ហើយអន្ទោលទៅមកតាមលំដាប់ ក៏បានមកកាន់កំណើតមនុស្សនេះទៀត ។ ពួកទេវតាបាំងស្វេតច្ឆត្រឲ្យខ្ញុំ ខ្ញុំកាលដែលចុះកាន់ផ្ទៃនៃមាតា ខ្ញុំមានអាយុ ៧ ឆ្នាំអំពីកំណើត ក៏បានចូលទៅកាន់ផ្នួស ។ ព្រាហ្មណ៍ឈ្មោះសុនន្ទ ជាអ្នកចេះចប់មន្ត ព្រាហ្មណ៍នោះកាន់យកឆត្រជាវិការៈនៃកែវផ្ទេក ប្រគេនដល់អគ្គសាវ័ក ។ ព្រះសារីបុត្ត ជាអគ្គសាវ័ក ជាអ្នកមានព្យាយាមធំ មានថ្វីព្រះឱស្ឋដ៏ប្រសើរ បានអនុមោទនា ខ្ញុំបានស្តាប់នូវអនុមោទនារបស់ព្រះសារីបុត្តនោះហើយ ក៏បាននឹកឃើញបុញ្ញកម្ម ។

៤២



អញ្ជលឹ បគ្គហេត្វាន សកំ ចិត្តំ បសាទយឹ
សរិត្វា បុរិមំ កម្មំ អរហត្តំ អបាបុណឹ ។
ឧដ្ឋាយ អាសនា តម្ហា សិរេ កត្វាន អញ្ជលឹ
សម្ពុទ្ធំ អភិវាទេត្វា ឥមំ វាចមុទីរយឹ ។
សតសហស្សេ ឥតោ កប្បេ ពុទ្ធោ លោកេ អនុត្តរោ
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ ។
តស្ស ឆត្តំ មយា ទិន្នំ វិចិត្តំ សមលង្កតំ
ឧភោហត្ថេហិ បគ្គណ្ហិ សយម្ភូ អគ្គបុគ្គលោ ។
អហោ ពុទ្ធោ អហោ ធម្មោ អហោ នោ សត្ថុសម្បទា
ឯកច្ឆត្តស្ស ទានេន ទុគ្គតឹ នូបបជ្ជហំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ខ្ញុំបានផ្គងអញ្ជលី ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយរលឹកបុព្វកម្ម ក៏បានដល់ព្រះអរហត្ត ។ ខ្ញុំក្រោកអំពីអាសនៈនោះ ហើយធ្វើអញ្ជលីលើក្បាលថ្វាយបង្គំព្រះសម្ពុទ្ធ ហើយពោលវាចានេះថា ក្នុងមួយសែនកប្ប អំពីកប្បនេះ ព្រះពុទ្ធដ៏ប្រសើរ ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា ត្រាស់ឡើងក្នុងលោក ។ ខ្ញុំបានថ្វាយឆត្រដ៏វិចិត្រ តាក់តែងល្អហើយ ដល់ព្រះបទុមុត្តរៈអង្គនោះ ឯព្រះសយម្ភូជាអគ្គបុគ្គល ទ្រង់ទទួលហើយ ដោយព្រះហស្តទាំងពីរ ។ ឱ! ព្រះពុទ្ធ ឱ! ព្រះធម៌ ឱ! សម្បទានៃព្រះសាស្តា របស់យើង ខ្ញុំមិនដែលទៅកាន់ទុគ្គតិ ដោយការថ្វាយឆត្រមួយប៉ុណ្ណោះ ។ ខ្ញុំដុតបំផ្លាញកិលេសទាំងឡាយហើយ ខ្ញុំគាស់រំលើងភពទាំងពួងហើយ ខ្ញុំកំណត់ដឹងនូវអាសវៈ ទាំងពួងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈឡើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

៤៣

ឧទ្ទានំ

ឥត្ថំ សុទំ អាយស្មា សបរិវារច្ឆត្តទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សបរិវារច្ឆត្តទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ឧទ្ទានំ

ឧម្មាបុប្ផញ្ច បុឡិនំ ហាសោ យញ្ញោ និមិត្តកោ
សំសារកោ និគ្គុណ្ឌិ ច សុមនា បុប្ផច្ឆត្តកោ
សបរិវារច្ឆត្តោ ច គាថា សត្តសតុត្តរា ។

ឧម្មាបុប្ផិយវគ្គោ តេត្តឹសោ ។

---

ឧទ្ទាន

បានឮថា ព្រះសបរិវារច្ឆត្តទាយកត្ថេរ មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សបរិវារច្ឆត្តទាយកត្ថេរាបទាន ។

## ឧទ្ទាន

ឧម្មាបុប្ផិយត្ថេរាបទាន ១ បុឡិនបូជកត្ថេរាបទាន ១ ហាសជនកត្ថេរាបទាន ១ យញ្ញសាមិកត្ថេរាបទាន ១ និមិត្តសញ្ញកត្ថេរាបទាន ១ អន្នសំសាវកត្ថេរាបទាន ១ និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ១ សុមនាវេឡិយត្ថេរាបទាន ១ បុប្ផច្ឆត្តិយត្ថេរាបទាន ១ សបរិវារច្ឆត្តទាយកត្ថេរាបទាន ១ មានគាថា ៧០ ។

ចប់ ឧម្មាបុប្ផិយវគ្គ ទី ៣៣ ។

# ចតុត្តឹសោ គន្ធោទកវគ្គោ

## បឋមំ គន្ធធូបិយត្ថេរាបទានំ

[៣១] សិទ្ធត្ថស្ស ភគវតោ　　គន្ធធូបំ អទាសហំ
សុមនេហិ បដិច្ឆន្នំ　　ពុទ្ធានុច្ឆវិកញ្ច តំ ។
កញ្ចនគ្ឃយសង្កាសំ　　ពុទ្ធំ លោកគ្គនាយកំ
ឥន្ទីវរំវ ជលិតំ　　អាទិត្តំវ ហុតាសនំ ។
ព្យគ្ឃុសភំវ បរមំ　　អភិជាតំវ កេសរឹ
និសិន្នំ សមណានគ្គំ　　ភិក្ខុសង្ឃបុរក្ខតំ ។
ទិស្វា ចិត្តំ បសាទេត្វា　　បគ្គហេត្វាន អញ្ជលឹ
វន្ទិត្វា សត្ថុនោ បាទេ　　បក្កាមឹ ឧត្តរាមុខោ ។
ចតុន្នវុតេ ឥតោ កប្បេ　　យំ គន្ធមទទឹ តទា
ទុគ្គតឹ នាភិជានាមិ　　គន្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

# គន្ធោទកវគ្គ ទី ៣៤

## គន្ធធូបិយត្ថេរាបទាន ទី ១

[៣១] ខ្ញុំបានថ្វាយធូបក្រអូប ដល់ព្រះមានព្រះភាគព្រះនាមសិទ្ធត្ថ ឯធូបក្រអូបនោះ ស្រោបដោយផ្កាម្លិះ ជារបស់សមគួរដល់ព្រះពុទ្ធ ។ ខ្ញុំបានឃើញព្រះពុទ្ធជាអគ្គនាយកក្នុងលោក ប្រាកដស្មើដោយចេតិយមាស ទ្រង់រុងរឿងដូចរាជព្រឹក្ស ឬដូចភ្លើងកំពុងឆេះ ទ្រង់អង់អាចក្រៃលែង ដូចជាខ្លាធំ ឬដូចកេសររាជសីហ៍ ជាអភិជាត ព្រះអង្គប្រសើរជាងពួកសមណៈ មានភិក្ខុសង្ឃចោមរោម ទ្រង់កំពុងគង់នៅ ។ លុះខ្ញុំឃើញហើយ ក៏ញុំាំងចិត្តឲ្យជ្រះថ្លា ផ្គងអញ្ជលីថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តា បែរមុខទៅកាន់ទិសឧត្តរ ហើយចៀសចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាគ្រឿងក្រអូប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាគ្រឿងក្រអូប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

៤៨

ទុតិយំ ឧទកបូជកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា គន្ធធូបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធធូបិយត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ ឧទកបូជកត្ថេរាបទានំ

[៣២] សុវណ្ណវណ្ណំ សម្ពុទ្ធំ　　គច្ឆន្តំ អនិលញ្ជសេ
ឃតាសនំវ ជលិតំ　　អាទិត្តំវ ហុតាសនំ ។
បាណិនា ឧទកំ គយ្ហ　　អាកាសេ ឧក្ខិបឹ អហំ
សម្បដិច្ឆិ មហាវីរោ　　ពុទ្ធោ ការុណិកោ ឥសិ ។
អន្តលិក្ខេ ឋិតោ សត្ថា　　បទុមុត្តរនាមកោ
មម សង្កប្បមញ្ញាយ　　ឥមំ គាថំ អភាសថ ។
ឥមិនា ទកទានេន　　បីតិឧប្បាទនេន ច
កប្បសតសហស្សំបិ　　ទុគ្គតឹ នូបបជ្ជសិ ។
តេន កម្មេន ទិបទិន្ទ　　លោកជេដ្ឋ នរាសភ
បត្តោម្ហិ អចលំ ឋានំ　　ហិត្វា ជយបរាជយំ ។

ឧទកបូជកត្ថេរាបទាន ទី ២

បានឮថា ព្រះគន្ធធូបិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធធូបិយត្ថេរាបទាន ។

# ឧទកបូជកត្ថេរាបទាន ទី ២

[៣២] (ខ្ញុំបានឃើញ) នូវព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានវណ្ណៈដូចមាស កំពុងពុទ្ធដំណើរទៅ ឰដ៏អាកាស រុងរឿងដូចភ្លើងឆេះខ្វាញ់ ឬដូចភ្លើងកំពុងឆេះ ខ្ញុំក្បង់យកទឹកដោយដៃ សាចឡើងទៅឰដ៏អាកាស ឯព្រះពុទ្ធជាឥសីទ្រង់ព្យាយាមធំ ប្រកបដោយសេចក្ដីករុណា ទ្រង់ទទួលយក ។ ព្រះសាស្ដាព្រះនាមបទុមុត្តរៈ ប្រថាប់នៅឰដ៏អាកាស ទ្រង់ជ្រាបនូវសេចក្ដីត្រិះរិះ របស់ខ្ញុំហើយ ទើបត្រាស់នូវគាថានេះថា អ្នកនឹងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប ដោយការថ្វាយទឹកនេះផង ដោយការញុំាងបីតិឲ្យកើតឡើងផង ។ បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ ជាច្បងក្នុងលោក ប្រសើរជាងពួកនរៈ ខ្ញុំព្រះអង្គលះបង់ នូវការឈ្នះនិងការចាញ់ ហើយបានដល់ នូវអចលដ្ឋាន ដោយកុសលកម្មនោះ ។

សហស្សរាជនាមេន តយោ ច ចក្កវត្តិនោ
បញ្ចសដ្ឋិកប្បសតេ ចាតុរន្តា ជនាធិបា ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧទកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកបូជកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ បុន្នាគបុប្ផិយត្ថេរាបទានំ

[៣៣] កាននំ វនមោគ្គយ្ហ វសាមិ លុទ្ទកោ អហំ
បុន្នាគំ បុប្ផិតំ ទិស្វា ពុទ្ធសេដ្ឋំ អនុស្សរឹ ។
តំ បុប្ផំ ឱចិនិត្វាន សុគន្ធំ គន្ធិតំ សុភំ
ថូបំ កត្វាន បុឡិនេ ពុទ្ធស្ស អភិរោបយឹ ។
ទ្វេនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ក្នុងកប្បទី ១៦៥ អំពីកប្បនេះ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ជាតិ ព្រះនាមសហស្សរាជ ទ្រង់មានសមុទ្រទាំង ៤ ជាទីបំផុត ជាធំជាងពួកជន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទកបូជកត្ថេរាបទាន ។

# បុន្នាគបុប្ផិយត្ថេរាបទាន ទី ៣

[៣៣] ខ្ញុំបានកើតជាព្រានព្រៃ អាស្រ័យនៅក្នុងព្រៃធំ បានឃើញនូវឈើបុន្នាគ ដែលមានផ្ការីក ក៏នឹកដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។ ខ្ញុំបេះយកផ្កាដែលមានក្លិនក្រអូបឈ្ងុយឈ្ងប់ល្អនោះ ធ្វើជាព្រះស្តូបលើផ្នូកខ្សាច់ ហើយបូជាចំពោះព្រះសម្ពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

៤៧

ចតុត្ថំ ឯកទុស្សទាយកត្ថេរាបទានំ

ឯកម្ហិ នវុតេ កប្បេ ឯកោ អាសិ តមោនុទោ
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្វលោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុន្នាគបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុន្នាគបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ ឯកទុស្សទាយកត្ថេរាបទានំ

[៣៤] នគរេ ហំសវតិយា អហោសឹ តិណហារកោ
តិណហារេន ជីវាមិ តេន បោសេមិ ទារកេ ។
បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
តមន្ធការំ នាសេត្វា ឧប្បជ្ជិ លោកនាយកោ ។

ក្នុងកប្បទី ៩១ ខ្ញុំបានកើតជាស្តេចចក្រពត្តិ មួយព្រះអង្គ ព្រះនាមតមោនុទៈ ទ្រង់បរិបូណ៌ ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះបុន្នាគបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុន្នាគបុប្ផិយត្ថេរាបទាន ។

# ឯកទុស្សទាយកត្ថេរាបទាន ទី ៤

[៣៤] ខ្ញុំបានកើតជាអ្នកនាំស្មៅ នៅក្នុងក្រុងហង្សវតី តែងចិញ្ចឹមជីវិត ដោយការនាំស្មៅ ទាំងចិញ្ចឹមប្រពន្ធកូន ដោយការនាំស្មៅនោះដែរ ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ជានាយកក្នុងលោក ទ្រង់ញុំាំងងងឹតអន្ធការឲ្យវិនាស ហើយត្រាស់ដឹងហើយ ។

សកេ ឃរេ និសីទិត្វា ឯវំ ចិន្តេសហំ តទា
ពុទ្ធោ លោកេ សមុប្បន្នោ ទេយ្យធម្មោ ច នត្ថិ មេ ។
ឥទំ មេ សាដកំ ឯកំ នត្ថិ មេ កោចិ ទាយកោ
ទុក្ខោ និរយសម្ផស្សោ រោបយិស្សាមិ ទក្ខិណំ ។
ឯវាហំ ចិន្តយិត្វាន សកំ ចិត្តំ បសាទយឹ
ឯកំ ទុស្សំ គហេត្វាន ពុទ្ធសេដ្ឋស្ស ទាសហំ ។
ឯកំ ទុស្សំ ទទិត្វាន ឧក្កុដ្ឋឹ សម្បវត្តយឹ
យទិ ពុទ្ធោ តុវំ វីរ តារេហិ មំ មហាមុនិ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
មម ទានំ បកិត្តេន្តោ អកាមេ អនុមោទនំ ។
ឥមិនា ឯកទុស្សេន ចេតនាបណិធីហិ ច
កប្បសតសហស្សានិ វិនិបាតំ ន គច្ឆតិ ។
ឆត្តឹសក្ខត្តុ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
តេត្តឹសក្ខត្តុ រាជា ច ចក្កវត្តិ ភវិស្សតិ ។

កាលនោះ ខ្ញុំអង្គុយក្នុងផ្ទះរបស់ខ្លួន ហើយគិតយ៉ាងនេះថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ឯទេយ្យធម៌ របស់អាត្មាអញមិនមាន អាត្មាអញមានតែសាដកមួយនេះ បើអាត្មាអញមិនមានការឲ្យអ្វីមួយទេ នោះការពាល់ត្រូវនូវនរកនាំមកនូវទុក្ខ ហេតុនោះ អាត្មាអញនឹងបណ្តុះទក្ខិណាទាន ។ លុះខ្ញុំគិតយ៉ាងនេះរួចហើយ ក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ខ្ញុំបានយកសំពត់មួយថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ លុះថ្វាយសំពត់មួយរួចហើយក៏ស្រែកហ៊ោឡើងថា បពិត្រព្រះអង្គទ្រង់មានព្យាយាមជាមហាមុនី បើព្រះអង្គជាព្រះពុទ្ធពិត សូមចម្លងខ្ញុំព្រះអង្គផង ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជា កាលសម្តែងទានរបស់ខ្ញុំ ទ្រង់បានធ្វើអនុមោទនាដល់ខ្ញុំថា កុលបុត្តនេះ នឹងមិនទៅកាន់វិនិបាតអស់មួយសែនកប្ប ដោយផលនៃសំពត់មួយនេះផង ដោយការតម្កល់ទុកនូវចេតនាផង នឹងបានកើតជាព្រះឥន្ទ្រ គ្រងទេវរាជ្យអស់ ៣៦ ដង នឹងកើតជាស្តេចចក្រពត្តិ ៣៣ ដង

៤៩

ចតុត្ថំ ឯកទុស្សទាយកត្ថេរាបទានំ

បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ទេវលោកេ មនុស្សេ វា សំសរន្តោ តុវំ ភវេ ។
រូបវា គុណសម្បន្នោ អនវក្កន្តទេហវា
អក្ខោភំ អមិតំ ទុស្សំ ភវិស្សតិ យទិច្ឆកំ ។
ឥទំ វត្វាន សម្ពុទ្ធោ ជលជុត្តមនាមកោ
នភំ អព្ភុគ្គមិ ធីរោ ហំសរាជាវ អម្ពរេ ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
ភោគេ មេ ឩនតា នត្ថិ ឯកទុស្សស្សិទំ ផលំ ។
បទុទ្ធារេ បទុទ្ធារេ ទុស្សំ និព្វត្តតេ មមំ
ហេដ្ឋា ទុស្សម្ហិ តិដ្ឋាមិ ឧបរិ ឆទនំ មម ។
ចក្កវាឡមុបាទាយ សកាននំ សបព្វតំ
ឥច្ឆមានោ ចហំ អជ្ជ ទុស្សេហច្ឆាទយេយ្យហំ ។
តេនេវ ឯកទុស្សេន សំសរន្តោ ភវាភវេ
សុវណ្ណវណ្ណោ ហុត្វាន សំសរាមិ ភវាភវេ ។

ឯកទុស្សទាយកត្ថេរាបទាន ទី ៤

នឹងគ្រប់គ្រងប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេ-
យ្យកប្ប អ្នកកាលអន្ទោលទៅ ក្នុងទេវលោកនិងមនុស្សលោក
នឹងមានរូបល្អ មានគុណធម៌បរិបូណ៌ មានរាងកាយមិនវិកល-
វិការៈ សំពត់ច្រើនរាប់មិនបាន នឹងកើតឡើង (ដល់អ្នក)
គួរតាមសេចក្ដីប្រាថ្នា ។ លុះព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ
ជាអ្នកប្រាជ្ញ ទ្រង់ត្រាស់នូវពាក្យនេះហើយ ស្ដេចហោះ
ឡើងទៅកាន់អាកាស ដូចស្ដេចហង្ស ហើរក្នុងអាកាស ។
ខ្ញុំបានទៅយកកំណើតណា ៗ ទោះបីជាទេវតាឬមនុស្ស ខ្ញុំ
មិនដែលខ្វះខាតភោគៈសោះឡើយ នេះជាផល នៃសំពត់
មួយ ។ សំពត់តែងកើតឡើងដល់ខ្ញុំរាល់ជំហាន ខាងក្រោម
ខ្ញុំឈរលើសំពត់ ខាងលើសំពត់ជាដំបូលបាំងខ្ញុំ ។ ក្នុងថ្ងៃ
នេះ សូម្បីខ្ញុំប្រាថ្នានឹងគ្រប ក៏អាចគ្របព្រៃនិងភ្នំ រហូតចក្រ-
វាឡ ដោយសំពត់ទាំងឡាយបាន ។ ខ្ញុំកាលអន្ទោលទៅក្នុង
ភពតូចភពធំ ជាអ្នកមានសម្បុរល្អដូចមាស តែងអន្ទោលទៅ
ក្នុងភពតូចភពធំ ដោយផលនៃការថ្វាយសំពត់មួយនោះ ។

៤០



វិបាកំ ឯកទុស្សស្ស    នជ្ឈគំ កត្ថចិក្ខយំ
អយំ មេ អន្តិមា ជាតិ    វិបច្ចតិ ឥធាបិ មេ ។
សតសហស្សិតោ កប្បេ    យំ ទុស្សមទទឹ តទា
ទុគ្គតឹ នាភិជានាមិ    ឯកទុស្សស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកទុស្សទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកទុស្សទាយកត្ថេរស្ស អបទានំ សមត្តំ ។

ខ្ញុំមិនចេះអស់ផលនៃសំពត់មួយ ក្នុងទីណាមួយឡើយ នេះជាជាតិបំផុតរបស់ខ្ញុំ កុសលកម្មនោះ ឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះផងទៀត ។ ក្នុងកប្បទីមួយសែនកប្ប អំពីកប្បនេះកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយសំពត់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់មួយ ។ ខ្ញុំដុតបំផ្លាញពួកកិលេសអស់ហើយ ខ្ញុំគាស់រំលើងភពទាំងពួងអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទីងហើយដូច្នោះដែរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទុស្សទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទុស្សទាយកត្ថេរាបទាន ។

៥១

# បញ្ចមំ ផុស្សិតកម្មិយត្ថេរាបទានំ

[៣៨] វិបស្សី នាម សម្ពុទ្ធោ លោកជេដ្ឋោ នរាសភោ
ខីណាសវេហិ សហិតោ សង្ឃារាមេ វសី តទា ។
អារាមទ្វារា និក្ខម្ម វិបស្សី លោកនាយកោ
សហ សតសហស្សេហិ(១) អដ្ឋខីណាសវេហិ សោ ។
អជិនេន និវត្ថោហំ វាកចីរធរោបិ ច
កុសុម្ភោទកមាទាយ សម្ពុទ្ធំ ឧបសង្កមឹ ។
សកំ ចិត្តំ បសាទេត្វា វេទជាតោ កតញ្ជលី
កុសុម្ភោទកមាទាយ ពុទ្ធមព្ភុកិរឹ អហំ ។
តេន កម្មេន សម្ពុទ្ធោ ជលជុត្តមនាមកោ
មម កម្មំ បកិត្តេត្វា អគមា យេន បត្ថិតំ ។
ផុស្សិតា បញ្ចសហស្សា យេហិ បូជេសហំ ជិនំ
អឌ្ឍតេយ្យសហស្សេហិ ទេវរជ្ជមការយឹ ។
អឌ្ឍតេយ្យសហស្សេហិ ចក្កវត្តិ អហោសហំ
អវសេសេន កម្មេន អរហត្តំ អបាបុណឹ ។
ទេវរាជា យទាហោសឹ មនុជាធិបតិ តទា
តំយេវ នាមធេយ្យំ មេ ផុស្សិតោ នាមហោសហំ ។

---

១ ម. សហស្សសតសិស្សេហីតិ ទិស្សតិ ។

# ផុស្សិតកម្មិយត្ថេរាបទាន ទី ៥

[៣៥] កាលនោះ ព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ប្រសើរជាងនរជន បរិបូណ៌ដោយព្រះខីណាស្រព ទ្រង់គង់នៅក្នុងសង្ឃារាម ។ ព្រះវិបស្សីលោកនាយក អង្គនោះ ស្តេចចេញអំពីទ្វារអារាម មួយអន្លើដោយព្រះខីណា-ស្រព ៨ សែនអង្គ ។ ខ្ញុំស្លៀកស្បែកខ្លាឃ្មុំ ដណ្តប់សម្បកឈើ ហើយដងយកទឹកអណ្តូង កាន់ដើរចូលទៅគាល់ព្រះសម្ពុទ្ធ ។ ខ្ញុំញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា មានសេចក្តីត្រេកអរកើតឡើង ក៏ធ្វើអញ្ជលី យកទឹកអណ្តូងនោះ ប្រោះព្រំព្រះសម្ពុទ្ធ ។ ហេតុតែកុសលកម្មនោះ ព្រះសម្ពុទ្ធ ព្រះនាមបទុ-មុត្តរៈ សម្តែងនូវកម្មនោះដល់ខ្ញុំ ហើយស្តេចពុទ្ធដំណើរទៅកាន់ទី គួរតាមប្រាថ្នា ខ្ញុំបានបូជាព្រះជិនស្រី ដោយទឹកប្រាំពាន់តំណក់ បានសោយទេវរាជ្យ ៣ ពាន់ដង ដោយកន្ទះ (២៥០០) ។ ខ្ញុំបានកើតជាស្តេចចក្រពត្តិ ៣ ពាន់ដង ដោយកន្ទះ បានដល់អរហត្ត ដោយកុសលកម្មដ៏សេសសល់ ។ ខ្ញុំបានជាស្តេចនៃទេវតា ជាធំជាងពួកមនុស្ស ក្នុងកាលណា កាលនោះ ឈ្មោះរបស់ខ្ញុំនោះ ក៏ឈ្មោះថាផុស្សិតៈ ។

ទេវភូតស្ស សន្តស្ស　　អថាបិ មានុសស្ស វា
សមន្តា ព្យាមតោ មយ្ហំ　　ផុស្សិតំបិ បវស្សតិ ។
ភវា ឧគ្ឃាដិតា មយ្ហំ　　កិលេសា ឈាបិតា មម
សព្វាសវបរិក្ខីណោ　　ផុស្សិតស្ស ឥទំ ផលំ ។
ចន្ទនស្សេវ មេ វស្សោ[១]　　តថា គន្ធោ បវាយតិ
សារីរិកោ មម គន្ធោ　　អឌ្ឍកោសេ បវាយតិ ។
ទិព្វគន្ធំ សម្បវន្តំ　　បុញ្ញកម្មសមង្គិនំ
គន្ធំ ឃត្វាន ជានន្តិ　　ផុស្សិតោ អាគតោ ឥធ ។
សាខា បលាសកដ្ឋានិ　　តិណានិបិច សព្វសោ
មម សង្កប្បមញ្ញាយ　　គន្ធោ សម្បជ្ជតេ ខណេ ។
សតសហស្សេឥតោ កប្បេ　　ចន្ទនំ[២] អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　　ផុស្សិតចស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

---
១ ម. កាយោ ។ ២ ផុស្សិគន្ទិបិ បាហោ យុត្តតរោ យេវ (មតិ.) ។

មួយទៀត កាលខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស គ្រាប់ភ្លៀងរមែងបង្អុរចុះដល់ខ្ញុំ មួយព្យាមដោយជុំវិញ ។ ខ្ញុំគាស់រំលើងភពចោលហើយ ខ្ញុំផុតបំផ្លាញពួកកិលេសអស់ហើយ ខ្ញុំជាអ្នកអស់អាសវៈទាំងពួងហើយ នេះជាផល នៃតំណក់ទឹក ។ កាយរបស់ខ្ញុំ មានក្លិនក្រអូបផ្សាយទៅ ដូចក្លិននៃខ្លឹមចន្ទន៍ ក្លិនដែលជាប់នឹងសរីរៈរបស់ខ្ញុំ រមែងផ្សាយទៅបានក្នុងទីកន្លះក្រោស (២៥០ជួរធ្នូ) ។ ពួកជនគ្រាន់តែធុំក្លិនខ្ញុំក៏ស្គាល់ខ្ញុំ ដែលមានក្លិនទិព្វផ្សព្វផ្សាយ ប្រកបដោយបុញ្ញកម្មថា ឱ! ផុស្សិតៈមកក្នុងទីនេះហើយ ។ សូម្បីតែមែកឈើ ស្លឹកឈើ កំណាត់ឈើ និងស្មៅ ក៏ហាក់ដូចជាដឹងបំណងរបស់ខ្ញុំ ដោយសព្វគ្រប់ ហើយបញ្ចេញនូវក្លិន ក្នុងខណៈនោះ ។ ក្នុងមួយសែនកប្ប អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយនូវតំណក់ទឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃតំណក់ទឹក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឆដ្ឋំ បភង្ករត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា ផុស្សិតកម្មិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផុស្សិតកម្មិយត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ បភង្ករត្ថេរាបទានំ

[៣៦] បទុមុត្តរភគវតោ លោកជេដ្ឋស្ស តាទិនោ
បវនេ[១] ចេតិយំ អាសិ វាឡមិគសមាកុលេ ។
ន កោចិ វិសហិ គន្តុំ ចេតិយំ អភិវន្ទិតុំ
តិណកដ្ឋលតោនទ្ធំ បលុគ្គំ អាសិ ចេតិយំ ។
វនកម្មិកោ តទា អាសឹ បិតាបេតាមហេនហំ[២]
អទ្ទសំ បវនេ ថូបំ លុគ្គំ តិណលតាកុលំ ។
ទិស្វានាហំ ពុទ្ធថូបំ គរុចិត្តំ ឧបដ្ឋហឹ
ពុទ្ធសេដ្ឋស្ស ថូបោយំ បលុគ្គោ អច្ឆតិ វនេ ។
នច្ឆន្នំ នប្បតិរូបំ ជានន្តស្ស គុណាគុណំ
ពុទ្ធថូបំ អសោធេត្វា អញ្ញំ កម្មំ បយោជយេ ។

---

១ ម. វិបិនេ ។ ២ ម. បិតុមាតុមតេនហិ ។

បានឮថា ព្រះផុស្សិតកម្មិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផុស្សិតកម្មិយត្ថេរាបទាន ។

# បភង្គរត្ថេរាបទាន ទី ៦

[៣៦] ចេតិយរបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាច្បងក្នុងលោក ប្រកបដោយតាទិគុណ តាំងនៅក្នុងព្រៃធំ ជាទីកុះករដោយម្រឹគសាហាវ ។ បុគ្គលណាមួយ មិនអាចនឹងទៅថ្វាយបង្គំចេតិយបានឡើយ ចេតិយនោះត្រូវស្មៅនិងឈើវល្លិរួបរឹតរលើងរលំ ។ កាលនោះ ខ្ញុំជាអ្នកធ្វើការងារក្នុងព្រៃ ជាមួយបិតានិងជីតា ក៏បានឃើញព្រះស្តូបក្នុងព្រៃធំ ដែលមានស្មៅវល្លិរួបរឹតរលើងរលំនោះ ។ លុះខ្ញុំឃើញពុទ្ធស្តូបហើយ ក៏តាំងចិត្តគោរពថា ព្រះស្តូបរបស់ព្រះសម្ពុទ្ធដ៏ប្រសើរនេះ នៅក្នុងព្រៃរលើងរលំខូចខាតអស់ អ្នកស្គាល់គុណនិងទោសនៃចេតិយនោះ បើមិនបានជម្រះនូវពុទ្ធស្តូបដែលមិនកំបាំង មិនសមគួរ ត្រឡប់ទៅប្រកបការងារដទៃវិញ

តិណកដ្ឋញ្ច វល្លិញ្ច   សោធយិត្វាន ចេតិយេ
វន្ទិត្វា អដ្ឋ វារានិ[១]   បដិកុដិកោ អគច្ឆហំ ។
តេន កម្មេន សុកតេន   ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ   តាវត្តឹសំ អគញ្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ   សោវណ្ណំ សប្បភស្សរំ
សដ្ឋិយោជនមុព្វិទ្ធំ   តឹសយោជនវិត្ថតំ ។
តិសតានិ ច វារានិ   ទេវរជ្ជមការយឹ
បញ្ចវីសតិក្ខត្តុញ្ច   ចក្កវត្តិ អហោសហំ ។
ភវាភវេ សំសរន្តោ   មហាភោគំ លភាមហំ
ភោគេ មេ ឩនតា នត្ថិ   សោធនាយ ឥទំ ផលំ ។
សិវិយា ហត្ថិខន្ធេន   បវនេ គច្ឆតោ មម
យំ យំ ទិសាហំ គច្ឆាមិ   សរណំ សម្បជ្ជតេ[២] វនំ ។
ខាណុំ វា កណ្ដកំ វាបិ   នាហំ បស្សាមិ ចក្ខុនា
បុញ្ញកម្មេន សំយុត្តោ   សយមេវាបនីយរេ ។
កុដ្ឋំ គណ្ឌោ កិលាសោ ច   អបមារោ វិតច្ឆិកា
ទទ្ទុ កណ្ឌុ ច មេ នត្ថិ   សោធនាយ ឥទំ ផលំ ។

---
១ ម. ឋានានិ ។ ២ ម. សិជ្ឈតេ ។

ការណ៍នោះមិនសមគួរទេ ។ ទើបខ្ញុំជម្រះស្មៅនិងឈើវល្លិ៍លើព្រះចេតិយ ហើយថ្វាយបង្គំ រួចថយក្រោយ អស់ ៨ ជំហាន រួចដើរចេញទៅ ។ លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្ម ដែលខ្លួនសាងល្អនោះផង ដោយការតាំងចេតនានោះផង ។ វិមានរបស់ខ្ញុំដែលបុញ្ញកម្មតាក់តែងល្អហើយ ក្នុងឋានតាវត្តិង្សនោះ មានវណ្ណៈភ្លឺផ្លេកដូចមាស មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ខ្ញុំបានសោយទេវរាជ្យ អស់ ៣០០ ដង បានកើតជាស្តេចចក្រពត្តិ ២៥ ដងទៀត ។ ខ្ញុំកាលអន្ទោលទៅក្នុងភពធំភពតូច រមែងបានភោគៈច្រើន ការខ្វះខាតដោយភោគៈ របស់ខ្ញុំមិនមានឡើយ នេះជាផលនៃការជម្រះ ។ កាលខ្ញុំទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬជិះលើ-កដំរី ខ្ញុំទៅកាន់ទិសណា ៗ ព្រៃរមែងសម្រេចជាទីពឹង (របស់ខ្ញុំក្នុងទិសនោះ ៗ) ។ ខ្ញុំប្រកបហើយដោយបុញ្ញកម្ម មិនដែលឃើញដង្គត់ឬបន្លាដោយចក្ខុឡើយ ដង្គត់ជាដើមនោះ តែងចៀសចេញទៅឯង ៗ ។ ខ្ញុំមិនដែលកើតរោគឃ្លង់ ពក ស្រែង ឆ្កួតជ្រូក ឃ្លង់ដែកដំណួចពិស ឬកមរមាស់ឡើយ នេះជាផលនៃការជម្រះ ។

## ឆដ្ឋំ បភង្ករត្ថេរាបទានំ

អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ[១]
នាភិជានាមិ មេ កាយេ    ជាតំ បិឡកពិន្ទុកំ ។
អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ
ទុវេ ភវេ សំសរាមិ    ទេវត្តេ អថ មានុសេ ។
អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ
សុវណ្ណវណ្ណោ សព្វត្ថ    សប្បភាសោ ភវាមហំ ។
អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ
អមនាបំ វិវជ្ជេតិ    មនាបំ ឧបតិដ្ឋតិ ។
អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ
វិសុទ្ធំ ហោតិ មេ ចិត្តំ    ឯកគ្គំ សុសមាហិតំ ។
អញ្ញំបិ មេ អច្ឆរិយំ    ពុទ្ធថូបម្ហិ សោធិតេ
ឯកាសនេ និសីទិត្វា    អរហត្តំ អបាបុណឹ ។
សតសហស្សេ ឥតោ កប្បេ    យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ    សោធនាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

---
១ ម. ពុទ្ធថូបស្ស សោធនេតិ ខាយតិ ។

## បភង្ករត្ថេរាបទាន ទី ៦

ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំមិនដែលស្គាល់ពក ឬ ផ្លូច កើតក្នុងកាយរបស់ខ្ញុំទេ ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំតែងអន្ទោលទៅកើតក្នុងភពពីរ គឺទេវតា ឬមនុស្ស ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំមានសម្បុរដូចមាស មានរស្មីរុងរឿងក្នុងទីទាំងពួង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ សេចក្តីមិនគាប់ចិត្តតែងចៀសវាង សេចក្តីគាប់ចិត្តតែងប្រាកដឡើង ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ចិត្តរបស់ខ្ញុំស្អាតល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តខ្ជាប់ខ្ជួន ។ ខ្ញុំមានសេចក្តីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូបដែលខ្ញុំជម្រះនោះ ខ្ញុំអង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ កាលនោះព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការជម្រះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា បកុ្កលោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បកុ្កលត្ថេរស្ស អបទានំ សមត្តំ ។

# សត្តមំ តិណកុដិទាយកត្ថេរាបទានំ

[៣៧] នគរេ ពន្ធុមតិយា អហោសឹ បរកម្មិកោ
បរកម្មាយនេ យុត្តោ បរភត្តំ អបស្សិតោ ។
រហោគតោ និសីទិត្វា ឯវំ ចិន្តេសហំ តទា
ពុទ្ធោ លោកេ សមុប្បន្នោ អធិការោ ច នត្ថិ មេ ។
កាលោ គតឹ មេ សោធេតុំ ខណោ មេ បដិបាទិតោ
ទុក្ខោ និរយសម្ផស្សោ អបុញ្ញានំ ហិ បាណិនំ ។
ឯវាហំ ចិន្តយិត្វាន កម្មសាមឹ ឧបាគមឹ
ឯកាហំ កម្មំ យាចិត្វា បវនំ បាវិសឹ អហំ ។
តិណកដ្ឋញ្ច វល្លិញ្ច អាហរិត្វានហន្តទា
តិទណ្ឌកេ ឋបេត្វាន អកំ តិណកុដឹ អហំ ។
សង្ឃស្សត្ថាយ កុដិកំ និយ្យាទេត្វាន តំ អហំ

បានឮថា ព្រះបភង្ករត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បភង្ករត្ថេរាបទាន ។

# តិណកុដិទាយកត្ថេរាបទាន ទី ៧

[៣៧] ខ្ញុំជាកម្មករនៃជនដទៃ នៅក្នុងក្រុងឈ្មោះពន្ធុមតី ប្រកបការងារនៃជនដទៃ ពឹងផ្អែកដោយថ្លៃឈ្នួលនូវនៃជនដទៃ ។ កាលនោះ ខ្ញុំទៅអង្គុយក្នុងទីស្ងាត់ ហើយគិតយ៉ាងនេះថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ឯការបរិច្ចាគរបស់អាត្មាអញមិនទាន់មាន កាលនេះ គួរតែអាត្មាជម្រះនូវគតិ ខណៈប្រាកដដល់អាត្មាអញហើយ ការពាល់ត្រូវនូវនរករមែងជាទុក្ខ របស់ពួកសត្វដែលមិនមានបុណ្យ ។ លុះខ្ញុំគិតយ៉ាងនេះហើយ ទើបចូលទៅរកបុគ្គលអ្នកម្ចាស់ការ ហើយសូមផ្អាកការងារមួយថ្ងៃ រួចដើរចូលទៅក្នុងព្រៃធំ ។ កាលនោះ ខ្ញុំយកស្មៅឈើនិងវល្លិមកហើយ ខ្ញុំបោះឈើ ៣ កំណាត់ ធ្វើជាកុដិស្មៅ ទើបខ្ញុំថ្វាយកុដិនោះ ដើម្បីប្រយោជន៍ដល់

៤៧

សត្តមំ តិណកុដិទាយកត្ថេរាបទានំ

តទហោយេវ អាគន្ត្វា កម្មាសាមឹ ឧបាគមឹ ។
តេន កម្មេន សុកតេន តាវត្តឹសំ អគញ្ឆហំ
តត្ថ មេ សុកតំ ព្យម្ហំ តិណកុដិកាយ និម្មិតំ ។
សហស្សកណ្ឌោ សតភេណ្ឌុ ធជាលុ ហរិតាមយោ
សតសហស្សនិយ្យូហា ព្យម្ហេ បាតុភវឹសុ មេ ។
យំ យំ យោនូបបជ្ជាមិ ទេវត្តំ អថ មានុសំ
មម សង្កប្បមញ្ញាយ បាសាទោ ឧបតិដ្ឋតិ ។
ភយំ វា ឆម្ភិតត្តំ វា លោមហំសោ ន វិជ្ជតិ
តាសំ មម ន ជានាមិ តិណកុដិកាយិទំ ផលំ ។
សីហា ព្យគ្ឃា ច ទីបិ ច អច្ឆកោកតរច្ឆយោ
សព្វេ មំ បរិវជ្ជន្តិ តិណកុដិកាយិទំ ផលំ ។
សិរឹសបា ច ភូតា ច អហិកុម្ភណ្ឌរក្ខសា
តេបិ មំ បរិវជ្ជន្តិ តិណកុដិកាយិទំ ផលំ ។

សង្ឃ ហើយវិលចូលមករកបុគ្គលជាម្ចាស់ការក្នុងថ្ងៃនោះ ។ ហេតុតែកុសលកម្ម ដែលខ្ញុំសាងល្អហើយនោះ ខ្ញុំក៏បាន ទៅកើតក្នុងឋានតាវត្តិង្ស មានវិមានដ៏វិសេសវិសាល ដែល បុញ្ញកម្មតាក់តែងហើយ ក្នុងឋានតាវត្តិង្សនោះ ព្រោះតែកុដិ ស្មៅរបស់ខ្ញុំ ។ វិមាននោះជាវិការៈនៃកែវមណីខៀវ មាន កម្ពស់មួយពាន់ជួរកូនសរ មានជាន់ ១០០ បរិបូណ៌ដោយទង់ ឯប្រាសាទកំពូលមួយសែន កើតឡើងក្នុងវិមាននៃខ្ញុំនោះ ។ ខ្ញុំទៅយកកំណើតណាៗ ទោះបីជាទេវតា ឬជាមនុស្ស ប្រា-សាទហាក់ដូចជាដឹងបំណងរបស់ខ្ញុំ ហើយផុសឡើង ។ ភ័យក្តី សេចក្តីតក់ស្លុតក្តី ការព្រឺរោមក្តី មិនដែលមានដល់ខ្ញុំឡើយ ខ្ញុំមិនដែលស្គាល់សេចក្តីតក់ស្លុត នេះជាផលនៃកុដិស្មៅ ។ សត្វទាំងពួងគឺ រាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន វៀងចៀសវាងខ្ញុំ នេះជាផលនៃកុដិស្មៅ ។ សត្វ ទាំងនោះ គឺពស់តូចពស់ធំ ភូត ពស់មានពិស កុម្ភណ្ឌ និងអារក្សទឹក វៀងចៀសវាងខ្ញុំ នេះជាផលនៃកុដិស្មៅ ។

ន ចាបសុបិនស្សាហំ　　សរាមិ ឧស្សនំ មម
ឧបដ្ឋិតា សតិ មយ្ហំ　　តិណកុដិកាយិទំ ផលំ ។
តាយេវ តិណកុដិកាយ　　អនុភោត្វាន សម្បទា
គោតមស្ស ភគវតោ　　ធម្មំ សច្ឆិការឹ អហំ ។
ឯកនវុតេ ឥតោ កប្បេ　　យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ　　តិណកុដិកាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណកុដិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណកុដិទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ ឧត្តរេយ្យទាយកត្ថេរាបទានំ

[៣៨] នគរេ ហំសវតិយា　　អហោសឹ ព្រាហ្មណោ តទា
អជ្ឈាយិកោ មន្តធរោ　　តិណ្ណំ វេទាន បារគូ ។

ខ្ញុំមិនយល់សប្តិ នូវសុបិនអាក្រក់សោះ ស្មារតីរបស់ខ្ញុំ ក៏តាំងនៅមាំ នេះជាផលនៃកុដិស្មៅ ។ ព្រោះតែកុដិស្មៅនោះ ខ្ញុំបានសោយសម្ប័ទទាំងឡាយ បានធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃកុដិស្មៅ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណកុដិទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណកុដិទាយកត្ថេរាបទាន ។

# ឧត្តរេយ្យទាយកត្ថេរាបទាន ទី ៨

[៣៨] កាលនោះ ខ្ញុំជាព្រាហ្មណ៍ នៅក្នុងនគរហង្សវតី ជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ។ ជាអ្នក

៤៩

អដ្ឋមំ ឧត្តរេយ្យទាយកត្ថេរាបទានំ

បុរក្ខតោ សសិស្សេហិ ជាតិមា ច សុសិក្ខិតោ
តោយាភិសេចនត្ថាយ នគរា និក្ខមឹ តទា ។
បទុមុត្តរោ លោកវិទូ សព្វធម្មាន បារគូ
ខីណាសវសហស្សេហិ នគរំ បាវិសី ជិនោ ។
សុចារុរូបំ ទិស្វាន អនេញ្ជំ ការិតំ វិយ
បរិវុតំ អរហន្តេហិ ទិស្វា ចិត្តំ បសាទយឹ ។
សិរសិ អញ្ជលឹ កត្វា នមស្សិត្វាន សុព្វតំ
បសន្នចិត្តោ សុមនោ ឧត្តរិយមទាសហំ ។
ឧភោហត្ថេហិ បគ្គយ្ហ សាដកំ ឧក្ខិបឹ អហំ
យាវតា ពុទ្ធបរិសា តាវ ឆាទេសិ សាដកំ ។
បិណ្ឌចារំ ចរន្តស្ស មហាភិក្ខុគណាទិនោ
ឆាទំ[១] ករោន្តោ អដ្ឋាសិ ហាសយន្តោ មមំ តទា ។

---

១ ម. ឆទំ ។

## ឧត្តរេយ្យទាយកត្ថេរាបទាន ទី ៨

មានជាតិខ្ពង់ខ្ពស់ផង ជាអ្នកសិក្សាស្ទាត់ផង មានពួកសិស្ស ចោមរោមផង កាលនោះ ខ្ញុំចេញអំពីទីក្រុង ដើម្បីនឹងទៅ ផ្ងូតទឹក ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវ ត្រៃលោក ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ស្តេចពុទ្ធដំណើរ ទៅកាន់ទីក្រុង មួយអន្លើដោយព្រះខីណាស្រព មួយពាន់ អង្គ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ដែលមានព្រះរូបល្អដូចមាស ទ្រង់មិនញាប់ញ័រ ដូចរូបដែលគេកសាង មានពួកព្រះអរហន្ត ចោមរោម លុះខ្ញុំឃើញហើយ ក៏ញុំាំងចិត្តឲ្យជ្រះថ្លា ។ ខ្ញុំមាន ចិត្តជ្រះថ្លា មានចិត្តរីករាយ ធ្វើនូវអញ្ជលីលើត្បូង ហើយ នមស្ការចំពោះព្រះសម្ពុទ្ធទ្រង់មានវត្តល្អ ហើយថ្វាយសំពត់ សាដក ។ ខ្ញុំផ្គងអញ្ជលីទាំងសងខាង ហើយលើកឡើងនូវ សំពត់សាដកនោះ ពួកពុទ្ធបរិស័ទមានត្រឹមណា សំពត់ សាដក ក៏គ្របត្រឹមនោះ ។ កាលនោះឯង សាដកនោះ គ្របទៅលើភិក្ខុបរិស័ទ មានចំនួនច្រើនរូប ដែលកំពុង ត្រាច់ទៅបិណ្ឌបាត ធ្វើឲ្យខ្ញុំរីករាយចិត្ត ជាខ្លាំងក្រៃលែង ។

ឃរតោ និក្ខមន្តស្ស   សយម្ភូ អគ្គបុគ្គលោ
វីថិយំ ឋិតកោ សត្ថា   អកាសិ[១] អនុមោទនំ ។
បសន្នចិត្តោ សុមនោ   យោ មេ ទទាសិ សាដកំ
តមហំ កិត្តយិស្សាមិ   សុណាថ មម ភាសតោ ។
តឹសកប្បសហស្សានិ   ទេវលោកេ រមិស្សតិ
បញ្ញាសក្ខត្តុំ ទេវិន្ទោ   ទេវរជ្ជំ ករិស្សតិ ។
ទេវលោកេ វសន្តស្ស   បុញ្ញកម្មសមង្គិនោ
សមន្តា យោជនសតំ   ទុស្សច្ឆន្នំ ភវិស្សតិ ។
ឆត្តឹសក្ខត្តុំ រាជា ច   ចក្កវត្តិ ភវិស្សតិ
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ ។
ភវេ សំសរមានស្ស   បុញ្ញកម្មសមង្គិនោ
មនសា បត្ថិតំ សព្វំ   និព្វត្តិស្សតិ តាវទេ ។
កោសេយ្យកម្ពលានិ ច   ខោមកប្បាសិកានិ ច
មហគ្ឃានិ ច ទុស្សានិ   បដិលច្ឆតិយំ នរោ ។
មនសា បត្ថិតំ សព្វំ   បដិលច្ឆតិយំ នរោ
ឯកទុស្សស្ស វិបាកំ   អនុភោស្សតិ សព្វទា ។

---
១ ម. អកាមេ ។

កាលខ្ញុំចេញអំពីផ្ទះ ព្រះសយម្ភូ ជាអគ្គបុគ្គល សាស្តាចារ្យ ទ្រង់ប្រថាប់ត្រង់ថ្នល់ ហើយធ្វើអនុមោទនាថា បុគ្គលណា មានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានថ្វាយសាដកដល់ តថាគត តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរ ស្តាប់តថាគតសម្តែងចុះ បុគ្គលអ្នកថ្វាយសាដកនេះ នឹងបាន រីករាយក្នុងទេវលោក អស់ ៣០.០០០ កប្ប កើតជាព្រះឥន្ទ សោយទេវរាជ្យ ៥០ ដង បុគ្គលអ្នកបរិបូណ៌ដោយបុញ្ញកម្ម នេះ កាលនៅក្នុងទេវលោក មានសំពត់បិទបាំង ដោយជុំ វិញ ១០០ យោជន៍ នឹងបានជាស្តេចចក្រពត្តិ ៣៦ ដង សោយបទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប បុគ្គលដែលបរិបូណ៌ ដោយបុញ្ញកម្មនេះ កាលអន្ទោលទៅ ក្នុងភព វត្ថុទាំងពួងដែលចិត្តចង់បាន នឹងកើតមួយរំពេច ។ បុគ្គលនេះ នឹងបានសំពត់ទាំងឡាយគឺសំពត់សូត្រ សំពត់ រោមសត្វ សំពត់សំបកឈើ និងសំពត់កប្បាស ដ៏មានតម្លៃ ច្រើន ។ បុគ្គលនេះនឹងបាន នូវសម្បត្តិទាំងពួង តាមចិត្ត ប្រាថ្នា នឹងបានទទួលនូវផលនៃសំពត់មួយនេះ សព្វកាល ។

៦១

## អដ្ឋមំ ឧត្តរេយ្យទាយកត្ថេរាបទានំ

| | |
|---|---|
| សោ បច្ឆា បព្វជិត្វាន | សុក្កមូលេន ចោទិតោ |
| គោតមស្ស ភគវតោ | ធម្មំ សច្ឆិការិស្សតិ ។ |
| អហោ មេ សុកតំ កម្មំ | សម្ពុទ្ធស្ស[១] មហេសិនោ |
| ឯកាហំ សាដកំ ទត្វា | បត្តោម្ហិ អមតំ បទំ ។ |
| មណ្ឌបេ រុក្ខមូលេ វា | វសតោ សុញ្ញកេ ឃរេ |
| ធារេតិ ទុស្សឆទនំ | សមន្តា ព្យាមតោ មម ។ |
| អវិញ្ញតំ និវាសេមិ | ចីវរំ បច្ចយញ្ចហំ |
| លាភិម្ហិ អន្នបានស្ស | ឧត្តរេយ្យស្សិទំ ផលំ ។ |
| សតសហស្សេ ឥតោ កប្បេ | យំ កម្មមករឹ តទា |
| ទុគ្គតឹ នាភិជានាមិ | វត្ថទានស្សិទំ ផលំ ។ |
| បដិសម្ភិទា ចតស្សោ | វិមោក្ខាបិ ច អដ្ឋិមេ |
| ឆឡភិញ្ញា សច្ឆិកតា | កតំ ពុទ្ធស្ស សាសនន្តិ ។ |

ឥត្ថំ សុទំ អាយស្មា ឧត្តរេយ្យទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧត្តរេយ្យទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សព្វញ្ញុស្ស ។

ឧត្តរេយ្យទាយកត្ថេរាបទាន ទី ៨

ខាងក្រោយមក បុគ្គលនោះ ត្រូវកុសលមូលដាស់តឿន នឹងបានបួស ហើយនឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ របស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ឱ ហ្ន៎! កុសលកម្មដែលខ្ញុំបានសាងល្អហើយ ចំពោះព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ព្រោះតែបានថ្វាយសំពត់សាដកមួយ ខ្ញុំក៏បានដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ។ កាលខ្ញុំនៅក្នុងមណ្ឌបក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី ដំបូលសំពត់តែងបិទបាំងខ្ញុំ ប្រវែងមួយព្យាម ដោយជុំវិញ ។ ខ្ញុំស្លៀកដណ្ដប់ចីវរប្បច្ច័យ មិនបាច់សុំជនដទៃផង ជាអ្នកបាននូវបាយនិងទឹកផង នេះជាផលនៃសំពត់សាដក ។ ក្នុងមួយសែនកប្ប អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយសំពត់សាដក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧត្តរេយ្យទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧត្តរេយ្យទាយកត្ថេរាបទាន ។

៦២

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# នវមំ ធម្មស្សវនិយត្ថេរាបទានំ

[៣៩] បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ចតុសច្ចំ បកាសេន្តោ សន្តារេតិ ពហុជ្ជនំ ។
អហំ តេន សមយេន ជដិលោ ឧគ្គតាបនោ
ធុនន្តោ វាកចីរានិ គច្ឆាមិ អម្ពរេ តទា ។
ពុទ្ធសេដ្ឋស្ស ឧបរិ គន្តុំ ន វិសហាមហំ
បក្ខីវ សេលមាបជ្ជ គមនំ ន លភិន្តទា ។
ន មេ ឥទំ ភូតបុព្វំ ឥរិយស្ស វិកោបនំ
ទកេ យថា ឧម្មិលិត្វា ឯវំ គច្ឆាមិ អម្ពរេ ។
ឧឡារភូតោ មនុជោ ហេដ្ឋាសីនោ ភវិស្សតិ
ហន្ទ មេតំ គវេសិស្សំ អបិ អត្ថំ លភេយ្យហំ ។
ឱរោហន្តោ អន្តលិក្ខា សទ្ទមស្សោសិ សត្ថុនោ
អនិច្ចតំ កថេន្តស្ស តមហំ ឧគ្គហឹ តទា ។
អនិច្ចសញ្ញមុគ្គយ្ហ អគមាសឹ មមស្សមំ
យាវតាយុំ វសិត្វាន តត្ថ កាលំ កតោ អហំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# ធម្មស្សវនិយត្ថេរាបទាន ទី ៩

[៣៩] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង កំពុងប្រកាសសច្ចៈ ៤ ចម្លងមហាជន ។ សម័យនោះ ខ្ញុំជាជដិលមានតបៈដ៏ខ្ពង់ខ្ពស់ កំពុងរលាស់សំពត់សម្បកឈើ ហោះទៅឰដ៏អាកាស ។ តែខ្ញុំមិនអាចនឹងទៅពីខាងលើ នៃព្រះសម្ពុទ្ធដ៏ប្រសើរបាន ក្នុងកាលនោះខ្ញុំក៏ខានធ្វើដំណើរទៅ ដូចសត្វស្លាបដែលជាប់នៅនឹងភ្នំ ។ ទើបខ្ញុំគិតថា ការខកដំណើរបែបនេះ អាត្មាអញមិនធ្លាប់កើតមានទេ អាត្មាអញទៅឰដ៏អាកាសម្តងនេះ ដូចបើកភ្នែកក្នុងទឹក ប្រហែលមានមនុស្សអស្ចារ្យ អង្គុយនៅឰដ៏ខាងក្រោមទេដឹង បើដូច្នោះ អាត្មាអញនឹងស្វែងរកមនុស្សនេះ បើឃើញគង់នឹងបានប្រយោជន៍ខ្លះ មិនខានឡើយ ។ កាលនោះ ខ្ញុំចុះអំពីអាកាសមក បានស្តាប់ព្រះសូរសៀងព្រះសាស្តា ដែលកំពុងសម្តែងអនិច្ចតាធម៌ ខ្ញុំក៏បានរៀននូវអនិច្ចតាធម៌នោះ ។ លុះខ្ញុំរៀនអនិច្ចសញ្ញាហើយ ក៏ដើរទៅកាន់អាស្រមរបស់ខ្ញុំខ្ញុំនៅដរាបដល់អស់អាយុ ក៏ធ្វើមរណកាល ក្នុងទីនោះ ។

## ៦៣

### នវមំ ធម្មស្សវនិយត្ថេរាបទានំ

ចរិមេ វត្តមានម្ហិ　　តំ ធម្មស្សវនំ សរឹ
តេន កម្មេន សុកតេន　　តាវត្តឹសំ អគច្ឆហំ ។
តឹសកប្បសហស្សានិ　　ទេវលោកេ រមឹ អហំ
ឯកបញ្ញាសក្ខត្តុញ្ច　　ទេវរជ្ជមការយឹ ។
ឯកសត្តតិក្ខត្តុញ្ច　　ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ　　គណនាតោ អសង្ខិយំ ។
បិតុឃរេ និសីទិត្វា　　សមណោ ភាវិតិន្ទ្រិយោ
គាថាយ បរិទីបេន្តោ　　អនិច្ចវត្ថុទាហរិ ។
អនុស្សរាមិ តំ សញ្ញំ　　សំសរន្តោ ភវាភវេ
ន កោដឹ បដិវិជ្ឈាមិ　　និព្វានំ អច្ចុតំ បទំ ។
អនិច្ចា វត សង្ខារា　　ឧប្បាទវយធម្មិនោ
ឧបជ្ជិត្វា និរុជ្ឈន្តិ　　តេសំ វូបសមោ សុខោ[១] ។

---

១ អនុស្សរាមិ តំ សញ្ញំ　　សំសរន្តោ ភវាភវេ
ន កោដឹ បដិវិជ្ឈាមិ　　និព្វានំ អច្ចុតំ បទំ ។
បិតុឃរេ និសីទិត្វា　　សមណោ ភាវិតិន្ទ្រិយោ
គាថាយ បរិទីបេន្តោ　　អនិច្ចវត្ថុទាហរិ ។
អនិច្ចា វត សង្ខារា　　ឧប្បាទវយធម្មិនោ
ឧបជ្ជិត្វា និរុជ្ឈន្តិ　　តេសំ វូបសមោ សុខោតិ បទានុក្កមោបិ យុត្តតរោយេវ ។

## ធម្មស្សវនិយត្ថេរាបទាន ទី ៩

កាលជវនចិត្តទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំនឹកឃើញនូវការស្តាប់ធម៌នោះ ក៏បានទៅកើតឯឋានតាវត្តិង្ស ព្រោះកុសលកម្មដែលខ្ញុំធ្វើនោះ ។ ខ្ញុំបានរីករាយក្នុងទេវលោក អស់ ៣០.០០០ កប្ប បានសោយទេវរាជ្យ ៥១ ដង ។ ខ្ញុំបានកើតជាស្តេចចក្រពត្តិអស់ ៧១ ដង បានសោយប្រទេសរាជ្យដ៏ធំ រាប់បានមួយអសង្ខេយ្យកប្ប ។ មានសមណៈមួយអង្គ មានឥន្ទ្រិយអប់រំហើយ អង្គុយក្នុងផ្ទះរបស់បិតាខ្ញុំ សម្តែងនូវគាថាទាក់ទងអនិច្ចវត្ថុ[១] ។ ខ្ញុំកាលអន្ទោលទៅ ក្នុងភពតូចភពធំ តែងនឹកឃើញសញ្ញានោះ តែមិនទាន់បានត្រាស់ដឹង នូវធម៌ជាទីបំផុត គឺព្រះនិព្វានជាអច្ចុតបទនៅឡើយថា សង្ខារទាំងឡាយមិនទៀងមែនពិត មានការកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងនោះ ទើបនាំមកនូវសេចក្តីសុខ ។

---

១ ផ្ទៃរឿងសេចក្តីយ៉ាងនេះវិញ : កាលខ្ញុំនៅអន្ទោលទៅមក ក្នុងភពតូចភពធំ តែងនឹកឃើញនូវសញ្ញានោះ តែមិនទាន់ត្រាស់ដឹងនូវធម៌ជាទីបំផុត គឺព្រះនិព្វានជាអច្ចុតបទនៅឡើយ ។ ស្រាប់តែមានសមណៈមួយអង្គ មានឥន្ទ្រិយអប់រំហើយ គង់នៅក្នុងផ្ទះបិតាខ្ញុំ ហើយសម្តែងគាថាដែលទាក់ទងអនិច្ចវត្ថុថា សង្ខារទាំងឡាយមិនទៀងមែនពិត មានការកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងពួងនោះ ទើបនាំមកនូវសេចក្តីសុខ ។

## ៦៤

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

សហ គាថំ សុណិត្វាន បុព្វកម្មំ អនុស្សរឹ
ឯកាសនេ និសីទិត្វា អរហត្តំ អបាបុណឹ ។
ជាតិយា សត្តវស្សោហំ អរហត្តំ អបាបុណឹ
ឧបសម្បាទយិ ពុទ្ធោ គុណមញ្ញាយ ចក្ខុមា ។
ទារកោវ អហំ សន្តោ ករណីយំ សមាបយឹ
កឹ មេ ករណីយំ អជ្ជ សក្យបុត្តស្ស សាសនេ ។
សតសហស្សេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ សទ្ធម្មស្សវនេ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ធម្មស្សវនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មស្សវនិយត្ថេរស្ស អបទានំ សមត្តំ ។

លុះខ្ញុំស្តាប់គាថាប្រដាប់ដោយអនិច្ចវត្ថុហើយ ក៏រលឹកឃើញនូវបុព្វកម្ម ខ្ញុំអង្គុយនៅលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ដែលខ្ញុំដល់ព្រះអរហត្តនោះ ខ្ញុំអាយុ ៧ ឆ្នាំ ព្រះពុទ្ធមានចក្ខុ ទ្រង់ជ្រាបគុណរបស់ខ្ញុំ ទើបទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ ។ ខ្ញុំបានញុំាងករណីយកិច្ចឲ្យសម្រេចហើយ តាំងពីនៅជាកុមារភាព គឺកិច្ចអ្វីក្នុងសាសនា របស់ព្រះសក្យបុត្រ ខ្ញុំធ្វើឲ្យចប់ស្រេច ក្នុងថ្ងៃនេះហើយ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល-កម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្តាប់ព្រះសទ្ធម្ម ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មស្សវនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មស្សវនិយត្ថេរាបទាន ។

# ទសមំ ឧក្ខិត្តបទុមិយត្ថេរាបទានំ

[៤០] នគរេ ហំសវតិយា អហោសឹ មាលិកោ តទា
ឱគាហេត្វា បទុមសរំ សត្តបត្តេ ឱចិនាមហំ ។
បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
សហ សតសហស្សេហិ[១] សន្តចិត្តេហិ តាទិភិ ។
ខីណាសវេហិ សុទ្ធេហិ ឆឡភិញ្ញេហិ ឈាយិភិ[២]
មម វុឌ្ឍឹ សមន្វេសំ អាគច្ឆិ បុរិសុត្តមោ ។
ទិស្វានហំ ទេវទេវំ សយម្ភុំ លោកនាយកំ
វណ្ដេ ឆេត្វា សត្តបត្តំ ឧក្ខិបឹ អម្ពរេ តទា ។
យទិ ពុទ្ធោ តុវំ ធីរ លោកជេដ្ឋោ នរាសភោ
សយំ គន្ត្វា សត្តបត្តោ មត្ថកេ ធារយន្តុ តេ ។
អធិដ្ឋហិ មហាវីរោ លោកជេដ្ឋោ នរាសភោ
ពុទ្ធស្ស អានុភាវេន មត្ថកេ ធារយឹសុ តេ ។

១ ម. សតសហស្សសិស្សេហិ ។ ២ ម. សោ សហាតិ ទិស្សតិ ។

# ឧក្ខិត្តបទុមិយត្ថេរាបទាន ទី ១០

[៤០] *កាលនោះ ខ្ញុំជាអ្នកក្រងផ្កា នៅក្នុងក្រុងហង្សវតី បានចុះទៅក្នុងស្រះឈូក ហើយកាច់យកផ្កាឈូក ។ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង មួយអន្លើដោយព្រះខីណាស្រព មួយសែនអង្គ ជាអ្នកមានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ មានសន្ដានស្អាត បានអភិញ្ញា ៦ និងមានឈាន ទ្រង់ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់ស្វែងរកសេចក្ដីចម្រើនដល់ខ្ញុំ បានធ្វើពុទ្ធដំណើរមករកខ្ញុំ ។ កាលនោះ ខ្ញុំបានឃើញព្រះសយម្ភូ ជាលោកនាយក ជាទេវតាក្រៃលែងជាងទេវតា ទើបកាច់ផ្កាឈូកត្រង់ទង បោះឡើងទៅនាអាកាស ។ ខ្ញុំប្រកាសថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ បើព្រះអង្គជាព្រះពុទ្ធ ជាច្បងក្នុងលោក ប្រសើរជាងពួកនរជនមែន សូមផ្កាឈូកទាំងនុ៎ះអណ្ដែតទៅឯង សូមផ្កាឈូកទាំងនុ៎ះ បាំងពីខាងលើព្រះសិរ្សៈ* (*របស់ព្រះអង្គ*) *ចុះ ។ ព្រះសម្ពុទ្ធទ្រង់មានព្យាយាមធំ ជាច្បងក្នុងលោក ប្រសើរជាងពួកនរជន ទ្រង់អធិដ្ឋានហើយ ផ្កាឈូកទាំងនោះក៏បាំងពីខាងលើព្រះសិរ្សនៃព្រះអង្គ ដោយពុទ្ធានុភាព ។*

៦៦



តេន កម្មេន សុកតេន　　ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ　　តាវតឹសំ អគច្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ　　សត្តបត្តន្តិ វុច្ចតិ
សដ្ឋិយោជនមុព្វិទ្ធំ　　តឹសយោជនវិត្ថតំ ។
សហស្សក្ខត្តុំ ទេវិន្ទោ　　ទេវរជ្ជមការយឹ
បញ្ចសត្តតិក្ខត្តុញ្ច　　ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ　　គណនាតោ អសង្ខិយំ
អនុភោមិ សកំ កម្មំ　　បុព្វេ សុកតមត្តនោ ។
តេនេវេកបទុមេន　　អនុភោត្វាន សម្បទា
គោតមស្ស ភគវតោ　　ធម្មំ សច្ឆិការឹ អហំ ។
កិលេសា ឈាបិតា មយ្ហំ　　ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា　　វិហរាមិ អនាសវោ ។
សតសហស្សេ ឥតោ កប្បេ　　យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　　ឯកបទុមស្សិទំ ផលំ ។

ដោយកុសលកម្មដែលខ្ញុំធ្វើនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះរាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានដែលបុញ្ញកម្មតាក់តែងល្អហើយសម្រាប់ខ្ញុំ ក្នុងឋានតាវត្តិង្សនោះ គេហៅថាសត្តបត្តៈ មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ខ្ញុំបានកើតជាព្រះឥន្ទ សោយទេវរាជ្យ អស់មួយពាន់ដង កើតជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។ ខ្ញុំបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ខ្ញុំសោយនូវកុសល-កម្មរបស់ខ្លួន ដែលខ្លួនធ្វើទុកល្អហើយក្នុងកាលមុន ។ ខ្ញុំសោយសម្បត្តិទាំងឡាយ ដោយការថ្វាយនូវផ្កាឈូក មួយនោះឯង ទាំងបានធ្វើឲ្យជាក់ច្បាស់នូវធម៌ របស់ព្រះមានព្រះភាគ ព្រះនាមព្រះគោតម ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំ-ផ្លាញអស់ហើយ ភពទាំងឡាយ ខ្ញុំបានគាស់រំលើងអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹងដូច្នោះឯង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្កាឈូកមួយ ។

៦៧

ឧទ្ទានំ

បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧក្ខិត្តបទុមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧក្ខិត្តបទុមិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

គន្ធោទកំ បូជនី ច　　បុន្នាគំ ឯកទុស្សិកា
ផុស្សិតោ ច បភង្ករោ　　កុដិទោ ឧត្តរីយកោ ។
សវនំ ឯកបទុមិ　　គាថាយោ សព្វបិណ្ឌិតា
ឯកគាថាសតញ្ចេវ　　ចតុត្តាឡីសមេវ ច ។

គន្ធោទកវគ្គោ ចតុត្តឹសោ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧក្ខិត្តបទុមិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧក្ខិត្តបទុមិយត្ថេរាបទាន ។

# ឧទ្ទាន

គន្ធធូបិយត្ថេរាបទាន ១ ឧទកបូជកត្ថេរាបទាន ១ បុន្នាគបុប្ផិយត្ថេរាបទាន ១ ឯកទុស្សទាយកត្ថេរាបទាន ១ ផុស្សិតកម្មិយត្ថេរាបទាន ១ បភង្ករត្ថេរាបទាន ១ តិណកុដិទាយកត្ថេរាបទាន ១ ឧត្តរេយ្យទាយកត្ថេរាបទាន ១ ធម្មស្សវនិយត្ថេរាបទាន ១ ឧក្ខិត្តបទុមិយត្ថេរាបទាន ១ មានគាថាជាប់គ្នាទាំងអស់ ១០១ ផង ៤៤ ផង (១៤៥) ។

ចប់ គន្ធោទកវគ្គ ទី ៣៥ ។

# បញ្ចត្តឹសោ ឯកបទុមវគ្គោ

## បឋមំ ឯកបទុមិយត្ថេរាបទានំ

[៤១] បទុមុត្តរោ នាម ជិនោ　　សព្វធម្មាន បារគូ
ភវាភវេ វិភាវេន្តោ　　តារេតិ ជនតំ ពហុំ ។
ហំសរាជា តទា ហោមិ　　ទិជានំ បវរោ អហំ
ជាតស្សរំ សមោគយ្ហ　　កីឡាមិ ហំសកីឡិតំ ។
បទុមុត្តរោ លោកវិទូ　　អាហុតីនំ បដិគ្គហោ
ជាតស្សរស្ស ឧបរិ　　អាគច្ឆិ តាវទេ ជិនោ ។
ទិស្វានហំ ទេវទេវំ　　សយម្ភុំ លោកនាយកំ
វណ្ដេ ឆេត្វាន បទុមំ　　សត្តបត្តំ មនោរមំ ។
មុខតុណ្ឌេន បគ្គយ្ហ　　វិប្បសន្នេន ចេតសា[១]
ឧក្ខិបិត្វាន គគនេ[២]　　ពុទ្ធសេដ្ឋំ អបូជយឹ ។
បទុមុត្តរោ លោកវិទូ　　អាហុតីនំ បដិគ្គហោ
អន្តលិក្ខេ ឋិតោ សត្ថា　　អកាសិ[៣] អនុមោទនំ ។
ឥមិនា ឯកបទុមេន　　ចេតនាបណិធីហិ ច
កប្បានំ សតសហស្សំ　　វិនិបាតំ ន គច្ឆសិ ។

---

១ ម. បសន្នោ លោកនាយកោតិ ទិស្សតិ ។ ២ ម. ឧក្ខិបិត្វា នលាដេនាតិ ខាយតិ ។
៣ ម. អកាមេ ។

# ឯកបទុមវគ្គ ទី ៣៥

## ឯកបទុមិយត្ថេរាបទាន ទី ១

[៤១] *ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង កំពុងទ្រង់សម្តែងធម៌ ឲ្យបណ្តាជនច្រើននាក់ឆ្លងនូវភពតូចនិងភពធំ ។ កាលនោះ ខ្ញុំកើតជាស្តេចហង្ស ប្រសើរជាងសត្វស្លាបទាំងឡាយ បានចុះកាន់ជាតស្រះហើយលេងល្បែងហង្ស ។ ខណៈនោះ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលគ្រឿងបូជា បានស្តេចពុទ្ធដំណើរមកពីខាងលើជាតស្រះ ។ ខ្ញុំបានឃើញព្រះសយម្ភូលោកនាយក ជាទេវតាក្រៃលែងជាងទេវតា ក៏កាច់ផ្កាបទុមជាត គឺផ្កាឈូកជាទីរីករាយនៃចិត្ត ត្រង់ទង ខ្ញុំមានចិត្តជ្រះថ្លា បានពាំយកផ្កានោះដោយចំពុះ ហើយបោះទៅឰដ៏អាកាស បូជាព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រះសាស្តាព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់ត្រៃលោក ទ្រង់គួរទទួលគ្រឿងបូជា បានប្រថាប់នៅឰដ៏អាកាស ហើយធ្វើអនុមោទនាថា អ្នកនឹងមិនទៅកើតក្នុងវិនិបាត អស់មួយសែនកប្ប ដោយផ្កាឈូកមួយនេះផង ដោយការតាំងចេតនានេះផង ។*

៦៩



ឥទំ វត្វាន សម្ពុទ្ធោ ជលជុត្តមនាមកោ
មម កម្មំ បកិត្តេត្វា អគមា យេន បត្ថិតំ ។
សតសហស្សេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកបទុមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកបទុមិយត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ តិណុប្បលមាលិយត្ថេរាបទានំ

[៤២] ចន្ទភាគានទីតីរេ អហោសឹ វានរោ តទា
អទ្ទសំ វិរជំ ពុទ្ធំ និសិន្នំ បព្វតន្តរេ ។
ឱភាសេន្តំ ទិសា សព្វា សាលរាជំវ ផុល្លិតំ
លក្ខណព្យញ្ជនុបេតំ ទិស្វា អត្តមនោ អហុ ។

ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ លុះទ្រង់សម្តែងនូវអនុមោទនានេះ ព្រមទាំងទ្រង់សរសើរកុសលកម្ម របស់ខ្ញុំរួចហើយ ស្តេចពុទ្ធដំណើរទៅ កាន់ទីគួរតាមប្រាថ្នា ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបទុមិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបទុមិយត្ថេរាបទាន ។

# តិណុប្បលមាលិយត្ថេរាបទាន ទី ២

[៤២] កាលនោះ ខ្ញុំកើតជាពានរ នៅទៀបឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះសម្ពុទ្ធ ប្រាសចាកធូលីគឺកិលេស ទ្រង់គង់នៅត្រង់ចន្លោះភ្នំ ។ ខ្ញុំមានចិត្តត្រេកអរ ព្រោះបានឃើញព្រះពុទ្ធ ទ្រង់ញុំាំងទិសទាំងពួងឲ្យភ្លឺ ប្រកបដោយលក្ខណៈនិងអនុព្យញ្ជនៈ ដូចស្តេចសាលព្រឹក្ស ដែលមានផ្ការីក ។

៧០



ឧទគ្គចិត្តោ សុមនោ បីតិយា ហដ្ឋមានសោ
តីណិ ឧប្បលបុប្ផានិ មត្ថកេ អភិរោបយឹ ។
បុប្ផានិ អភិរោបេត្វា វិបស្សិស្ស មហេសិនោ
សគារវោ ភវិត្វាន[១] បក្កាមឹ ឧត្តរាមុខោ ។
គច្ឆន្តោ បដិកុដិកោ វិប្បសន្នេន ចេតសា
សេលន្តរេ បបតិត្វា ចាបុណឹ ជីវិតក្ខយំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគច្ឆហំ ។
សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ
សតានំ បញ្ចក្ខត្តុញ្ច ចក្កវត្តិ អហោសហំ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ម. នមិត្វាន ។

ខ្ញុំមានចិត្តខ្ពស់ឯក មានចិត្តរីករាយ មានចិត្តស្រស់ស្រាយដោយបីតិ បានប្រទូលលើក្បាលនូវផ្កាឧប្បល ៣ ថ្វាយព្រះអង្គ ។ លុះខ្ញុំបូជាផ្កាទាំងឡាយ ចំពោះព្រះមហេសី ព្រះនាមវិបស្សីរួចហើយ ជាអ្នកមានសេចក្តីគោរព បែរមុខឆ្ពោះទៅកាន់ទិសឧត្តរ ដើរចេញទៅ ។ ខ្ញុំកំពុងមានចិត្តជ្រះថ្លាដើរត្រឡប់ថយក្រោយ ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំ ដល់នូវការអស់ទៅនៃជីវិត ។ ដោយកុសលកម្ម ដែលខ្ញុំបានធ្វើនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយទេវរាជ្យ អស់ ៣០០ ដង បានកើតជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

៧១



ឥត្ថំ សុទំ អាយស្មា តិណុប្បលមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណុប្បលមាលិយត្ថេរស្ស អបទានំ សមត្តំ ។

# តតិយំ ធជទាយកត្ថេរាបទានំ

[៤៣] តិស្សោ នាម អហុ សត្ថា លោកជេដ្ឋោ នរាសភោ
តយោបធិក្ខយេ ទិស្វា ធជំ អារោបិតំ មយា ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ ។
សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ
សតានំ បញ្ចក្ខត្តុញ្ច ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
អនុភោមិ សកំ កម្មំ បុព្វេ សុកតមត្តនោ ។
ទ្វេនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ធជទានស្សិទំ ផលំ ។

បានឮថា ព្រះតិណុប្បលមាលិយត្ថេរ មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណុប្បលមាលិយត្ថេរាបទាន ។

# ធជទាយកត្ថេរាបទាន ទី ៣

[៤៣] ព្រះសាស្តាព្រះនាមតិស្សៈ ទ្រង់ជាច្បងក្នុងលោក ប្រសើរជាងពួកនរជន ព្រោះអស់ឧបធិ ៣ ប្រការ ខ្ញុំបានឃើញ (ព្រះអង្គ) ហើយលើកឡើងនូវទង់ថ្វាយ ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើនោះផង ដោយការតាំងចេតនានោះផង លុះខ្ញុំលះ បង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ខ្ញុំបានសោយទេវរាជ្យ អស់ ៣០០ ដង បានជាស្តេចចក្រពត្តិ អស់ ៥០០ ដង ។ បានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ខ្ញុំទទួលកុសលកម្មរបស់ខ្លួន ដែលខ្លួនធ្វើល្អហើយក្នុងភពមុន ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយទង់ ។

ឥច្ឆមានោ ចហំ អជ្ជ សកាននំ សបព្វតំ
ខោមទុស្សេន ឆាទេយ្យំ តទា មយ្ហំ កតេ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ធជទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ធជទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ចតុត្ថំ តីណិកិង្កណិបុប្ផកត្ថេរាបទានំ

[៤៤] ហិមវន្តស្សវិទូរេ ភូតគណោ នាម បព្វតោ
តត្ថទ្ទសំ បំសុកូលំ ទុមគ្គម្ហិ វិលគ្គិតំ ។
តីណិ កិង្កណិបុប្ផានិ ឱចិនិត្វានហំ តទា
ហដ្ឋោ ហដ្ឋេន ចិត្តេន បំសុកូលំ អបូជយឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ តិណ្ណំ បុប្ផានិទំ ផលំ ។

សូម្បីថ្ងៃនេះ ខ្ញុំមានប្រាជ្ញានឹងគ្រប ក៏អាចគ្របនូវព្រៃនិងភ្នំ ដោយសំពត់សំបកឈើបាន នេះជាផល នៃអំពើដែលខ្ញុំធ្វើហើយ ក្នុងភពនោះ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធជទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធជទាយកត្ថេរាបទាន ។

# តីណិកិង្កណិបូជកត្ថេរាបទាន ទី ៤

[៤៤] មានភ្នំមួយឈ្មោះភូតគណៈ នៅជិតព្រៃហិមពាន្ត ខ្ញុំបានឃើញសំពត់បង្សុកូល ដែលគេព្យួរលើចុងឈើក្បែរភ្នំនោះ ។ កាលនោះ ខ្ញុំជាអ្នករីករាយ មានចិត្តត្រេកអរ បានបេះផ្កាកណ្តឹង ៣ បូជាចំពោះសំពត់បង្សុកូលនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះផលនៃផ្កាកណ្តឹង ៣ ។

៧៣



បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា តីណិកិង្កណិបូជកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

តីណិកិង្កណិបូជកត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ នឡាគារិកត្ថេរាបទានំ

[៤៨] ហិមវន្តស្សាវិទូរេ  ហារិកោ នាម បព្វតោ
សយម្ភូ នាម នាមេន[១]  រុក្ខមូលេ វសី តទា ។
នឡាគារំ ករិត្វាន  តិណេន ឆាទយឹ អហំ
ចង្កមំ សោធយិត្វាន  សយម្ភុស្ស អទាសហំ ។
ចតុទ្ទសេសុ កប្បេសុ  ទេវលោកេ រមឹ អហំ
ចតុសត្តតិក្ខត្តុញ្ច  ទេវរជ្ជមការយឹ ។
សត្តសត្តតិក្ខត្តុញ្ច[២]  ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ  គណនាតោ អសង្ខិយំ ។
ឧព្វិទ្ធំ ភវនំ មយ្ហំ  ឥន្ទលដ្ឋីវ ឧគ្គតំ
សហស្សថម្ភំ អតុលំ  វិមានំ សប្បភស្សរំ ។

១ ម. សយម្ភូ នារទោ នាមាតិ ខាយតិ ។ ២ ម. ចតុសត្តតិក្ខត្តុញ្ច ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏ បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណិកិង្កណិបូជកត្ថេរ មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តីណិកិង្កណិបូជកត្ថេរាបទាន ។

# នឡាគារិកត្ថេរាបទាន ទី ៥

[៤៥] មានភ្នំមួយឈ្មោះហារិកៈ នៅជិតព្រៃហិមពាន្ត កាលនោះ ព្រះពុទ្ធព្រះនាមសយម្ភូ ស្តេចគង់នៅក្បែរគល់ ឈើមួយ ។ ខ្ញុំបានធ្វើរោងបបុសប្រក់ដោយស្មៅ ខ្ញុំជម្រះទី ចង្រ្កម ថ្វាយព្រះសយម្ភូ ។ ក្នុងកប្បទី ១៤ ខ្ញុំបានរីករាយ ក្នុងទេវលោក ខ្ញុំបានសោយទេវរាជ្យ ៧៤ ដង បានកើតជា ស្តេចចក្រពត្តិ ៧៧ ដង សោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ វិមានជាលំនៅ របស់ខ្ញុំ ខ្ពស់ទទុង ដូចលំពង់ដើមឥន្ទព្រឹក្សដ៏ខ្ពស់ មានសសរមួយ ពាន់ដើម មានលម្អឥតប្រៀបបាន មានរស្មីរុងរឿងភ្លឺផ្លេក ។

ទ្វេសម្បត្តី អនុភោត្វាន សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ សាសនេ បព្វជឹ អហំ ។
បធានំ បហិតត្តោម្ហិ ឧបសន្តោ និរូបធិ
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នឡាគារិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

នឡាគារិកត្ថេរស្ស អបទានំ សមត្តំ ។

## ឆដ្ឋំ ចម្បកបុប្ផិយត្ថេរាបទានំ

[៤៦] ហិមវន្តស្សាវិទូរេ ឆាបលោ នាម[១] បព្វតោ
ពុទ្ធោ សុទស្សនោ នាម វិហាសិ បព្វតន្តរេ ។
បុប្ផំ ហេមវណ្ណំ[២] គយ្ហ គច្ឆំ វេហាយសេនហំ
អទ្ទសំ វិរជំ ពុទ្ធំ ឱឃតិណ្ណមនាសវំ ។

---

១ ម. ជាបលោ នាម ។ ២ ម. ហេមវន្តំ ។

ខ្ញុំបានសោយសម្បត្តិទាំងពីរ ត្រូវកុសលមូលដាស់តឿន ក៏បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ខ្ញុំមានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់រម្ងាប់ ជាអ្នកមិនមានឧបធិ មិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទឹងរួចហើយដូច្នោះឯង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡាគារិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នឡាគារិកត្ថេរាបទាន ។

# ចម្បកបុប្ផិយត្ថេរាបទាន ទី ៦

[៤៦] មានភ្នំមួយឈ្មោះធាបលៈ នៅជិតព្រៃហិមពាន្ត ព្រះពុទ្ធព្រះនាមសុទស្សនៈ ស្តេចគង់ត្រង់ចន្លោះភ្នំ ។ កាលនោះ ខ្ញុំកាន់យកផ្កាមានសម្បុរដូចមាស ហើយហោះទៅតាមអាកាស បានឃើញព្រះសម្ពុទ្ធ ដែលប្រាសចាកធូលីគឺកិលេស ស្តេចទ្រង់ធ្វងឱឃៈហើយ ទ្រង់មិនមានអាសវៈ ។

៧៩

សត្តមំ បទុមបូជកត្ថេរាបទានំ

សត្តចម្បកបុប្ផានិ សីសេ កត្វានហំ តទា
ពុទ្ធស្ស អភិរោបេសឹ សយម្ភុស្ស មហេសិនោ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចម្បកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចម្បកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ បទុមបូជកត្ថេរាបទានំ

[៤៧] ហិមវន្តស្សាវិទូរេ រោមសោ នាម បព្វតោ
ពុទ្ធោ ច សោភិតោ នាម[១] អព្ភោកាសេ វសី តទា ។
ភវនា និក្ខមិត្វាន បទុមំ ធារយឹ អហំ
ឯកាហំ ធារយិត្វាន បុនព្ភវំ ឧចាគមឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

---

១ ម. ពុទ្ធោបិ សម្ភវោ នាម ។

លុះឃើញ ខ្ញុំតម្កល់នូវផ្កាចម្បា ៧ លើក្បាល បូជាដល់ព្រះសម្ពុទ្ធជាសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចម្បកបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចម្បកបុប្ផិយត្ថេរាបទាន ។

# បទុមបូជកត្ថេរាបទាន ទី ៧

[៤៧] មានភ្នំមួយឈ្មោះរោមសៈ នៅជិតព្រៃហិមពាន្ត កាលនោះ ព្រះពុទ្ធព្រះនាមសោភិតៈ ទ្រង់គង់នៅត្រង់ទីវាល ។ ខ្ញុំចេញអំពីលំនៅ ហើយកាន់យកនូវផ្កាឈូក បាំងថ្វាយព្រះសម្ពុទ្ធ លុះខ្ញុំបាំងថ្វាយអស់មួយថ្ងៃហើយ ត្រឡប់ចូលកាន់លំនៅវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បទុមបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមបូជកត្ថេរស្ស អបទានំ សមត្តំ ។

តេរសមំ ភាណវារំ ។

# អដ្ឋមំ តិណមុដ្ឋិទាយកត្ថេរាបទានំ

[៤៨] ហិមវន្តស្សាវិទូរេ　　លម្ពកោ នាម បព្វតោ
ឧបតិស្សោ នាម សម្ពុទ្ធោ　　អព្ភោកាសម្ហិ ចង្កមិ ។
មិគលុទ្ទោ បុរេ អាសឹ　　អរញ្ញេ កាននេ អហំ
និស្វាន តំ ទេវទេវំ　　សយម្ភុំ អបរាជិតំ ។
វិប្បសន្នេន ចិត្តេន　　តទា តស្ស មហេសិនោ
និសីទនត្ថំ ពុទ្ធស្ស　　តិណមុដ្ឋិមទាសហំ ។
ទត្វាន ទេវទេវស្ស　　ភិយ្យោ ចិត្តំ បសាទយឹ
សម្ពុទ្ធំ អភិវាទេត្វា　　បក្កាមិ ឧត្តរាមុខោ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមបូជកត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ១៣ ។

# តិណមុដ្ឋិទាយកត្ថេរាបទាន ទី ៨

[៤៨] មានភ្នំមួយឈ្មោះលម្ពកៈ នៅជិតព្រៃហិមពាន្ត ព្រះសម្ពុទ្ធ ព្រះនាមឧបតិស្សៈ ទ្រង់ចង្ក្រមក្នុងទីវាលជិតភ្នំនោះ ។ កាលនោះ ខ្ញុំបានកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញព្រះសយម្ភូនោះ ជាទេវតាក្រៃលែងជាងទេវតា ទ្រង់ឈ្នះមារ ។ លុះឃើញហើយ ខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយស្មៅមួយក្តាប់ដល់ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ សម្រាប់ក្រាលគង់ ។ លុះខ្ញុំថ្វាយដល់ព្រះសម្ពុទ្ធ ជាទេវតាក្រៃលែងជាងទេវតាហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាដ៏ក្រៃលែង ថ្វាយបង្គំព្រះសម្ពុទ្ធ ឈមមុខទៅកាន់ទិសឧត្តរ ហើយដើរចេញទៅ ។

## ៧៧

### អដ្ឋមំ តិណមុដ្ឋិទាយកត្ថេរាបទានំ

អចិរំ កតមត្តំ មំ មិគរាជា អហេឋយិ
សីហេន ចាតិតោ សន្តោ តត្ថ កាលំ កតោ អហំ ។
អាសន្នេ មេ កតំ កម្មំ ពុទ្ធសេដ្ឋេ អនាសវេ
សុមុត្តោ សរវេគោវ ទេវលោកំ អគច្ឆហំ ។
យូបោ តត្ថ សុភោ អាសិ បុញ្ញកម្មាភិនិម្មិតោ
សហស្សកណ្ឌោ សតភេណ្ឌុ ធជាលុ ហរិតាមយោ ។
បភា និទ្ធាវតេ តស្ស សតរំសីវ ឧគ្គតោ
អាកិណ្ណោ ទេវកញ្ញាហិ អាមោទឹ កាមកាមិហំ ។
ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
អាគន្ត្វាន មនុស្សត្តំ បត្តោម្ហិ អាសវក្ខយំ ។
ចតុន្នវុតេ ឥតោ កប្បេ និសីទនមទាសហំ
ទុគ្គតឹ នាភិជានាមិ តិណមុដ្ឋិយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

## តិណមុដ្ឋិទាយកត្ថេរាបទាន ទី ៨

ខ្ញុំកំពុងដើរទៅ មិនយូរប៉ុន្មាន ស្តេចម្រឹគគឺសីហៈក៏ខាំខ្ញុំ ខ្ញុំដែលត្រូវសីហៈខាំផ្តួលហើយនោះ ក៏ធ្វើមរណៈកាលត្រង់កន្លែងនោះ ។ ព្រោះកុសលកម្មដែលខ្ញុំធ្វើហើយ ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ មិនមានអាសវៈ ក្នុងពេលជិតមរណៈនោះ ខ្ញុំក៏បានទៅកើត ឯឋានទេវលោក ដូចកម្ទាំងសរដែលរបូតចេញ ។ ប្រាសាទជាវិការនៃកែវមណី មានពណ៌ខៀវដែលបុញ្ញកម្មនិម្មិតហើយសម្រាប់ខ្ញុំ ក្នុងទេវលោកនោះ ជាប្រាសាទដ៏ល្អ មានកម្ពស់មួយពាន់ជួរក្លូនសរ មានជាន់ ១០០ បរិបូណ៌ដោយទង់ ។ ពន្លឺនៃប្រាសាទនោះផ្សាយចេញទៅដូចព្រះអាទិត្យរះឡើង ខ្ញុំជាអ្នកប្រាថ្នារីករាយក្នុងកាម កុះករដោយស្រីទេពកញ្ញា ។ ខ្ញុំច្យុតចាកទេវលោកហើយ ត្រូវកុសលមូលដាស់តឿន ក៏បានមកកាន់មនុស្សភាព ហើយដល់នូវការក្ស័យនៃអាសវៈ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយស្មៅសម្រាប់អង្គុយ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃស្មៅមួយក្តាប់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា តិណមុដ្ឋិទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណមុដ្ឋិទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ តិន្ទុកផលទាយកត្ថេរាបទានំ

[៤៩] កណិការំវ ជោតន្តំ និសិន្នំ បព្វតន្តរេ
អទ្ទសំ វិរជំ ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
តិន្ទុកំ សផលំ ទិស្វា ភិន្ទិត្វាន សកោដិកំ(១)
បសន្នចិត្តោ សុមនោ វេស្សភុស្ស អទាសហំ(២) ។
ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិន្ទុកផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិន្ទុកផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សកោសកំ ។ ២ ម. សយម្ភុស្សមទាសហំ ។

បានឮថា ព្រះតិណមុដ្ឋិទាយកត្ថេរ មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណមុដ្ឋិទាយកត្ថេរាបទាន ។

# តិន្ទុកផលទាយកត្ថេរាបទាន ទី ៩

[៤៩] ខ្ញុំឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលីគឺកិលេស ទ្រង់ធ្ងន់ហើយ មិនមានអាសវៈ ស្តេចគង់ក្នុងចន្លោះភ្នំ រុងរឿងដូចផ្កាកណិការ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តសោមនស្ស បានឃើញដើមទន្លាប់ដែលមានផ្លែ ទើបកាច់យកទាំងទង ថ្វាយព្រះវេស្សភូ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែទន្លាប់ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយផ្លែទន្លាប់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិន្ទុកផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិន្ទុកផលទាយកត្ថេរាបទាន ។

៧៩

# ទសមំ ឯកញ្ជលិយត្ថេរាបទានំ

[៨០] រេវតោ នាម[1] សម្ពុទ្ធោ  នទីកូលេ វសី តទា
អទ្ទសំ វិរជំ ពុទ្ធំ  បីតរំសីវ ភាណុមំ ។
ឧក្កាមុខំ បហដ្ឋំវ  ខទិរង្គារសន្និភំ
ឱសធី វិយ ពេចន្តំ  ឯកញ្ជលិមកាសហំ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ អញ្ជលិមកាសហំ
ទុគ្គតឹ នាភិជានាមិ  អញ្ជលិយា ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកញ្ជលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកញ្ជលិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. រោមសោ នាម ។

# ឯកញ្ជលិយត្ថេរាបទាន ទី ១០

[៩០] កាលនោះ ព្រះសម្ពុទ្ធព្រះនាមរេវតៈ ស្តេចគង់នៅទៀបឆ្នេរស្ទឹង ខ្ញុំបានឃើញព្រះពុទ្ធ ដែលប្រាសចាកធូលីគឺកិលេស ដូចព្រះអាទិត្យមានរស្មីលឿង ឬដូចមុខភ្លើងគប់ដែលត្រូវខ្យល់បក់ហើយ ពុំនោះសោតដូចរងើកភ្លើងនៃឧសគគីរ ទ្រង់រុងរឿងដូចផ្កាយព្រឹក ខ្ញុំធ្វើអញ្ជលីម្តង ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើអញ្ជលី ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើអញ្ជលី ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកញ្ជលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកញ្ជលិយត្ថេរាបទាន ។

៨០

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ឧទ្ទានំ

បទុមី ឧប្បលមាលី ធជោ កិង្កណិកំ ធជំ
ចម្បកោ បទុមមុដ្ឋិ តិន្ទុកោកញ្ចលី តថា
ធ ច សង្ខិ ច គាថាយោ គណិតាយោ វិភាវិហិ ។

ឯកបទុមវគ្គោ បញ្ចត្តឹសោ ។

## ឧទ្ទាន

ឯកបទុមិយត្ថេរាបទាន ១ តីណុប្បលមាលិយត្ថេរាបទាន ១ ធជទាយកត្ថេរាបទាន ១ តីណិកិង្កណិបូជកត្ថេរាបទាន ១ នឡាគារិកត្ថេរាបទាន ១ ចម្បកបុប្ផិយត្ថេរាបទាន ១ បទុ-មបូជកត្ថេរាបទាន ១ តិណមុដ្ឋិទាយកត្ថេរាបទាន ១ តិន្ទុក-ផលទាយកត្ថេរាបទាន ១ ឯកញ្ជលិយត្ថេរាបទាន ១ ចំនួនគាថា ៦៦ គាថា ដែលពួកអ្នកប្រាជ្ញរាប់ឃើញហើយ ។

ចប់ ឯកបទុមវគ្គ ទី ៣៥ ។

# ឆត្តឹសោ សទ្ទសញ្ញិកវគ្គោ

## បឋមំ សទ្ទសញ្ញិកត្ថេរាបទានំ

[៨១] មិគលុទ្ធោ បុរេ អាសឹ អរញ្ញេ កាននេ អហំ
តត្ថទ្ទសាសឹ សម្ពុទ្ធំ ទេវសង្ឃបុរក្ខតំ ។
ចតុសច្ចំ បកាសេន្តំ ឧទ្ធរន្តំ មហាជនំ
អស្សោសឹ មធុរំ វាចំ ករវិករុទោបមំ ។
ព្រហ្មស្សរស្ស មុនិនោ សិខិនោ លោកពន្ធុនោ
ឃោសេ ចិត្តំ បសាទេត្វា បត្តោម្ហិ អាសវក្ខយំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ បសាទស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា សទ្ទសញ្ញិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សទ្ទសញ្ញិកត្ថេរស្ស អបទានំ សមត្តំ ។

# សទ្ទសញ្ញិកវគ្គ ទី ៣៦

## សទ្ទសញ្ញិកត្ថេរាបទាន ទី ១

[៥១] *ពីជាតិមុន ខ្ញុំជាព្រានម្រឹគ នៅក្នុងព្រៃធំ ខ្ញុំបាន ឃើញព្រះសម្ពុទ្ធ មានពួកទេវតាចោមរោមក្នុងទីនោះ ដែល កំពុងទ្រង់ប្រកាសនូវសច្ចៈ ៤ ស្រោចស្រង់មហាជន ខ្ញុំបាន ស្តាប់នូវព្រះពុទ្ធដីកាដ៏ពីរោះ ឧបមាដូចសម្រែកនៃករវិក ។ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសូរសៀងគឹកកង របស់ព្រះមុនី ព្រះនាមសិខី ជាលោកពន្ធុ មានព្រះសូរសៀងដូចសំឡេង នៃព្រហ្ម ហើយដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបាន ធ្វើនូវកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃ សេចក្តីជ្រះថ្លា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះ ពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។*

*បានឮថា ព្រះសទ្ទសញ្ញិកត្ថេរ មានអាយុ បានសម្តែងនូវ គាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ សទ្ទសញ្ញិកត្ថេរាបទាន ។

# ទុតិយំ យវកលាបិយត្ថេរាបទានំ

[៨២] នគរេ អរុណវតិយា អាសឹ យវសិកោ តទា
បន្ថេ ទិស្វាន សម្ពុទ្ធំ យវកលាបំ អបត្ថរឹ[១] ។
អនុកម្បកោ ការុណិកោ សិខី លោកគ្គនាយកោ
មម សង្កប្បមញ្ញាយ និសីទិ យវសន្ថរេ ។
ទិស្វា និសិន្នំ វិមលំ មហាឈាយឹ វិនាយកំ
បាមោជ្ជំ ជនយិត្វាន តត្ថ កាលំ កតោ អហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ យវត្ថរេ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---
១ ម. សន្ថរឹ ។

# យវកលាបិយត្ថេរាបទាន ទី ២

[៨២] ក្នុងកាលនោះ ខ្ញុំជាអ្នកធ្វើស្រែ នៃស្រូវដំណើប នៅក្នុងនគរអរុណវតី បានឃើញព្រះសម្ពុទ្ធក្នុងផ្លូវ ក៏បានក្រាលកណ្តាប់ស្រូវដំណើប (ថ្វាយព្រះអង្គ) ។ ព្រះសិខី ព្រះអង្គជាអគ្គនាយកក្នុងលោក មានសេចក្តីអនុគ្រោះ មានសេចក្តីករុណា ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ហើយគង់លើកម្រាលនៃស្រូវដំណើបនោះ ។ ខ្ញុំលុះបានឃើញ (ព្រះសម្ពុទ្ធនោះ) ព្រះអង្គគ្មានមន្ទិល មានឈានដ៏ប្រសើរ ជាអ្នកដឹកនាំ (សត្វលោក) កំពុងគង់នៅ ក៏ញុំាងប្រាមោទ្យឲ្យកើតឡើង ហើយធ្វើមរណកាលក្នុងទីនោះ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រាលកណ្តាប់ស្រូវដំណើប ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

៨៣

តតិយំ កឹសុកបូជកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា យវកលាបិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យវកលាបិយត្ថេរស្ស អបទានំ សមត្តំ ។

# តតិយំ កឹសុកបូជកត្ថេរាបទានំ

[៨៣] កឹសុកំ បុប្ផិតំ ទិស្វា បគ្គហេត្វាន អញ្ជលឹ
ពុទ្ធំ សរិត្វា សិទ្ធត្ថំ អាកាសេ អភិបូជយឹ ។
ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កឹសុកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កឹសុកបូជកត្ថេរស្ស អបទានំ សមត្តំ ។

បានឮថា ព្រះយវកលាបិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យវកលាបិយត្ថេរាបទាន ។

# កឹសុកបូជកត្ថេរាបទាន ទី ៣

[៥៣] ខ្ញុំបានឃើញផ្កាចារីក ហើយបេះផ្គងអញ្ជលីឡើងនឹកដល់ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ បូជាបោះទៅឰដ៏អាកាស ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកឹសុកបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កឹសុកបូជកត្ថេរាបទាន ។

# ចតុត្ថំ សកោដកកោរណ្ឌទាយកត្ថេរាបទានំ

[៨៤] អក្កន្តញ្ច បទំ ទិស្វា សិខិនោ លោកពន្ធុនោ
ឯកំសំ អជិនំ កត្វា បទំ សេដ្ឋំ អវន្ទហំ ។
កោរណ្ឌំ បុប្ផិតំ ទិស្វា បាទបំ ធរណីរុហំ
សកោដកំ[១] គហេត្វាន បទេ ចក្កំ អបូជយឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សកោដកកោរណ្ឌទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សកោដកកោរណ្ឌទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. សកោសកំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# សកោដកកោរណ្ឌទាយកត្ថេរាបទាន ទី ៤

[៨៤] ខ្ញុំបានឃើញស្នាមព្រះបាទ របស់ព្រះសិរី ជាផៅពង្សនៃលោក ដែលទ្រង់ដាន់ទុក ហើយធ្វើនូវស្បែកខ្លាធៀងស្មាម្ខាង ថ្វាយបង្គំស្នាមព្រះបាទដ៏ប្រសើរ ។ ខ្ញុំឃើញនូវដើមឈើដែលដុះលើផែនដី ឈ្មោះកោរណ្ឌព្រឹក្ស មានផ្ការីក ហើយក៏កាច់យកទាំងត្រួយ មកបូជានូវចក្រព្ធដ៏ស្នាមព្រះបាទ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសកោដកកោរណ្ឌទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សកោដកកោរណ្ឌទាយកត្ថេរាបទាន ។

៨៤

# បញ្ចមំ ទណ្ឌទាយកត្ថេរាបទានំ

[៤៤] កាននំ វនមោគ្គយ្ហ វេឡុំ ឆេត្វានហន្តទា

អាលម្ពនំ កហេត្វាន សង្ឃស្ស អទទំ អហំ ។

តេន ចិត្តប្បសាទេន សុព្វតេ អភិវាទិយ

អាលម្ពនម្បិ ទត្វាន បក្កាមិ ឧត្តរាមុខោ ។

ចតុន្នវុតេ ឥតោ កប្បេ យំ ទណ្ឌមទទិន្តទា

ទុគ្គតឹ នាភិជានាមិ ទណ្ឌទានស្សិទំ ផលំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ទណ្ឌទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ទណ្ឌទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ទណ្ឌទាយកត្ថេរាបទាន ទី ៥

[៩៥] ក្នុងកាលនោះ ខ្ញុំបានចូលទៅក្នុងព្រៃធំ ហើយកាប់នូវឫស្សី យកមកធ្វើបង្កាន់ដៃ ប្រគេនដល់ព្រះសង្ឃ ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំថ្វាយបង្គំព្រះសង្ឃដែលមានវត្តដ៏ល្អ លុះប្រគេននូវបង្កាន់ដៃហើយ ក៏បែរមុខឆ្ពោះកាន់ឧត្តរទិស ដើរចេញទៅ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានប្រគេននូវបង្កាន់ដៃ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការប្រគេនបង្កាន់ដៃ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះទណ្ឌទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ទណ្ឌទាយកត្ថេរាបទាន ។

# ឆដ្ឋំ អម្ពយាគុទាយកត្ថេរាបទានំ

[៨៦] សតរំសី នាម សម្ពុទ្ធោ សយម្ភូ អបរាជិតោ
វុដ្ឋហិត្វា សមាធិម្ហា ភិក្ខាយ មមុបាគមិ ។
បច្ចេកពុទ្ធំ ទិស្វាន អម្ពយាគុំ អទាបយឹ
វិប្បសន្នមនន្តស្ស វិប្បសន្នេន ចេតសា ។
ចតុន្នវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ អម្ពយាគុយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អម្ពយាគុទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពយាគុទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អម្ពយាគុទាយកត្ថេរាបទាន ទី ៦

[៨៦] ព្រះបច្ចេកសម្ពុទ្ធ ព្រះនាមសតរង្សី ត្រាស់ដឹងឯង គ្មានសត្រូវផ្ចាលផ្ចាញ់បាន ទ្រង់ចេញអំពីសមាធិ ហើយស្តេចសំដៅមករកខ្ញុំដើម្បីភិក្ខា ។ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធដែលមានព្រះហឫទ័យស្អាត ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនបបរស្វាយ ដល់ព្រះបច្ចេកពុទ្ធនោះ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃបបរស្វាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពយាគុទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពយាគុទាយកត្ថេរាបទាន ។

# សត្តមំ បុដកបូជកត្ថេរាបទានំ

[៨៧] ទិវាវិហារា និក្ខន្តោ    វិបស្សី លោកនាយកោ
ភិក្ខាយ វិចរន្តោ សោ    មម សន្តិកមុបាគមិ ។
តតោ បីតិតោ សុមនោ    ពុទ្ធសេដ្ឋស្ស តាទិនោ
លោណសុបុដកំ ទត្វា    កប្បំ សគ្គម្ហិ មោទហំ ។
ឯកនវុតេ ឥតោ កប្បេ    យំ បុដកមទាសហំ
ទុគ្គតឹ នាភិជានាមិ    បុដកស្ស ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុដកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បុដកបូជកត្ថេរស្ស អបទានំ សត្តមំ ។

# បុដកបូជកត្ថេរាបទាន ទី ៧

[៥៧] ព្រះពុទ្ធព្រះនាមវិបស្សី ជានាយកនៃលោក ទ្រង់ស្តេចចេញអំពីបង្ហារសម្រាប់សម្រាក ក្នុងវេលាថ្ងៃ ទ្រង់ធ្វើព្រះដំណើរទៅដើម្បីភិក្ខា បានទ្រង់ចូលសំដៅទៅរកខ្ញុំ ។ លំដាប់នោះ ខ្ញុំមានបីតិសោមនស្ស ក៏បានប្រគេននូវកញ្ចប់អំបិល ដល់ព្រះពុទ្ធជាបុគ្គលប្រសើរ ប្រកបដោយតាទិគុណ ដោយសារកុសលនេះ ក៏បានរីករាយក្នុងឋានសួគ៌ អស់មួយកប្ប ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយកញ្ចប់អំបិល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយកញ្ចប់អំបិល ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុដកបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុដកបូជកត្ថេរាបទាន ។

# អដ្ឋមំ វច្ឆទាយកត្ថេរាបទានំ

[៨៨] វិបស្សិនោ ភគវតោ លោកជេដ្ឋស្ស តាទិនោ
ឯកវច្ឆោ មយា ទិន្នោ(១) បសន្នេន សចាណិនា ។
ហត្ថិយានំ អស្សយានំ ទិព្វយានំ សមជ្ឈគំ
តេន វច្ឆកទានេន(២) បត្តោម្ហិ អាសវក្ខយំ ។
ឯកនវុតេ ឥតោ កប្បេ យំ វច្ឆមទទឹ តទា
ទុគ្គតឹ នាភិជានាមិ វច្ឆទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា វច្ឆទាយកោ(៣) ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វច្ឆទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. ឯកមញ្ចំ មយា ទិន្នន្តិ ទិស្សន្តិ ។ ២ ម. មញ្ចកទានេន ។ ៣ ម. មញ្ចទាយកោ ។

# វច្ឆទាយកត្ថេរាបទាន ទី ៨

[៩៨] ខ្ញុំជ្រះថ្លាបានប្រគេនគ្រែមួយ ដល់ព្រះមានព្រះភាគ ព្រះនាមវិបស្សី ជាច្បងក្នុងលោក ជាតាទិបុគ្គល ដោយដៃរបស់ខ្លួន ។ ដោយការថ្វាយគ្រែនោះ ខ្ញុំក៏បាននូវយានដំរី យានសេះ ជាយានទិព្វ ទាំងបានដល់នូវការអស់ទៅនៃអាសវៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយគ្រែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយគ្រែ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះវច្ឆទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វច្ឆទាយកត្ថេរាបទាន ។

៨៩

# នវមំ សរណាគមនិយត្ថេរាបទានំ

[៥៩] អារុហិម្ហា តទា នាវំ ភិក្ខុ ចាជីវកោ ចហំ
នាវាយ ភិជ្ជមានាយ ភិក្ខុ មេ សរណំ អទា ។
ឯកត្តឹសេ ឥតោ កប្បេ យញ្ច មេ សរណំ អទា
ទុគ្គតឹ នាភិជានាមិ សរណាគមនេ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សរណាគមនិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សរណាគមនិយត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ បិណ្ឌបាតិកត្ថេរាបទានំ

[៦០] តិស្សោ នាមាសិ សម្ពុទ្ធោ វិហាសិ បវនេ តទា
តុសិតាហិ ឥធាគន្ត្វា បិណ្ឌបាតំ អទាសហំ ។
សម្ពុទ្ធំ អភិវាទេត្វា តិស្សំ នាម មហាយសំ
សកំ ចិត្តំ បសាទេត្វា តុសិតំ អគមាសហំ

# សរណាគមនិយត្ថេរាបទាន ទី ៩

[៥៩] ក្នុងកាលនោះ ភិក្ខុនិងខ្ញុំជាអាជីវក បានឡើងជិះទូក កាលទូកបែកធ្លាយ ភិក្ខុបានឲ្យសរណាគមន៍ដល់ខ្ញុំ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលភិក្ខុ បានឲ្យសរណាគមន៍ដល់ខ្ញុំ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសរណាគមន៍ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសរណាគមនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សរណាគមនិយត្ថេរាបទាន ។

# បិណ្ឌបាតិកត្ថេរាបទាន ទី ១០

[៦០] កាលនោះ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ គង់នៅក្នុងព្រៃធំ ខ្ញុំចេញអំពីឋានតុសិតមកក្នុងទីនេះ បានថ្វាយបិណ្ឌបាត ។ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធព្រះនាមតិស្សៈ ព្រះអង្គមានយសធំ ហើយក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយត្រឡប់ទៅកាន់ឋានតុសិតវិញ ។

ទ្វេនវុតេ ឥតោ កប្បេ　　យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ　　បិណ្ឌបាតស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បិណ្ឌបាតិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បិណ្ឌបាតិកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

សទ្ទសញ្ញី យវសិកោ　　កឹសុកោរណ្ឌបុប្ផិយោ
អាលម្ពនម្ពយាគូ ច　　បុដកវច្ឆទាយកោ
សរណំ បិណ្ឌបាតោ ច　　គាថា តាឡីសមេវ ច ។

សទ្ទសញ្ញិកវគ្គោ ឆត្តឹសោ ។

ក្នុងកប្បទី ៩២ អំពីកប្បនេះ កាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបិណ្ឌបាត ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិណ្ឌបាតិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិណ្ឌបាតិកត្ថេរាបទាន ។

## ឧទ្ទាន

សទ្ទសញ្ញិកត្ថេរាបទាន ១ យវកលាបិយត្ថេរាបទាន ១ កឹសុកបូជកត្ថេរាបទាន ១ សកោដកកោរណ្ឌបុប្ផិយត្ថេរាបទាន ១ អាលម្ពលន ឬ ទណ្ឌទាយកត្ថេរាបទាន ១ អម្ពយាគុទាយកត្ថេរាបទាន ១ បុដកបូជកត្ថេរាបទាន ១ វច្ឆទាយកត្ថេរាបទាន ១ សរណាគមនិយត្ថេរាបទាន ១ បិណ្ឌបាតិកត្ថេរាបទាន ១ មានគាថា ៤០ ។

ចប់ សទ្ទសញ្ញិកវគ្គ ទី ៣៦ ។

# សត្តតឹសោ មន្ទារវបុប្ផិយវគ្គោ

## បឋមំ មន្ទារវិយត្ថេរាបទានំ

[៦១] តាវត្តឹសា ឥធាគន្ត្វា　　មង្គលោ នាម មាណវោ
មន្ទារវំ គហេត្វាន　　វិបស្សិស្ស មហេសិនោ ។
សមាធិនា និសិន្នស្ស　　មត្ថកេ ធារយឹ អហំ
សត្តាហំ ធារយិត្វាន　　ទេវលោកំ បុនាគមឹ ។
ឯកនវុតេ ឥតោ កប្បេ　　យំ ពុទ្ធំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសន្តិ ។

ឥត្ថំ សុទំ អាយស្មា មន្ទារវិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មន្ទារវិយត្ថេរស្ស អបទានំ សមត្តំ ។

# មន្ទារវបុប្ផិយវគ្គ ទី ៣៧

## មន្ទារវិយត្ថេរាបទាន ទី ១

[៦១] ខ្ញុំជាទេវតាកំលោះ ឈ្មោះមង្គលៈ ចេញអំពីឋានតាវត្តិង្ស ហើយមកក្នុងទីនេះ បានយកផ្កាមន្ទារវៈ បាំងលើព្រះសិរ្សៈ នៃព្រះពុទ្ធព្រះនាមវិបស្សី ព្រះអង្គស្វែងនូវគុណដ៏ធំ ដែលគង់នៅដោយសមាធិ លុះខ្ញុំបាំងថ្វាយអស់ ៧ ថ្ងៃហើយ ទើបបានទៅកាន់ទេវលោកវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមន្ទារវិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មន្ទារវិយត្ថេរាបទាន ។

## ទុតិយំ កក្ការុបុប្ផិយត្ថេរាបទានំ

[៦២] យាមា ទេវា ឥធាគន្ត្វា គោតមំ សិរិវច្ឆយំ
កក្ការុបុប្ផំ[១] បគ្គយ្ហ ពុទ្ធស្ស អភិរោបយឹ ។
ទេវបុត្តេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កក្ការុបុប្ផិយោ[២] ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កក្ការុបុប្ផិយត្ថេរស្ស[៣] អបទានំ សមត្តំ ។

## តតិយំ ភិសមុឡាលទាយកត្ថេរាបទានំ

[៦៣] ផុស្សោ នាមាសិ សម្ពុទ្ធោ សព្វធម្មាន បារគូ
វិវេកកាមោ សប្បញ្ញោ អាគច្ឆិ មម សន្តិកេ ។
តស្មឹ ចិត្តំ បសាទេត្វា មហាការុណិកេ ជិនេ
ភិសមុឡាលំ បគ្គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ ។

---

១ ម. គោត្ថុនុមាលំ ។ ២ ម. គោត្ថុនុបុប្ផិយោ ។ ៣ ម. គោត្ថុនុបុប្ផិយត្ថេរស្ស ។

# កក្ការុបុប្ផិយត្ថេរាបទាន ទី ២

[៦២] ខ្ញុំចេញអំពីទេវលោក ជាន់យាមៈ មកក្នុងទីនេះ បានឃើញព្រះគោតម ជាសិរិវច្ឆយគោត្រ ហើយយកផ្កាត្រឡាចបូជាដល់ព្រះពុទ្ធ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកក្ការុបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កក្ការុបុប្ផិយត្ថេរាបទាន ។

# ភិសមុឡាលទាយកត្ថេរាបទាន ទី ៣

[៦៣] ព្រះសម្ពុទ្ធព្រះនាមផុស្សៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ប្រាថ្នានូវវិវេក ទ្រង់ប្រកបដោយបញ្ញា បានស្តេចមកក្នុងសម្នាក់របស់ខ្ញុំ ។ ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះជិនស្រី ព្រះអង្គប្រកបដោយមហាករុណានោះ ហើយ បានយកក្រអៅឈូកថ្វាយ ដល់ព្រះពុទ្ធដ៏ប្រសើរ ។

ទ្វេនវុតេ ឥតោ កប្បេ　　យំ ភិសំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ　　ភិសទានស្សិទំ ផលំ ។
បដិសម្ភិទា ចតស្សោ　　វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា　　កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភិសមុឡាលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភិសមុឡាលទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ចតុត្ថំ កេសរបុប្ផិយត្ថេរាបទានំ

[៦៤] វិជ្ជាធរោ តទា អាសឹ　　ហិមវន្តម្ហិ បព្វតេ
អទ្ទសំ វិរជំ ពុទ្ធំ　　ចង្កមន្តំ មហាយសំ ។
តីណិ កេសរបុប្ផានិ　　សីសេ កត្វានហំ តទា
ឧបសង្កម្ម សម្ពុទ្ធំ　　វេស្សភុំ អភិបូជយឹ ។
ឯកត្តឹសេ ឥតោ កប្បេ　　យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។

ក្នុងកប្បទី ៩២ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយក្រអៅឈូក ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការថ្វាយក្រអៅឈូក ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភិសមុឡាលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភិសមុឡាលទាយកត្ថេរាបទាន ។

# កេសរបុប្ផិយត្ថេរាបទាន ទី ៤

[៦៤] ក្នុងកាលនោះ ខ្ញុំកើតជាវិជ្ជាធរ នៅលើភ្នំហិមពាន្ត បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាករាគៈ មានយសធំ កំពុងចង្រ្កម ។ លុះឃើញហើយ ខ្ញុំបានតម្កល់ផ្កាកេសរ ៣ ទងលើក្បាល ហើយនាំចូលទៅបូជាព្រះសម្ពុទ្ធ ព្រះនាមវេស្សភូ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

បដិសម្ភិទា ចតស្សោ     វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា     កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កេសរបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កេសរបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## បញ្ចមំ អង្កោលបុប្ផិយត្ថេរាបទានំ

[៦៤] បទុមោ នាម សម្ពុទ្ធោ     ចិត្តក្ខូដេ វសី តទា
ទិស្វាន តមហំ ពុទ្ធំ     សយម្ភុំ ឧបគញ្ឆហំ[១] ។
អង្កោលំ បុប្ផិតំ ទិស្វា     ឱចិនិត្វានហំ តទា
ឧបគន្ត្វាន សម្ពុទ្ធំ     បូជេសឹ បទុមំ ជិនំ ។
ឯកត្តឹសេ ឥតោ កប្បេ     យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ     ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ     វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា     កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. អបរាជិតំ ។

បដិសម្ភិទា ៤ វិមោក្ខ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកេសរបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កេសរបុប្ផិយត្ថេរាបទាន ។

# អង្កោលបុប្ផិយត្ថេរាបទាន ទី ៥

[៦៥] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមបទុមៈ គង់នៅលើភ្នំចិត្តកូដ ខ្ញុំបានឃើញព្រះពុទ្ធ ជាសយម្ភូអង្គនោះហើយក៏ចូលទៅជិត ។ ក្នុងកាលនោះ ខ្ញុំបានឃើញផ្កាអង្កោលរីកហើយបេះកាន់ដើរចូលទៅ បូជាព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមៈ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផល នៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឆដ្ឋំ កទម្ពបុប្ផិយត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា អង្កោលបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អង្កោលបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ កទម្ពបុប្ផិយត្ថេរាបទានំ

[៦៤] សុវណ្ណវណ្ណំ សម្ពុទ្ធំ  កច្ចន្តំ អន្តរាបណេ
កញ្ចនគ្ឃិយសង្កាសំ  ទ្វត្តឹសវរលក្ខណំ ។
និសជ្ជ ចាសាទវរេ  អទ្ទសំ លោកនាយកំ
កទម្ពបុប្ផំ បគ្គយ្ហ  វិបស្សឹ អភិបូជយឹ ។
ឯកនវុតេ ឥតោ កប្បេ  យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ  ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កទម្ពបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កទម្ពបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

បានឮថា ព្រះអង្កោលបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អង្កោលបុប្ផិយត្ថេរាបទាន ។

# កទម្ពបុប្ផិយត្ថេរាបទាន ទី ៦

[៦៦] ខ្ញុំអង្គុយលើប្រាសាទដ៏ប្រសើរ បានឃើញព្រះសម្ពុទ្ធជាលោកនាយក ព្រះអង្គមានវណ្ណៈដូចមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ប្រាកដស្មើដោយគ្រឿងបូជាមាស កំពុងស្តេចទៅកាន់ចន្លោះនៃរានផ្សារ ខ្ញុំបានយកផ្កាកទម្ព បូជាព្រះពុទ្ធព្រះនាមវិបស្សី ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកទម្ពបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កទម្ពបុប្ផិយត្ថេរាបទាន ។

## សត្តមំ ឧទ្ទាលកបុប្ផិយត្ថេរាបទានំ

[៦៧] សុជាតោ នាម[១]សម្ពុទ្ធោ គង្គាកូលេ វសី តទា
ឧទ្ទាលកំ គហេត្វាន បូជយឹ អបរាជិតំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ឧទ្ទាលកបុប្ផិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទ្ទាលកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## អដ្ឋមំ ឯកចម្បកបុប្ផិយត្ថេរាបទានំ

[៦៨] ឧបសន្តោ ច សម្ពុទ្ធោ វសតិ បព្វតន្តរេ
ឯកចម្បកមាទាយ ឧបគញ្ឆឹ នរុត្តមំ ។

---
១ ម. អនុមោ នាម ។

# ឧទ្ទាលកបុប្ផិយត្ថេរាបទាន ទី ៧

[៦៧] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមសុជាត ព្រះអង្គគង់នៅលើច្រាំងនៃទន្លេគង្គា ខ្ញុំបានយកផ្កាពជព្រឹក្សបូជាព្រះពុទ្ធ ទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទ្ទាលកបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទ្ទាលកបុប្ផិយត្ថេរាបទាន ។

# ឯកចម្បកបុប្ផិយត្ថេរាបទាន ទី ៨

[៦៨] ព្រះសម្ពុទ្ធមានព្រះហឫទ័យស្ងប់រម្ងាប់ គង់នៅនាចន្លោះភ្នំ ខ្ញុំបានយកផ្កាចម្បាមួយ ដើរចូលទៅគាល់ព្រះសម្ពុទ្ធដ៏ឧត្តម ។

បសន្នចិត្តោ សុមនោ បច្ចេកមុនិមុត្តមំ
ឧភោហត្ថេហិ បគ្គយ្ហ បូជយឹ អបរាជិតំ ។
ឯកត្តឹសេ ឥតោ[១]កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ឯកចម្បកបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកចម្បកបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# នវមំ តិមិរបុប្ផិយត្ថេរាបទានំ

[៦៩] ចន្ទភាគានទីតីរេ អនុសោតំ វជាមហំ
អទ្ទសំ វិរជំ ពុទ្ធំ សាលរាជំវ បុប្ផិតំ ។
បសន្នចិត្តោ សុមនោ បច្ចេកមុនិមុត្តមំ
គហេត្វា តិមិរំ បុប្ផំ មត្ថកេ ឱកិរឹ អហំ ។

១ ម. បញ្ច សដ្ឋិម្ហិតោ ។

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានកាន់ផ្កានោះដោយដៃទាំងពីរ ហើយបូជាព្រះបច្ចេកមុនីដ៏ឧត្តម ដែលទ្រង់ឈ្នះកិលេស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកចម្បកបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកចម្បកបុប្ផិយត្ថេរាបទាន ។

# តិមិរបុប្ផិយត្ថេរាបទាន ទី ៩

[៦៩] ខ្ញុំទៅតាមទីបណ្តោយខ្សែទឹក បានឃើញព្រះពុទ្ធជិតឆ្នេរស្ទឹងចន្ទភាគា ទ្រង់ប្រាសចាកធូលីគឺរាគៈ ទ្រង់ដូចសាលរាជព្រឹក្សមានផ្ការីក ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយចំពោះព្រះបច្ចេកមុនីដ៏ឧត្តម បាននាំយកផ្កាតិមិរព្រឹក្ស មករោយលើព្រះកេសព្រះអង្គ ។

ឯកនវុតេ ឥតោ កប្បេ    យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ    ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិមិរបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិមិរបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ទសមំ សលឡបុប្ផិយត្ថេរាបទានំ

[៧០] ចន្ទភាគានទីតីរេ    អហោសឹ កិន្នរោ តទា
តត្ថទ្ទសំ ទេវទេវំ    ចង្កមន្តំ នរាសភំ ។
ឱចិនិត្វាន សលឡំ    ពុទ្ធសេដ្ឋស្សទាសហំ
ឧបសិង្ឃិ មហាវីរោ    សលឡំ ទេវគន្ធិកំ ។
បដិគ្គហេត្វា សម្ពុទ្ធោ    វិបស្សី លោកនាយកោ
ឧបសិង្ឃិ មហាវីរោ    បេក្ខមានស្ស មេ តទា ។

ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិមិរបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិមិរបុប្ផិយត្ថេរាបទាន ។

## សលឡបុប្ផិយត្ថេរាបទាន ទី ១០

[៧០] ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរ នៅទៀបឆ្នេរស្ទឹងចន្ទភាគា បានឃើញ (នូវព្រះវិបស្សីសម្ពុទ្ធ) ព្រះអង្គជាទេវតាកន្លងទេវតា ប្រសើរជាងពួកនរជន កំពុងចង្រ្កមក្នុងទីនោះ ។ ខ្ញុំបានបេះផ្កាស្រល់ បូជាដល់ព្រះពុទ្ធ ដ៏ប្រសើរឯព្រះសម្ពុទ្ធ មានព្យាយាមធំ ទ្រង់បានស្រង់ក្លិនផ្កាស្រល់ជាក្លិនទិព្វ ។ ក្នុងកាលនោះឯង ព្រះវិបស្សីសម្ពុទ្ធ ជាលោកនាយក មានព្យាយាមធំ ទ្រង់បានទទួល ហើយស្រង់ក្លិនផ្ការបស់ខ្ញុំ ដែលខ្ញុំកំពុងតែក្រឡេកមើល ។

៩៩

ឧទ្ទានំ

បសន្នចិត្តោ សុមនោ		វន្ទិត្វា ទិបទុត្តមំ
អញ្ជលឹ បគ្គហេត្វាន		បុន បព្វតមារុហឹ ។
ឯកនវុតេ ឥតោ កប្បេ		យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ		ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ		វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា		កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សលឡបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សលឡបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

មន្ទារវញ្ច កក្ការុ		ភិសកេសរបុប្ផិយោ
អង្កោលកោ កទម្ពី ច		ឧទ្ទាលំ ឯកចម្បកោ
តិមិរំ សលឡញ្ចេវ		គាថា តាឡីសមេវ ច ។

មន្ទារវបុប្ផិយវគ្គោ សត្តត្តឹសោ ។

ឧទ្ទាន

ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានផ្គងអញ្ជលីថ្វាយបង្គំ ព្រះទិបទុត្តមាចារ្យ ហើយឡើងទៅលើភ្នំវិញ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡបុប្ផិយត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សលឡបុប្ផិយត្ថេរាបទាន ។

# ឧទ្ទាន

មន្ទារវិយត្ថេរាបទាន ១ កក្ការុបុប្ផិយត្ថេរាបទាន ១ ភិសមុឡាលទាយកត្ថេរាបទាន ១ កេសរបុប្ផិយត្ថេរាបទាន ១ អង្កោលបុប្ផិយត្ថេរាបទាន ១ កទម្ពបុប្ផិយត្ថេរាបទាន ១ ឧទ្ទាលកបុប្ផិយត្ថេរាបទាន ១ ឯកចម្បកបុប្ផិយត្ថេរាបទាន ១ តិមិរបុប្ផិយត្ថេរាបទាន ១ សលឡបុប្ផិយត្ថេរាបទាន ១ មានគាថា ៤០ ។

ចប់ មន្ទារវបុប្ផិយវគ្គ ទី ៣៧ ។

# អដ្ឋត្តឹសោ ពោធិវន្ទនវគ្គោ

## បឋមំ ពោធិវន្ទកត្ថេរាបទានំ

[៧១] បាដលឹ ផលិតំ ទិស្វា បាទបំ ធរណីរុហំ
ឯកំសំ អញ្ជលឹ កត្វា អវន្ទឹ បាដលឹ អហំ ។
អញ្ជលឹ បគ្គហេត្វាន គរុំ កត្វាន មានសំ
អន្តោសុទ្ធំ ពហិសុទ្ធំ សុវិមុត្តំ អនាសវំ ។
វិបស្សឹ លោកមហិតំ ករុណាញាណសាគរំ
សម្មុខា វិយ សម្ពុទ្ធំ អវន្ទឹ បាដលឹ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ ពោធិមភិវន្ទិហំ
ទុគ្គតឹ នាភិជានាមិ វន្ទនាយ ឥទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា ពោធិវន្ទកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ពោធិវន្ទកត្ថេរស្ស អបទានំ សមត្តំ ។

# ពោធិវន្ទនវគ្គ ទី ៣៨

## ពោធិវន្ទកត្ថេរាបទាន ទី ១

[៧១] ខ្ញុំបានឃើញដើមច្រនៀង ដ៏រុងរឿង ជាឈើដុះលើផែនដី ហើយខ្ញុំធ្វើ (នូវសំពត់) ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីថ្វាយបង្គំនូវដើមច្រនៀង ។ ខ្ញុំផ្គងអញ្ជលី ធ្វើសេចក្តីគោរពក្នុងចិត្ត ថ្វាយបង្គំដើមច្រនៀង ហាក់ដូចជាព្រះសម្ពុទ្ធព្រះនាមវិបស្សី គង់នៅចំពោះមុខ ព្រះអង្គស្អាតទាំងក្នុងស្អាតទាំងក្រៅ ទ្រង់រួចស្រឡះចាកវដ្តទុក្ខ មិនមានអាសវៈដែលត្រៃលោកបូជាហើយ មានព្រះករុណាញាណដូចសា-គរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយបង្គំពោធិព្រឹក្ស ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយបង្គំ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះពោធិវន្ទកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ពោធិវន្ទកត្ថេរាបទាន ។

# ទុតិយំ បាដលិបុប្ផិយត្ថេរាបទានំ

[៧២] វិបស្សី នាម ភគវា សយម្ភូ អគ្គបុគ្គលោ
បុរក្ខតោ សសិស្សេហិ ពន្ធុមំ ចារិសី ជិនោ ។
តីណិ បាដលិបុប្ផានិ ឧច្ឆង្គេ ឋបិតានិ មេ
សីសំ ន្ហាយិតុកាមោហំ នទីតិរំ អគច្ឆហំ ។
និក្ខម្ម ពន្ធុមតិយា អទ្ទសំ លោកនាយកំ
ឥន្ទីវរំវ ជលិតំ អាទិត្តំវ ហុតាសនំ ។
ព្យគ្ឃុសភំវ បវរំ អភិជាតំវ កេសរឹ
គច្ឆន្តំ សមណានគ្គំ ភិក្ខុសង្ឃបុរក្ខតំ ។
តស្មឹ បសន្នោ(១) សុគតេ កិលេសមលធោវនេ
គហេត្វា តីណិ បុប្ផានិ ពុទ្ធសេដ្ឋំ អបូជយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

---
១ ម. សមណោ ។

# បាដលិបុប្ផិយត្ថេរាបទាន ទី ២

[៧២] ព្រះជិនស្រីមានព្រះភាគ ព្រះនាមវិបស្សី ព្រះអង្គត្រាស់ដឹងឯង ជាបុគ្គលដ៏ប្រសើរ មានពពួកសិស្សហែហមហើយ ស្តេចចូលទៅកាន់ពន្ធុមតីនគរ ។ ខ្ញុំបានដក់ផ្កាប្រនៀង ៣ ទងក្នុងថ្នក់ ខ្ញុំប្រាថ្នានឹងកក់ក្បាល ខ្ញុំបានដើរទៅកាន់ឆ្នេរស្ទឹង ។ ខ្ញុំចេញអំពីក្រុងពន្ធុមតី បានឃើញព្រះពុទ្ធ ជាលោកនាយក ទ្រង់ដូចជាដើមរាជព្រឹក្សដ៏រុងរឿងកំពុងឆេះ ទ្រង់ដូចជាខ្លាធំ ឬដូចគោឧសភដ៏ប្រសើរ ឬក៏ដូចកេសររាជសីហ៍ មានជាតិដ៏ខ្ពស់ ព្រះអង្គប្រសើរជាងពួកសមណៈ កំពុងស្តេចទៅ ដោយមានភិក្ខុសង្ឃចោមរោម ខ្ញុំជ្រះថ្លាចំពោះព្រះសុគតអង្គនោះ ទ្រង់លាងមន្ទិលគឺកិលេសហើយ ខ្ញុំកាន់យកផ្កាប្រនៀងទាំង ៣ ទង បូជាព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចាដលិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បាដលិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ តីណុប្បលមាលិយត្ថេរាបទានំ

[៧៣] ចន្ទភាគានទីតីរេ អហោសឹ វានរោ តទា
អទ្ទសំ វិរជំ ពុទ្ធំ និសិន្នំ បព្វតន្តរេ ។
ឱភាសេន្តំ ទិសា សព្វា សាលរាជំវ ផុល្លិតំ
លក្ខណព្យញ្ជនូបេតំ និស្វា អត្តមនោ អហំ ។
ឧទគ្គចិត្តោ សុមនោ បីតិយា ហដ្ឋមានសោ
តីណិ ឧប្បលបុប្ផានិ មត្ថកេ អភិរោបយឹ ។

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះបាដលិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ បាដលិបុប្ផិយត្ថេរាបទាន ។

# តីណុប្បលមាលិយត្ថេរាបទាន ទី ៣

[៧៣] *ក្នុងកាលនោះ ខ្ញុំកើតជាស្វា នៅទៀបឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ដែលប្រាសចាកធូលី គឺរាគៈ គង់នៅនាចន្លោះភ្នំ ។ លុះខ្ញុំបានឃើញ (ព្រះសម្ពុទ្ធនោះ) ទ្រង់ប្រកបដោយលក្ខណៈនិងព្យញ្ជនៈ ដែលកំពុងញុំាងទិសទាំងពួងឲ្យភ្លឺស្វាង ដូចជាផ្កាសាលរាជព្រឹក្សរីកហើយ ខ្ញុំក៏មានចិត្តត្រេកអរ ។ លុះខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តសោមនស្ស មានចិត្តរីករាយដោយបីតិ ហើយបូជាផ្កាទាំង ៣ លើព្រះសិរ្សៈ ។*

១០៣

## តតិយំ តីណុប្បលមាលិយត្ថេរាបទានំ

បូជយិត្វាន បុប្ផានិ ផុស្សស្សាបិ មហេសិនោ
សគារវោ ភវិត្វាន បក្កាមឹ ឧត្តរាមុខោ ។
គច្ឆន្តោ បដិកុដិកោ វិប្បសន្នេន ចេតសា
សេលន្តរេ បតិត្វាន ចាបុណឹ ជីវិតក្ខយំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា បុរិមំ ជាតឹ តាវត្តឹសំ អគច្ឆហំ
សតានំ តីណិក្ខត្តុញ្ច ទេវរជ្ជមការយឹ
សតានំ បញ្ចក្ខត្តុំ ច ចក្កវត្តិ អហោសហំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តីណុប្បលមាលិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តីណុប្បលមាលិយត្ថេរស្ស អបទានំ សមត្តំ ។

## តីណុប្បលមាលិយត្ថេរាបទាន ទី ៣

លុះខ្ញុំបូជាផ្កាទាំងឡាយ ដល់ព្រះផុស្សសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយខ្ញុំក៏ធ្វើសេចក្តីគោរព រួចបែរមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចៀសចេញទៅ ។ ខ្ញុំកំពុងដើរថយក្រោយ ទាំងមានចិត្តជ្រះថ្លា ក៏ធ្លាក់ទៅក្នុងជ្រោះភ្នំ ដល់នូវការអស់ទៅនៃជីវិត ដោយកុសលកម្មដែលខ្ញុំធ្វើនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបុរិមជាតិនោះហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស បានសោយទេវរាជ្យអស់៣០០ដង បានជាស្តេចចក្រពត្តិ អស់៥០០ដង ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតីណុប្បលមាលិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តីណុប្បលមាលិយត្ថេរាបទាន ។

# ចតុត្ថំ បត្តិបុប្ផិយត្ថេរាបទានំ

[៧៤] យទា និព្វាយិ សម្ពុទ្ធោ មហេសី បទុមុត្តរោ
សមាគម្ម ជនា សព្វេ សរីរំ នីហរន្តិ តេ ។
នីហរន្តេ សរីរម្ហិ វជ្ជមានាសុ ភេរិសុ
បសន្នចិត្តោ សុមនោ បត្តិបុប្ផមភិបូជយឹ ។
សតសហស្សេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ សរីរេ បូជិតេ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

# បត្តិបុប្ផិយត្ថេរាបទាន ទី ៤

[៧៤] *វេលាដែលព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គស្វែងរកនូវគុណដ៏ធំ បរិនិព្វានហើយ ពួកជនទាំងអស់នោះនាំគ្នាមកប្រជុំ រំកិលនូវព្រះសរីរៈ កាលកំពុងរំកិលព្រះសរីរៈកំពុងវាយស្គរ (លាន់ឮគឹកកងរំពង) ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កា ជាចំណែកបុណ្យ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាព្រះសរីរៈ ឱ ! ខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់តើហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណាង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

១០៩

បញ្ចមំ សត្តបណ្ណិយត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា បត្តិបុប្ផិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បត្តិបុប្ផិយត្ថេរស្ស អបទានំ សមត្តំ ។

# បញ្ចមំ សត្តបណ្ណិយត្ថេរាបទានំ

[៧៩] សុមនោ នាម សម្ពុទ្ធោ ឧប្បជ្ជិ លោកនាយកោ
បសន្នចិត្តោ សុមនោ សត្តបណ្ណិមបូជយឹ ។
សតសហស្សេ ឥតោ កប្បេ សត្តបណ្ណិមបូជយឹ
ទុគ្គតឹ នាភិជានាមិ សត្តបណ្ណិបូជាយិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

បានឮថា ព្រះបត្តិបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បត្តិបុប្ផិយត្ថេរាបទាន ។

# សត្តបណ្ណិយត្ថេរាបទាន ទី ៥

[៧៥] ព្រះសម្ពុទ្ធព្រះនាមសុមនៈ ជាលោកនាយក ទ្រង់ត្រាស់ឡើង ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជានូវផ្កាសត្តបណ្ណិ (ដល់ព្រះអង្គ) ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កាសត្តបណ្ណិ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាផ្កាសត្តបណ្ណិ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា សត្តបណ្ណិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តបណ្ណិយត្ថេរស្ស អបទានំ សមត្តំ ។

# ឆដ្ឋំ គន្ធមុដ្ឋិយត្ថេរាបទានំ

[៧៦] ចិតកេ កយិរមានេ   នានាគន្ធេ សមាគតេ
បសន្នចិត្តោ សុមនោ   គន្ធមុដ្ឋឹ អបូជយឹ ។
សតសហស្សេ ឥតោ កប្បេ   ចិតកំ យំ អបូជយឹ
ទុគ្គតឹ នាភិជានាមិ   ចិតបូជាយិទំ ផលំ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

បានឮថា ព្រះសត្តបណ្ណិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សត្តបណ្ណិយត្ថេរាបទាន ។

# គន្ធមុដ្ឋិយត្ថេរាបទាន ទី ៦

[៧៦] កាលគេកំពុងធ្វើជើងថ្ករ កាលក្លិនក្រអូបផ្សេង ៗ កំពុងប្រជុំព្រម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានបូជាផ្កាមួយក្តាប់ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាជើងថ្ករ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

១០៧

សត្តមំ ចិតកបូជកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា គន្ធមុដ្ឋិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គន្ធមុដ្ឋិយត្ថេរស្ស អបទានំ សមត្តំ ។

# សត្តមំ ចិតកបូជកត្ថេរាបទានំ

[៧៧] បរិនិព្វុតេ ភគវតិ ជលជុត្តមនាមកេ
អារោបិតម្ហិ ចិតកេ[១] សាលបុប្ផំ អបូជយឹ ។
សតសហស្សេ ឥតោ កប្បេ យំ បុប្ផំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ចិតបូជាយិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ចិតកបូជកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ចិតកបូជកត្ថេរស្ស អបទានំ សមត្តំ ។

---
១ ម. សមយេ ។

បានឮថា ព្រះគន្ធមុដ្ឋិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គន្ធមុដ្ឋិយត្ថេរាបទាន ។

# ចិតកបូជកត្ថេរាបទាន ទី ៧

[៧៧] កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ បរិនិព្វាន កាលគេកំពុងលើកជើងថ្ករ ខ្ញុំបានបូជាផ្កាពាំងភ្នំ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាជើងថ្ករ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះចិតកបូជកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ចិតកបូជកត្ថេរាបទាន ។

# អដ្ឋមំ សុមនតាលវណ្ដិយត្ថេរាបទានំ

[៧៨] សិទ្ធត្ថស្ស ភគវតោ តាលវណ្ដំ អទាសហំ
សុមនេហិ បដិច្ឆន្នំ ធារយាមិ មហាយសំ[១] ។
ចតុន្នវុតេ ឥតោ កប្បេ តាលវណ្ដំ អទាសហំ
ទុគ្គតឹ នាភិជានាមិ តាលវណ្ដស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុមនតាលវណ្ដិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុមនតាលវណ្ដិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. មហារហំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# សុមនតាលវណ្តិយត្ថេរាបទាន ទី ៨

[៧៨] ខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ដែលគេរំលេចដោយផ្កាម្លិះទាំងឡាយ ដល់ព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ខ្ញុំបានបាំងថ្វាយព្រះពុទ្ធមានយសធំ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្ចិតស្លឹកត្នោត ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផ្ចិតស្លឹកត្នោត ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនតាលវណ្តិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនតាលវណ្តិយត្ថេរាបទាន ។

១០៩

នវមំ សុមនទាមិយត្ថេរាបទានំ

[៧៩] សិទ្ធត្ថស្ស ភគវតោ ឆ្កាតកាស្ស តបស្សិនោ
កត្វាន សុមនទាមំ ធារយឹ បុរតោ ឋិតោ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទាមំ អភិបូជយឹ
ទុគ្គតឹ នាភិជានាមិ សុមនទាមស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា សុមនទាមិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សុមនទាមិយត្ថេរស្ស អបទានំ សមត្តំ ។

សុមនទាមិយត្ថេរាបទាន ទី ៩

[៧៩] ខ្ញុំធ្វើកម្រងផ្កាម្លិះ ហើយឈរបាំងថ្វាយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ព្រះអង្គមានកិលេសលាងហើយ មានតបធម៌ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាកម្រងផ្កា ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាម្លិះ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមនទាមិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមនទាមិយត្ថេរាបទាន ។

# ទសមំ កាសុមារិផលទាយកត្ថេរាបទានំ

[៨០] កណិការំវ ជោតន្តំ  និសិន្នំ បព្វតន្តរេ
អទ្ទសំ វិរជំ ពុទ្ធំ  លោកជេដ្ឋំ នរាសភំ ។
បសន្នចិត្តោ សុមនោ  សិរេ កត្វាន អញ្ជលឹ
កាសុមារិផលំ គយ្ហ  ពុទ្ធសេដ្ឋស្សទាសហំ ។
ឯកត្តឹសេ ឥតោ កប្បេ  យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ  ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# កាសុមារិផលទាយកត្ថេរាបទាន ទី ១០

[៨០] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលីគឺរាគៈ ជាច្បងក្នុងលោក ប្រសើរជាងនរៈ ដែលគង់នៅនាចន្លោះភ្នំ ទ្រង់រុងរឿងដូចផ្កាកណិការ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើអញ្ជលីលើត្បូង ហើយកាន់ផ្លែកាសុមារិព្រឹក្ស ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

១១១

ឧទានំ

ឥត្ថំ សុទំ អាយស្មា កាសុមារិផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កាសុមារិផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ឧទ្ទានំ

ពោធិចាដលិឧប្បលិ បត្តិ ច សត្តបណ្ណិយោ
គន្ធមុដ្ឋី ច ចិតកោ តាលំ សុមងជាមកោ
កាសុមារិផលីបិច គាថា ឯកូនសដ្ឋិយោ ។

ពោធិវន្ទនវគ្គោ អដ្ឋត្តឹសោ ។

---

បានឮថា ព្រះកាសុមារិផលទាយកត្ថេរ មានអាយុ បានសម្តែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កាសុមារិផលទាយកត្ថេរាបទាន ។

# ឧទ្ទាន

ពោធិវន្ទកត្ថេរាបទាន ១ បាដលិបុប្ផិយត្ថេរាបទាន ១ តីណុប្បលមាលិយត្ថេរាបទាន ១ បត្តិបុប្ផិយត្ថេរាបទាន ១ សត្តុបណ្ណិយត្ថេរាបទាន ១ គន្ធមុដ្ឋិយត្ថេរាបទាន ១ ចិតកបូជកត្ថេរាបទាន ១ សុមនតាលវណ្តិយត្ថេរាបទាន ១ សុមនទាមិយត្ថេរាបទាន ១ កាសុមារិផលទាយកត្ថេរាបទាន ១ មានគាថា ៥៩ ។

ចប់ ពោធិវន្ទនវគ្គ ទី ៣៨ ។

# ឯកូនចត្តាឡីសោ អម្ពដផលវគ្គោ[១]

## បឋមំ អម្ពដផលទាយកត្ថេរាបទានំ

[៨១] សតរំសី ណាម ភគវា សយម្ភូ អបរាជិតោ
វិវេកកាមោ សម្ពុទ្ធោ គោចរាយាភិនិក្ខមិ ។
ផលហត្ថោ អហំ ទិស្វា ឧបគញ្ឆឹ ណរាសភំ
បសន្នចិត្តោ សុមនោ អម្ពដំ[២] អទទឹ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ផលំ អទទឹ អហំ
ទុគ្គតឹ ណាភិជាណាមិ ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
ណាគោវ ពន្ធនំ ឆេត្វា វិហរាមិ អណាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ម. អវដផលវគ្គោ ។ ២ ម. អវដំ ។

# អម្ពដផលវគ្គ ទី ៣៩

## អម្ពដផលទាយកត្ថេរាបទាន ទី ១

[៨១] ព្រះសម្ពុទ្ធមានព្រះភាគ ព្រះនាមសតរង្សី ព្រះអង្គត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេស មានប្រាថ្នានូវវិវេក បានចេញទៅដើម្បីគោចរ ។ ខ្ញុំមានផ្លែឈើក្នុងដៃ បានឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ ដ៏ប្រសើរជាងនរៈ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ ហើយបានថ្វាយផ្លែម្កាក់ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

១១៣

ទុតិយំ លពុជទាយកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា អម្ពដជផលទាយកោ[១] ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពដជផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## ទុតិយំ លពុជទាយកត្ថេរាបទានំ

[៨២] នគរេ ពន្ធុមតិយា អាសឹ អារាមិកោ តទា
អទ្ទសំ វិរជំ ពុទ្ធំ គច្ឆន្តំ អនិលញ្ជសេ ។
លពុជស្ស ផលំ គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ
អាកាសេ ឋិតកោ សន្តោ បដិគ្គណ្ហិ មហាយសោ ។
បីតិសញ្ជននំ មយ្ហំ ទិដ្ឋធម្មសុខាវហំ
ផលំ ពុទ្ធស្ស ទត្វាន វិប្បសន្នេន ចេតសា ។
អធិគញ្ឆឹ តទា បីតឹ វិបុលញ្ច សុខុត្តមំ
ឧប្បជ្ជតេវ រតនំ និព្វត្តស្ស យហឹ តហឹ ។
ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។

១ ម. អវដផលទាយកោ ។

លពុជទាយកត្ថេរាបទាន ទី ២

បានឮថា ព្រះអម្ពដផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពដផលទាយកត្ថេរាបទាន ។

# លពុជទាយកត្ថេរាបទាន ទី ២

[៨២] ក្នុងកាលនោះ ខ្ញុំជាអារាមិកជន (អ្នកថែសួនច្បារ) នៅក្នុងនគរពន្ធុមតី បានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលីគឺរាគៈ កំពុងស្តេចទៅឰដ៏អាកាស ។ ខ្ញុំបានយកផ្លែខ្នុរសម្ងួថ្វាយព្រះពុទ្ធដ៏ប្រសើរ ឯព្រះសម្ពុទ្ធ មានយសដ៏ធំ មានព្រះហឫទ័យស្ងប់រម្ងាប់ បានទ្រង់ឋិតនៅឰដ៏អាកាស ទទួលយក ។ ខ្ញុំមានការកើតឡើងនៃបីតិ ដែលជាគុណនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះតែថ្វាយផ្លែខ្នុរ ដល់ព្រះពុទ្ធដោយចិត្តជ្រះថ្លា ។ ក្នុងកាលនោះឯង ខ្ញុំមានបីតិដ៏ទូលំទូលាយផង មានសេចក្តីសុខដ៏ឧត្តមផង រតនៈ តែងកើតឡើងដល់ខ្ញុំ ដែលកើតហើយក្នុងឋានទាំងពួង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។

ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា លពុជទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

លពុជទាយកត្ថេរស្ស អបទានំ សមត្តំ ។

## តតិយំ ឧទុម្ពរផលទាយកត្ថេរាបទានំ

[៨៣] និន្នគានទិយា[១] តីរេ    វិហាសិ បុរិសុត្តមោ
អទ្ទសំ វិរជំ ពុទ្ធំ    ឯកគ្គំ សុសមាហិតំ ។
តស្មឹ បសន្នមានសោ    កិលេសមលធោវនេ
ឧទុម្ពរផលំ គយ្ហ    ពុទ្ធសេដ្ឋស្សទាសហំ ។

១ ម. វិនតានទិយា ។

ឱ ! ដំណើរ ដែលខ្ញុំមកក្នុងសម្នាក់ នៃព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះលពុជទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ លពុជទាយកត្ថេរាបទាន ។

# ឧទុម្ពរផលទាយកត្ថេរាបទាន ទី ៣

[៨៣] ព្រះពុទ្ធជាបុរសខ្ពង់ខ្ពស់ គង់នៅទៀបឆ្នេរស្ទឹងវិនិទ្ធគា ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលី គឺរាគៈ មានព្រះហឫទ័យតម្កល់មាំ មានអារម្មណ៍តែមួយ ។ ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះសម្ពុទ្ធនោះ ព្រះអង្គលាងមន្ទិលគឺកិលេស ខ្ញុំក៏បានយកផ្លែឧទុម្ពរ ថ្វាយដល់ព្រះសម្ពុទ្ធដ៏ប្រសើរ ។

១១៨

តតិយំ ឧទុម្ពរផលទាយកត្ថេរាបទានំ

ឯកនវុតេ ឥតោ កប្បេ  យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ  ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧទុម្ពរផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទុម្ពរផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

ឧទុម្ពរផលទាយកត្ថេរាបទាន ទី ៣

ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទុម្ពរផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទុម្ពរផលទាយកត្ថេរាបទាន ។

# ចតុត្ថំ មិលក្ខុផលទាយកត្ថេរាបទានំ

[៨៤] វនន្តរេ ពុទ្ធំ ទិស្វា អត្ថទស្សឹ មហាយសំ
បសន្នចិត្តោ សុមនោ មិលក្ខុស្ស ផលំ អទំ[(១)] ។
អដ្ឋារសេ កប្បសតេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មិលក្ខុផលទាយកោ[(១)] ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មិលក្ខុផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. បិលក្ខស្សាទទឹ ផលន្តិ ទិស្សន្តិ ។ ២ ម. មិលក្ខផលទាយកោ ។

# មិលក្ខុផលទាយកត្ថេរាបទាន ទី ៤

[៨៤] ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គយល់ឃើញនូវប្រយោជន៍ មានយសធំ ត្រង់ចន្លោះព្រៃ ក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែមិលក្ខុព្រឹក្ស (ដីប្លី) ។ ក្នុងកប្បទី ១.៨០០ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមិលក្ខុផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មិលក្ខុផលទាយកត្ថេរាបទាន ។

# បញ្ចមំ ផារុសផលទាយកត្ថេរាបទានំ

[៨៩] សុវណ្ណវណ្ណំ សម្ពុទ្ធំ    អាហុតីនំ បដិគ្គហំ
រថិយំ បដិបជ្ជន្តំ    ផារុសផលំ អទាសហំ ។
ឯកនវុតេ ឥតោ កប្បេ    យំ ផលំ អទទឹ អហំ
ទុគ្គតឹ នាភិជានាមិ    ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ផារុសផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ផារុសផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

# ផារុសផលទាយកត្ថេរាបទាន ទី ៥

[៨៥] ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គមានវណ្ណៈដូចមាស ព្រះអង្គគួរទទួលនូវគ្រឿងសក្ការៈ ដែលពួកជននាំមកបូជា កំពុងស្តេចទៅក្នុងច្រក ហើយខ្ញុំប្រគេនផ្លែមៈប្រាង ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់តើហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះផារុសផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ផារុសផលទាយកត្ថេរាបទាន ។

# ឆដ្ឋំ វល្លិផលទាយកត្ថេរាបទានំ

[៨៦] សព្វេ ជនា សមាគម្ម អាគមឹសុ វនំ តទា
ផលមន្វេសមានា តេ អលភឹសុ ផលំ តទា ។
តត្ថទ្ទសាសឹ សម្ពុទ្ធំ សយម្ភុំ អបរាជិតំ
បសន្នចិត្តោ សុមនោ វល្លិផលមទាសហំ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

# វល្លិផលទាយកត្ថេរាបទាន ទី ៦

[៨៦] ក្នុងកាលនោះ ជនទាំងពួងមកប្រជុំគ្នា ក្នុងព្រៃ ជនទាំងឡាយនោះ បាននាំគ្នាស្វែងរកផ្លែឈើ ក៏បាននូវផ្លែឈើ ។ ក្នុងកាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេស ក្នុងទីនោះ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយផ្លែវល្លិ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

១១៩

សត្តមំ កទលិផលទាយកត្ថេរាបទានំ

ឥត្ថំ សុទំ អាយស្មា វល្លិផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

វល្លិផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ កទលិផលទាយកត្ថេរាបទានំ

[៨៧] កណិការំវ ជលិតំ បុណ្ណមាយេវ ចន្ទិមំ
ជលន្តំ ទីបរុក្ខំវ អទ្ទសំ លោកនាយកំ ។
កទលិយា ផលំ គយ្ហ អទាសឹ សត្ថុនោ អហំ
បសន្នចិត្តោ សុមនោ វន្ទិត្វាន អបក្កមឹ ។
ឯកត្តឹសេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

បានឮថា ព្រះវល្លិផលទាយកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ វល្លិផលទាយកត្ថេរាបទាន ។

# កទលិផលទាយកត្ថេរាបទាន ទី ៧

[៨៧] ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ឬដូចព្រះចន្ទ្រក្នុងថ្ងៃទី ១៥ កើត ឬក៏ដូចទីបរុក្ខ (ដើមឈើប្រចាំទ្វីប) ដ៏រុងរឿង ។ ខ្ញុំក៏មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្លែចេកថ្វាយព្រះសាស្ដា ហើយថ្វាយបង្គំដើរចេញទៅ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កទលិផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

កទលិផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ បនសផលទាយកត្ថេរាបទានំ

[៨៨] អជ្ជុនោ នាម សម្ពុទ្ធោ ហិមវន្តេ វសី តទា
ចរណេន ច សម្បន្នោ សមាធិកុសលោ មុនិ ។
កុម្ភមត្តំ គហេត្វាន បនសំ ជីវជីវកំ
ឆត្តបណ្ណេ ឋបេត្វាន អទាសឹ សត្ថុនោ អហំ ។
ឯកនវុតេ ឥតោ កប្បេ យំ ផលំ អទទឹ តទា
ទុគ្គតឹ នាភិជានាមិ ផលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកទលិផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កទលិផលទាយកត្ថេរាបទាន ។

# បនសផលទាយកត្ថេរាបទាន ទី ៨

[៨៨] ក្នុងកាលនោះ ព្រះសម្ពុទ្ធព្រះនាមអជ្ជុនៈ ព្រះអង្គបរិបូណ៌ដោយចរណៈផង ជាអ្នកប្រាជ្ញឈ្លាសវៃក្នុងសមាធិផង គង់នៅក្នុងហិមវន្តប្រទេស ។ ខ្ញុំបានយកផ្លែខ្នុរទាំងស្រស់ ប្រមាណប៉ុនក្អម តម្កល់លើស្លឹកឈើមានសណ្ឋានដូចឆត្រ ថ្វាយដល់ព្រះសាស្តា ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានថ្វាយផ្លែ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃផលទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។

១២១

នវមំ សោណកោដិវីសត្ថេរាបទានំ

កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បនសផលទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បនសផលទាយកត្ថេរស្ស អបទានំ សមត្តំ ។

## នវមំ សោណកោដិវីសត្ថេរាបទានំ

[៨៩] វិបស្សិនោ ចាវចនេ   ឯកំ លេណំ មយា កតំ
ចាតុទ្ទិសស្ស សង្ឃស្ស   ពន្ធុមារាជធានិយា ។
ទុស្សេហិ ភូមឹ លេណស្ស   សន្ថរិត្វា បរិច្ចជឹ
ឧទគ្គចិត្តោ សុមនោ   អកាសឹ បណិធឹ តទា ។
អារាធយេយ្យំ សម្ពុទ្ធំ   បព្វជ្ជញ្ច លភេយ្យហំ
អនុត្តរញ្ច និព្វានំ   ផុសេយ្យំ សន្តិមុត្តមំ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដក ចោលចេញហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបនសផលទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បនសផលទាយកត្ថេរាបទាន ។

# សោណកោដិវីសត្ថេរាបទាន ទី ៩

[៨៩] ក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមវិបស្សី ខ្ញុំបានធ្វើគុហាមួយ ក្នុងរាជធានី ឈ្មោះពន្ធុមតី ដើម្បីសង្ឃ ដែលមកអំពីទិសទាំង ៤ ។ ខ្ញុំបានចំណាយសំពត់ក្រាលទីគុហាដោយសំពត់ ខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តសោមនស្ស ក៏ធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលនោះថា ខ្ញុំសូមឲ្យព្រះសម្ពុទ្ធប្រោសប្រាណផង សូមឲ្យបានបព្វជ្ជាផង សូមពាល់ត្រូវ នូវព្រះនិព្វានដ៏ប្រសើរ ជាសន្តិសុខដ៏ឧត្តមផង កុំបីអាក់ខាន ។

តេនេវ សុក្កមូលេន កប្បេ នវុតិ សំសរឹ
ទេវភូតោ មនុស្សោ ច កតបុញ្ញោ វិរោចហំ ។
តតោ កម្មាវសេសេន ឥធ បច្ឆិមកេ ភវេ
ចម្បាយំ អគ្គសេដ្ឋិស្ស ជាតោម្ហិ ឯកបុត្តកោ ។
ជាតមត្តស្ស មេ សុត្វា បិតុឆន្ទោ អយំ អហុ
ទទាមហំ កុមារស្ស វីសកោដី អនូនកា ។
ចតុរង្គុលា ច មេ លោមា ជាតា ចាទតលេ ឧភោ
សុខុមា មុទុសម្ផស្សា តុលាបិចុសមា សុភា ។
អតីតា នវុតិ កប្បា អយំ ឯកោ ច ឧត្តរឹ
ណាភិជានាមិ និក្ខិត្តេ ចាទេ កុម្មេ អសន្ថតេ ។
អារាជិតោ មេ សម្ពុទ្ធោ បព្វជឹ អនគារិយំ
អរហត្តញ្ច មេ បត្តំ សីតិភូតោម្ហិ និព្វុតោ ។
អគ្គារទ្ធវីរិយានំ និទ្ទិដ្ឋោ សព្វទស្សិនា
ទីណាសោណោ ច អរហា ឆឡភិញ្ញោ មហិទ្ធិកោ ។

ដោយកុសលមូលនោះឯង ខ្ញុំអន្ទោលទៅកើតជាទេវតា និងមនុស្ស បានធ្វើបុណ្យ ហើយរុងរឿង អស់ ៩០ កប្ប ។ ក្នុងភពជាទីបំផុតនេះ ខ្ញុំបានកើតជាបុត្តឯក របស់សេដ្ឋីដ៏ប្រសើរ ក្នុងក្រុងចម្បា ដោយសំណល់នៃបុញ្ញកម្មនោះ ។ ឆន្ទៈរបស់បិតានៃខ្ញុំនេះ បានកើតឡើងថា អាត្មាអញនឹងឲ្យដល់កុមារនូវទ្រព្យ ២០ កោដិ មិនឲ្យខ្វះខាត ព្រោះឮថាខ្ញុំកើតហើយ ។ រោមទាំងឡាយនៃខ្ញុំ ប្រវែង ៤ ធ្នាប់ ដុះត្រង់ផ្ទៃនៃបាតជើងទាំងគូ ជារោមល្អិត មានសម្ផស្សទន់ល្អដូចប៉ុយគ ។ កន្លងទៅ ៩១ កប្ប នឹងកប្បនេះហើយ ខ្ញុំមិនដែលស្គាល់ដាក់ជើងជាន់លើទី ដែលគេមិនក្រាលឡើយ ។ ខ្ញុំបានឲ្យព្រះសម្ពុទ្ធទ្រង់ប្រោសប្រាណ ខ្ញុំបានចូលទៅកាន់ផ្នួស ខ្ញុំបានដល់ព្រះអរហត្តហើយ ខ្ញុំជាបុគ្គលមានសេចក្តីត្រជាក់ត្រជុំកើតឡើងហើយ ជាបុគ្គលមានទុក្ខរំលត់អស់ហើយ ។ ព្រះសម្ពុទ្ធព្រះអង្គយល់ឃើញសព្វ បានសម្តែងថា បណ្តាបុគ្គលដែលមានព្យាយាមប្រារព្ធដ៏ប្រសើរ ខ្ញុំនេះ ជាបុគ្គលមានអាសវៈអស់ហើយ ជាព្រះអរហន្ត បានអភិញ្ញា ៦ មានឫទ្ធិដ៏ច្រើន ។

១២៣

នវមំ  សោណកោដិវីសត្ថេរាបទានំ

ឯកនវុតេ ឥតោ កប្បេ   យំ ធាតុមកាសិ តទា
ទុគ្គតឹ នាភិជានាមិ   លេណទានស្សិទំ ផលំ ។

ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវោ ។

បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។

ថេរោ កោដិវីសោ សោណោ ភិក្ខុសង្ឃស្ស អគ្គតោ
បញ្ហំ បុដ្ឋោ វិយាកាសិ   អនោតត្តមហាសរេតិ ។

ឥត្ថំ សុទំ អាយស្មា សោណោ កោដិវីសោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សោណកោដិវីសត្ថេរស្ស អបទានំ សមត្តំ ។

សោណកោដិវីសត្ថេរាបទាន ទី ៩

ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃលេណទាន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ពុទ្ធសាសនា ខ្ញុំក៏បានធ្វើហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាបុគ្គលមិនមាន អាសវៈដូចជាដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ ព្រះសោណកោដិវីសត្ថេរ បានព្យាករដោយសេចក្ដីពិស្ដារ នូវប្រស្នា ដែលភិក្ខុសង្ឃ សួរហើយជិតមហាស្រះ ឈ្មោះអនោតត្ត ។

បានឮថា ព្រះសោណកោដិវីសត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោណកោដិវីសត្ថេរាបទាន ។

# ទសមំ បុព្វកម្មបិលោតិ នាម ពុទ្ធាបទានំ

[៩០] អនោតត្តសរាសន្នេ រមណីយេ សិលាតលេ
នានារតនបជ្ជោតេ នានាគន្ធវនន្តរេ ។
មហតា ភិក្ខុសង្ឃេន បរេតោ លោកនាយកោ
អាសីនោ ព្យាករិ តត្ថ បុព្វកម្មានិ អត្តនោ ។
សុណាថ ភិក្ខវេ មយ្ហំ យំ កម្មំ បកតំ មយា
ឯកំ អរញ្ញកំ ភិក្ខុំ ទិស្វា ទិន្នំ បិលោតិកំ(១) ។
បត្ថិតំ បឋមំ ពុទ្ធំ ពុទ្ធត្តាយ មយា តទា(២)
បិលោតិយស្ស កម្មស្ស ពុទ្ធត្តេបិ វិបច្ចតិ ។
គោបាលកោ បុរេ អាសឹ គាវឹ បាជេតិ គោចរំ
បិវន្តឹ ឧទកំ អាវិលំ គាវឹ ទិស្វា និវារយឹ ។
តេន កម្មវិបាកេន ឥធ បច្ឆិមកេ ភវេ
បិបាសិតោ យទិច្ឆកំ ន ហិ បាតុំ លភាមហំ(៣) ។

---

១ ម. អយំ ឧបឌ្ឍគាថា ន ទិស្សតិ ។ ២ ម. ឥមេ ទ្វេ បាឋា នត្ថិ ។ ៣ ម. គោបាលកោ បុរេ អាសឹ ។ល។ ន ហិ បាតុំ លភាមហន្តិ ឥមេ បាឋា ន វិជ្ជន្តិ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ទី ១០

[៩០] *ព្រះលោកនាយក មានភិក្ខុសង្ឃច្រើនចោមរោម ទ្រង់គង់លើផ្ទៃនៃថ្ម ជាទីរីករាយ ជិតស្រះអនោតត្ត រុងរឿង ដោយរតនៈផ្សេង ៗ ក្នុងចន្លោះនៃព្រៃ មានក្លិនផ្កាផ្សេង ៗ ទ្រង់ព្យាករនូវបុព្វកម្ម របស់ព្រះអង្គ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវអំពើរបស់តថាគត ដែលបានធ្វើទុកមកហើយ ដូចតទៅនេះ តថាគតបានឃើញនូវភិក្ខុមួយរូបនៅក្នុងព្រៃ ហើយបានប្រគេនកំណាត់សំពត់ ។ ក្នុងកាលនោះ តថាគតបានប្រាថ្នាជាព្រះសម្ពុទ្ធ ជាដំបូង ដើម្បីការត្រាស់ដឹង ឯសេចក្តីប្រាថ្នានោះ ក៏ឲ្យផលក្នុងការបានត្រាស់ជាព្រះពុទ្ធ ដោយអំណាចនៃបិលោតិកម្ម ។ ក្នុងកាលមុន តថាគត កើតជានាយគោបាល កៀងមេគោទៅកាន់ទីគោចរ បានឃើញមេគោ កំពុងផឹកទឹកល្អក់ ហើយដេញចេញ ។ ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតស្រេកទឹក ហើយមិនបានផឹកដូចសេចក្តីប្រាថ្នា ។*

១២៨

ទសមំ បុព្វកម្មបិលោតិ នាម ពុទ្ធាបទានំ

បុនាលិ នាមហំ ធុត្តោ បុព្វេ អញ្ញាសុ ជាតិសុ
បច្ចេកពុទ្ធំ សុរភឹ អព្ភាចិក្ខឹ អទូសកំ
តេន កម្មវិបាកេន និរយេ សំសរឹ ចិរំ
ពហូ វស្សសហស្សានិ ទុក្ខំ វេទេសិ វេទនំ ។
តេន កម្មាវសេសេន ឥធ បច្ឆិមកេ ភវេ
អព្ភក្ខានំ មយា លទ្ធំ សុន្ទរិកាយ ការណា ។
សព្វាភិភុស្ស ពុទ្ធស្ស នន្ទោ នាមាសិ សាវកោ
តំ អព្ភាចិក្ខាយ និរយេ ចិរំ សំសរិតំ មយា ។
ទសវស្សសហស្សានិ និរយេ សំសរឹ ចិរំ
មនុស្សលោកំ លទ្ធាហំ អព្ភក្ខានំ ពហុំ លភឹ ។
តេន កម្មាវសេសេន ចិញ្ចមាណវិកា មមំ
អព្ភាចិក្ខិ អភូតេន ជនកាយស្ស អាគតា ។
ព្រាហ្មណោ សុតវា អាសឹ អហំ សក្កតបូជិតោ
មហាវនេ បញ្ចសតេ មន្តេ វាចេមិ មាណវេ ។

បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ទី ១០

កាលកពមុន ក្នុងជាតិដទៃ តថាគតជាអ្នកលេង ឈ្មោះ បុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។ ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ រងទុក្ខវេទនា អស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគត បាននូវការពោលចង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ មួយទៀត តថាគតពោលបង្កាច់សាវ័កឈ្មោះនន្ទ របស់ព្រះពុទ្ធ ទ្រង់គ្រប់សង្កត់ នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ព្រោះការពោលបង្កាច់ នូវសាវ័កនោះ ។ តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ចំនួនមួយហ្មឺនឆ្នាំ លុះតថាគត បានមកជាមនុស្ស ក៏បាននូវការពោលបង្កាច់ជាច្រើន ។ ដោយសំណល់នៃកម្មនោះ នាងចិញ្ចមានវិកាមកពោលបង្កាច់តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត ។ តថាគតកើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្ត មានគេធ្វើសក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ក្នុងព្រៃធំ ។

តត្ថាគតោ[១] ឥសីភិមោ បញ្ចាភិញ្ញោ មហិទ្ធិកោ
តញ្ចាហំ អាគតំ ទិស្វា អព្ភាចិក្ខឹ អទូសកំ ។
តតោហំ អវចំ សិស្សេ កាមភោគី អយំ ឥសិ
មយ្ហំបិ ភាសមានស្ស អនុមោទឹសុ មាណវា ។
តតោ មាណវកា សព្វេ ភិក្ខមានា កុលេ កុលេ
មហាជនស្ស អាហំសុ កាមភោគី អយំ ឥសិ ។
តេន កម្មវិបាកេន បញ្ច ភិក្ខុសតា ឥមេ
អព្ភក្ខានំ លភុំ សព្វេ សុន្ទរិកាយ ការណា ។
វេមាតុ ភាតរំ បុព្វេ ធនហេតុ ហនឹ អហំ
បក្ខិបឹ គិរិទុគ្គេសុ សិលាយ ច អបឹសយឹ ។
តេន កម្មវិបាកេន ទេវទត្តោ សិលំ ខិបិ
អង្គុដ្ឋំ បឹសយិ ចាទេ មម ចាសាណសក្ខរា ។
បុរេហំ ទារកោ ហុត្វា កីឡមានោ មហាបថេ
បច្ចេកពុទ្ធំ ទិស្វាន មគ្គេ សកលិកំ ទហឹ ។
តេន កម្មវិបាកេន ឥធ បច្ឆិមកេ ភវេ
វធត្ថំ មំ ទេវទត្តោ អតិមារេ បយោជយិ ។

---
១ ម. តមាគតោ ។

ឥសីភិមៈ បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគត បានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្ត និមន្តមក ក៏បានពោលបង្កាច់ ។ លំដាប់នោះ តថាគតនិយាយនឹងពួក សិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយ ប្រាប់ ឯពួកមាណព ក៏បានរីករាយតាម ។ លំដាប់នោះ មាណពទាំងអស់ ត្រាច់ទៅសូមក្នុងត្រកូលតូចធំនិយាយប្រាប់ មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃ កម្មនោះ ភិក្ខុទាំងអស់ចំនួន ៥០០ នេះ ក៏បាននូវការពោល បង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ។ កាលភពមុន តថាគត សម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឲ្យប៉ះនឹងថ្ម ។ ដោយវិបាក នៃកម្មនោះ ទេវទត្ត បានប្រមៀលថ្ម ដុំថ្មក៏រមៀលមកប៉ះ អង្គុដ្ឋបាទ (មេជើង) នៃតថាគត ។ កាលពីជាតិមុន តថាគត ជាទារក កំពុងលេងក្នុងផ្លូវធំ បានឃើញព្រះបច្ចេកពុទ្ធ ក៏ ដុតព្រៃទាំងមូល ក្បែរផ្លូវ ។ ដោយវិបាកនៃកម្មនោះ ក្នុង បច្ឆិមភពនេះ ទេវទត្តក៏ប្រើខ្មាន់ធ្នូ ឲ្យសម្លាប់តថាគត ។

១២៧

ទសមំ បុព្វកម្មបិលោតិ នាម ពុទ្ធាបទានំ

ហត្ថារោហោ បុរេ អាសឹ　　បច្ចេកមុនិមុត្តមំ
បិណ្ឌាយ វិចរន្តំបិ　　អាសាទេសឹ គជេនហំ ។
តេន កម្មវិបាកេន　　ភន្តោ ទាឡាគិរី គជោ
គិរិព្វជេ បុរវរេ　　ទារុណោ សមុបាគមិ ។
រាជាហំ បត្ថិកោ អាសឹ　　សត្តិយា បុរិសេ ហនឹ
តេន កម្មវិបាកេន　　និរយេ បច្ចិសំ ភុសំ ។
កម្មុនោ តស្ស សេសេន　　សោទានិ សកលំ មម
បាទេ ឆវឹ បកប្បេសិ　　ន ហិ កម្មំ វិនស្សតិ ។
អហំ កេវដ្ដគាមស្មឹ　　អហុ កេវដ្ដទារកោ
មច្ឆោបឃាតកេ ទិស្វា　　ជនយឹ សោមនស្សកំ ។
តេន កម្មវិបាកេន　　សីសទុក្ខំ អហុ មម
សក្កេសុ ហញ្ញមានេសុ　　យទា ហនិ វិដដុភោ ។
ផុស្សស្សាហំ បាវចនេ　　សាវកេ បរិភាសយឹ
យវំ ខាទថ ភុញ្ជថ　　មា ច ភុញ្ជថ សាលិយោ ។

បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ទី ១០

កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រួចព្រះបច្ចេកមុនី ដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ។ ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរីចុះប្រេងកាច ចូលមកព្រួចតថាគតក្នុងគិរិព្វជបុរីដ៏ប្រសើរ (រាជគហ:) ។ តថាគតកើតជាស្តេច ឈ្មោះបត្តិក: បានយកលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ តថាគតឆេះក្នុងភ្លើងនរកក្លាខ្លាំង ។ ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះកម្មវិបាកនោះ ក៏ធ្វើឲ្យរបកស្បែងជើងទាំងអស់របស់តថាគត ព្រោះថាកម្មនៅតែមិនទាន់វិនាស ។ តថាគតកើតជាទារកនៃព្រានត្រី ក្នុងកេវដ្តគ្រាម បានឃើញពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។ ដោយវិបាកនៃកម្មនោះ ស្តេចវិដដុក:សម្លាប់ពួកសក្យ: ក្នុងកាលណា ទុក្ខក្នុងក្បាលក៏មានដល់តថាគត (ក្នុងកាលនោះ) ព្រោះពួកសក្យ: ត្រូវគេសម្លាប់ ។ តថាគតបានពោលផ្តន្ទា នូវពួកសាវ័កក្នុងសាសនា នៃព្រះពុទ្ធព្រះនាមផុស្ស:ថា ចូរលោកទាំងឡាយទំពាស៊ីបរិភោគនូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។

១២៨



តេន កម្មវិបាកេន  តេមាសំ ខាទិតំ យវំ
និមន្តិតោ ព្រាហ្មណេន  វេរញ្ជាយំ វសឹ តទា ។
និព្ពុតេ វត្តមានម្ហិ  មល្លបុត្តំ និសេធយឹ
តេន កម្មវិបាកេន  បិដ្ឋិទុក្ខំ អហុ មម ។
តិកិច្ឆកោ អហំ អាសឹ  សេដ្ឋិបុត្តំ វិរេចយឹ
តេន កម្មវិបាកេន  ហោតិ បក្ខន្ទិកាំ មម ។
អវចាហំ ជោតិបាលោ  សុគតំ កស្សបំ តទា
កុតោ នុ ពោធិមុណ្ឌស្ស  ពោធិ បរមទុល្លភា ។
តេន កម្មវិបាកេន  អចរឹ ទុក្ករំ ពហុំ
ឆព្វស្សានុរុវេលាយំ  តតោ ពោធឹ អបាបុណឹ ។
នាហំ ឯតេន មគ្គេន  បាបុណឹ ពោធិមុត្តមំ
កុមគ្គេន គវេសិស្សំ  បុព្វកម្មេន ចោទិតោ ។
បុញ្ញបាបបរិក្ខីណោ  សព្វសន្តាបវជ្ជិតោ
អសោកោ អនុបាយាសោ  និព្វាយិស្សំ អនាសវោ ។

ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគត នៅក្នុងស្រុកវេរញ្ជា ព្រាហ្មណ៍និមន្តឲ្យឆាន់តែបាយដំណើបអស់ ៣ ខែ ។ តថាគតបានហាមឃាត់កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើងដល់តថាគត ។ តថាគតកើតជាពេទ្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាកនៃកម្មនោះ ជំងឺចុះឈាមក៏កើតឡើងដល់តថាគត ។ ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានផ្ចាញ់ផ្ចាល់ព្រះសុគត ព្រះនាមកស្សបៈថា ព្រោះអ្វីក៏ថាត្រាស់ដឹងពោធិញ្ញាណ ជាទីផូរផង់ គេរកបានដោយកម្រក្រៃលែង ។ ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្តទុក្ករកិរិយាជាច្រើន ក្នុងឧរុវេលប្រទេស អស់ ៦ វស្សាទើបបានត្រាស់ដឹងឡើង ។ តថាគតមិនបានទូវពោធិញ្ញាណដ៏ឧត្តម ដោយផ្លូវនុ៎ះទេ តថាគតហេតុតែបុព្វកម្មនោះដាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។ តថាគតមានបុណ្យនិងបាបអស់រលីងហើយ បានវៀរបង់នូវកម្ដៅទាំងពួង មិនមានសេចក្ដីសោក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ។

១២៩

ឧទ្ទានំ

ឯវំ ជិនោ វិយាកាសិ ភិក្ខុសង្ឃស្ស អគ្គតោ
សព្វាភិញ្ញាពលប្បត្តោ អនោតត្តេ មហាសរេ ។

ឥត្ថំ សុទំ ភគវា អត្តនោ បុព្វចរិតំ បុព្វកម្ម-
បិលោតឹ នាម ពុទ្ធាបទានំ ធម្មបរិយាយំ អភាសិត្ថាតិ ។

បុព្វកម្មបិលោតិ នាម ពុទ្ធាបទានំ សមត្តំ ។

## ឧទ្ទានំ

អម្ពដំ លពុជញ្ចេវ ឧទុម្ពរមិលក្ខុ ច
ផារុស្សី ច កទលិ បនសោ កោដិវីសកោ ។
បុព្វកម្មបិលោតិ ច អបទានំ មហេសិនោ
គាថាយោ ឯកនវុតិ គណិតាយោ វិភាវិហិ ។

អម្ពដផលវគ្គោ ឯកូនចត្តាឡីសោ ។

ចុទ្ទសមំ ភាណវារំ ។

ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញា និងពលៈទាំងពួង បានព្យាករដោយសេចក្តីពិស្តារ ដល់ភិក្ខុសង្ឃ ជិតមហាស្រះឈ្មោះអនោតត្ត ដូចរៀបរាប់មកនេះឯង ។

បានឮថា ព្រះមានព្រះភាគ បានសម្តែងនូវពុទ្ធាបទាន ឈ្មោះបុព្វកម្មបិលោតិ ជាធម្មបរិយាយ ដែលជាបុព្វចរិត របស់ព្រះអង្គ ដោយប្រការដូច្នេះ ។

ចប់ បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ។

# ឧទ្ទាន

អម្ពដផលទាយកត្ថេរាបទាន ១ លពុជទាយកត្ថេរាបទាន ១ ឧទុម្ពរផលទាយកត្ថេរាបទាន ១ មិលក្ខុផលទាយកត្ថេរាបទាន ១ ផារុសផលទាយកត្ថេរាបទាន ១ វល្លិផលទាយកត្ថេរាបទាន ១ កទលិផលទាយកត្ថេរាបទាន ១ បនសផលទាយកត្ថេរាបទាន ១ សោណកោដិវីសត្ថេរាបទាន ១ បុព្វកម្មបិលោតាបទាន នៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ១ មានគាថា ៩១ ពួកអ្នកប្រាជ្ញបានរាប់ឃើញហើយ ។

ចប់ អម្ពដផលវគ្គ ទី ៣៩ ។

ចប់ ភាណវារៈ ទី ១៥ ។

# ចត្តាឡីសោ បិលិន្ទវគ្គោ

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

[៩១] នគរេ ហំសវតិយា  អាសឹ ទោវារិកោ អហំ
អក្ខោភ្ភំ អមិតំ ភោគំ  ឃរេ សន្និចិតំ មម ។
រហោគតោ និសីទិត្វា  បហំសិត្វាន មានសំ
និសជ្ជ បាសាទវរេ  ឯវំ ចិន្តេសហំ តទា ។
ពហូ មេវ គតា ភោគា  ផីតំ អន្តេបុរំ មម
រាជាបិ មំ និមន្តេសិ  អានន្ទោ បឋវិស្សរោ ។
អយញ្ច ពុទ្ធោ ឧប្បន្នោ  អធិច្ចុប្បត្តិកោ មុនិ
សំវិជ្ជន្តិ ច មេ ភោគា  ទានំ ទស្សាមិ សត្ថុនោ ។
បទុមេន រាជបុត្តេន  ទិន្នំ ទានវរំ ជិនេ
ហត្ថិនាគេ ច បល្លង្កេ  អបស្សេនំ ចនប្បកំ ។
អហំបិ ទានំ ទស្សាមិ  សង្ឃេ គណវរុត្តមេ
អទិន្នបុព្វំ ទានវរំ  ករិស្សំ អាទិកម្មិកោ ។

# បិលិន្ទវគ្គ ទី ៤០

## បិលិន្ទវច្ឆត្ថេរាបទាន ទី ១

[៩១] ខ្ញុំជាឆ្មាំទ្វារ ក្នុងនគរហង្សវតី ខ្ញុំសន្សំភោគសម្បត្តិជាអក្ខោភិនី រាប់មិនបាន ទុកក្នុងផ្ទះ ។ ក្នុងកាលនោះ ខ្ញុំទៅអង្គុយក្នុងទីស្ងាត់ ហើយញុំាងចិត្តឲ្យរីករាយ គឺអង្គុយក្នុងប្រាសាទដ៏ប្រសើរ ហើយគិតយ៉ាងនេះថា ភោគសម្បត្តិរបស់អញមានច្រើន ទីខាងក្នុងបុរីរបស់អញក៏ធំទូលាយ សូម្បីព្រះរាជាព្រះនាមអានន្ទ ជាធំលើផែនដី ក៏ទ្រង់ហៅរកអញ ។ ព្រះពុទ្ធនេះ ជាមុនី កើតឡើងព្រោះអាស្រ័យហេតុ ក៏កើតឡើងហើយ ទាំងភោគសម្បត្តិរបស់អញក៏មាន អញនឹងថ្វាយទាន ចំពោះព្រះសាស្តា ។ វត្ថុទានដ៏ប្រសើរ គឺបង្អែកក្នុងបល្ល័ង្កលើដំរី និងវត្ថុមានចំនួនច្រើន ព្រះអង្គម្ចាស់ព្រះនាមបទុមៈ បានថ្វាយចំពោះព្រះពុទ្ធជិនសិរី ។ ឯអញនឹងថ្វាយទានចំពោះព្រះសង្ឃ ជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះទានដ៏ប្រសើរ អញមិនធ្លាប់ថ្វាយឡើយ អញជាអាទិកម្មិកបុគ្គល ។

១៣១

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ចិន្តេត្វាហំ ពហុវិធំ　　យាគេ យស្ស សុខំ ផលំ
បរិក្ខារទានមទ្ទក្ខឹ　　មម សង្កប្បបូរណំ ។
បរិក្ខារានិ ទស្សាមិ　　សង្ឃេ គណវរុត្តមេ
អចិន្នបុព្វំ អញ្ញេសំ　　ករិស្សំ អាទិកម្មិកោ ។
ទក្សការេ ឧចាកម្ម　　ឆត្តំ ការេសិ តាវទេ
ឆត្តសតសហស្សានិ　　ឯកតោ សន្និចាតយឹ ។
ទុស្សសតសហស្សានិ　　ឯកតោ សន្និចាតយឹ
បត្តសតសហស្សានិ　　ឯកតោ សន្និចាតយឹ ។
វាសិយោ សត្ថកេ ចាបិ　　សូចិយោ នខឆេទនេ[១]
ហេដ្ឋាឆត្តេ បចាបេសឹ　　ការេត្វា តទនុច្ឆវេ ។
វិធូបនេ តាលបណ្ណេ[២]　　មោរហត្ថេ ច ចាមរេ
បរិស្សាវនេ តេលធារេ[៣]　　ការយឹ តទនុច្ឆវេ ។
សូចិឃរេ អំសវទ្ធេ　　អថោបិ កាយពន្ធនេ
អាធារកេ ច សុកតេ　　ការយឹ តទនុច្ឆវេ ។
បរិភោគភាជនេ ច　　អថោបិ លោហថាលកេ
ភេសជ្ជេ បូរយិត្វាន　　ហេដ្ឋាឆត្តេ ឋបេសហំ ។

១ ម. នខភេទនេ ។ ២ តាលវណ្ដេ ។ ៣ តេលាធារេ ។

## បិលិន្ទវច្ឆត្ថេរាបទាន ទី ១

សេចក្តីសុខជាផល នៃអំពើណា ក្នុងការបូជា អញនឹងគិត នូវអំពើនោះឲ្យច្រើន អញបានឃើញបរិក្ខារទាន ជាទីញ៉ាំង សេចក្តីត្រិះរិះ របស់អញឲ្យពេញ ។ អញនឹងឲ្យនូវបរិក្ខារ ចំពោះព្រះសង្ឃ ជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ (ព្រោះថា) អញមិន ដែលឲ្យទានដល់ពួកជនដទៃសោះ អញជាអាទិកម្មិកបុគ្គល ។ ខណៈនោះ ខ្ញុំចូលទៅរកពួកជាងត្បាញផែង ហើយឲ្យធ្វើ ឆត្រ រួចឲ្យគេប្រមូលឆត្រមួយសែនទុកក្នុងទីមួយ ។ ឲ្យគេប្រ-មូលសំពត់មួយសែនទុកក្នុងទីមួយ ឲ្យគេប្រមូលបាត្រមួយសែន ទុកក្នុងទីមួយ ។ ខ្ញុំឲ្យគេធ្វើកាំបិតព្រា កាំបិតកោរ ម្ជុលនិងកាំ-បិតកាត់ក្រចកឲ្យសមគួរដល់វត្ថុនោះ ហើយឲ្យគេទុកក្នុងទីខាង ក្រោមឆត្រ ។ ខ្ញុំឲ្យគេធ្វើផ្ចិតសម្រាប់បក់និងផ្ចិតស្លឹកត្នោត ផ្ចិត ស្លាបក្ងោក ផ្ចិតរោមកន្ទុយចាមរី តម្រងទឹក និងវត្ថុសម្រាប់ទ្រ ប្រេងឲ្យសមគួរដល់វត្ថុនោះ ខ្ញុំឲ្យគេធ្វើបំពង់ម្ជុល ខ្សែអាយោគ វត្ថពន្ធចង្កេះ និងជើងបាត្រដែលធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានញ៉ាំងភេសជ្ជៈទាំងឡាយ ឲ្យពេញក្នុងភាជន៍សម្រាប់បរិ-ភោគ និងក្នុងផ្តិលលោហៈ ហើយទុកក្នុងទីខាងក្រោមឆ័ត្រ ។

វចំ ឧសីរំ លដ្ឋិមធុំ បិប្ផលិមរិចានិ ច
ហរីតកឹ សិង្គិវេរំ សព្វេ ឫបេសិ ភាជនេ ។
ឧទាហនា ទាធុកាយោ អថោ ឧធកបុព្ផនេ
កត្តរធណ្ឌោ សុកតេ ការយឹ តធធុច្ឆវេ ។
ឱសធំ អញ្ជនាបិច សលាកា ធម្មកុត្តរា
កុញ្ចិកា បញ្ចវណ្ណោហិ សិព្វិតេ កុញ្ចិកាឃរេ ។
អាយោគេ ធូមនេត្តេ ច អថោបិ ទីបធារកេ
តុម្ពកេ ច ករណ្ឌេ ច ការយឹ តធធុច្ឆវេ ។
សណ្ឌាសេ បិប្ផលេ ចេវ អថោបិ មលហារិណេ
ភេសជ្ជថវិកេ ចេវ ការយឹ តធធុច្ឆវេ ។
អាសន្ទិយោ បីឋកេ ច បល្លង្កេ ចតុរោមយេ
តធធុច្ឆវេ ការេត្វា ហេដ្ឋាធត្តេ ឋបេសហំ ។
ឧណ្ណាភិសី តុលភិសី អថោបិ បីឋកាភិសី
ពិព្វោហនេ ច សុកតេ ការយឹ តធធុច្ឆវេ ។
កុរុវិន្ទេ មធុសិត្ថេ តេលហត្ថបតាបកំ
សិបេដិផលកំ សុចឹ មញ្ចំ អត្ថរណោធ(១) ច ។

១ ម. សត្ថរកេន ។

ខ្ញុំបានញុំាងភាជន៍ទាំងអស់ឲ្យពេញដោយលំពាន់ ស្បូវភ្លាំង ឈើឯម ដីប្ញី និងម្រេច សម៉ ខ្ញី ។ ខ្ញុំឲ្យគេធ្វើស្បែកជើង ទ្រនាប់ជើង សំពត់សម្រាប់ជូតទឹក និងឈើច្រត់ដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ (ខ្ញុំឲ្យគេធ្វើ) នូវថ្នាំឱសថ ថ្នាំបន្តក់ភ្នែក ចង្កឹះ ធម្មក្រកដ៏ប្រសើរ កូនសោរ និងប្រអប់កូនសោរ ដែលបុគ្គលដេរដោយចេសមានពណ៌ ៥ ។ ខ្ញុំឲ្យគេធ្វើនូវសំពត់អាយោគ ខ្សែ ជើងប្រទីប ល័កចន៍ និងដប ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើនូវចន្ទាស កាំបិតកាត់ក្រចក កន្ធារត្រចៀក និងថង់យាមដាក់ភេសជ្ជៈ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើនូវគ្រែដ៏វិសេស តាំងនិងបល្ល័ង្ក សុទ្ធតែមានជើង ៤ ឲ្យសមគួរដល់វត្ថុនោះ ហើយឲ្យទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំបានឲ្យគេធ្វើនូវពូកញាត់ដោយរោម ពូកញាត់ដោយសំឡី ពូកដេរភ្ជាប់នឹងតាំង និងខ្នើយដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំឲ្យគេធ្វើនូវកុរុវិន្ទៈ គឺខ្សែសម្រាប់ដុសក្អែល ក្រមួនឃ្មុំ ជើងក្រានដុតប្រេងសម្រាប់កម្តៅដៃ និងគ្រែសិវេដិផលកៈដ៏ស្អាត ព្រមទាំងកម្រាល ។

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

សេនាសនេ ចាគបុញ្ញេ សយនាសនទណ្ឌកោ
ទន្តបោណោ ច កថលី សីសលេបនតក្កោ ។
អរណី ផលបីឋេ ច បត្តបិធានថាលកោ
ឧទកស្ស កាជច្ឆុញ្ញ ចុណ្ណកំ វជនាម្ពណំ ។
សម្មុញ្ជនំ ឧទវត្តំ តថា វស្សិកសាដកំ
និសីទនំ កណ្ឌុច្ឆាទី អថ អន្តរវាសកំ ។
ឧត្តរាសង្គសង្ឃាដឹ នត្ថុកំ មុខសោធនំ
ពិលង្គលោណភត្តញ្ច មធុំ ច ទធិបានកំ ។
បុប្ផសិត្ថំ[១] បិលោតិញ្ច មុខបុញ្ឆនសុត្តកំ
ធាតព្វំ នាម យំ អត្ថិ យញ្ច កប្បតិ សត្ថុនោ
សព្វមេតំ សមានេត្វា អានន្ទំ ឧបសង្កមឹ
ឧបសង្កម្ម រាជានំ ជនេតារំ មហាយសំ[២]។
សិរសា អភិវាទេត្វា ឥទំ វចនមព្រវឹ
ឯកតោ ជាតិសំវឌ្ឍា ឧភិន្នំ ឯកតោ យសោ[៣]។

១ ម. ធូមំ សិត្ថំ ។ ២ ម. មហិស្សរំ ។ ៣ ម. មនំ ។

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

ខ្ញុំឲ្យគេធ្វើសេនាសនៈ គ្រឿងជូតជើង ទីដេកទីអង្គុយ ឈើប្រត់ ឈើស្ទន់ ឈើរងជើង និងគ្រឿងក្រអូប សម្រាប់លាបសីសៈ ។ ខ្ញុំឲ្យគេធ្វើដែកភ្លើង តាំងផែនក្តារ គ្របបាត្រ ថាស ប៉ោយសម្រាប់ដងទឹក លម្អិតសម្រាប់ផ្លូត និងស្នូកសម្រាប់ជ្រលក់ ។ (ខ្ញុំបានឲ្យគេធ្វើ) សំពត់ជូតមុខ សំពត់ផ្លូតទឹក សំពត់សម្រាប់ផ្លូតទឹកភ្លៀង និសីទនៈ សំពត់បិទបូស និងស្បង់ ។ ខ្ញុំឲ្យគេធ្វើចីពរ សង្ឃាដី ថ្នាំហិតប្រាសជុសធ្មេញ ទឹកជ្រក់ វត្ថុប្រៃ ទឹកឃ្មុំនិងទឹកដោះជូរ ។ វត្ថុណា ឈ្មោះថាដែលគេគប្បីឲ្យ គឺក្រមួនឃ្មុំ កំណាត់សំពត់កន្សែងជូតមុខ និងបេស ឬវត្ថុណា គួរដល់ព្រះសាស្តា ខ្ញុំក៏ប្រមូលរបស់ទាំងអស់នុ៎ះ ហើយនាំចូលទៅគាល់ព្រះរាជាព្រះនាមអានន្ទ ព្រះអង្គជាអ្នកចម្ងងពួកជន ជាអ្នកមានយសធំ ។ ខ្ញុំក្រាបថ្វាយបង្គំដោយត្បូង រួចក្រាបទូលថា យើងទាំងពីរនាក់ មានជាតិខ្ពង់ខ្ពស់ស្មើគ្នា មានយសចុំច្រើនស្មើគ្នា ។

សាធារណា សុខេ ទុក្ខេ    ឧភោ ច អនុវត្តកា
អត្ថិ ចេតសិកំ ទុក្ខំ    តវាធេយ្យំ អរិន្ទម ។
យទិ សក្កោសិ តំ ទុក្ខំ    វិនោទេយ្យាសិ ខត្តិយ
តវ ទុក្ខំ មម ទុក្ខំ    ឧភិន្នំ ឯកតោ មនំ ។
និដ្ឋិតន្តិ វិជានាសិ    តំ មោចេយ្យ[១] សតេ តុវំ
ជានាហិ ខោ មហារាជ    ទុក្ខំ មេ ទុព្វិនោទយំ ។
ពហុំ សមានោ កង្ខស្សុ    ឯតន្តេ ទុច្ចជំ ជនំ[២]
យាវតា វិជិតេ អត្ថិ    យាវតា មម ជីវិតំ ។
ឯតេហិ យទិ តេ អត្ថោ    ទស្សាមិ អវិកម្បិតោ
កង្ខិតំ ខោ តយា ទេវ    មិច្ឆា តំ ពហុកង្ខិតំ ។
ជានិស្សាមិ តុវំ មង្ខ    សព្វធម្មេ បតិដ្ឋិតំ
អតិពាឡ្ហំ និបីឡេសិ    ទទមានស្ស មេ សតោ ។

១ ម. មមាធេយ្យំ ។ ២ ម. វរំ ។

យើងទាំងពីរនាក់ ជាសាធារណៈ ប្រព្រឹត្តទៅតាមគ្នាក្នុងសុខនិងទុក្ខ បពិត្រព្រះអង្គអ្នកទូន្មានសត្រូវ សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត មានព្រះអង្គជាទីតាំង ។ បពិត្រព្រះបរមក្សត្រ បើព្រះអង្គអាច ក៏សូមបន្ទោបង់សេចក្តីទុក្ខនោះចុះ សេចក្តីទុក្ខរបស់ព្រះអង្គ ក៏ដូចជាទុក្ខរបស់ខ្ញុំ ចិត្តរបស់យើងទាំងពីរនាក់ រមែងមានក្នុងទីដូចគ្នា ។ បើព្រះអង្គជ្រាបស្រេចហើយ ព្រះអង្គគប្បីដោះទុក្ខនោះចេញ បពិត្រមហារាជ សូមព្រះអង្គជ្រាបនូវទុក្ខ ដែលខ្ញុំព្រះអង្គ បន្ទោបង់បានដោយក្រចុះ ។ សូមព្រះអង្គមានព្រះបន្ទូលទៅមើល តើទ្រព្យទាំងប៉ុន្មានក្នុងដែន និងជីវិតទាំងប៉ុន្មានរបស់ខ្ញុំ ទ្រព្យនុ៎ះឯង ព្រះអង្គលះបង់បាន ដោយកម្រឬទេ ។ បើព្រះអង្គមានសេចក្តីត្រូវ-ការដោយទ្រព្យ និងជីវិតនុ៎ះ ព្រះអង្គនឹងថ្វាយដោយឥតញាប់ញ័រ បពិត្រព្រះសម្មតិទេព ព្រះអង្គធ្លាប់មានបន្ទូលនឹងខ្ញុំមកហើយ តែព្រះបន្ទូលនោះ ច្រើនតែខុស ។ ខ្ញុំនឹងដឹងនូវព្រះអង្គដែលបិតនៅ ក្នុងធម៌ទាំងពួងក្នុងថ្ងៃនេះ ព្រះអង្គតែងបៀតបៀនចំពោះខ្ញុំ ដែលជាអ្នកឲ្យទានខ្លាំងពេក ។

១៣៥

### បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ភិន្តេ សល្វបិតេនត្តោ បត្ថិតំ តេ កាថេហិ មេ
ឥច្ឆាមហំ មហារាជ ពុទ្ធសេដ្ឋំ អនុត្តរំ ។
ភោជយិស្សាមិ សម្ពុទ្ធំ វឌ្ឍំ មេ មាហុ ជីវិតំ
អញ្ញំ តេហំ វរំ ទម្មិ អយាចិតោ តថាគតោ ។
អនេយ្យោ កស្សចិ ពុទ្ធោ មណិ ជោតិរសោ យថា
ននុ តេ គដ្ឋិតំ នេវ យាវ ជីវិតមត្តិកំ ។
ជីវិតំ ននមានេន យុត្តំ ជាតុំ តថាគតំ
បឋនីយោ មហាវីរោ អនេយ្យោ កស្សចិ ជិនោ។
ន មេ បដិស្សុតោ ពុទ្ធោ វរស្ស អមិតំ ជនំ
វិនិច្ឆយំ ចាបុណាមិ បុច្ឆិស្សាមិ វិនិច្ឆយេ ។
យថា សណ្ហំ កាថេស្សន្តិ បដិបុច្ឆាម តំ តថា
រញ្ញោ ហត្ថេ គហេត្វាន អគមាសឹ វិនិច្ឆយំ ។

ព្រះអង្គមានប្រយោជន៍អ្វី ដោយការចរចាគ្នា សូមព្រះអង្គប្រាប់ខ្ញុំ នូវហេតុដែលព្រះអង្គប្រាថ្នាចុះ បពិត្រមហារាជ ឯខ្ញុំព្រះអង្គចង់បានព្រះពុទ្ធ ជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ។ ខ្ញុំនឹងញ៉ាំងព្រះសម្ពុទ្ធឲ្យឆាន់ សូមកុំឲ្យជីវិតរបស់ខ្ញុំមានទោសឡើយ ខ្ញុំថ្វាយពរដទៃដល់ព្រះអង្គថា ព្រះតថាគត មិនត្រូវអ្នកណានិមន្តឡើយ ។ ព្រះពុទ្ធដូចជាកែវមណិជោតិរស មិនត្រូវឲ្យដល់អ្នកណាមួយទេ បពិត្រព្រះសម្មតិទេព ក្រែងព្រះអង្គធ្លាប់មានព្រះបន្ទូលហើយថា ជីវិតមានប្រយោជន៍ជាដរាប ។ ព្រះអង្គ កាលឲ្យនូវជីវិត គួរឲ្យព្រះតថាគតដល់ខ្ញុំ ព្រះជិនស្រីជាមហាវីរបុរស ដែលគេត្រូវតែតម្កល់ទុក មិនត្រូវឲ្យដល់បុគ្គលណាមួយឡើយ ។ ព្រះពុទ្ធខ្ញុំមិនទាន់ទទួលទេ សូមព្រះអង្គទទួលទ្រព្យ ដែលរាប់មិនបានចុះ ខ្ញុំព្រះអង្គនឹងដល់នូវការវិនិច្ឆ័យ នឹងសួរក្នុងទីវិនិច្ឆ័យ ។ ពួកតុលាការនឹងពោលនូវពាក្យដ៏ល្អិត យ៉ាងណា ខ្ញុំនឹងសួរតបពាក្យនោះ យ៉ាងនោះ ខ្ញុំចាប់ព្រះហស្តព្រះរាជា ដើរទៅកាន់ទីវិនិច្ឆ័យ ។

បុរតោ អក្ខុនស្សាគំ     ឥធំ វចនមព្រវី

សុណាត្ថុ មេ អក្ខុនស្សា     រាជា វាំ អគាសិ មេ ។

ន កិញ្ចិ បបយិត្វាន     ជីវិតំបិ បរាយឹ

តស្ស មេ វរជិន្ទស្ស     ពុទ្ធសេដ្ឋំ វាំ អហំ ។

សុជិន្នោ ហោតិ មេ ពុទ្ធោ     ជិន្នេជ(១) សំសយំ មម

សុស្សាម តវ វចនំ     ភូមិចាលស្ស រាជិនោ ។

ឧភិន្នំ វចនំ សុត្វា     ជិន្និស្សាមេត្ត សំសយំ

សព្វំ នេវ តយា ជិន្នំ     ឥមស្ស សព្វកាហិតំ ។

ន កិញ្ចិ បបយិត្វាន     ជីវិតំបិ បរាយឹ

កិច្ចប្បត្តោវ ហុត្វាន     យាវជីវមនុត្តរំ ។

ឥមំ សុខុក្ខិតំ ញត្វា     អគាសឹ សព្វកាហិតំ

បរាជយោ តុវំ នេវ     អស្ស នេយ្យោ តថាគតោ ។

១ ម. ភគវា ។

ខ្ញុំបានពោលពាក្យនេះ ចំពោះមុខពួកតុលាការថា សូមពួកអ្នកតុលាការស្តាប់ពាក្យខ្ញុំ ដ្បិត ព្រះរាជាបានប្រទានពរដល់ខ្ញុំ ។ ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិតក៏បរារណាដែរ កាលព្រះរាជាបានប្រទានពរ ដល់ខ្ញុំហើយ ខ្ញុំក៏ទទួលយក នូវព្រះពុទ្ធជាបុគ្គលប្រសើរ ។ ព្រះរាជាបានប្រទានព្រះពុទ្ធល្អហើយ អ្នកទាំងឡាយចូរកាត់ នូវសេចក្តីសង្ស័យរបស់ខ្ញុំ ខ្ញុំនឹងស្តាប់នូវព្រះឱង្ការរបស់ព្រះអង្គ ជាស្តេចរក្សាផែនដី ។ (អ្នកតុលាការពោលថា) យើងស្តាប់ពាក្យរបស់ជនទាំងពីរហើយ នឹងកាត់សេចក្តីសង្ស័យក្នុងរឿងនុ៎ះ ដូចតទៅនេះ បពិត្រព្រះសម្មតិទេព ពរទាំងពួងដែលព្រះអង្គប្រទានហើយ ដល់ឆ្មាំទ្វារនេះ ជាពរដែលគេត្រូវតែកាន់យកទាំងអស់ ។ ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិតក៏បរារណាដែរ ខ្ញុំស៊ូដល់នូវសេចក្តីលំបាក ដរាបដល់អស់ជីវិត ប្រសើរជាង ។ ខ្ញុំដឹងច្បាស់នូវព្រះអង្គនេះដែលដល់នូវទុក្ខក្រៃលែង ហើយបានប្រទានពរ ដែលគេត្រូវតែកាន់យកទាំងអស់ បពិត្រព្រះសម្មតិទេព ព្រះអង្គជាបរាជ័យហើយ គួរតែព្រះរាជានុញ្ញាតឲ្យព្រះតថាគត ដល់ឆ្មាំទ្វារនោះចុះ ។

១៣៧

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ឧភិន្នំ សំសយោ ឆិន្នោ យថា សណ្ឋាម្ហិ តិដ្ឋថ

រាជា តត្ថេវ ឋត្វាន អក្ខាសិ ញាណមុត្តមំ ។

សម្មា មយ្ហំបិ នេយ្យាថ បុន ពុទ្ធំ លភាមហំ

បូរេត្វា តវ សង្កប្បំ ភោជយិត្វា តថាគតំ ។

បុន នេយ្យាសិ សម្ពុទ្ធំ អានន្ទស្ស យសស្សិនោ

អក្ខាសេឡភិរាជេត្វា អានន្ទមបិ ខត្តិយំ ។

តុដ្ឋោ បមុទិតោ ហុត្វា សម្ពុទ្ធំ ឧបសង្កមី

ឧបសង្កម្ម សម្ពុទ្ធំ ឱឃតិណ្ណំ អនាសវំ ។

សិរសា អភិវាទេត្វា ឥទំ វចនមព្រវី

វសីសតសហស្សេហិ អធិវាសេហិ ចក្ខុមា ។

សេចក្ដីសង្ស័យរបស់អ្នកទាំងពីរនាក់ ខ្ញុំកាត់រួចហើយ សូមព្រះអង្គឋិតនៅក្នុងរោងដ៏សមគួរចុះ ។ ព្រះរាជាឋិតនៅក្នុងរោងនោះហើយ ក៏ពោលពាក្យនេះចំពោះពួកតុលាការថា អ្នកទាំងឡាយចូរឲ្យដល់ខ្ញុំ ដោយប្រពៃចុះ ខ្ញុំត្រូវបានព្រះពុទ្ធម្ដងដែរ ខ្ញុំញ៉ាំងសេចក្ដីប្រាថ្នារបស់អ្នកឲ្យពេញហើយ ខ្ញុំសូមនិមន្តព្រះតថាគតឲ្យឆាន់ផង ។ អ្នកតុលាការពោលនឹងខ្ញុំជាអ្នកឆ្មាំទ្វារថា អ្នកចូរថ្វាយបង្គំមហាក្សត្រ ព្រះនាមអានន្ទចំពោះមុខពួកតុលាការ ហើយថ្វាយព្រះសម្ពុទ្ធដល់ព្រះរាជាព្រះនាមអានន្ទ មានយសវិញផង ។ ខ្ញុំក៏មានចិត្តត្រេកអររីករាយ ហើយចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅគាល់ព្រះសម្ពុទ្ធព្រះអង្គជាអ្នកធ្វងនូវឱឃៈ មិនមានអាសវៈហើយ ខ្ញុំក៏បានថ្វាយបង្គំដោយត្បូង ក្រាបបង្គំទូលពាក្យនេះថា បពិត្រព្រះអង្គមានបញ្ញាចក្ខុ សូមព្រះអង្គ ព្រមទាំងភិក្ខុអ្នកសង្រួមឥន្ទ្រិយ ចំនួនមួយសែនរូប ទទួលនិមន្តន៍ ឲ្យទាន ។

ហាសយន្តោ មម ចិត្តំ    និវេសនមុបេហិ មេ
បទុមុត្តរោ លោកវិទូ    អាហុតីនំ បដិគ្គហោ ។
មម សង្កប្បមញ្ញាយ    អធិវាសេសិ ចក្ខុមា
អធិវាសនមញ្ញាយ    អភិវាទិយ សត្ថុនោ ។
ហដ្ឋោ ឧទគ្គចិត្តោហំ    និវេសនមុបាគមឹ
មិត្តាមច្ចេ សមានេត្វា    ឥទំ វចនមព្រវឹ ។
សុទុល្លភោ មយា លទ្ធោ    មណិ ជោតិរសោ យថា
តេន តំ បូជយិស្សាមិ    អប្បមេយ្យោ អនូបមោ ។
អតុលោ អសមោ ធីរោ    ជិនោ អប្បដិបុគ្គលោ
តថាសមសមោ ចេវ    អទុតិយោ នរាសភោ ។
ទុក្ករំ អធិការំ ហិ    ពុទ្ធានុច្ឆវិកំ មយា
នានាបុប្ផេ សមានេត្វា    ករោម បុប្ផមណ្ឌបំ ។

សូមព្រះអង្គញុំាំងចិត្តរបស់ខ្ញុំឲ្យរីករាយ ហើយស្ដេចចូលមកកាន់និវេសន៍របស់ខ្ញុំ ។ ឯព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់មានចក្ខុ ជ្រាបសេចក្ដីត្រិះរិះរបស់ខ្ញុំហើយ ក៏ទទួលនិមន្តន៍ ។ ខ្ញុំដឹងនូវការទទួលនិមន្តន៍ហើយ ទើបថ្វាយបង្គំលាព្រះសាស្ដា ។ ខ្ញុំមានចិត្តត្រេកអរ រីករាយយ៉ាងក្រៃពេក ទើបចូលទៅកាន់និវេសន៍ ប្រមូលពួកមិត្តនិងអាមាត្យ ហើយពោលពាក្យនេះថា ព្រះសម្ពុទ្ធដូចជាកែវមណិជោតិរស ដែលគេបានដោយក្រក្រៃលែង ឥឡូវនេះ ខ្ញុំបានហើយ ខ្ញុំនឹងបូជាព្រះអង្គដោយវត្ថុដូចម្ដេច ព្រោះព្រះជិនស្រីជាអ្នកប្រាជ្ញ ប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម រកបុគ្គលថ្លឹងផងមិនបាន មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបបាន ព្រះអង្គស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើដូចគ្នា ប្រសើរជាងជនឥតមានបុគ្គលជាគម្រប់ពីរ ។ ពិតណាស់ ការកសាងដំសមគួរដល់ព្រះពុទ្ធ យើងធ្វើបានដោយក្រ (ហេតុនោះ) យើងទាំងឡាយ ចូរប្រមូលផ្កាផ្សេង ៗ ធ្វើមណ្ឌបដោយផ្កា ។

១៣៩

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ពុទ្ធានុច្ឆវិកំ ឯតំ សព្វបូជា ករិស្សតិ
ឧប្បលំ បទុមំ វាបិ វស្សិកំ អធិមុត្តកំ ។
ចម្បកំ នាគបុប្ផញ្ច មណ្ឌបំ ការយឹ អហំ
សតាសនសហស្សានិ ឆត្តឆាយាយ បញ្ញបឹ ។
បច្ឆិមំ អាសនំ មយ្ហំ អធិកំ សតមគ្ឃតិ
សតាសនសហស្សានិ ឆត្តឆាយាយ បញ្ញបឹ ។
បដិយាទេត្វា អន្នចានំ កាលំ អារោចយឹ អហំ
អារោចិតម្ហិ កាលម្ហិ បទុមុត្តរោ មហាមុនិ ។
វសីសតសហស្សេហិ និវេសនមុបេសិ មេ
ធារេន្តំ ឧបរិច្ឆត្តំ សុផុល្លបុប្ផមណ្ឌបេ ។
វសីសតសហស្សេហិ និសីទិ បុរិសុត្តមោ
ឆត្តសតសហស្សានិ សតសហស្សមាសនំ ។
កប្បិយំ អនវជ្ជញ្ច បដិគ្គណ្ហាហិ ចក្ខុមា
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ ។

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

បុប្ផជាតទាំះ គឺ ផ្កាឧប្បល ផ្កាឈូក ផ្កាម្លិះរួត ផ្កាវំដួល ជា ផ្កាដ៏សមគួរដល់ព្រះពុទ្ធ នឹងបានឈ្មោះថា ជាគ្រឿងបូជាគ្រប់យ៉ាង ។ ខ្ញុំបានឲ្យគេយកផ្កាចម្បានិងផ្កាខ្ទឹង ធ្វើជាមណ្ឌប ហើយក្រាលអាសនៈមួយសែន ក្នុងម្លប់ឆត្រ ។ អាសនៈរបស់ខ្ញុំ ខាងក្រោយបង្អស់ ដល់នូវតម្លៃ មួយរយកហាបណៈ ជាយ៉ាងក្រៃលែង ខ្ញុំក្រាលអាសនៈមួយសែន ក្នុងម្លប់ឆត្រ ។ ខ្ញុំចាត់ចែងបាយនិងទឹករួចហើយ ទៅក្រាបទូលនូវភត្តកាល កាលដែលខ្ញុំក្រាបទូលភត្តកាលហើយ ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់ស្តេចចូលមក កាន់និវេសនដ្ឋានរបស់ខ្ញុំ ដែលបាំងឆត្រអំពីខាងលើ ក្នុងមណ្ឌបដែលធ្វើអំពីផ្កាវីកដ៏ល្អ (ជាមួយ) នឹងពួកភិក្ខុមួយសែនអង្គ ជាអ្នកសង្រួមឥន្ទ្រិយ ។ ព្រះពុទ្ធជាបុរសឧត្តម (ព្រមទាំង) ពួកភិក្ខុមួយសែនអង្គ ជាអ្នកសង្រួមឥន្ទ្រិយ ក៏គង់នៅ គ្រប់ចំនួនឆត្រមួយសែន និងអាសនៈមួយសែន ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ សូមព្រះអង្គទទួលកប្បិយវត្ថុ ដែលឥតទោស ។ ឯព្រះបទុមុត្តរៈសម្ពុទ្ធ ជ្រាបច្បាស់នូវលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា

មមំ តារេតុកាមោ សោ សម្បជិច្ឆិ មហាមុនិ
ភិក្ខុនោ ឯកមេកស្ស បច្ចេកំ បត្តជាសហំ ។
ជហឹសុ សម្ភតំ បត្តំ លោហបត្តំ អជាយុំ
សត្តរត្តិន្ទិវំ ពុទ្ធោ និសីទិ បុប្ផមណ្ឌបេ ។
ពោធយន្តោ ពហូ សត្តេ ធម្មចក្កំ បវត្តយិ
ធម្មចក្កំ បវត្តេន្តោ ហេដ្ឋតោ បុប្ផមណ្ឌបេ ។
ចុល្លាសីតិសហស្សានំ ធម្មាភិសមយោ អហុ
សត្តមេ ទិវសេ បត្តេ បទុមុត្តរោ មហាមុនិ ។
ឆត្តឆាយាយ និសិន្នោ ឥមា គាថា អភាសថ
អនូនកំ ញាណវរំ យោ មេ ឆាទាសិ មាណវោ ។
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ
ហត្ថី អស្សា រថា បត្តី សេនា ច ចតុរង្គិនី ។
បរិវារេស្សន្តិ តំ[1] និច្ចំ សព្វទានស្សិទំ ផលំ

១ ម. មំ ។

ជាមហាមុនី ព្រះអង្គប្រាថ្នាដើម្បីចម្ងង់ខ្ញុំ ក៏ទ្រង់ទទួលវត្ថុនោះ ខ្ញុំបានប្រគេនបាត្រ ផ្សេងដោយឡែក ដល់ភិក្ខុមួយរូប ៗ ។ ពួកភិក្ខុក៏លះបង់បាត្រ ដែលខ្លួនធ្លាប់មាន ហើយទ្រទ្រង់នូវបាត្រជាវិការៈនៃលោហៈ ។ ព្រះពុទ្ធទ្រង់គង់ក្នុងមណ្ឌប ជាវិការៈនៃផ្កា អស់ ៧ យប់ ៧ ថ្ងៃ ទ្រង់ញុំាងពួកសត្វជាច្រើនឲ្យត្រាស់ដឹង ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ កាលញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ (ក៏ទ្រង់គង់នៅ) ខាងក្រោមមណ្ឌបជាវិការនៃផ្កា ។ ពួកសត្វ ៨ ម៉ឺន ៤ ពាន់ ក៏បានត្រាស់ដឹងមគ្គផល លុះដល់ថ្ងៃជាគម្រប់ ៧ ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ព្រះអង្គគង់នៅក្នុងម្លប់ឆត្រ បានសម្តែងនូវគាថាទាំងនេះថា មាណពណា បានឲ្យទានដ៏ប្រសើរ ជាទានមិនខ្វះខាត ដល់តថាគត តថាគតនឹងសរសើរមាណពនោះ ហេតុនោះ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យរបស់តថាគតកាលសម្តែង ដូចតទៅនេះចុះ សេនាប្រកបដោយអង្គ ៤ គឺ ដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ នឹងចោមរោមនូវមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ យានដំរី

១៤១

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ហត្ថិយានំ អស្សយានំ សិវិកំ សន្ទមានិកំ ។
ឧបដ្ឋិស្សន្តិ តំ[១] និច្ចំ សព្វទានស្សិទំ ផលំ
សដ្ឋី រថសហស្សានិ សព្វាលង្ការភូសិតា ។
បរិវារេស្សន្តិ តំ[១] និច្ចំ សព្វទានស្សិទំ ផលំ
សដ្ឋី តុរិយសហស្សានិ ភេរិយោ សមលង្កតា ។
វជ្ជយិស្សន្តិ តំ[១] និច្ចំ សព្វទានស្សិទំ ផលំ
ឆឡាសីតិសហស្សានិ នារិយោ សមលង្កតា ។
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា
អាឡារមុខា[២] ហសុលា សុសញ្ញា តនុមជ្ឈិមា ។
បរិវារេស្សន្តិ តំ និច្ចំ សព្វទានស្សិទំ ផលំ
តឹសកប្បសហស្សានិ ទេវលោកេ រមិស្សតិ ។
សហស្សក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ទេវលោកេ វសន្តស្ស បុញ្ញកម្មសមង្គិនោ ។

១ ម. មំ ។ ២ អាឡារបម្ហា ។

យានសេះ ត្រៃស្នែង រថទ្រង់គ្រឿង នឹងបម្រើមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ រថ ៦ ម៉ឺនដែលស្អិតស្អាង ដោយគ្រឿងអលង្ការគ្រប់មុខ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ តូរ្យតន្ត្រី ៦ ម៉ឺន និងស្គរដែលគេតាក់តែងល្អ នឹងប្រគំឲ្យមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ ពួកនាងនារី ៨ ម៉ឺន ៦ ពាន់នាក់ ដែលតាត់តែងល្អ មានសំពត់និងគ្រឿងប្រដាប់ដ៏វិចិត្រ ពាក់កណ្ឌលនៃកែវមណី និងកែវមុក្តា មានមុខទូលាយ ស្រស់ស្រាយ មានត្រគាកល្អ មានចង្កេះរៀវ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ មាណពនោះនឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានជាព្រះឥន្ទ្រសោយរាជ្យ ក្នុងទេវលោក មួយពាន់ដង នឹងបានជាស្តេចចក្រពត្តិមួយពាន់ដង នឹងបានសោយប្រទេសរាជ្យ ដ៏ធំទូលាយ ដែលរាប់បានមួយអសង្ខេយ្យកប្ប កាលមាណពនោះនៅក្នុងទេវលោក ជាអ្នកព្រមព្រៀងដោយបុញ្ញកម្ម ។

ទេវលោកាធុបរិយន្តេ　　រតនឆត្តំ ធរិស្សតិ
ឥច្ឆិស្សតិ យទា វយំ　　ឆទនំ ទុស្សបុប្ផំ ។
ឥមស្ស ចិត្តមញ្ញាយ　　និវទ្ធំ ឆាទយិស្សតិ
ទេវលោកា ចវិត្វាន　　សុក្កមូលេន ចោទិតោ ។
បុញ្ញកម្មេន សំយុត្តោ　　ព្រហ្មពន្ធុ ភវិស្សតិ
កប្បសតសហស្សម្ហិ　　ឱក្កាកកុលសម្ភវោ ។
គោតមោ នាម នាមេន　　សត្ថា លោកេ ភវិស្សតិ
សព្វមេតំ អភិញ្ញាយ　　គោតមោ សក្យបុង្គវោ ។
ភិក្ខុសង្ឃេ និសីទិត្វា　　ឯតទគ្គេ ឋបេស្សតិ
បិលិន្ទវច្ឆោ នាមេន　　ហេស្សតិ សត្ថុសាវកោ ។
ទេវានំ អសុរានញ្ច　　គន្ធព្វានញ្ច សក្កតោ
ភិក្ខូនំ ភិក្ខុនីនញ្ច　　គិហីនញ្ច តថេវ សោ ។
បិយោ ហុត្វាន សព្វេសំ　　វិហរិស្សតិ នាសវោ
សតសហស្សេ កតំ កម្មំ　　ផលំ ទស្សេសិមេ ឥធ ។
សុមុត្តោ សរវេគោវ　　កិលេសេ ឈាបយឹ អហំ

ឆត្រវត្ថ៍នឹងបាំង ក្នុងទីបំផុតទេវលោកទៀត មាណពនេះ នឹងប្រាថ្នានូវគ្រឿងបាំង ដែលកើតអំពីសំពត់និងផ្កា ក្នុងកាលណា (ទេវបុត្រ) ដឹងនូវចិត្តរបស់មាណពនេះ នឹងបាំងអស់កាលជានិច្ច (ក្នុងកាលនោះ) ។ មាណពនោះ ច្យុតចាកទេវលោក ត្រូវកុសលមូលដាស់តឿន ជាអ្នកប្រកបដោយបុញ្ញកម្ម នឹងមានផៅសន្តានដ៏ប្រសើរ ។ ក្នុងមួយសែនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ក្នុងលោក ។ ព្រះគោតមសក្យបុង្គវៈ ទ្រង់ជ្រាបហេតុទាំងអស់នុ៎ះហើយ ទ្រង់គង់នៅក្នុងពួកភិក្ខុ ហើយតាំងមាណពនេះក្នុងទីជាឯតទគ្គៈ នឹងបានជាសាវ័ករបស់ព្រះសាស្តា ឈ្មោះបិលិន្ទវច្ឆៈ ។ បិលិន្ទវច្ឆត្ថេរនោះ មានពួកទេវតា អសុរ គន្ធព្វ ភិក្ខុ ភិក្ខុនី និងគ្រហស្ថ ធ្វើសក្ការៈដូចគ្នា បានជាទីស្រឡាញ់នៃជនទាំងពួង ជាអ្នកមិនមានអាសវៈ ។ បុញ្ញកម្មដែលខ្ញុំធ្វើហើយ ក្នុងកប្បទីមួយសែន ឲ្យផលដល់ខ្ញុំក្នុងជាតិនេះ ។ ខ្ញុំរួចស្រឡះហើយ ដូចជាកម្ទាំងកូនសរ ខ្ញុំដុតបំផ្លាញនូវកិលេសទាំងឡាយហើយ

១៤៣

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

អហោ មេ សុកតំ កម្មំ   បុញ្ញក្ខេត្តេ អនុត្តរេ ។
យត្ថ ការំ ការិត្វាន   បត្តោស្មិ អចលំ បទំ
អន្ននកំ ទានវរំ   អទាសិ យោ ហិ មាណវោ។
អាទិបុព្វង្គមោ អាសិ   តស្ស ទានស្សិទំ ផលំ
ឆត្តេ សុកតេ ទត្វាន   សង្ឃេ គណវរុត្តមេ ។
អដ្ឋានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម
សីតំ ឧណ្ហំ ន ជានាមិ   រជោជល្លំ ន លិម្បតិ ។
អនុបទ្ទវោ អនីតិ ច   ហោមិ អបចិតោ សទា
សុខុមច្ឆវិកោ ហោមិ   វិសទំ ហោមិ មានសំ ។
ឆត្តសតសហស្សានិ   ភវេ សំសរតោ មម
សព្វាលង្ការយុត្តានិ   តស្ស កម្មស្ស វាហសា ។
ឥមំ ជាតឹ ឋបេត្វាន   មត្ថកេ ធារយន្តិ មេ
តស្មា ឥមាយ ជាតិយា   នត្ថិ មេ ឆត្តធារណា ។
មម សព្វំ កតំ កម្មំ   វិមុត្តិឆត្តបត្តិយា

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

ឱ! កម្មដែលខ្ញុំធ្វើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ ព្រោះហេតុដែលខ្ញុំធ្វើគ្រឿងសក្ការៈចំពោះបុញ្ញក្ខេត្ត ទើបខ្ញុំដល់នូវអចលបទ គឺព្រះនិព្វាន ។ មាណពណា ជាប្រធានខាងដើម បានឲ្យទានដ៏ប្រសើរមិនខ្វះខាត នេះជាផលនៃទាន របស់មាណពនោះ ។ ព្រោះតែខ្ញុំបានថ្វាយឆត្រ ចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃដ៏ឧត្តម ទើបបាននូវអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំមិនស្គាល់ត្រជាក់ ១ ក្តៅ ១ ផង់ធូលីមិនប្រឡាក់ ១ ខ្ញុំមិនមានឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរពកោតក្រែងសព្វ ៗ កាល ១ ខ្ញុំមានសម្បុរដ៏សុខុម ១ ខ្ញុំមានចិត្តក្លៀវក្លា ១ ។ កាលខ្ញុំអន្ទោលទៅក្នុងភពតូចធំ ឆត្រទាំងមួយសែន ប្រកបដោយគ្រឿងអលង្ការគ្រប់មុខ តែងបាំងលើក្បាលរបស់ខ្ញុំ ព្រោះហេតុនៃបុញ្ញកម្មនោះ វៀរលែងតែជាតិនេះចេញ ព្រោះហេតុនោះ បានជាក្នុងជាតិនេះ ខ្ញុំមិនមានឆត្របាំង តែអំពើទាំងអស់ដែលខ្ញុំធ្វើហើយ នាំឲ្យបាននូវឆត្រគឺវិមុត្តិ ។

ទុស្សានិ សុគតេ ទត្វា   សង្ឃេ គណវរុត្តមេ ។
អដ្ឋានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម
សុវណ្ណវណ្ណោ វិរជោ   សប្បភាសោ បតាបវា ។
សិនិទ្ធំ ហោតិ មេ គត្តំ   ភវេ សំសរតោ មម
ទុស្សសតសហស្សានិ   សេតា បីតា ច លោហិតា ។
ជាយន្តិ មត្ថកេ មយ្ហំ   ទុស្សទានស្សិទំ ផលំ
កោសេយ្យកម្ពលិយានិ   ខោមកប្បាសិកានិ ច ។
សព្វត្ថ បដិលភាមិ   តេសំ និស្សន្ទតោ អហំ
បត្តេ ច សុគតេ ទត្វា   សង្ឃេ គណវរុត្តមេ ។
ទសានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម
សុវណ្ណថាលេ មណិថាលេ   រជតេបិច ថាលកេ ។
លោហិតង្គមយេ ថាលេ   បរិភុញ្ជាមិ សព្វទា
អនុបទ្ទវោ អនីតិ ច   ហោមិ អបចិតោ សទា ។

ព្រោះតែខ្ញុំថ្វាយនូវសំពត់ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានវណ្ណៈដូចមាស ១ប្រាសចាកធូលី ១ ប្រកបដោយពន្លឺ ១ មានតេជះ ១ ខ្លួនរបស់ខ្ញុំជិតស្និទ្ធ ១ កាលខ្ញុំអន្ទោលទៅ ក្នុងភពតូចធំ សំពត់ទាំងមួយសែន ពណ៌ស លឿង និងក្រហម រមែងបាំងលើក្បាលខ្ញុំ ១ នេះជាផលនៃទានសំពត់ ខ្ញុំរមែងបាននូវសំពត់កោសេយ្យពស្ត្រ និងសំពត់កម្ពល ១ បាននូវសំពត់ដែលធ្វើដោយសំបកឈើ និងសំពត់ធ្វើដោយកប្បាស ក្នុងទីទាំងពួង ១ ព្រោះអានិសង្សនៃសំពត់ទាំងឡាយនោះ ។ ព្រោះតែខ្ញុំបានថ្វាយបាត្រ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំរមែងប្រើប្រាស់ ថាសមាស ១ ថាស កែវមណី ១ ថាសប្រាក់ ១ ថាសដែលធ្វើអំពីកែវទទឹម គ្រប់កាលទាំងពួង ១ ខ្ញុំជាអ្នកមិនមានឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរពកោតក្រែងគ្រប់កាល ១

១៤៨

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

លាភី អន្នស្ស បានស្ស　　វត្ថស្ស សយនស្ស ច
ន វិនស្សន្តិ មេ ភោគា　　បិតចិត្តោ ភវាមហំ ។
ធម្មកាមោ សទា ហោមិ　　អប្បក្កោសោ អនាសវោ
ទេវលោកេ មនុស្សេ វា　　អនុពន្ធា ឥមេ គុណា ។
ឆាយា យថាបិ រូបស្ស　　សព្វត្ថ ន ជហន្តិ មំ
ចិត្តពន្ធនសម្ពន្ធា　　សុកតា វាសិយោ ពហូ ។
ទត្វាន ពុទ្ធសេដ្ឋស្ស　　សង្ឃស្ស ច តថេវហំ
អដ្ឋានិសំសេ អនុភោមិ　　កម្មានុច្ឆវិកេ មម ។
សូរោ ហោមិ វិសារី ច　　វេសារជ្ជេសុ បារមី
ធិតិវីរិយវា ហោមិ　　បគ្គហិតមនោ សទា ។
កិលេសច្ឆេទនំ ញាណំ　　សុខុមំ អតុលំ សុចឹ
សព្វត្ថ បដិលភាមិ　　តស្ស និស្សន្ទតោ មម ។

## បិលិន្ទវច្ឆត្ថេរាបទាន ទី ១

ខ្ញុំជាអ្នកបានទូវបាយ ទឹក សំពត់ និងទីដេក ១ ភោគៈទាំង-ឡាយរបស់ខ្ញុំ មិនដែលវិនាសបាត់ ១ ខ្ញុំមានចិត្តខ្ជាប់ខ្ជួន ១ ។ មិនតែប៉ុណ្ណោះ ខ្ញុំជាអ្នកពេញចិត្តនឹងធម៌គ្រប់កាល មិនមានកិលេស មិនមានអាសវៈ គុណធម៌ទាំងនេះ ជាប់តាមហើយក្នុងទេវលោក ទាំងក្នុងមនុស្សលោក ។ គុណធម៌ទាំងឡាយជាប់ដោយចំណងគឺចិត្ត រមែងមិនលះបង់ខ្ញុំក្នុងទីទាំងពួង ដូចស្រមោល មិនលះបង់រូប ។ ព្រោះតែខ្ញុំបានថ្វាយកាំបិតព្រាជាច្រើនដែលខ្ញុំធ្វើល្អហើយ ដល់ព្រះពុទ្ធដ៏ប្រសើរ និងព្រះសង្ឃ ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំជាអ្នកក្លៀវក្លា ១ អង់អាច ១ មានបារមីក្នុងធម៌ជាគ្រឿងក្លៀវក្លា ១ ខ្ញុំមានព្យាយាមខ្ជាប់ខ្ជួន ១ មានចិត្តផ្គងទុកគ្រប់កាល ១ ខ្ញុំរមែងបានទូវញាណជាគ្រឿងកាត់បង់នូវកិ-លេស ១ ញាណដ៏សុខុម ១ ញាណដ៏ស្អាតឥតមានអ្វីប្រៀបស្មើក្នុងទីទាំងពួង ១ ដោយអានិសង្សនៃកាំបិតព្រារបស់ខ្ញុំនោះ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

អកក្កសេ អផរុសេ     អធោតេ សត្ថកេ ពហូ
បសន្នចិត្តោ ទត្វាន     ពុទ្ធេ សង្ឃេ តថេវ ច ។
បញ្ចានិសំសេ អនុភោមិ     កម្មានុច្ឆវិកេ មម
កល្យាណមិត្តំ វីរិយំ     ខន្តិញ្ច មេត្តិសត្ថកំ ។
តណ្ហាសល្លស្ស ឆិន្ទត្វា     បញ្ញាសត្ថំ អនុត្តរំ
វជិរេន សមំ ញាណំ     តេសំ និស្សន្ទតោ លភេ ។
សូចិយោ សុគតេ ទត្វា     សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ     កម្មានុច្ឆវិកេ មម ។
ធមស្សិយោ កង្ខច្ឆេទោ     អភិរូបោ ច ភោគវា
តិក្ខប្បញ្ញោ សទា ហោមិ     សំសរន្តោ ភវាភវេ ។
គម្ភីរំ និបុណំ ឋានំ     អត្ថំ ញាណេន បស្សយឹ
វជិរគ្គសមំ ញាណំ     ហោតិ មេ តមឃាតនំ ។

ព្រោះតែខ្ញុំមានចិត្តជ្រះថ្លា បានថ្វាយកាំបិតជាច្រើន ជាកាំបិត មិនរឹង មិនអាក្រក់ មិនបាច់សំលៀង ចំពោះព្រះពុទ្ធ និង ព្រះសង្ឃ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើ របស់ខ្ញុំ គឺ ខ្ញុំបានកល្យាណមិត្រ ១ សេចក្តីព្យាយាម ១ កាំបិតគឺខន្តី និងមេត្រី ១ កាំបិតគឺប្រាជ្ញាដ៏ប្រសើរ ព្រោះ កាត់នូវសរគឺតណ្ហា ១ ញាណស្មើដោយកែវវជីរ ១ ដោយ អានិសង្សនៃកាំបិតទាំងនោះ ។ ព្រោះតែខ្ញុំបានថ្វាយនូវម្ជុល ទាំងឡាយ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃ ខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើ របស់ខ្ញុំ គឺខ្ញុំគួរគេនមស្ការ អាចកាត់សេចក្តីសង្ស័យ ១ មាន រូបល្អ មានភោគសម្បត្តិ ១ កាលអន្ទោលទៅក្នុងភពតូចធំ ជាអ្នកមានបញ្ញាមុតគ្រប់កាលទាំងពួង ១ ខ្ញុំឃើញនូវអត្ថដ៏ ជ្រាលជ្រៅ និងហេតុដ៏ល្អិតដោយញាណ ១ ញាណរបស់ ខ្ញុំ ស្មើដោយចុងនៃកែវវជីរ សម្រាប់កម្ចាត់នូវងងឹត ១ ។

១៤៧

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

នខច្ឆេទនេ សុកេ ជាតា    សង្ឃ៉េ កណាវុត្តមេ
បញ្ញានិសំសេ អនុភោមិ    កម្មានុច្ឆវិកោ មម ។
ជាសជាសី គវស្សេ ច    ភដកោ ជាដកោ ពហូ
ឆ្គាបិតេ ភត្តកោ ស្វទេ    សព្វត្តេវ លភាមហំ ។
វិជ្ជបនេ សុកេ ជាតា    តាលបណ្ណោ ច សោភណោ
អដ្ឋានិសំសេ អនុភោមិ    កម្មានុច្ឆវិកោ មម ។
សីតំ ឧណ្ហំ ន ជាជាមិ    បរិឡាហោ ន វិជ្ជតិ
ទរថំ ជាភិជាជាមិ    ចិត្តសន្តាបនំ មម ។
រាគគ្គិ ទោសមោហគ្គិ    មានគ្គិ ទិដ្ឋិអគ្គិ ច
សព្វគ្គិ និព្វុតោ មយ្ហំ    តស្ស និស្សន្ទតោ មម ។
មោរហត្ថេ ចាមរិយោ    ជាតា សង្ឃ៉េ កណ្ហាត្តមេ
ឧបសន្តក្កិលេសោហំ    វិហរាមិ អនង្គណោ ។

ព្រោះតែខ្ញុំបានថ្វាយ នូវកាំបិតកាត់ក្រចក ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំបាននូវខ្ញុំប្រុស ខ្ញុំស្រី ១ គោនិងសេះ ១ អ្នករបាំជាអ្នកបម្រើច្រើននាក់ ១ ជាងកំណោរ ១ អ្នកគ្រូជាអ្នកធ្វើបាយ ក្នុងទីទាំងពួង ១ ។ ព្រោះតែខ្ញុំបានថ្វាយផ្ចិតសម្រាប់បក់ និងផ្ចិតស្លឹកត្នោតដ៏ល្អ ចំពោះព្រះសុគត ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនស្គាល់នូវត្រជាក់និងក្តៅ ១ មិនមានសេចក្តីអន្ទះអន្ទែង ១ មិនស្គាល់នូវសេចក្តីក្រវល់ក្រវាយ ជាគ្រឿងញុាំងចិត្តខ្ញុំឲ្យក្តៅ ១ ភ្លើងទាំងពួងរបស់ខ្ញុំ គឺភ្លើងរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ភ្លើង គឺមានះ ១ ភ្លើងគឺទិដ្ឋិ ១ ក៏រលត់អស់ហើយ ដោយអានិសង្សនៃការថ្វាយផ្ចិតរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយផ្ចិតស្លាបក្ងោក និងផ្ចិតចាមរី ចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបជាអ្នកមានកិលេសស្ងប់រម្ងាប់ មិនមានទីទួលគឺកិលេស ។

បរិស្សាវនេ សុកតេ ទត្វា សុកតេ ធម្មកុត្តរេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
សព្វសំ សមតិក្កម្ម ទិព្វំ អាយុំ លភាមហំ
អប្បសយ្ហោ សទា ហោមិ ចោរបច្ចត្ថិកេហិ វា ។
សត្ថេន វា វិសេន វា វិហេសំបិ ន កុព្វតេ
អន្តរា មរណំ នត្ថិ តេសំ និស្សន្ទតោ មម ។
តេលធារេ សុកតេ ទត្វា សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
សុចារុរូបោ សុភទ្ទោ សុសមុគ្គតមានសោ
អវិក្ខេបមនោ ហោមិ សព្វារក្ខេហិ រក្ខិតោ
សុចិឃរេ សុកតេ ទត្វា សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
ចេតោសុខំ កាយសុខំ ឥរិយាបថជំ សុខំ

ព្រោះតែខ្ញុំបានថ្វាយសំពត់តម្រងទឹក និងធម្មក្រក ចំពោះព្រះសុគត ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំកន្លងផុតនូវជនទាំងពួង បាននូវអាយុជាទិព្វ ១ ពួកចោរជាសត្រូវ កំហែងមិនបាន គ្រប់កាលទាំងពួង ១ បុគ្គលមិនហ៊ានធ្វើនូវការបៀតបៀន ដោយគ្រឿងសស្ត្រាវុធ ១ ដោយថ្នាំពិស ១ សេចក្តីស្លាប់ក្នុងចន្លោះមិនមាន ១ ដោយអានិសង្សនៃតម្រងទឹកនិងធម្មក្រកទាំងនោះរបស់ខ្ញុំ ។ ព្រោះតែខ្ញុំ បានថ្វាយវត្ថុសម្រាប់ទ្រប្រេង ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំមានរូបដូចមាស ១ មានវ័យដ៏ល្អ ១ មានចិត្តខ្ពស់ឡើង ដោយល្អ ១ មានចិត្តមិនរវើរវាយ ១ មានគេគ្រប់គ្រងរក្សាហើយ ដោយការរក្សាគ្រប់យ៉ាង ១ ។ ព្រោះតែខ្ញុំបានថ្វាយបំពង់ម្ជុល ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំបាននូវគុណធម៌ទាំងនេះ គឺសុខក្នុងចិត្ត ១ សុខក្នុងកាយ ១ សុខ

១៤៩

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ឥមេ គុណេ បដិលភាមិ   តស្ស និស្សន្ទតោ អហំ ។
អំសវទ្ធេ ធិតេ ទត្វា   សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម ។
សទ្ធម្មេ គាធំ វិន្ទាមិ   សភាមិ ទុតិយំ ភវំ
សព្វត្ថ សុច្ឆវិ ហោមិ   តស្ស និស្សន្ទតោ អហំ ។
កាយពន្ធេ ធិតេ ទត្វា   សង្ឃេ គណវរុត្តមេ
ឆានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម ។
សមាធីសុ ន កម្បាមិ   វសី ហោមិ សមាធិសុ
អភេជ្ជបរិសោ ហោមិ   អាទេយ្យវចនោ សទា ។
ឧបដ្ឋិតស្សតិ ហោមិ   តាសោ មយ្ហំ ន វិជ្ជតិ
ទេវលោកេ មនុស្សេ វា   អនុពន្ធា ឥមេ គុណា ។
អាធារកេ ធិតេ ទត្វា   សង្ឃេ គណវរុត្តមេ
បញ្ញវណ្ណោ ភយាភាវោ   អចលោ ហោមិ កេនចិ ។

កើតអំពីឥរិយាបថ ១ ដោយអានិសង្សនៃបំពង់ម្ជុលនោះ ។ ព្រោះតែខ្ញុំបានថ្វាយសំពត់អង្សៈ ចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំតែងបាននូវព្រះសទ្ធម្មដ៏មាំមួន ១ រលឹកឃើញនូវភពជាតម្រប់ពីរ ១ ជាអ្នកមានសម្បុរល្អក្នុងទីទាំង-ពួង ១ ដោយអានិសង្សនៃអង្សៈនោះ ។ ព្រោះតែខ្ញុំបានថ្វាយវត្ថពន្ធចង្កេះ ចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំមិនញាប់ញ័រក្នុងសមាធិទាំងឡាយ ១ ជាអ្នកស្ទាត់ក្នុងសមាធិទាំងឡាយ ១ ជាអ្នកមានបរិស័ទមិនបែកខ្ញែក ១ ពាក្យសម្ដីខ្ញុំ គេតែងជឿស្ដាប់សព្វកាល ១ ជាអ្នកមានសតិតាំងនៅមាំ ១ ខ្ញុំមិនមានសេចក្ដីតក់ស្លុត ១ គុណធម៌ទាំងនេះ ជាប់តាមខ្ញុំ ទៅក្នុងទេវលោក និងមនុស្សលោក ។ ព្រោះតែខ្ញុំបានថ្វាយ នូវដើងបាត្រមានពណ៌ ៥ ចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបជាអ្នកមិនមានភ័យ មិនញាប់ញ័រ ដោយហេតុណាមួយ ។

យេកេចិ មេ សុតា ជម្មា   សតិញ្ញាណប្បពោជនា
ជតា[1] មេ ន វិនស្សន្តិ   ភវន្តិ សុវិនិច្ឆិតា ។

ភាជនេ បរិភោគេ ច   ទត្វា ពុទ្ធេ គណុត្តមេ
តីណានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម ។

សោវណ្ណមយេ មណិមយេ   អថោបិ ផលិកាមយេ
លោហិតង្គមយេ ចេវ   លភាមិ ភាជនេ អហំ ។

ភរិយា ទាសទាសី ច   ហត្ថិស្សរថបត្តិកេ
ឥត្ថី បតិព្វតា ចេវ   បរិភោគានិ សព្វទា ។

វិជ្ជា មន្តបទេ ចេវ   វិវិធេ អាគមេ ពហូ
សព្វសិប្បំ និសាមេមិ   បរិភោគានិ សព្វទា ។

ថាលកេ សុគតេ ទត្វា   សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម ។

១ ម. បិតា ។

ធម៌ទាំងឡាយណាមួយ ជាគ្រឿងដាស់តឿននូវសតិនិងបញ្ញា ដែលខ្ញុំបានចេះដឹងហើយ ធម៌ទាំងនោះ ខ្ញុំចងចាំទុកមិនភ្លេចឡើយ ធម៌ទាំងនោះ ខ្ញុំវិនិច្ឆ័យល្អហើយ ។ ព្រោះតែខ្ញុំបានថ្វាយភាជន៍ជាគ្រឿងប្រើប្រាស់ ចំពោះព្រះពុទ្ធនិងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំបាននូវភាជន៍ទាំងឡាយ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ឬជាវិការៈនៃកែវទទឹម ១ បាននូវភរិយា ខ្ញុំប្រុស ខ្ញុំស្រី ដំរី សេះ រថ ពលថ្មើរជើង ស្ត្រីជាអ្នកមានវត្តដល់ប្តី និងគ្រឿងប្រើប្រាស់ គ្រប់កាលទាំងពួង ១ ខ្ញុំពិចារណានូវវិជ្ជា បទនៃមន្តអាគមផ្សេង ៗ ជាច្រើន និងសិល្បៈទាំងពួង ជាគ្រឿងប្រើប្រាស់គ្រប់កាលទាំងពួង ១ ។ ព្រោះតែខ្ញុំបានថ្វាយ នូវថាស ចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ ។

១៨១

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

សោវណ្ណមយេ មណិមយេ អថោបិ ផលិកាមយេ
លោហិតង្គមយេ ចេវ លភាមិ ថាលកេ អហំ ។
អស្សដ្ឋកេ ផលមយេ អថោ ថោក្ខុរបត្តកេ
មធុបានកសង្ខេ ច លភាមិ ថាលកេ អហំ ។
វត្តេ គុណេ បដិបត្តី អាចារកិរិយាសុ ច
ឥមេ គុណេ បដិលភេ តស្ស និស្សន្ទតោ អហំ ។
ភេសជ្ជំ សុគតេ ទត្វា សង្ឃេ គណវរុត្តមេ
ទសានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
អាយុវា ពលវា ធីរោ វណ្ណវា យសវា សុខី
អនុបទ្ទវោ អនីតិ ច ហោមិ អបចិតោ សទា
ន មេ បិយវិយោគត្ថិ[១] តស្ស និស្សន្ទតោ មម[២]។
ឧបាហនេ ជិនេ ទត្វា សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។

១ ម. បិយវិយោគោត្ថិ ។ ២ ម. អហំ ។

គឺខ្ញុំបានថាសជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ឬជាវិការៈនៃកែវទទឹម ១ បានទូវថាសឈ្មោះអស្សផ្ទក: ដែលធ្វើអំពីផែនក្តារ មានសណ្ឋានដូចស្នឹកឈូក ឬមានសណ្ឋានដូចសង្ខ័សម្រាប់ដាក់ទឹកឃ្មុំ ១ បានទូវគុណ-ធម៌ទាំងនេះ គឺវត្ត គុណ សេចក្តីប្រតិបត្តិក្នុងអាចារៈនិងកិរិយា ១ ដោយអានិសង្សនៃការថ្វាយទូវថាសនោះ ។ ព្រោះតែខ្ញុំបានថ្វាយទូវភេសជ្ជៈ ចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំជាអ្នកមានអាយុវែង ១ មានកម្លាំង ១ មានប្រាជ្ញា ១ មានពណ៌សម្បុរ ១ មានយស ១ មានសេចក្តីសុខ ១ មិនមានឧបទ្រព ១ មិនមានចង្រៃ ១ ត្រូវគេគោរពកោតក្រែង សព្វកាល ១ ខ្ញុំមិនមានការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ១ ដោយអានិសង្សនៃការថ្វាយភេសជ្ជៈរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយទូវស្បែកជើងចំពោះព្រះជិនស្រីនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ ។

ហត្ថិយានំ អស្សយានំ  សិវិកំ សន្ទមានិកំ
សដ្ឋី រថសហស្សានិ  បរិវារេន្តិ មំ សទា ។
មណិមយា តម្ពមយា  សោណ្ណរជតបាទុកា
និព្វត្តន្តិ បទុទ្ធារេ  ភវេ សំសរតោ មម ។
និយាមំ បដិជាវន្តិ  អាចារគុណសោធនំ
ឥមេ គុណេ បដិលភេ  តស្ស និស្សន្ទតោ អហំ ។
បាទុកេ សុគតេ ទត្វា  សង្ឃេ គណវរុត្តមេ
ឥទ្ធិបាទុកមារុយ្ហ  វិហរាមិ យទិច្ឆកំ ។
មុខបុញ្ឆនំ សុគតេ ទត្វា  សង្ឃេ គណវរុត្តមេ[១]
បញ្ចានិសំសេ អនុភោមិ  កម្មានុច្ឆវិកេ មម ។
សុវណ្ណវណ្ណោ វិរជោ  សប្បភាសោ បតាបវា
សិនិទ្ធំ ហោតិ មេ គត្តំ  រជោជល្លំ ន លិម្បតិ ។
ឥមេ គុណេ បដិលភេ  តស្ស និស្សន្ទតោ អហំ

---
ម. ឧទកបុញ្ឆនចោឡេ ទត្វា ពុទ្ធេ គណុត្តមេតិ ឥមេ បាឋា ទិស្សន្តិ ។

គឺ យានដំរី យានសេះ គ្រែស្នែងនិងរថទ្រង់គ្រឿង រថ ៦ ម៉ឺន តែងចោមរោមខ្ញុំ គ្រប់កាលទាំងពួង ១ កាលខ្ញុំអន្ទោលទៅក្នុងភព ទ្រនាប់ជើងមាសប្រាក់ ជាវិការៈកែវមណី ជាវិការៈកែវក្រហម តែងកើតឡើងគ្រប់ជំហាន ១ (ទ្រនាប់ជើងទាំងនោះ) រមែងនាំខ្ញុំឲ្យស្ទុះទៅកាន់សម្មត្តនិយាម ជាគ្រឿងជម្រះនូវអាចារ និងគុណធម៌ ១ ខ្ញុំរមែងបាន នូវគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយស្បែកជើងនោះ ។ ព្រោះតែខ្ញុំបានថ្វាយទ្រនាប់ជើង ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានឡើងកាន់ទ្រនាប់ជើងគឺឫទ្ធិសមតាមប្រាថ្នា ។ ព្រោះតែខ្ញុំបានថ្វាយកន្សែងជូតមុខចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំមានវណ្ណៈដូចមាស ១ ប្រាសចាកធូលី ១ ប្រកបដោយរស្មី ១ មានតេជះ ១ ខ្លួនខ្ញុំជិតស្និទ្ធផង់ធូលីមិនប្រឡាក់ ១ ។ ខ្ញុំបាននូវគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយកន្សែងជូតមុខនោះ ។

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

កត្តរទណ្ឌោ សុគតេ ទត្វា   សង្ឃេ គណវរុត្តមេ ។
បញ្ចានិសំសេ[១] អនុភោមិ   កម្មានុច្ឆវិកេ មម
បុត្តា មយ្ហំ ពហូ ហោន្តិ   តាសោ មយ្ហំ ន វិជ្ជតិ ។
អប្បសយ្ហោ សទា ហោមិ   សព្វារក្ខេហិ រក្ខិតោ
ខលិតម្បិ ន ជានាមិ   អភន្តំ មានសំ មម ។
ឱសធំ អញ្ជនំ ទត្វា   សង្ឃេ គណវរុត្តមេ[២]
អដ្ឋានិសំសេ អនុភោមិ   កម្មានុច្ឆវិកេ មម ។
វិសាលនយនោ ហោមិ   សេតបីតោ ច លោហិតោ
អនាវិលបសន្នក្ខោ   សព្វរោគវិវជ្ជិតោ ។
លភាមិ ទិព្វនយនំ   បញ្ញាចក្ខុំ អនុត្តរំ
ឥមេ គុណេ បដិលភេ   តស្ស និស្សន្ទតោ អហំ ។
កុញ្ចិកេ សុគតេ ទត្វា   សង្ឃេ គណវរុត្តមេ
ធម្មទ្វារវិវរណំ   លភាមិ ញាណកុញ្ចិកំ ។

---

១ ម. ឆានិសំសេ ។ ២ ម. ពុទ្ធេ សង្ឃេ គណុត្តមេតិ ទិស្សន្តិ ។

ព្រោះតែខ្ញុំបានថ្វាយឈើច្រត់ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានកូនច្រើន ១ ខ្ញុំមិនតក់ស្លុត ១ ខ្ញុំ គេមិនកំហែងបានគ្រប់កាល ត្រូវគេថែរក្សា ដោយគ្រឿងរក្សាគ្រប់យ៉ាង ១ ខ្ញុំមិនស្គាល់សេចក្តីភ្លាំងភ្លាត់ ១ ចិត្តរបស់ខ្ញុំមិនវេះវ័ន្តប្រឡំ ១ ។ ព្រោះតែខ្ញុំបានថ្វាយឱសថបន្តក់ភ្នែក ចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានភ្នែកទូលាយ ១ មានសម្បុរស ១ លឿង ១ ក្រហម ១ មានភ្នែកថ្លាមិនល្អក់ ១ ជាអ្នកវៀរចាករោគគ្រប់យ៉ាង ១ ខ្ញុំបានចក្ខុទិព្វ ១ បញ្ញា-ចក្ខុដ៏ប្រសើរ ១ ខ្ញុំបានគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយនូវឱសថបន្តក់ភ្នែកនោះ ។ ព្រោះតែខ្ញុំបានថ្វាយកូនសោ ចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានកូនសោគឺញាណ សម្រាប់បើកទ្វារព្រះធម៌ ។

កុញ្ជិកានំ ឃរេ ទត្វា សង្ឃេ គណវរុត្តមេ[១]
ទ្វានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
អប្បកោធោ អនុបាយាសោ សំសរន្តោ ភវេ អហំ
អាយោគេ សុកតេ ទត្វា សង្ឃេ គណវរុត្តមេ ។
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម
សមាធីសុ ន កម្បាមិ វសី ហោមិ សមាធិសុ ។
អភេជ្ជបរិសោ ហោមិ អាទេយ្យវចនោ សទា
ជាយតិ ភោគសម្បត្តិ ភវេ សំសរតោ មម ។
ធូមនេត្តេ ជិនេ[២] ទត្វា សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
សតិ មេ ឧជុកា ហោតិ សុសម្ពន្ធា ច ន្ហារុយោ[៣]
លភាមិ ទិព្វសយនំ[៤] តស្ស និស្សន្ទតោ អហំ ។
ទីបធានេ[៥] ជិនេ ទត្វា សង្ឃេ គណវរុត្តមេ
តីណានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។

---

១ ម. សុគតេ ។ ២ ម. ន្ហារវោ ។ ៣ ម. ទិព្វនយនំ ។ ៥ ម. ទីបដ្ឋាបេ ។

ព្រោះតែខ្ញុំបានថ្វាយប្រអប់កូនសោ ចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំកាលត្រាច់ទៅក្នុងភព ជាអ្នកមិនមានសេចក្តីក្រោធ ១ មិនមានសេចក្តីតានតឹង ១ ។ ព្រោះតែខ្ញុំបានថ្វាយខ្សែអាយោគ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំមិនញាប់ញ័រក្នុងសមាធិទាំងឡាយ ១ ជាអ្នកស្ទាត់ក្នុងសមាធិ ១ ខ្ញុំមានបរិស័ទមិនបែកខ្ញែក ១ មានពាក្យគួរអ្នកផងកាន់យក គ្រប់កាលទាំងពួង ១ ភោគសម្បត្តិរមែងកើតឡើងដល់ខ្ញុំ កាលអន្ទោលទៅក្នុងភព ១ ។ ព្រោះតែខ្ញុំបានថ្វាយខ្សៀ ចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានសតិត្រង់ ១ សរសៃទាំងឡាយសង្វារបានចងដោយល្អ ១ ខ្ញុំបានទីដេកទិព្យ ១ ដោយអានិសង្សនៃការថ្វាយខ្សៀនោះ ។ ព្រោះតែខ្ញុំបានថ្វាយប្រទីបចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៣ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ

១៨៤

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ជាតិមា អង្គសម្បន្នោ បញ្ញវា ពុទ្ធសម្មតោ
ឥមេ គុណេ បដិលភេ តស្ស និស្សន្ទតោ មម ។
តុម្ពកេ ច ករណ្ឌេ ច ទត្វា ពុទ្ធេ គណុត្តមេ
ទសានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
តជា កុត្តោ[១] សុខសមង្គី មហាយសវា តថា គតិ
វិភត្តិកត្តោ[២] សុខុមាលោ សព្វីតិបរិវជ្ជិតោ ។
វិបុលេ ច គុណេ លាភី សម្មានចលជា មម
សុវិរជ្ជិតឧព្វេកោ តុម្ពកេ ច ករណ្ឌកេ ។
លភាមិ ចតុរោ វណ្ណេ ហត្ថិស្សរតណានិ ច
តានិ មេ ន វិនស្សន្តិ តុម្ពការេ ឥទំ ផលំ ។
ហត្ថលីលង្គកេ ទត្វា ពុទ្ធេ សង្ឃេ គណុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។

---

១ ម.សង្គុត្តោ ។ ២ ម. វិបត្តិវិគត្តោ ។

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

គឺ ខ្ញុំជាអ្នកមានជាតិខ្ពង់ខ្ពស់ ១ បរិបូណ៌ដោយអវយវៈ ១ មានប្រាជ្ញាដែលព្រះពុទ្ធសន្មតហើយ ១ ខ្ញុំបានគុណធម៌ទាំងនេះ ដោយអានិសង្សនៃការថ្វាយប្រទីបរបស់ខ្ញុំនោះ ។ ព្រោះតែខ្ញុំបានថ្វាយល័ក្ខចាន់និងជប ចំពោះព្រះពុទ្ធ និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺក្នុងកាលនោះ ខ្ញុំត្រូវគេគ្រប់គ្រង ១ ប្រកបដោយសេចក្តីសុខ ១ មានយសបរិវារច្រើន ១ មានដំណើរដ៏ប្រសើរ ១ មានខ្លួនដែលគេគួរគប់រកដោយវិសេស ១ ចម្រើនសេចក្តីសុខ ១ វៀរស្រឡះចាកចង្រៃគ្រប់យ៉ាង ១ ជាអ្នកបាននូវគុណធម៌ដ៏ទូលំទូលាយ ដោយការកម្រើក គឺសេចក្តីរាប់អានរបស់ខ្ញុំ ១ មានសេចក្តីតក់ស្លុតវៀរស្រឡះហើយ ១ ខ្ញុំបានល័ក្ខចាន់ ជបមានពណ៌ ៤ និងដំរីកែវសេះកែវ វត្ថុទាំងនោះ របស់ខ្ញុំ រមែងមិនវិនាស ១ នេះជាផល ក្នុងការថ្វាយល័ក្ខចាន់ ។ ព្រោះតែខ្ញុំបានថ្វាយហត្ថលីលង្គ ចំពោះព្រះពុទ្ធ និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបមានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ

សព្វលក្ខណសម្បន្នោ អាយុបញ្ញាសមាហិតោ
សព្វាយាសវិនិមុត្តោ កាយោ មេ ហោតិ សព្វទា ។

តនុជារេ[១] សុនិសិតេ សង្ឃេ ទត្វាន បិប្ផលេ[២]
កិលេសកន្តនំ ញាណំ លភាមិ អតុលំ សុចឹ ។

សណ្ឌាសេ សុគតេ ទត្វា សង្ឃេ គណវរុត្តមេ
កិលេសលុញ្ចនំ ញាណំ លភាមិ អតុលំ សុចឹ ។

ទត្ថកេ សុគតេ ទត្វា សង្ឃេ គណវរុត្តមេ
អដ្ឋានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។

សទ្ធា សីលំ ហិរិញ្ចាបិ អថ ឱត្តប្បិយំ គុណំ
សុតំ ចាគញ្ច ខន្តី ច បញ្ញា មេ អដ្ឋមំ គុណំ ។

បីឋកេ សុគតេ ទត្វា សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។

១ ម. អនុធារេ ។ ២ ម. វប្ផលេ ។

គឺកាយរបស់ខ្ញុំ បរិបូណ៌ដោយលក្ខណៈទាំងពួង ១ ប្រកប ដោយអាយុវែង ១ ដោយបញ្ញា ១ ចិត្តតម្កល់មាំ ១ ផុត ស្រឡះចាកសេចក្ដីលំបាកគ្រប់យ៉ាងសព្វកាល ១ ។ ព្រោះ តែខ្ញុំបានថ្វាយកន្ត្រៃមានមុខស្ដើង ដែលគេសំលៀងយ៉ាងល្អ ចំពោះព្រះសង្ឃ ទើបបានញាណដែលថ្មីងមិនបាន ដ៏ស្អាត សម្រាប់កាត់ផ្ដាច់នូវកិលេស ។ ព្រោះតែខ្ញុំបានថ្វាយចន្ទាស ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាននូវញាណ ដែលថ្មីងមិនបាន ដ៏ស្អាតសម្រាប់ដក នូវកិលេស ។ ព្រោះតែខ្ញុំបានថ្វាយនូវថ្នាំហិត ចំពោះព្រះ សុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបាន អានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺសទ្ធា ១ សីល ១ ហិរិ ១ គុណគឺឱត្តប្បៈ ១ សុតៈ ១ ចាគៈ ១ ខន្តី ១ គុណគឺបញ្ញារបស់ខ្ញុំជាគម្រប់ ៨ ។ ព្រោះតែខ្ញុំបានថ្វាយ តាំងចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ឧច្ចេ កុលេ បជាយាមិ មហាភោគោ ភវាមហំ
សព្វេ មំ អបចាយន្តិ កិត្តិ អព្ភុគ្គតា មម ។
កប្បសតសហស្សានិ បល្លង្កា ចតុរស្សកា
បរិវារេន្តិ មំ និច្ចំ សំវិភាគរតោ អហំ ។
ភិសិយោ សុគតេ ទត្វា សង្ឃេ គណវរុត្តមេ
ជាតិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
សមសុគត្តោបចិតោ មុទុកោ ចារុទស្សនោ
លភាមិ ញាណបវរំ ភិសិទានស្សិទំ ផលំ ។
តូលិកា វិកតិកាយោ កដិស្សា ចិត្តកា ពហូ
វរបោត្ថកេ កម្ពលេ ច លភាមិ វិវិធេ អហំ ។

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

គឺ ខ្ញុំកើតក្នុងត្រកូលខ្ពស់ ជាអ្នកមានភោគៈច្រើន ១ ជនទាំង-ពួងតែងគោរពកោតក្រែងចំពោះខ្ញុំ ១ កិត្តិសព្ទរបស់ខ្ញុំ ខ្ចរខ្ចាយទៅ ១ បល្ល័ង្កមានជ្រុង ៤ តែងចោមរោមខ្ញុំជានិច្ចអស់មួយសែនកប្ប ១ ខ្ញុំជាអ្នកត្រេកអរក្នុងការចែករំលែក ១ ។ ព្រោះតែខ្ញុំបានថ្វាយពូក ចំពោះព្រះសុគត និងព្រះសង្ឃជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំជាអ្នកមានចិត្តស្ងប់ មានខ្លួនសមល្អ ត្រូវគេគោរពកោតក្រែង ១ មានចិត្តទន់ មានកាយល្អ ប្រកបដោយគ្រឿងប្រដាប់មានពណ៌ដូចមាស ១ បាននូវញាណដ៏ប្រសើរ ១ នេះជាផល នៃការថ្វាយពូក ខ្ញុំបាននូវកម្រាលផ្សេង ៗ ជាច្រើនបែប គឺតូលិកៈ (កម្រាលដែលធ្វើដោយគ) វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វហើយវិចិត្រដោយរូបសត្វដ៏ប្លែក ៗ) កដិស្សៈ (កម្រាលដែលប៉ាក់ឌិន ចម្រុះមាសនិងសូត្រ ហើយចាក់ស្រេះដោយរតនៈ) ចិត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វសាហាវ) វរបោត្ថកៈ (កម្រាលដែលធ្វើដោយសំពត់សម្បកឈើដ៏ប្រសើរ) កម្ពលៈ (កម្រាលដែលធ្វើដោយរោមសត្វ) ១

១៤៨

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ចាវរកោ ច មុទុកោ មុទុកាជិនវេណិយោ
លភាមិ វីជដ្ឋានេ ភិសិទានស្សិទំ ផលំ ។
យតោ សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
អតុច្ឆោ ឈានមញ្ចោម្ហិ ភិសិទានស្សិទំ ផលំ ។
ពិព្វោហានេ ជិនេ ទត្វា សង្ឃេ គណវរុត្តមេ
ឆានិសំសេ អនុភោមិ កម្មានុច្ឆវិកោ មម ។
ឧណ្ណិកោ បទុមកោ ច អថោ លោហិតចន្ទនេ
ពិព្វោហានេ ឧចាតេមិ ឧត្តមដ្ឋំ សទា មម ។
អដ្ឋង្គិកោ មគ្គវរេ សាមញ្ញេ ចតុរោ ផលេ
តេសុ ញាណំ ឧប្បាទេត្វា វិហរេ និច្ចកាលិកំ ។
ទានេ ទមេ សញ្ញមេ ច អប្បមញ្ញាសុ រូបិសុ
តេសុ ញាណំ ឧប្បាទេត្វា វិហរេ សព្វកាលិកំ ។
វត្តេ គុណេ ច បដិមេ អាចារកិរិយាសុ ច
តេសុ ញាណំ ឧប្បាទេត្វា វិហរេ សព្វទា អហំ ។

ខ្ញុំបានកម្រាលទាំងឡាយ គឺ បាវារកៈដ៏ទន់ អជិនបវេណី (កម្រាលដែលធ្វើដោយស្បែកខ្លាឃ្មុំ) ដ៏ទន់ក្នុងទីផ្សេង ៗ ១ នេះជាផលនៃការថ្វាយពូក កាលណា ខ្ញុំរលឹកឃើញនូវខ្លួន កាលណាខ្ញុំបានដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនមែនជាបុគ្គលទទេ គឺជាអ្នកមានគ្រែ គឺឈាន ក្នុងកាលនោះ ១ នេះជាផលនៃការថ្វាយពូក ។ ព្រោះតែខ្ញុំបានថ្វាយខ្នើយ ចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៦ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំរមែងដាក់ក្បាលខ្ញុំលើខ្នើយរោមសត្វកែះ ខ្នើយផ្កាឈូក ឬខ្នើយចន្ទន៍ក្រហម គ្រប់កាលទាំងពួង ១ ខ្ញុំញុំាងញាណឲ្យកើតឡើង ក្នុងធម៌ទាំងនោះ គឺ មគ្គមានអង្គ ៨ ដ៏ប្រសើរ និងសាមញ្ញផល ៤ អស់កាលជានិច្ច ១ ខ្ញុំញុំាងញាណឲ្យកើតឡើង ក្នុងធម៌ទាំងនោះ គឺ ទាន ទមៈ សញ្ញមៈ និងអប្បមញ្ញា មានរូបជាអារម្មណ៍ គ្រប់កាលទាំងពួង ១ ខ្ញុំញុំាងញាណឲ្យកើតឡើង ក្នុងធម៌ទាំងនោះ គឺវត្ត គុណការប្រៀបផ្ទឹម ក្នុងអាចារៈនិងកិរិយា គ្រប់កាលទាំងពួង ១

១៤៩

## បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ចង្កមេ វា បធានេ វា　　វីរិយេ ពោធិបក្ខិកេ
តេសុ ញាណំ ឧប្បាទេត្វា　　វិហរាមិ យថិច្ឆកំ ។
សីលំ សមាធិ បញ្ញា ច　　វិមុត្តិ ច អនុត្តរា
តេសុ ញាណំ ឧប្បាទេត្វា　　វិហរាមិ សុខំ អហំ ។
ផលបីឋេ ឋិតេ ទត្វា　　សង្ឃេ គណវរុត្តមេ
ទ្វានិសំសេ អនុភោមិ　　កម្មានុច្ឆវិកេ មម ។
សោណ្ណមយេ មណិមយេ　　ទន្តសារមយេ ពហូ
បល្លង្កសេដ្ឋេ វិន្ទាមិ　　ផលបីឋស្សិទំ ផលំ ។
ចាទបីឋេ ឋិតេ ទត្វា　　សង្ឃេ គណវរុត្តមេ
ទ្វានិសំសេ អនុភោមិ　　កម្មានុច្ឆវិកេ មម ។
លភាមិ ពហុកេ យានេ　　ចាទបីឋស្សិទំ ផលំ
ទាសីទាសា ច ភរិយា　　យេ ចញ្ញេ អនុជីវិនោ
សម្មា បរិចរន្តេវ　　ចាទបីឋស្សិទំ ផលំ ។

បិលិន្ទវច្ឆត្ថេរាបទាន ទី ១

ខ្ញុំញ៉ាំងញាណឲ្យកើតឡើង ក្នុងធម៌ទាំងនោះ គឺ ការចង្រ្កម ការប្រឹងប្រែង ការព្យាយាម និងពោធិបក្ខិយធម៌ ហើយនៅតាមប្រាថ្នា ១ ខ្ញុំញ៉ាំងញាណឲ្យកើតឡើង ក្នុងធម៌ទាំងនោះ គឺ សីល សមាធិ បញ្ញាវិមុត្តិដ៏ប្រសើរ ហើយនៅជាសុខ ១ ។ ព្រោះតែខ្ញុំបានថ្វាយតាំងផែនក្តារ ចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំបានបល្ល័ង្កដ៏ប្រសើរ ដែលសម្រេចដោយមាស សម្រេចដោយកែវមណី ១ សម្រេចដោយភ្លុកនិងខ្លឹមជាច្រើន ១ នេះជាផលនៃតាំងផែនក្តារ ។ ព្រោះតែខ្ញុំបានថ្វាយតាំងមានជើង ចំពោះព្រះជិនស្រី និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ២ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំបានយានដ៏ច្រើន នេះជាផល នៃតាំងមានជើង ១ ជនទាំងឡាយដទៃ ដែលជាអ្នករស់នៅដោយសារ គឺ ទាសី ទាសៈ ភរិយា ជនទាំងនោះ តែងបម្រើនូវខ្ញុំ ដោយប្រពៃ នេះជាផល នៃតាំងមានជើង ១ ។

តេលអព្ភញ្ជនេ ទត្វា សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
អព្យាធិតា រូបវតា ខិប្បំ ធម្មនិសន្តិតា
លាភិតា អន្នបានស្ស អាយុំ បញ្ចមកំ មម ។
សប្បិតេលញ្ច ទត្វាន សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
ថាមវា រូបសម្បន្នោ បហដ្ឋតនុជោ សទា
អព្យាធិ ច សទា ហោមិ សប្បិតេលស្សិទំ ផលំ ។
មុខធោវនំ ទត្វាន សង្ឃេ គណវរុត្តមេ
បញ្ចានិសំសេ អនុភោមិ កម្មានុច្ឆវិកេ មម ។
វិសុទ្ធកណ្ឋោ មធុស្សរោ កាសសាសវិវជ្ជិតោ
ឧប្បលគន្ធោ មុខតោ ឧបវាយតិ មេ សទា ។

ព្រោះតែខ្ញុំបានថ្វាយប្រេងសម្រាប់លាប ចំពោះព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ភាពជាអ្នកមិនមានព្យាធិ ១ ភាពជាអ្នកមានរូបល្អ ១ ភាពជាអ្នកពិចារណាធម៌ដោយរហ័ស ១ ភាពជាអ្នកបានបាយនិងទឹក ១ ខ្ញុំមានអាយុវែងជាគម្រប់ ៥ ។ ព្រោះតែខ្ញុំ បានថ្វាយទឹកដោះថ្លានិងប្រេង ចំពោះព្រះសង្ឃ ដែលជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺ ខ្ញុំជាបុគ្គលមានកម្លាំង ១ បរិបូណ៌ដោយរូប ១ ជាអ្នករីករាយ ១ ជាអ្នកមានកូនសព្វ ៗ កាល ១ ជាអ្នកមិនមានជំងឺ គ្រប់កាលទាំងពួង ១ នេះជាផលនៃទឹកដោះថ្លា និងប្រេង ។ ព្រោះតែខ្ញុំបានថ្វាយទឹកលុបមុខ ចំពោះព្រះសង្ឃ ដែលជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៥ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំជាបុគ្គលមានកដ៏ល្អ ១ មានសំឡេងពីរោះ ១ គ្មានរោគក្អក ១ គ្មានរោគហឺត ១ មានក្លិនផ្កាឧប្បល ផ្សាយចេញអំពីមាត់ខ្ញុំ គ្រប់កាលទាំងពួង ១ ។

១៦១

បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ

ទធឹ ទត្វាន សម្បុណ្ណំ　　ពុទ្ធេ សង្ឃេ គណុត្តមេ
ភុញ្ជាមិ អមតំ ភត្តំ　　វរំ កាយគតាសតឹ ។
វណ្ណគន្ធរសោបេតំ　　មធុំ ទត្វា ជិនេ គណេ ។
អនូបមំ អនញ្ញម្បិ　　លភាមិ វិមុត្តិរសំ
យថាភូតំ រសំ ទត្វា　　ពុទ្ធេ សង្ឃេ គណុត្តមេ ។
ចតុរោ ផលេ អនុភោមិ　　កម្មានុច្ឆវិកេ មម
អន្នបានញ្ច ទត្វាន　　ពុទ្ធេ សង្ឃេ គណុត្តមេ ។
ទសានិសំសេ អនុភោមិ　　កម្មានុច្ឆវិកេ មម
អាយុវា ពលវា ធីរោ　　វណ្ណវា យសវា សុខី ។
លាភី អន្នស្ស បានស្ស　　សូរោ បញ្ញាណវា តថា
ឥមេ គុណេ បដិលភេ　　សំសរន្តោ ភវេ អហំ ។
ធូបំ ទត្វាន សុគតេ　　សង្ឃេ គណវរុត្តមេ
ទសានិសំសេ អនុភោមិ　　កម្មានុច្ឆវិកេ មម ។
សុគន្ធទេហោ យសវា　　សីឃបញ្ញោ ច កិត្តិមា

ព្រោះតែខ្ញុំបានថ្វាយទឹកដោះជូរដ៏បរិបូណ៌ ចំពោះព្រះពុទ្ធ និង ព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបរិភោគភត្តគឺអមតៈ និងកាយគតាសតិដ៏ប្រសើរ ។ ព្រោះតែខ្ញុំបានថ្វាយទឹកឃ្មុំ ដែលប្រកបដោយពណ៌ ក្លិន និងរស ចំពោះព្រះជិនស្រី និងគណៈសង្ឃ ទើបបានវិមុត្តិរស រកអ្វីផ្ទឹមគ្មាន មិនមែន ជាធម៌ផ្តេសផ្តាសឡើយ ។ ព្រោះតែខ្ញុំបានថ្វាយភោជនមាន រសគួរតាមបំណង ចំពោះព្រះពុទ្ធ និងព្រះសង្ឃ ជាគណៈ សង្ឃខ្ពង់ខ្ពស់ ទើបបានផល ៤ ដ៏សមគួរដល់អំពើរបស់ ខ្ញុំ ។ ព្រោះតែខ្ញុំបានថ្វាយបាយនិងទឹក ចំពោះព្រះពុទ្ធ និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានអាយុវែង ១ មានកម្លាំង ១ ជាអ្នកប្រាជ្ញ ១ មានពណ៌សម្បុរល្អ ១ មាន យស ១ មានសេចក្តីសុខ ១ ជាអ្នកបានបាយ ១ ទឹក ១ ក្លៀវក្លា ១ មានប្រាជ្ញា ១ កាលខ្ញុំអន្ទោលទៅក្នុងភព តែងបានគុណធម៌ទាំងនេះឯង ។ ព្រោះតែខ្ញុំបានថ្វាយធូបក្រ-អូប ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃខ្ពង់ខ្ពស់ ទើបបានអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានរាងកាយក្រអូប ១ មានយស ១ មានប្រាជ្ញារហ័ស ១

តិក្ខបញ្ញោ ភូរិបញ្ញោ ហាសគម្ភីរបញ្ញវា ។
វេបុល្លជវនសប្បញ្ញោ សំសរន្តោ ភវាភវេ
តស្សេវ វាហសាធានិ បត្តោ សន្តិសុខំ សិវំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បិលិន្ទវច្ឆោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បិលិន្ទវច្ឆត្ថេរស្ស អបទានំ សមត្តំ ។

មានកេរ្តិ៍ឈ្មោះ ១ មានប្រាជ្ញាមុត ១ មានប្រាជ្ញាដូចផែនដី ១ មានប្រាជ្ញាស្រស់ស្រាយ ១ មានប្រាជ្ញាជ្រៅ ១ មានប្រាជ្ញាទូលាយ ១ មានប្រាជ្ញាស្ទុះលឿនទៅ ១ ខ្ញុំកាលអន្ទោលទៅក្នុងភពតូច ភពធំ ជាអ្នកដល់នូវព្រះនិព្វាន ជាសន្តិសុខ ក្នុងកាលឥឡូវនេះ ព្រោះហេតុនៃការថ្វាយធូបក្រអូបនោះឯង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់នូវចំណង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិលិន្ទវច្ឆត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បិលិន្ទវច្ឆត្ថេរាបទាន ។

១៦៣

# ទុតិយំ សេលត្ថេរាបទានំ

[៩២] នគរេ ហំសវតិយា     វីថិស្សាមី អហោសហំ
មម ញាតី សមានេត្វា     ឥទំ វចនមព្រវី ។
ពុទ្ធោ លោកេ សមុប្បន្នោ     បុញ្ញក្ខេត្តោ អនុត្តរោ
អាសិ សោ សព្វលោកស្ស     អាហុតីនំ បដិគ្គហោ ។
ខត្តិយា នេគមា ចេវ     មហាសាលា ច ព្រាហ្មណា
បសន្នចិត្តា សុមនា     បូគធម្មំ អកំសុ តេ ។
ហត្ថារោហា អនីកត្ថា     រថិកា បត្តិការកា
បសន្នចិត្តា សុមនា     បូគធម្មំ អកំសុ តេ ។
ឧគ្គា ច រាជបុត្តា ច     វេសិយានា ច ព្រាហ្មណា
បសន្នចិត្តា សុមនា     បូគធម្មំ អកំសុ តេ ។
អាឡារិកា ច សូឡា[១] ច     ន្ហាបកា មាលការកា
បសន្នចិត្តា សុមនា     បូគធម្មំ អកំសុ តេ ។
រជកា បេសកា ច     តុន្នវាយា ច ន្ហាបិកា
បសន្នចិត្តា សុមនា     បូគធម្មំ អកំសុ តេ ។

១ ម. អាឡារិកា កប្បកា ច ។

# សេលត្ថេរាបទាន ទី ២

[៩២] ខ្ញុំជាម្ចាស់ថ្នល់ នៅក្នុងនគរហង្សវតី ប្រមូលពួកញាតិរបស់ខ្ញុំមក ហើយពោលពាក្យនេះថា ព្រះពុទ្ធជាបុញ្ញក្ខេត្តដ៏ប្រសើរ កើតហើយក្នុងលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា របស់សត្វលោកទាំងពួង ។ ពួកក្សត្រ ពួកអ្នកនិគម និងពួកព្រាហ្មណមហាសាល មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកឧគ្គជន (ម្តាយជាសូទ្រៈ ឪពុកជាក្សត្រ) ពួករាជបុត្រ ពួកវេស្សៈ និងពួកព្រាហ្មណ៍ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកដាំស្ល អ្នកគ្រួ អ្នកកាត់សក់ និងអ្នកធ្វើកម្រងផ្កា មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងជ្រលក់ ជាងតម្បាញ ជាងដេរប៉ាក់ និងស្រីអ្នកកាត់សក់ មានចិត្តជ្រះ-ថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។

ឧសុការា ភមការា ចម្មការា ច តច្ឆកា
បសន្នចិត្តា សុមនា បូជយិំសុ តទា ជិនំ ។
កម្មារា សោណ្ណការា ច តិបុលោហការា តថា
បសន្នចិត្តា សុមនា បូជយិំសុ តទា ជិនំ ។
ភតកា ចេដកា ចេវ ទាសកម្មករា ពហូ
យថា សកេន ថាមេន បូជយិំសុ តទា ជិនំ ។
ឧទហារា កដ្ឋហារា កស្សកា តិណហារកា
យថា សកេន ថាមេន បូជយិំសុ តទា ជិនំ ។
បុប្ផិកា មាលិកា ចេវ បណ្ណិកា ផលហារកា
យថា សកេន ថាមេន បូជយិំសុ តទា ជិនំ ។
គណិកា កុម្ភទាសី ច បូវិកា មច្ឆិកាបិច
យថា សកេន ថាមេន បូជយិំសុ តទា ជិនំ ។
ឯតេ សព្វេ សមាគន្ត្វា គណពន្ធាវ ឯកតោ
អធិការំ ករិស្សាម បុញ្ញក្ខេត្តេ អនុត្តរេ ។

ពួកជាងធ្វើកូនសរ ជាងក្រឡឹង ជាងធ្វើស្បែក និងជាងចាំង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងដែក ពួកជាងមាស ជាងសំណនិងលោហៈ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកស៊ីឈ្នួល ពួកអ្នកកាន់ទង់សំពត់ និងពួកទាសកម្មករជាច្រើន ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកដងទឹក ពួកអ្នករកឧស ពួកអ្នកភ្ជួររាស់ ពួកអ្នកនាំស្មៅ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកបេះផ្កា អ្នកក្រងផ្កា អ្នកលក់បន្លែ និងអ្នកនាំផ្លែឈើ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ស្រីពេស្យា នាងកុម្ភទាសី ស្រីអ្នកលក់នំ និងអ្នកនេសាទត្រី ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ជនទាំងអស់នុ៎ះឯង មកប្រជុំគ្នា ចងគ្នាជាពួក ក្នុងទីមួយ (ហើយពោលថា) យើងទាំងឡាយ នឹងធ្វើនូវការកសាង ចំពោះព្រះពុទ្ធ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។

១៦៤

## ទុតិយំ សេលត្ថេរាបទានំ

តេ មេ សុត្វាន វចនំ	គណំ ពន្ធឹសុ តាវទេ
ឧបដ្ឋានសាលំ សុកតំ	ភិក្ខុសង្ឃស្ស ការយុំ ។
និដ្ឋាបេត្វាន តំ សាលំ	ឧទគ្គោ តុដ្ឋមានសោ
បរេតោ តេហិ សព្វេហិ	សម្ពុទ្ធំ ឧបសង្កមឹ ។
ឧបសង្កម្ម សម្ពុទ្ធំ	លោកនាថំ នរាសភំ
វន្ទិត្វា សត្ថុនោ បាទេ	ឥទំ វចនមព្រវឹ ។
ឥមេ តីណិសតា វីរ	បុរិសា ឯកតោ គណា
ឧបដ្ឋានសាលំ សុកតំ	និយ្យាទេន្តិ តវ មុនិ ។
ភិក្ខុសង្ឃស្ស បុរតោ	សម្បដិច្ឆតុ ចក្ខុមា
តិណ្ណំ សតានំ[១] បុរតោ	ឥមា គាថា អភាសថ ។
តិសតាបិ ច ជេដ្ឋោ ច	អនុវត្តឹសុ ឯកតោ
សម្បត្តី ហិ ករិត្វាន	សព្វេ អនុភវិស្សថ ។

១ ម. តីណិ សតានិ ។

សេលត្ថេរាបទាន ទី ២

ជនទាំងនោះ ស្តាប់ពាក្យខ្ញុំហើយ ក៏ចងពួកក្នុងខណៈនោះ បានឲ្យពួកជាងធ្វើឧបដ្ឋានសាលា ដែលធ្វើដោយល្អ ថ្វាយព្រះភិក្ខុសង្ឃ ។ ខ្ញុំធ្វើសាលានោះរួចហើយ ក៏មានចិត្តរីករាយ មានចិត្តត្រេកអរ មានពួកជនទាំងអស់នោះហែហមចូលទៅគាល់ព្រះសម្ពុទ្ធ ។ លុះចូលទៅគាល់ព្រះសម្ពុទ្ធ ព្រះអង្គជាទីពឹងនៃលោក ប្រសើរជាងជន ហើយថ្វាយបង្គំព្រះបាទាព្រះសាស្តា រួចពោលនូវពាក្យនេះថា បពិត្រព្រះមុនី ជាវីរបុរស ពួកបុរស ៣០០ នាក់នេះ ជាពួកតែមួយ វេរថ្វាយឧបដ្ឋានសាលា ដែលធ្វើយ៉ាងល្អ ចំពោះព្រះសង្ឃ សូមព្រះអង្គមានបញ្ញាចក្ខុទទួល (នូវសាលា) ចំពោះមុខភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែង នូវគាថាទាំងឡាយនេះ ចំពោះមុខបុរសទាំង ៣០០ នាក់ថា ពួកបុរស ៣០០ នាក់ និងបុរសជាធំ ប្រព្រឹត្តត្រូវគ្នាតែបែបមួយ ដ្បិតពួកអ្នកទាំងអស់គ្នា ធ្វើអំពើនេះហើយ នឹងបានទទួលសម្បត្តិសុខ ។

១៦៦



បច្ឆិមេ ភវសម្បត្តេ　　សីតិភាវមនុត្តរំ
អជរំ អមរំ ខេមំ[១]　　និព្វានំ បស្សយិស្សថ ។
ឯវំ ពុទ្ធោ វិយាកាសិ　　សព្វញ្ញុតមនុត្តរោ
ពុទ្ធស្ស វចនំ សុត្វា　　សោមនស្សម្បវេទយឹ ។
តឹសកប្បសហស្សានិ　　ទេវលោកេ រមឹ អហំ
ទេវាធិបោ បញ្ចសតំ　　ទេវរជ្ជមការយឹ ។
សហស្សក្ខត្តុំ រាជា ច　　ចក្កវត្តិ អហោសហំ
បទេសរជ្ជំ វិបុលំ　　គណនាតោ អសង្ខិយំ[២] ។
ឥធ មានុសកេ រជ្ជេ　　បរិសា ហោន្តិ ពន្ធវា
បច្ឆិមេ ភវសម្បត្តេ　　វាសេដ្ឋោ នាម ព្រាហ្មណោ ។
អសីតិកោដិនិចយោ　　តស្ស បុត្តោ អហោសហំ
សេលោ ឥតិ មម នាមំ　　ឆឡង្គេ បារមឹ គតោ ។
ជង្ឃាវិហារំ វិចរំ　　សសិស្សេហិ បុរក្ខតោ
ជដាភារភរិតំបិ　　កេណិយំ នាម តាបសំ ។
បដិយត្តាហុតឹ ទិស្វា　　ឥទំ វចនមព្រវឹ
អាវាហោ វា វិវាហោ វា　　រាជា វា តេ និមន្តិតោ ។

---

១ ម. អមតិ សន្តំ ។ ២ ម. ទេវរជ្ជំ ករោន្តស្ស មហាទេវា អវិន្ទសុំ ឥតិ ឥមេ បាឋា ទិស្សន្តិ ។

លុះដល់បច្ឆិមភព អ្នកទាំងឡាយ នឹងឃើញច្បាស់ព្រះនិព្វាន មានភាពដ៏ត្រជាក់ត្រជុំ ជាគុណជាតដ៏ប្រសើរ ឥតចាស់ ឥតស្លាប់ ជាទីក្សេមក្សាន្ត ។ ព្រះសព្វញ្ញុពុទ្ធជាបុគ្គលប្រសើរ បានព្យាករយ៉ាងនេះ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកាហើយ ក៏ទទួលនូវសេចក្តីសោមនស្ស ។ ខ្ញុំរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប ខ្ញុំជាធំជាងទេវតា សោយទេវរាជ្យ អស់ ៥០០ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង បានសោយបទេសរាជ្យដ៏ទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ ពួកបរិស័ទបានមកជាផៅពង្ស ក្នុងរាជ្យជារបស់មនុស្សនេះ លុះដល់បច្ឆិមភព មានព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ សន្សំទ្រព្យទុកបាន ៨០ កោដិ ។ ខ្ញុំក៏បានជាកូន របស់វាសេដ្ឋព្រាហ្មណ៍នោះ ពាក្យថាសេលព្រាហ្មណ៍ ជាឈ្មោះរបស់ខ្ញុំ ៗ ជាអ្នកដល់នូវបារមី ក្នុងឆឡង្គទាន ។ កាលខ្ញុំដើរទៅកាន់ទីសម្រាកស្នង ពួកសិស្សរបស់ខ្លួនចោមរោម ខ្ញុំឃើញគ្រឿងបូជាដែលគេចាត់ចែង ក៏ពោលពាក្យនេះ នឹងកេនិយតាបស ដែលពេញដោយភារៈគឺផ្នួងសក់ថា លោកធ្វើអាវាហមង្គល ឬវិវាហមង្គល ឬក៏លោកអញ្ជើញព្រះរាជាមក ។

១៦៧

dutiyaṃ selattherapadānaṃ

ទុតិយំ សេលត្ថេរាបទានំ

អាហុតឹ យិដ្ឋុកាមោហំ ព្រាហ្មណោ ទេវសម្មតេ
ន និមន្តេមិ រាជានំ អាហុតិ មេ ន វិជ្ជតិ ។
ន ចត្ថិ មយ្ហមាវាហោ វិវាហោ មេ ន វិជ្ជតិ
សក្យានំ នន្ទិជននោ សេដ្ឋោ លោកេ សទេវកេ ។
សព្វលោកហិតត្ថាសិ សព្វសត្តសុខាវហោ
សោ មេ និមន្តិតោ អជ្ជ តស្សេតំ បដិយាទនំ ។
តិម្ពរុសកវណ្ណាភោ អប្បមេយ្យោ អនូបមោ
រូបេនាសទិសោ ពុទ្ធោ ស្វាតនាយ និមន្តិតោ ។
ឧក្កាមុខបហដ្ឋោ ច ខទិរង្គារសន្និភោ
វិជ្ជូបមោ មហាវីរោ សោ មេ ជាថោ(១) និមន្តិតោ ។

១ ម. ពុទ្ធោ ។

## សេលត្ថេរាបទាន ទី ២

(កេនិយតាបសតបថា) ខ្ញុំមានប្រាថ្នាបូជានូវគ្រឿងបូជា ចំ-ពោះព្រាហ្មណ៍ដែលទេវតាសន្មតហើយ ខ្ញុំមិនមែនអញ្ជើញព្រះរាជាទេ គ្រឿងបូជា មិនមានដើម្បីខ្ញុំទេ ។ អាវាហមង្គលរបស់ខ្ញុំក៏មិនមាន ទាំងវិវាហមង្គលរបស់ខ្ញុំក៏មិនមានដែរ ព្រះពុទ្ធព្រះអង្គទ្រង់ញ៉ាំងសេចក្តីរីករាយ របស់ពួកសក្យៈឲ្យកើតឡើង ជាបុគ្គលប្រសើរក្នុងលោក ព្រមទាំងទេវលោក ។ ព្រះពុទ្ធជាបុគ្គលមានប្រយោជន៍ និងសេចក្តីចម្រើនដល់សត្វលោកទាំងពួង នាំមកនូវសេចក្តីសុខដល់សព្វសត្វ ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយ ក្នុងថ្ងៃនេះ ការចាត់ចែងនុ៎ះ ដើម្បីព្រះសាស្តានុ៎ះទេតើ ។ ព្រះពុទ្ធទ្រង់មានពន្លឺនៃពណ៌ដូចផ្លៃទន្ទាប់ទុំ មានប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹមមិនមានបុគ្គលស្មើដោយរូប ខ្ញុំបាននិមន្តហើយ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះពុទ្ធជាទីពឹងនោះ ព្រះអង្គរីករាយដូចមាត់បាវមាសផង់ ប្រាកដស្មើដោយរងើកភ្លើងគគីរផង ជាមហាវីរបុរស ឧបមាដូចផ្ទេកបន្ទោរ ខ្ញុំបាននិមន្តហើយ ។

បព្វតគ្គេ យថា អគ្គិ[១] បុណ្ណមាយេវ ចន្ទិមា
ជប្បត្តិវណ្ណសង្កាសោ សោ មេ ពុទ្ធោ និមន្តិតោ ។
អសម្ភីតោ ភយាតីតោ ភវន្តករណោ មុនិ
សីហូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
កុសលោ ពុទ្ធធម្មេសុ អប្បសយ្ហោ បរេហិ សោ
នាគូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
សទ្ធម្មចារកុសលោ[២] ពុទ្ធនាគោ អសាទិសោ
ឧសភូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
អនន្តវណ្ណោ អមិតយសោ វិចិត្តសព្វលក្ខណោ
សក្កូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
វសិ គណី បតាបី ច តេជសី ច ទុរាសទោ
ព្រហ្មូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។

---

១ ម. អច្ចិ ។ ២ ម. សទ្ធម្មចារកុសលោ ។

ព្រះពុទ្ធនោះ ដូចជាភ្លើងលើកំពូលភ្នំ ឬដូចព្រះចន្ទ្រក្នុងថ្ងៃពេញបូណ៌មី ពុំនោះសោត ប្រាកដស្មើពណ៌ភ្លើងដែលឆេះព្រៃបបុស ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ មិនតក់ស្លុត មានភ័យកន្ទង់ផុតហើយ ធ្វើនូវទីបំផុតនៃភព ជាមហាវីរបុរស ឧបមាដូចសីហៈ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកឈ្លាសវៃ ក្នុងធម៌របស់ព្រះពុទ្ធទាំងឡាយ ដែលពួកបុគ្គលដទៃកំហែងមិនបាន ជាមហាវីរបុរស ឧបមាដូចដំរី ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់ឈ្លាសវៃក្នុងត្រើយនៃព្រះសទ្ធម្ម ជាព្រះពុទ្ធនាគ មិនមានបុគ្គលស្មើ ជាមហាវីរបុរស ឧបមាដូចគោឧសភ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ មានគុណឥតមានទីបំផុត មានយសរាប់មិនបាន មានលក្ខណៈទាំងអស់ដ៏វិចិត្រ ជាមហាវីរបុរស ឧបមាដូចព្រះឥន្ទ្រ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់ស្ទាត់ផង មានពួកផង មានអំណាចផង មានតេជះផង គេបៀតបៀនមិនបានផង ជាមហាវីរបុរស ឧបមាដូចព្រហ្ម ខ្ញុំបាននិមន្តហើយ ។

១៦៩

ទុតិយំ សេលត្ថេរាបទានំ

មហាត្តធម្មោ[១] ទសពលោ    ពលាតិពលបារគូ
ធរណូបមោ មហាវីរោ    សោ មេ ពុទ្ធោ និមន្តិតោ ។
សីលធីតិសមាធិញ្ញោ    ធម្មវិញ្ញាណខោភិតោ
ឧទធូបមោ មហាវីរោ    សោ មេ ពុទ្ធោ និមន្តិតោ ។
ទុរាសទោ ទុប្បសហោ    អចលោ ឧគ្គតោ ព្រហ្មា
នេរូបមោ មហាវីរោ    សោ មេ ពុទ្ធោ និមន្តិតោ ។
អនន្តញ្ញាណោ អសមោ    អតុលោ អគ្គតំ គតោ
គគនូបមោ មហាវីរោ    សោ មេ ពុទ្ធោ និមន្តិតោ ។

បណ្ណរសមំ ភាណវារំ ។

បតិដ្ឋា ភយភីតានំ    តាណោ សរណគាមិនំ
អស្សាសកោ មហាវីរោ    សោ មេ ពុទ្ធោ និមន្តិតោ ។

---

១ ម. បត្តធម្មោ ។

## សេលត្ថេរាបទាន ទី ២

ព្រះពុទ្ធនោះ ព្រះអង្គមានធម៌ដ៏ប្រសើរលើស មានកម្លាំង ១០ ប្រការ ដល់នូវត្រើយនៃកម្លាំងតូច-ធំ ជាមហាវីរបុរស ឧបមាដូចផែនដី ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គកុះករដោយសីល និងសេចក្តីព្យាយាម ទ្រង់ញ៉ាំងធម្មវិញ្ញាណឲ្យរំជួល ជាមហាវីរបុរស ឧបមាដូចសមុទ្រ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ គេបៀតបៀនមិនបាន គេគ្របសង្កត់បានដោយក្រ ជាបុគ្គលមិនញាប់ញ័រ ខ្ពង់ខ្ពស់ប្រសើរ ជាមហាវីរបុរស ឧបមាដូចភ្នំសិនេរុ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ទ្រង់មានញាណរកទីបំផុតគ្មាន ឥតមានបុគ្គលស្មើ រកបុគ្គលប្រឹងស្មើមិនមាន ដល់នូវភាពជាបុគ្គលប្រសើរ ជាមហាវីរបុរស មានឧបមាដូចមេឃ ខ្ញុំបាននិមន្តហើយ ។

ចប់ ភាណវារ ទី ១៥ ។

ព្រះពុទ្ធនោះ ព្រះអង្គជាទីពឹងរបស់ពួកសត្វដែលមានភ័យភិត ជាទីពំនាក់នៃពួកសត្វដែលដល់នូវសរណៈ ជាមហាវីរ-បុរស ញ៉ាំងសត្វឲ្យស្រស់ស្រាយ ខ្ញុំបាននិមន្តហើយ ។

អាសយោ ពុទ្ធិមន្តានំ   បុញ្ញក្ខេត្តំ សុខេសិនំ
រតនាករោ មហាវីរោ   សោ មេ ពុទ្ធោ និមន្តិតោ ។
អស្សាសកោ វេទករោ   សាមញ្ញផលទាយកោ
មេឃូបមោ មហាវីរោ   សោ មេ ពុទ្ធោ និមន្តិតោ ។
លោកេ សមុស្សិតោ វីរោ   សព្វតមវិនោទនោ[១]
សុរិយូបមោ មហាវីរោ   សោ មេ ពុទ្ធោ និមន្តិតោ ។
អារម្មណវិមុត្តីសុ   សភាវទស្សកោ មុនិ
ចន្ទូបមោ មហាវីរោ   សោ មេ ពុទ្ធោ និមន្តិតោ ។
ពុទ្ធោ សមុស្សិតោ លោកេ   លក្ខណេហិ អលង្កតោ
អប្បមេយ្យោ មហាវីរោ   សោ មេ ពុទ្ធោ និមន្តិតោ ។
យស្ស ញាណំ អប្បមេយ្យំ   សីលំ យស្ស អនូបមំ
វិមុត្តិ អសទិសា យស្ស   សោ មេ ពុទ្ធោ និមន្តិតោ ។

---

១ ម. លោកចក្ខុ មហាតេជោ សព្វន្តមំ វិនោទនោតិ ទិស្សន្តិ ។

ព្រះពុទ្ធនោះ ព្រះអង្គជាទីអាស្រ័យ នៃពួកបុគ្គលមានប្រាជ្ញា ជាបុញ្ញក្ខេត្តរបស់ពួកជនអ្នកស្វែងរកសុខ ព្រះអង្គជាអណ្តូង នៃរតនវត្ថុ ជាមហាវីរបុរស ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គញុំាំងសត្វឲ្យស្រស់ស្រាយ ធ្វើឲ្យទៅជាទេវតា ទ្រង់ឲ្យនូវសាមញ្ញផល ជាមហាវីរបុរស ឧបមាដូចមេឃ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ជាវីរបុរស ផុសឡើងហើយក្នុងលោក ទ្រង់បន្ទោបង់នូវងងឹតទាំងពួង ជាមហាវីរបុរស ឧបមាដូចព្រះអាទិត្យ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់បង្ហាញនូវសេចក្តីពិតក្នុងអារម្មណ៍និងវិមុត្តិទាំងឡាយ ជាមហាវីរបុរស ឧបមាដូចព្រះចន្ទ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គផុសឡើងហើយក្នុងលោក ប្រដាប់ហើយដោយលក្ខណៈទាំងឡាយ ជាមហាវីរបុរស មិនមានប្រមាណ ខ្ញុំបាននិមន្តហើយ ។ ញាណរបស់ព្រះពុទ្ធណា មិនមានប្រមាណ សីលរបស់ព្រះពុទ្ធណា រកសេចក្តីប្រដូចគ្មាន វិមុត្តិរបស់ព្រះពុទ្ធណា រកអ្វីស្មើគ្មាន ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយ ។

១៧១

## ទុតិយំ សេលត្ថេរាបទានំ

យស្ស ធីតិ អសទិសា ថាមោ យស្ស អចិន្តិយោ
យស្ស បរក្កមោ សេដ្ឋោ សោ មេ ពុទ្ធោ និមន្តិតោ ។
រាគោ ទោសោ ច មោហោ ច វិសា សព្វេ សមូហតា
អគទូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
កិលេសព្យាធិ[១] ពហុទុក្ខា ឱសធីវ វិនោទកោ[២]
វិជ្ជូបមោ មហាវីរោ សោ មេ ពុទ្ធោ និមន្តិតោ ។
ពុទ្ធោតិ ឃោសំ វទេសិ ឃោសោ មេ សោ សុទុល្លភោ
ពុទ្ធោតិ ឃោសនំ សុត្វា បីតិ មេ ឧបបជ្ជថ ។
អព្ភន្តរំ អគណ្ហន្តំ បីតិ មេ ពហិ និច្ឆរេ
សោហំ បីតិមនោ សន្តោ ឥទំ វចនមព្រវី ។

---

១ ម. ក្លេសព្យាធិ ។ ២ ម. សព្វំ តមំ វិនោទនោ ។

សេលត្ថេរាបទាន ទី ២

សេចក្តីព្យាយាម របស់ព្រះពុទ្ធណា ឥតមានអ្វីស្មើ កម្លាំង របស់ព្រះពុទ្ធណា ដែលបុគ្គលគិតមិនឃើញ សេចក្តីប្រឹង-ប្រែងរបស់ព្រះពុទ្ធណា ជាឧបាយដ៏ប្រសើរ ព្រះពុទ្ធនោះ ខ្ញុំបាននិមន្តហើយ ។ ពិសទាំងពួង គឺរាគៈ ទោសៈ មោហៈ ដែលព្រះពុទ្ធអង្គណា គាស់រំលើងហើយ ព្រះពុទ្ធអង្គនោះ ជាមហាវីរបុរស មានឧបមាដូចឱសថ ខ្ញុំបាននិមន្តហើយ ។ ព្រះពុទ្ធនោះ ដូចបុគ្គលមានឱសថ ព្រះអង្គជាអ្នកបន្ទោបង់នូវ ព្យាធិគឺកិលេស ដែលជាទុក្ខច្រើនប្រការ ជាមហាវីរបុរស ឧបមាដូចផ្ទេកបន្ទោរ ខ្ញុំបាននិមន្តហើយ ។

កេនិយតាបសបានពោលឃោសនាថា ព្រះពុទ្ធ ៗ ដូច្នេះ ការឃោសនានោះ ខ្ញុំបានឮដោយកម្រណាស់ ខ្ញុំមានបីតិកើតឡើង ព្រោះឮពាក្យឃោសនាថា ព្រះពុទ្ធ ។ ចិត្តរបស់ខ្ញុំ ឥតប្រកាន់ បីតិរបស់ខ្ញុំ ក៏ផ្សាយចេញទៅខាងក្រៅ ខ្ញុំនោះ មានចិត្តប្រកបដោយបីតិ មានចិត្តស្ងប់ បានពោលពាក្យនេះថា

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

កហំ នុ ខោ សោ ភគវា លោកជេដ្ឋោ នរាសភោ
តត្ថ គន្ត្វា នមស្សិស្សំ សាមញ្ញផលទាយកំ ។
បគ្គយ្ហ ទក្ខិណំ ពាហុំ វេទជាតោ កតញ្ជលី
អាចិក្ខ មេ ធម្មរាជំ សោកសល្លវិនោទនំ ។
ឧទេន្តំវ មហាមេឃំ នីលំ អញ្ជនសន្និភំ
សាគរំ វិយ ទិស្សន្តំ បស្សសេតំ មហាវនំ ។
ឯត្ថ សោ វសតេ ពុទ្ធោ អទន្តទមកោ មុនិ
វិនយន្តោ ច វេនេយ្យេ ពោធេន្តោ ពោធិបក្ខិយេ ។
បិបាសិតោវ ឧទកំ ភោជនំវ ជិឃច្ឆិតោ
គាវី យថា វច្ឆគិទ្ធា ឯវាហំ វិចិនឹ ជិនំ ។
អាចារឧបចារញ្ញូ ធម្មានុច្ឆវិសំវរំ
សិក្ខាបេសឹ សកេ សិស្សេ គច្ឆន្តេ ជិនសន្តិកំ ។

ព្រះមានព្រះភាគនោះ ព្រះអង្គជាចម្បងក្នុងលោក ប្រសើរជាងជន គង់នៅក្នុងទីណា ខ្ញុំនឹងទៅនមស្ការព្រះអង្គក្នុងទីនោះ ទ្រង់ជាអ្នកឲ្យនូវសាមញ្ញផល ។ ខ្ញុំមានសេចក្តីត្រេកអរកើតឡើង ធ្វើអញ្ជលីលើកដៃខាងស្តាំ (សួរថា) លោកចូរប្រាប់ខ្ញុំផង នូវព្រះពុទ្ធជាស្តេចហេតុធម៌ ទ្រង់បន្ទោបង់នូវសរគឺសេចក្តីសោក ។ (កេនិយតាបសប្រាប់ថា) អ្នកចូរមើលព្រៃធំទុំះ ដែលហាក់ដូចជាមហាមេឃ បើកស្រឡះ ឬដូចផ្កាអញ្ជ័នខៀវ ឬក៏ប្រាកដដូចជាសាគរ ព្រះពុទ្ធនោះជាអ្នកប្រាជ្ញ ទូន្មាននូវបុគ្គល ដែលមានខ្លួនមិនទាន់ទូន្មាន ទ្រង់ប្រៀនប្រដៅ នូវពួកវេនេយ្យសត្វ ញុំាងវេនេយ្យសត្វឲ្យត្រាស់ដឹងនូវពោធិបក្ខិយធម៌ ទ្រង់គង់នៅក្នុងព្រៃធំទុំះ ។ ខ្ញុំក៏ពិនិត្យមើលនូវព្រះជិនស្រី គួរនាដូចជាបុគ្គលស្រេកទឹក ឬដូចបុគ្គលឃ្លានបាយ ឬក៏ដូចមេគោ ដែលជាប់ចំពាក់នឹងកូនគោ ខ្ញុំជាអ្នកស្គាល់នូវអាចារៈ និងឧបចារៈ បានញុំាងពួកសិស្សរបស់ខ្លួន ដែលកំពុងដើរទៅកាន់សម្នាក់ព្រះជិនស្រី ឲ្យសិក្សានូវការប្រុង ឲ្យសមតាមប្រពៃណីថា

១៧៣

## ទុតិយំ សេលត្ថេរាបទានំ

ទុរាសទា ភគវន្តោ សីហាវ ឯកចារិនោ
ចាគេ ចាគំ និក្ខិបន្តា អាគច្ឆេយ្យាថ មាណវា ។
អាសិវិសោ យថា ឃោរោ មិគរាជាវ កេសរី
មត្តោវ កុញ្ជរោ ទន្តោ ឯវំ ពុទ្ធា ទុរាសទា ។
ឧក្កាសិតញ្ច ខិបិតំ អជ្ឈុបេក្ខាយ មាណវា
ចាគេ ចាគំ និក្ខិបន្តា ឧបេថ ពុទ្ធសន្តិកំ ។
បដិសល្លានគរុកា អប្បសទ្ទា ទុរាសទា
ទុរូបសង្កមា ពុទ្ធា គរូ ហោន្តិ សទេវកេ ។
យមហំ បញ្ហំ បុច្ឆាមិ បដិសម្មោទយាមិ វា
អប្បសទ្ទា តទា ហោថ មុនីភូតាវ តិដ្ឋថ ។

សេលត្ថេរាបទាន ទី ២

ម្នាលមាណពទាំងឡាយ ព្រះមានព្រះភាគទាំងឡាយ គេចូល ទៅរកបានដោយក្រ ដូចជាសីហៈ ដែលត្រាច់ទៅតែឯង អ្នកទាំងឡាយ ចូរដើរដាក់ជើងជិតជើង (សន្សឹម ៗ) ដើរមក ចុះ ។ ព្រះពុទ្ធទាំងឡាយ អ្នកផងចូលទៅរកបានដោយក្រ ដូចជាពស់អាសិរពិស ដ៏ឃោរឃៅ ដូចជាកេសររាជសីហ៍ ជាស្តេចម្រឹគ ឬក៏ដូចជាដំរីកុញ្ជរ បានបទដែលចុះប្រេង ។ ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរទប់នូវអាការក្អក និងកណ្តាល ចូរដើរដាក់ជើងជិតជើង ចូលទៅកាន់សំ-ណាក់ព្រះពុទ្ធចុះ ។ ព្រះពុទ្ធទាំងឡាយ ព្រះអង្គធ្ងន់ព្រះទ័យ ក្នុងការពួនសម្ងំ ពេញព្រះហឫទ័យនឹងសំឡេងតិច ៗ អ្នក ផងចូលទៅរកបានដោយក្រ ចូលទៅជិតបានដោយលំបាក ជាគ្រូក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ កាលណា ខ្ញុំកំពុងសាកសួរប្រស្នា ឬកំពុងនិយាយរាក់ទាក់ កាលនោះ អ្នកទាំងឡាយ ចូរនិយាយសំឡេងតិច ៗ ចូរបិតនៅស្ងៀម ។

យំ សោ ទេសេសិ សទ្ធម្មំ     ខេមំ និព្វានបត្តិយា
តមេវត្ថំ និសាមេថ     សទ្ធម្មស្សវនំ សុភំ ។
ឧបសង្កម្ម សម្ពុទ្ធំ     សម្មោទឹ មុនិនា អហំ
តំ កថំ វីតិសារេត្វា     លក្ខណេ ឧបធារយឹ ។
លក្ខណេ ទ្វេ ច ទក្ខាមិ[1]     បស្សាមិ តឹសលក្ខណេ
កោសោហិតវត្ថុំ គុយ្ហំ     ឥទ្ធិយា ទស្សយិ មុនិ ។
ជិវ្ហំ និន្នាមយិត្វា ច     កណ្ណសោតេ ច នាសិកេ
បដិមស្ស នលាដន្តំ     កេវលំ ឆាទយិ ជិនោ ។
តស្សាហំ លក្ខណេ ទិស្វា     បរិបុណ្ណេ សព្យញ្ជនេ
ពុទ្ធោតិ និដ្ឋំ គន្ត្វាន     សហ សិស្សេហិ បព្វជឹ ។
សតេហិ តីហិ សហិតោ     បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ     សព្វេ បត្តម្ហ និព្វុតឹ ។

---

១ ម. ទ្វេ ច កង្ខាមីតិ ទិស្សតិ ។

កាលណា ព្រះពុទ្ធនោះ ទ្រង់សម្តែងព្រះសទ្ធម្ម ជាធម៌ក្សេម ដើម្បីដល់ព្រះនិព្វាន (កាលនោះ) អ្នកទាំងឡាយ ចូរត្រង់ត្រាប់ស្តាប់សេចក្តីនោះ) ដ្បិតការស្តាប់នូវព្រះសទ្ធម្ម ជាការល្អ ។ ខ្ញុំបានចូលទៅគាល់ព្រះសម្ពុទ្ធ ហើយនិយាយរាក់ទាក់ (ជាមួយ) នឹងព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ លុះបញ្ចប់ពាក្យនោះហើយ ក៏ពិនិត្យមើលលក្ខណៈទាំងឡាយ ។ ខ្ញុំមិនទាន់ឃើញលក្ខណៈ ២ ប្រការ ឃើញតែលក្ខណៈ ៣០ ប្រការ ទើបព្រះមុនីទ្រង់បង្ហាញដោយឫទ្ធិ នូវគុយ្ហៈ ជាវត្ថុបិទបាំងដោយស្រោម ។ ព្រះជិនស្រីទ្រង់លៀនព្រះជិវ្ហា ហើយប៉ះពាល់នូវព្រះកាណ៌ និងព្រះនាសិកៈ បាំងនូវទីបំផុតព្រះនលាដៈទាំងអស់ ។ លុះខ្ញុំឃើញលក្ខណៈរបស់ព្រះអង្គ ដ៏បរិបូណ៌ ព្រមទាំងអនុព្យញ្ជនៈ ក៏ដល់នូវសេចក្តីចូលចិត្តថាជាព្រះពុទ្ធ ហើយបួសជាមួយនឹងពួកសិស្ស ។ លុះខ្ញុំព្រមទាំងពួកសិស្ស ៣០០ នាក់ ចូលទៅកាន់ផ្នួសហើយ កាលមិនទាន់ដល់កន្លះខែនៅឡើយ ពួកយើងទាំងអស់ ក៏ដល់នូវសេចក្តីរលត់ទុក្ខ ។

១៧៤

## ទុតិយំ សេលត្ថេរាបទានំ

ឯកតោ កម្មំ កត្វាន  បុញ្ញក្ខេត្តេ អនុត្តរេ
ឯកតោ សំសរិត្វាន  ឯកតោ វិនិវដ្ដយុំ ។
កោចានសិយោ ធត្វាន  បូគធម្មេ រសឹ អហំ
តេន កម្មេន សុកតេន  អដ្ឋ ហេតូ លភាមហំ ។
ឌិសាសុ បូជិតោ ហោមិ  ភោគា ច អមិតា មម
បតិដ្ឋា ហោមិ សព្វេសំ  តាសោ មម ន វិជ្ជតិ ។
ព្យាធយោ មេ ន វិជ្ជតិ  ឌីឃាយុំ ចាលយាមិ ច
សុខុមច្ឆវិកោ ហោមិ  អាវាសេ បត្ថិតេ វស្សេ ។
អដ្ឋ កោចានសី ធត្វា  បូគធម្មេ រសឹ អហំ
បដិសម្ភិទា អរហត្តញ្ច  ឯតំ មេ អបរដ្ឋមំ ។
សព្វវោសិតវោសានោ  កតកិច្ចោ អនាសវោ
អដ្ឋកោចានសី នាម  តវ បុត្តោ មហាមុនិ ។
បញ្ច ថម្ភានិ ធត្វាន  បូគធម្មេ រសឹ អហំ
តេន កម្មេន សុកតេន  បញ្ច ហេតូ លភាមហំ ។

## សេលត្ថេរាបទាន ទី ២

ជនទាំងឡាយបានធ្វើនូវបុញ្ញកម្មជាមួយគ្នា ចំពោះបុញ្ញក្ខេត្ត ដ៏ប្រសើរ អន្ទោលទៅក្នុងទីជាមួយគ្នា វិលមកកើតក្នុងទីជាមួយគ្នា ។ ខ្ញុំបានប្រគេនបង្កង់ទាំងឡាយ (ចំពោះសង្ឃ) ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺអានិសង្ស ៨ ប្រការ គឺ ខ្ញុំត្រូវគេបូជាក្នុងទិសទាំងឡាយ ១ ភោគៈទាំងឡាយរបស់ខ្ញុំរាប់មិនអស់ ១ ខ្ញុំជាទីពឹងរបស់ពួកជនទាំងពួង ១ ខ្ញុំមិនមានសេចក្ដីតក់ស្លុត ១ ខ្ញុំមិនមានជំងឺទាំងឡាយ ១ ខ្ញុំរមែងរក្សាអាយុឲ្យរស់នៅវែង ១ ជាអ្នកមានសម្បុរថ្ងៃដ៏ល្អិត ១ កាលដែលភ្លៀងធ្លាក់ ក្នុងអាវាស ខ្ញុំឲ្យនូវបង្កង់ ៨ ហើយនៅក្នុងពួក អំពើជាកុសលនេះ នាំឲ្យខ្ញុំបានបដិសម្ភិទានិងអរហត្ត នេះជាអានិសង្សគម្រប់ ៨ ។ បពិត្រព្រះមហាមុនី កូនរបស់ព្រះអង្គ ឈ្មោះអដ្ឋគោបានសី មានព្រហ្មចរិយធម៌ជាទីបំផុត នៅចប់សព្វគ្រប់ហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ ខ្ញុំបានឲ្យសសរ ៥ ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺបានអានិសង្ស ៥ ប្រការ

អចលោ ហោមិ មេត្តាយ អក្ខោភោភវាមហំ
អាទេយ្យវចនោ ហោមិ ន ធំសេមិ យថា អហំ ។
អភន្តំ ហោតិ មេ ចិត្តំ អខិលោ ហោមិ កស្សចិ
តេន កម្មេន សុកតេន វិមលោ ហោមិ សាសនេ ។
សគារវោ សប្បតិស្សោ កតកិច្ចោ អនាសវោ
សាវកោ តេ មហាវីរ ភិក្ខុ តំ វន្ទតេ មុនិ ។
កត្វា សុកតបល្លង្កំ សាលាយំ បញ្ញបេសហំ
តេន កម្មេន សុកតេន បព្វ ហេតូ លភាមហំ ។
ឧច្ចេ កុលេ បជាយាមិ មហាភោគោ ភវាមហំ
សព្វសម្បត្តិកោ ហោមិ មច្ឆេរំ មេ ន វិជ្ជតិ ។
គមនេ បត្ថិតេ មយ្ហំ បល្លង្កោ ឧបតិដ្ឋតិ
សហ បល្លង្កសេដ្ឋេន គច្ឆាមិ មម បត្ថិតំ ។
តេន បល្លង្កទានេន តមំ សព្វំ វិនោទយឹ
សព្វាភិញ្ញាពលប្បត្តោ ថេរោ វន្ទតិ តំ មុនេ ។

គឺ ខ្ញុំជាអ្នកមិនក្រេវក្រោធ ចាកមេត្តា ១ មានភោគៈមិនខ្វះខាត ១ មានពាក្យសម្តីគួរអ្នកផងកាន់យក ១ មិនកម្ចាត់បង់ (នូវគុណនៃបុគ្គលដទៃ) ១ ចិត្តរបស់ខ្ញុំមិនកន្ត្រប់ឡប់ ខ្ញុំជាអ្នកមិនរឹងចចេស ចំពោះបុគ្គលណាមួយ ១ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំជាអ្នកមិនមានមន្ទិល ក្នុងសាសនា ។ បពិត្រព្រះមុនី ជាមហាវីរបុរស ភិក្ខុជាសាវ័ករបស់ព្រះអង្គ ប្រកបសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង មានកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ រមែងថ្វាយបង្គំព្រះអង្គ ។ ខ្ញុំបានធ្វើនូវបល្ល័ង្ក ដែលធ្វើដ៏ល្អ ហើយតាំងទុកក្នុងសាលា ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺអានិសង្ស ៥ ប្រការ គឺ ខ្ញុំកើតក្នុងត្រកូលខ្ពង់ខ្ពស់ ១ ជាអ្នកមានភោគៈច្រើន ១ ជាអ្នកមានសម្បត្តិគ្រប់មុខ ១ ខ្ញុំមិនមានសេចក្តីកំណាញ់ ១ បល្ល័ង្ករមែងផុសឡើងដល់ខ្ញុំ ក្នុងដំណើរដែលខ្ញុំប្រាថ្នា ១ ខ្ញុំរមែងទៅកាន់ទីដែលខ្ញុំប្រាថ្នា ព្រមដោយបល្ល័ង្កដ៏ប្រសើរ ។ ខ្ញុំបន្ទោបង់នូវងងឹតទាំងពួងបាន ព្រោះទាននៃបល្ល័ង្កនោះឯង បពិត្រព្រះមុនី ព្រះថេរៈដែលដល់នូវកម្លាំង នៃអភិញ្ញាទាំងពួង រមែងថ្វាយបង្គំនូវព្រះអង្គ ។

១៧៧

## ទុតិយំ សេលត្ថេរាបទានំ

បរកិច្ចត្តកិច្ចានិ សព្វកិច្ចានិ សាធយឹ
តេន កម្មេន សុកតេន បាវិសឹ អភយំ បុរំ ។
បរិនិដ្ឋិតសាលស្មឹ បរិភោគមទាសហំ
តេន កម្មេន សុកតេន សេដ្ឋត្តំ អជ្ឈុបាគតោ ។
យេ កេចិ ទមកា លោកេ ហត្ថិអស្សេ ទមេន្តិ តេ
ការេត្វា ការណា នានា ទារុណេន ទមេន្តិ តេ ។
ន ហេវ ត្វំ មហាវីរ ទមេសិ នរនារិយោ
អទណ្ឌេន អសត្ថេន ទមេសិ ឧត្តមេ ទមេ ។
ទានស្ស វណ្ណេ កិត្តេន្តោ ទេសនាកុសលោ មុនិ
ឯកបញ្ហំ កថេន្តោ ច ពោធេសិ តិសតេ មុនិ ។

សេលត្ថេរាបទាន ទី ២

ខ្ញុំញ៉ាំងកិច្ចទាំងពួង ដែលជាកិច្ចរបស់អ្នកដទៃ និងកិច្ចរបស់ខ្លួនឲ្យសម្រេច ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបានចូលទៅកាន់បុរី ឥតមានភ័យ ។ ខ្ញុំបានឲ្យគ្រឿងប្រើប្រាស់ទុកក្នុងសាលា ដែលកសាងស្រេចហើយ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបបានដល់នូវភាពនៃខ្លួនជាបុគ្គលប្រសើរ ។ ពួកជនអ្នកទូន្មានណាទីមួយ ក្នុងលោក ពួកជនអ្នកទូន្មានទាំងនោះ រមែងទូន្មាន នូវដំរីនិងសេះទាំងឡាយ ពួកជនអ្នកទូន្មានទាំងនោះ ធ្វើដោយហេតុផ្សេង ៗ ហើយទូន្មានដោយអំពើដ៏អាក្រក់ ។ បពិត្រព្រះមហាវីរបុរស ព្រះអង្គមិនមែនទូន្មាន នូវពួកបុរសស្ត្រីដូច្នោះទេ ព្រះអង្គតែងទូន្មាននូវពពួកជនដ៏ខ្ពង់ខ្ពស់ ដែលគួរទូន្មាន ដោយហេតុមិនបាច់ប្រើដំបង មិនបាច់ប្រើគ្រឿងសស្ត្រាវុធ ។ បពិត្រព្រះមហាមុនី ព្រះអង្គឈ្វាសវៃក្នុងការទេសនា ទ្រង់សរសើរគុណនៃទាន បពិត្រព្រះមុនី ព្រះអង្គកាលសម្តែង នូវប្រស្នាតែមួយសោះ ក៏ញ៉ាំងពួកបុរស ទាំង ៣០០ នាក់ ឲ្យត្រាស់ដឹងធម៌បាន ។

ទន្តា មយំ សារថិនា  សុវិមុត្តា អនាសវា
សព្វាភិញ្ញាពលប្បត្តា  និព្វុតា ឧបធិក្ខយេ ។
សតសហស្សេ ឥតោ កប្បេ  យំ ទានមទទិន្តទា
អតិក្កន្តា ភយា សព្វេ  សាលទានស្សិទំ ផលំ ។
ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវោ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សេលោ សបរិសោ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិត្ថាតិ ។

សេលត្ថេរស្ស អបទានំ សមត្តំ ។

ពួកយើងដែលព្រះអង្គជាសារថីបានទូន្មានហើយ ជាអ្នកមានចិត្តរួចស្រឡះ មិនមានអាសវៈ ដល់នូវកម្លាំង នៃអភិញ្ញាទាំងពួង មានទុក្ខរលត់ហើយ ព្រោះអស់ទៅ នៃឧបធិក្កិលេស ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក្នុងកាលនោះព្រោះហេតុដែលខ្ញុំបានឲ្យទាន ភ័យគ្រប់យ៉ាង ខ្ញុំកន្លងផុតហើយ នេះជាផលនៃការឲ្យសាលា ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ប្រការខ្ញុំបានដល់ហើយ ទាំងសាសនធម៌ របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើចប់ហើយ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់នូវទន្នឹង ។ បដិសម្ភិទា ៤ វិមោក្ខ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសេលត្ថេរ មានអាយុ ព្រមទាំងបរិស័ទ បានពោលនូវគាថាទាំងនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ សេលត្ថេរាបទាន ។

# តតិយំ សព្វកិត្តិកត្ថេរាបទានំ

[៩៣] កណិការំវ ជលិតំ ទីបរុក្ខំវ ជោតិតំ(១)
ឱសធឹវ វិរោចន្តំ វិជ្ជុវ គគនេ យថា ។
អសម្ភីតំ អនុត្រាសី មិគរាជំវ កេសរឹ
ញាណាលោកំ បកាសេន្តំ មទ្ទន្តំ តិត្ថិយេ គណេ ។
ឧទ្ធរន្តំ ឥមំ លោកំ ឆិន្ទន្តំ សព្វសំសយំ
អសម្ភីតំ(២) មិគរាជំវ អទ្ទសំ លោកនាយកំ ។
ជដាជិនធរោ អាសឹ ព្រហា ឧជុ បតាបវា
វាកចីរំ គហេត្វាន ចាទមូលេ អបត្ថរឹ ។
កាឡានុសារិយំ គយ្ហ អនុលិម្បឹ តថាគតំ
សម្ពុទ្ធំ ឧបលិម្បិត្វា សន្ថវឹ លោកនាយកំ ។
សម្ពុទ្ធរសិមំ លោកំ ឱឃតិណ្ណោ មហាមុនិ
ញាណាលោកេន ជោតេសិ បវរំ(៣) ញាណមុត្តមំ ។
ធម្មចក្កំ បវត្តេសិ(៤) មទ្ទសេ បរតិត្ថិយេ
ឧសភោ ជិតសង្គាមោ សម្បកម្បេសិ មេទនឹ ។

---

១ ម. ឧជ្ជលិ ។ ២ ម. គច្ឆន្តំ ។ ៣ ម. នាវដំ ។ ៤ ម. តុវំ ចក្កំ ។

# សព្វកិត្តិកត្ថេរាបទាន ទី ៣

[៩៣] ខ្ញុំបានឃើញព្រះលោកនាយក ទ្រង់រុងរឿងដូចផ្កាកណិការ ទ្រង់ភ្លឺដូចឈើប្រចាំទ្វីប ភ្លឺច្រាលដូចផ្កាយព្រឹក ពុំនោះដូចផ្លេកបន្ទោរឰដ៏អាកាស ។ ព្រះអង្គមិនខ្លាច មិនតក់ស្លុត ដូចកេសររាជសីហ៍ជាស្តេចម្រឹគ ទ្រង់ប្រកាសនូវពន្លឺគឺញាណ ទ្រង់ញាំញីនូវពួកតិរ្ថិយ ។ ទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់ផ្តាច់បង់នូវសេចក្តីសង្ស័យទាំងអស់ មិនខ្លាចដូចស្តេចម្រឹគ ។ ខ្ញុំជាព្រាហ្មណ៍ អ្នកទ្រទ្រង់នូវជដា និងស្បែកខ្លាមានចិត្តត្រង់ មានព្យាយាម បានកាន់យកនូវសំពត់សម្បកឈើ ទៅក្រាលទៀបបាទមូល ។ បានយកខ្ទឹមក្ងាំពាក់ទៅលាបព្រះតថាគត លុះលាបព្រះសម្ពុទ្ធហើយ បានសរសើរព្រះលោកនាយក ដូច្នេះថា

បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ស្រង់នូវសត្វលោកនេះ ទ្រង់បានឆ្លងនូវឱឃធម៌ ទ្រង់ធ្វើញាណដ៏ប្រសើរឧត្តម ឲ្យភ្លឺដោយពន្លឺ គឺញាណ ។ ព្រះអង្គញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងលោក ទ្រង់ញាំញីនូវអន្យតិរ្ថិយ ជាបុគ្គលប្រសើរ ទ្រង់ឈ្នះសង្គ្រាម ទ្រង់ញុំាងផែនដីឲ្យកម្រើក ។

មហាសមុទ្ទេ ឩម្មីវ    វេលន្តម្ហិ បភិជ្ជតិ
តថេវ តវ ញាណស្មឹ    សព្វទិដ្ឋិ បភិជ្ជតិ ។
សុខុមច្ឆិកជាលានិ    សរម្ហិ សម្បតានិ តេ
អន្តោជាលិកតា ចាណា    បីឡិតា ហោន្តិ តាវទេ ។
តថេវ តិត្ថិយា លោកេ    មុឡ្ហា សច្ចវិនិស្សិតា[១]
អន្តោញាណវរេ តុយ្ហំ    បរិវត្តន្តិ មារិស ។
បតិដ្ឋាវ វុយ្ហតំ ឱឃេ    ត្វញ្ហិ នាថោ អពន្ធុនំ
ភយដ្ដិតានំ សរណា    មុត្តត្ថិនំ បរាយណោ ។
ឯកច្ចរោ[២] អសទិសោ    មេត្តាករុណាសញ្ញុតោ[៣]
បញ្ញាយ យុត្តចាគោ ច[៤]    វសី តាទី គុណាលយោ[៥] ។

---

១ ម. ផុដ្ឋសច្ចវិនិស្សដា ។ ២ ម. ឯកវីរោ ។ ៣ ម. មេត្តាករុណាសញ្ចយោតិ ខាយតិ ។

៤ ម. អសមោ សុសមោ សន្តោតិ ទិស្សតិ ។ ៥ ម. ជិតជ្ជយោ ។

ទិដ្ឋិទាំងអស់បែកធ្លាយ ក្នុងញាណរបស់ព្រះអង្គ ប្រៀបដូចរលកក្នុងមហាសមុទ្រ រមែងបែកធ្លាយ ក្នុងទីបំផុតច្រាំង ។ សំណាញ់នៃព្រានត្រីដ៏ល្អិត ដែលគេបង់ចុះក្នុងស្រះ ពួកសត្វទាំងនោះ ដែលតាំងនៅក្នុងសំណាញ់ ត្រូវគេបៀតបៀន ក្នុងខណៈនោះ យ៉ាងណា ។ បពិត្រព្រះអង្គនិរទុក្ខ ពួកអន្យតិរ្ថិយក្នុងលោក ជាមនុស្សវង្វេង ប្រាសចាកសច្ចៈ រមែងប្រព្រឹត្តទៅក្នុងខាងក្នុង នៃញាណដ៏ប្រសើររបស់ព្រះអង្គ ក៏យ៉ាងនោះដែរ ។ ព្រះអង្គជាទីពឹង របស់ពួកជនដែលឥតផៅពង្ស ដូចជាពួកមនុស្ស ដែលជាទីពំនាក់នៃពួកជន ដែលហែលលិចលង់ក្នុងអន្ទង់ ព្រះអង្គជាទីរលឹករបស់សត្វ ដែលឋិតនៅក្នុងភ័យ ជាទីប្រព្រឹត្តទៅខាងមុខ នៃពួកសត្វដែលត្រូវការ ក្នុងការរួចចាកកិលេស ។ ព្រះអង្គទ្រង់ត្រាច់ទៅតែមួយអង្គឯង រកបុគ្គលស្មើគ្មាន ទ្រង់ប្រកបដោយមេត្តានិងករុណា ទ្រង់មានប្រាជ្ញា ទ្រង់ប្រកបក្នុងការលះ ទ្រង់ស្ងាត់ជំនាញ ទ្រង់នឹងធឹង ជាលំនៅនៃគុណ ។

១៨១

## តតិយំ សព្វកិត្តិកត្ថេរាបទានំ

ធីរោ វិគតសម្មោហោ អនេញ្ជោ អកថំកថី
តុស្សិតោ វន្តទោសាសិ និម្មលោ សំយតោ សុចិ ។
សង្គាតីតោ គតមទោ(១) តេវិជ្ជោសិ ភវន្តគោ
សីមាតិគោ ធម្មគរុ គតត្ថោ ហិតវប្បកោ(២) ។
តារកោ ត្វំ យថា នាវា(៣) និធិវស្សា សការកោ
អសម្ភីតោ យថា សីហោ គជរាជាវ ទប្បិតោ ។
ថោមេត្វា ទសគាថាហិ បទុមុត្តរំ មហាមុនឹ
វន្ទិត្វា សត្ថុនោ បាទេ តុណ្ហី អដ្ឋាសហំ តទា ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ភិក្ខុសង្ឃេ ឋិតោ សត្ថា ឥមា គាថា អភាសថ ។
យោ មេ សីលញ្ច បញ្ញញ្ច ធម្មញ្ចាបិ បកិត្តយិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

---
១ ម. សង្គាតិនោ តមនុទោតិ ទិស្សន្តិ ។ ២ ម. ហិតវព្វតោ ។ ៣ ម. នាគោ ។

សព្វកិត្តិកត្ថេរាបទាន ទី ៣

ព្រះអង្គជាអ្នកប្រាជ្ញ ប្រាសចាកការរវើង មិនញាប់ញ័រ មិនមានសេចក្តីសង្ស័យ ទ្រង់មានសេចក្តីសន្តោស មានទោសៈខ្ជាក់ចោលហើយ ព្រះអង្គមិនមានមន្ទិល ទ្រង់សង្រួមស្អាតបាត ។ ព្រះអង្គកន្លងនូវកិលេសជាគ្រឿងជាប់ចំពាក់ មានសេចក្តីស្រវឹងកន្លងហើយ ទ្រង់មានវិជ្ជា ៣ ទ្រង់ដល់នូវទីបំផុតនៃភព ទ្រង់កន្លងនូវធម៌ជាដែន មានព្រះទ័យធ្ងន់ក្នុងធម៌ ទ្រង់ផ្សាយសេចក្តីចម្រើន ទ្រង់សាបព្រោះប្រយោជន៍ ។ ព្រះអង្គជាអ្នកចម្លងពួកសត្វដូចសំពៅ ទ្រង់ធ្វើនូវសេចក្តីទំនុកបម្រុងដូចកំណាប់ទ្រព្យ ទ្រង់មិនខ្លាចដូចរាជសីហ៍ ពុំនោះសោតដូចស្តេចដំរីដែលហ្មត់ទូន្មានហើយ ។ ខ្ញុំលុះសរសើរព្រះមហាមុនី ព្រះនាមបទុមុត្តរៈដោយគាថាទាំង ១០ ហើយថ្វាយបង្គំព្រះបាទាព្រះសាស្តា រួចឈរនៅស្ងៀមក្នុងកាលនោះ ។

ព្រះលោកវិទូព្រះនាមបទុមុត្តរៈ ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់ជាសាស្តា ឋិតនៅក្នុងពួកភិក្ខុ ទ្រង់បានពោលនូវគាថាទាំងនេះថា កុលបុត្រណាសរសើរនូវសីល បញ្ញា និងធម៌របស់តថាគត តថាគតនឹងសរសើរកុលបុត្រនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។

១៨២



សដ្ឋី កប្បសហស្សានិ ទេវលោកេ រមិស្សតិ
អញ្ញេ ទេវេភិភវិត្វា ឥស្សរំ ការយិស្សតិ ។
សោ បច្ឆា បព្វជិត្វាន សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ សាសនេ បព្វជិស្សតិ ។
បព្វជិត្វាន កាយេន បាបកម្មំ វិវជ្ជិយ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
យថា ច មេឃោ ថនយំ តប្បេតិ មេទនឹ ឥមំ
តថេវ ត្វំ មហាវីរ ធម្មេន តប្បយិ មមំ ។
សីលញ្ច បញ្ញញ្ច ធម្មញ្ច ថវិត្វា លោកនាយកំ
បត្តោម្ហិ បរមំ សន្តិំ និព្វានំ បទមច្ចុតំ ។
អហោ នូន ស ភគវា ចិរំ តិដ្ឋេយ្យ ចក្ខុមា
អញ្ញាតញ្ច វិជានេយ្យុំ បស្សេយ្យុំ អមតំ បទំ ។
អយំ មេ បច្ឆិមា ជាតិ ភវា សព្វេ សមូហតា
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។

បុគ្គលនេះនឹងរីករាយក្នុងលោក នឹងបានជាធំគ្របសង្កត់ទេវ-តាដទៃ នឹងសោយនូវឥស្សរភាព អស់ ៦ ម៉ឺនកប្ប ។ ក្នុងកាលជាខាងក្រោយមក កុលបុត្រនោះនឹងចេញបួស ត្រូវកុសលមូលដាស់តឿនហើយ នឹងបួសក្នុងសាសនា នៃព្រះគោតមមានព្រះភាគ ។ លុះបួសហើយ បានវៀរបង់នូវបាប-កម្មដោយកាយ កំណត់ដឹងនូវអាសវធម៌ទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

មេឃកាលកម្មរ ធ្វើផែនដីនេះឲ្យឆ្អែត យ៉ាងណាមិញ បពិត្រព្រះមហាវីរៈ ព្រះអង្គទ្រង់ញ៉ាំងខ្ញុំឲ្យឆ្អែតដោយធម៌ ក៏យ៉ាងនោះដែរ ។ ខ្ញុំព្រះអង្គសរសើរនូវសីល បញ្ញា និងធម៌នៃព្រះលោកនាថ ជាអ្នកដល់នូវព្រះនិព្វាន ជាទីស្ងប់ដ៏ក្រៃលែង ជាបទមិនឃ្លៀងឃ្លាត ។ ធ្វើម្ដេចហ្ន៎ ! ព្រះមានព្រះភាគអង្គនោះ ទ្រង់មានចក្ខុ នឹងឋិតនៅអស់កាលយូរ អាត្មាអញនឹងបានដឹងនូវធម៌ដែលមិនទាន់ដឹងផង នឹងឃើញនូវអមតបទផង ។ នេះជាបច្ឆិមជាតិរបស់ខ្ញុំ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។

១៨៣



សតសហស្សេ ឥតោ កប្បេ  យំ ពុទ្ធមភិថោមយឹ
ទុគ្គតឹ នាភិជានាមិ  ភិត្តិទាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា  នត្ថិទានិ បុនព្ភវោ ។
ស្វាគតំ វត មេ អាសិ  មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សព្វកិត្តិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សព្វកិត្តិកត្ថេរស្ស អបទានំ សមត្តំ ។

# ចតុត្ថំ មធុទាយកត្ថេរាបទានំ

[៩៤] សិន្ធុយា នទិយា តីរេ  សុកតោ អស្សមោ មម
តត្ថ វាចេមហំ សិស្សេ  ឥតិហាសំ សលក្ខណំ ។

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំសរសើរព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការសរសើរ ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានឡើយ ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើចប់ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វកិត្តិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សព្វកិត្តិកត្ថេរាបទាន ។

# មធុទាយកត្ថេរាបទាន ទី ៤

[៩៤] អាស្រមបរមសាលារបស់ខ្ញុំ ជាងបានស្ថាបនាល្អហើយ ទៀបឆ្នេរទន្លេឈ្មោះសិន្ធុ ខ្ញុំបានឲ្យពួកសិស្ស រៀនគម្ពីរឥតិហាសៈ ព្រមទាំងលក្ខណៈ ក្នុងអាស្រមនោះ ។

ធម្មកាមា វិនីតា តេ សោតុកាមា សុសាសនំ
ឆឡង្គេ ចារមិប្បត្តា សិន្ធុកូលេ វសន្តិ តេ ។
ឧប្បាតគមនេ ចេវ លក្ខណេសុ ច កោវិទា
ឧត្តមត្ថំ គវេសន្តា វសន្តិ បវនេ តទា ។
សុមេធោ នាម សម្ពុទ្ធោ លោកេ ឧប្បជ្ជិ តាវទេ
អម្ហាកំ អនុកម្បន្តោ ឧបគច្ឆិ វិនាយកោ ។
ឧបាគតំ មហាវីរំ សុមេធំ លោកនាយកំ
តិណសន្ថារកំ កត្វា លោកជេដ្ឋស្សទាសហំ
បវនាតោ មធុំ គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ ។
សម្ពុទ្ធោ បរិភុញ្ជិត្វា ឥទំ វចនមព្រវិ ។
យោ តំ អទាសិ មធុំ មេ បសន្នោ សេហិ បាណិភិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
ឥមិនា មធុទានេន តិណសន្ថារកេន ច
តឹសកប្បសហស្សានិ ទេវលោកេ រមិស្សតិ ។

ពួកសិស្សខ្ញុំ ទាំងអម្បាលនោះ ជាអ្នកប្រាថ្នានូវធម៌ ជាអ្នកប្រាថ្នាដើម្បីស្តាប់ នូវពាក្យប្រៀនប្រដៅដ៏ល្អ ជាអ្នកដល់នូវបារមីក្នុងធម្មឡង្គធម៌ ខ្ញុំបានទូន្មានហើយ ពួកសិស្សទាំងនោះនៅក្បែរច្នេរទន្លេសិន្ធុ ។ ក្នុងកាលនោះ ពួកសិស្សដែលឈ្លាសក្នុងការកើតនិងដំណើរមកផង ក្នុងលក្ខណៈផង ស្វែងរកនូវប្រយោជន៍ដ៏ឧត្តម នៅក្នុងព្រៃធំ ។ កាលនោះឯង ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់កើតឡើងក្នុងលោក ទ្រង់ជាអ្នកដឹកនាំពួកសត្វ អនុគ្រោះយើងខ្ញុំ បានស្តេចចូលមកជិតខ្ញុំ ។ ខ្ញុំបានឃើញព្រះសុមេធៈ ជាលោកនាយក មានព្យាយាមធំស្តេចចូលមកដល់ហើយ ក៏ធ្វើកម្រាលស្មៅ ថ្វាយព្រះលោកជេដ្ឋ ខ្ញុំយកទឹកឃ្មុំអំពីព្រៃធំ មកថ្វាយព្រះពុទ្ធដ៏ប្រសើរ ។

ព្រះសម្ពុទ្ធទ្រង់សោយ ហើយសម្តែងនូវព្រះពុទ្ធដីកានេះថា កុលបុត្រណា ជ្រះថ្លាបានថ្វាយទឹកឃ្មុំនោះ ដល់តថាគតដោយដៃរបស់ខ្លួន តថាគតនឹងសរសើរនូវកុលបុត្រនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ពាក្យតថាគត ដែលនឹងសម្តែងចុះ ។ ដោយអំណោយទឹកឃ្មុំនេះផង ដោយកម្រាលស្មៅនេះផង បុរសនេះនឹងរីករាយក្នុងទេវលោក អស់ ៣ ម៉ឺនកប្ប ។

១៨៤

ចតុត្ថំ មធុទាយកត្ថេរាបទានំ

តឹសកប្បសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
ទេវលោកា ឥធាគន្ត្វា មាតុកុច្ឆិម្ហុបាគតោ
អធុវស្សោ បវស្សិត្ថ ឆាទយំ មធុនា មហឹ ។
មម និក្ខន្តមត្តម្ហិ កុម្ភិយា[1] ច សុទុត្តរា
តត្រាបិ មធុវស្សោ មេ វស្សតេ និច្ចកាលិកំ ។
អគារា អភិនិក្ខម្ម បព្វជឹ អនគារិយំ
លាភី អន្នស្ស បានស្ស មធុទានស្សិទំ ផលំ ។
សព្វកាមសមិទ្ធោហំ ភវិត្វា ទេវមានុសេ
តេនេវ មធុទានេន បត្តោម្ហិ អាសវក្ខយំ ។
វុដ្ឋម្ហិ ទេវេ ចតុរង្គុលេ តិណេ
សុបុប្ផិតេ ធរណីរុហេ វប្បទេសេ[1]
សុញ្ញេ ឃរេ មណ្ឌបរុក្ខមូលកេ
វសាមិ និច្ចំ សុខិតោ អនាសវោ ។

១ ម. លញ្ឆន្នេ ។

កន្លងទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្ដាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុងលោក ។ ឯបុរសនេះ នឹងជាអ្នកទទួលមត៌ក ក្នុងធម៌របស់ព្រះសាស្ដាអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ខ្ញុំច្យុតចាកទេវលោក មកចាប់ផ្ទៃនៃមាតា ក្នុងមនុស្សលោកនេះ ភ្លៀងទឹកឃ្មុំបានបង្អុរចុះ គ្របនូវផែនដីដោយទឹកឃ្មុំ ។ ក្នុងពេលដែលខ្ញុំប្រសូតចេញមក ភ្លៀងទឹកឃ្មុំរមែងបង្អុរចុះមកឲ្យខ្ញុំ អស់កាលជានិច្ច ក្នុងទីនោះ (ដូចជាគេចាក់ទឹក) អំពីក្អម ផែនដី គេឆ្លងបានដោយក្រ ។ ខ្ញុំបានចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកបានបាយទឹក ជាប្រក្រតី នេះជាផលនៃទានទឹកឃ្មុំ ។ ខ្ញុំកើតក្នុងទេវលោក និងមនុស្សលោក ជាអ្នកបានសម្រេចដូចសេចក្ដីប្រាថ្នាគ្រប់ប្រការ ជាអ្នកដល់នូវធម៌ជាគ្រឿងអស់អាសវៈ ដោយទានទឹកឃ្មុំនោះឯង ។

កាលភ្លៀងបង្អុរចុះមក កាលស្មៅ(ដុះ) កម្ពស់ ៤ ធ្នាប់
កាលដើមឈើលើប្រឹថពី ជាទីគួរសាបព្រោះ មានផ្កា
រីកល្អ ខ្ញុំមិនមានអាសវៈ ដល់នូវសេចក្ដីសុខជានិច្ច
នៅក្នុងផ្ទះស្ងាត់ ទៀបគល់ឈើ ជាមណ្ឌប ។

មជ្ឈេ មយ្ហំ ភវា អស្សុ យេ ភវេ សមតិក្កមឹ[១]
អជ្ជ មេ អាសវា ខីណា នត្ថិទានិ បុនព្ភវោ ។
តឹសកប្បសហស្សម្ហិ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ មធុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មធុទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មធុទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. យោ ភវេសុ បកិត្តយីតិ ទិស្សតិ ។

ខ្ញុំបានកន្ទងបង់ នូវភពទាំងឡាយ ដែលជាភពក្នុងបច្ចុប្បន្ន របស់ខ្ញុំ ក្នុងថ្ងៃនេះ អាសវៈរបស់ខ្ញុំអស់ហើយ ឥឡូវនេះ ភពថ្មី មិនមានទៀតឡើយ ។ ក្នុងកប្បទី ៣ ម៉ឺន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានទឹកឃ្មុំ ។ កិលេសទាំងឡាយ ខ្ញុំបានដុតចោលហើយ ភពទាំងអស់ ខ្ញុំបានដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមធុទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មធុទាយកត្ថេរាបទាន ។

# បញ្ចមំ បទុមកូដាគារិកត្ថេរាបទានំ

[៩៤] បិយទស្សី នាម ភគវា សយម្ភូ លោកនាយកោ
វិវេកកាមោ សម្ពុទ្ធោ សមាធិកុសលោ មុនិ ។
វនសណ្ឌំ សមោគយ្ហ បិយទស្សី មហាមុនិ
បំសុកូលំ បត្ថរិត្វា និសីទិ បុរិសុត្តមោ ។
មិគលុទ្ធោ បុរេ អាសឹ ឥរិនេ កាននេ អហំ
បសទំ មិគមេសន្តោ អាហិណ្ឌាមិ អហំ តទា ។
តត្ថទ្ទសាសឹ សម្ពុទ្ធំ ឱឃតិណ្ណំ អនាសវំ
បុប្ផិតំ សាលរាជំវ សតរំសីវ ឧគ្គតំ ។
និស្វានាហំ ទេវទេវំ បិយទស្សឹ មហាយសំ
ជាតសរំ សមោគយ្ហ បទុមំ អាហរឹ តទា ។
អាហរិត្វាន បទុមំ សតបត្តំ មនោរមំ
កូដាគារំ ករិត្វាន ឆាទយឹ បទុមេនហំ ។

# បទុមកូដាគារិកត្ថេរាបទាន ទី ៥

[៩៥] ព្រះភគវន្តសម្ពុទ្ធ ព្រះនាមបិយទស្សី ទ្រង់ត្រាស់ដឹងឯង ទ្រង់ជានាយកនៃសត្វលោក ទ្រង់ប្រាថ្នានូវសេចក្តីស្ងប់ស្ងាត់ ជាអ្នកប្រាជ្ញឆ្លៀវឆ្លាសក្នុងសមាធិ ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ជាបុរសខ្ពង់ខ្ពស់ ទ្រង់ចូលទៅកាន់ដងព្រៃ ទ្រង់ក្រាលនូវចីវរបំសុកូល ហើយគង់នៅហើយ ។ ក្នុងកាលនោះ ខ្ញុំបានកើតជាព្រានម្រឹគ ខ្ញុំកំពុងដើរស្វែងរកម្រឹគក្តាន់ ក្នុងព្រៃធំ ។ ខ្ញុំបានឃើញ ក្នុងព្រៃនោះ នូវព្រះសម្ពុទ្ធ ទ្រង់ឆ្លងនូវឱឃៈ មិនមានអាសវៈ ដូចដើមសាលរាជព្រឹក្សមានផ្ការីក ឬដូចព្រះអាទិត្យដែលរះឡើង ។ លុះខ្ញុំឃើញ នូវព្រះបិយទស្សីសម្ពុទ្ធ ទ្រង់មានយសច្រើន ជាទេវតាកន្លងទេវតា ក្នុងកាលនោះ ខ្ញុំក៏ចុះកាន់ជាតស្រះ ហើយបេះផ្កាឈូក ។ ខ្ញុំបេះនាំយកផ្កាឈូក ជាទីរីករាយនៃចិត្ត ហើយធ្វើនូវកូដាគារស្តាន ប្រក់ដោយផ្កាឈូក ។

អនុកម្បកោ ការុណិកោ បិយទស្សី មហាមុនិ
សត្ត រត្តិន្ទិវេ ពុទ្ធោ កូដាគារេ វសី ជិនោ ។
បុរាណំ ឆឌ្ឌយិត្វាន នវេន ឆាទយឹ អហំ
អញ្ជលឹ បគ្គហេត្វាន អដ្ឋាសឹ តាវទេ អហំ ។
វុដ្ឋហិត្វា សមាធិម្ហា បិយទស្សី មហាមុនិ
ទិសា អនុវិលោកេន្តោ និសីទិ លោកនាយកោ ។
តទា សុទស្សនោ នាម ឧបដ្ឋាកោ មហិទ្ធិកោ
ចិត្តមញ្ញាយ ពុទ្ធស្ស បិយទស្សិស្ស សត្ថុនោ ។
អសីតិយា សហស្សេហិ ភិក្ខូហិ បរិវារិតោ
វនន្តេ សុខមាសីនំ ឧបេសិ លោកនាយកំ ។
យាវតា វនសណ្ឌម្ហិ អធិវត្ថា ច ទេវតា
ពុទ្ធស្ស ចិត្តមញ្ញាយ សព្វេ សន្និបតុំ តទា ។
សមាគតេសុ យក្ខេសុ កុម្ភណ្ឌេ សហរក្ខសេ
ភិក្ខុសង្ឃេ ច សម្បត្តេ គាថា សព្យាហរី ជិនោ ។

ព្រះមហាមុនី ព្រះនាមបិយទស្សី ជិនស្រីសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីអនុគ្រោះ ប្រកបដោយករុណា ទ្រង់គង់ក្នុងកូដាគារស្ថាន អស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំបកផ្កាឈូកចាស់ចោលចេញ ហើយប្រក់ផ្កាឈូកថ្មីវិញ រួចឈរផ្គងអញ្ជលី ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ជាលោកនាយក ទ្រង់ចេញអំពីសមាធិ ហើយគង់ប្រមើលមើលទិសទាំងឡាយ ។ គ្រានោះ ព្រះថេរៈឈ្មោះសុទស្សនៈ ជាឧបដ្ឋាកមានរិទ្ធិច្រើន បានជ្រាបព្រះទ័យនៃព្រះបិយទស្សី សម្ពុទ្ធ ជាសាស្តា ។ ព្រះថេរៈនោះ មានភិក្ខុ ៨ ម៉ឺនចោមរោម ហើយចូលទៅគាល់ព្រះលោកនាយក ដែលគង់ជាសុខ ក្នុងទីបំផុតព្រៃ ។ ក្នុងកាលនោះ ទេវតាទាំងឡាយ ទាំងអស់ ដែលនៅអាស្រ័យក្នុងដងព្រៃ ទាំងប៉ុន្មាន បានដឹងព្រះទ័យ នៃព្រះសម្ពុទ្ធ ក៏មកប្រជុំគ្នា ។ កាលពួកយក្ស ពួកកុម្ភណ្ឌ ព្រមទាំងពួកអារក្ស មកប្រជុំគ្នាផង ភិក្ខុសង្ឃក៏បានមកដល់ព្រមផង ទើបព្រះជិនស្រី ទ្រង់ត្រាស់ព្រះគាថាទាំងឡាយថា

១៨៩

## បញ្ចមំ បទុមកូដាគារិកត្ថេរាបទានំ

យោ មំ សត្តាហំ បូជេសិ អាវាសញ្ច អាកាសិ មេ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
សុទុទ្ទសំ សុនិបុណំ គម្ភីរំ សុប្បកាសិតំ
ញាណេន កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
ចតុទ្ទសានិ កប្បានិ ទេវរជ្ជំ ករិស្សតិ
កូដាគារំ ព្រហន្តស្ស បទុមបុប្ផេហិ ឆាទិតំ ។
អាកាសេ ធារយិស្សន្តិ បុព្វកម្មស្សិទំ ផលំ
ចតុទ្ទសេ កប្បសតេ វោកិណ្ណំ សំសរិស្សតិ ។
តត្ថ បុប្ផមយំ ព្យម្ហំ អាកាសេ ធារយិស្សតិ
យថា បទុមបត្តម្ហិ តោយំ ន ឧបលិម្បតិ ។
តថេវិមស្ស ញាណម្ហិ កិលេសា នោបលិម្បរេ
មនសា វិនិវដ្ដេត្វា បញ្ចនីវរណេ អយំ ។
ចិត្តំ ជនេត្វា និក្ខម្មេ អគារា បព្វជិស្សតិ
តតោ បុប្ផមយំ ព្យម្ហំ ធារេន្តំ និក្ខមិស្សតិ ។

## បទុមកូដាគារិកត្ថេរាបទាន ទី ៥

កុលបុត្រណាបានបូជាតថាគតអស់ ៧ ថ្ងៃ ទាំងបានធ្វើអាវាសដល់តថាគត ៗ នឹងសរសើរកុលបុត្រនោះ អ្នកទាំង-ឡាយ ចូរប្រុងស្តាប់នូវភាសិត ដែលតថាគតនឹងសម្តែងចុះ ។ តថាគតនឹងសម្តែងនូវធម៌ ដ៏ល្អិតជ្រាលជ្រៅ ដែលបុគ្គលកម្រយល់ឃើញបានដោយងាយ ដែលតថាគតប្រកាសល្អហើយដោយញាណ អ្នកទាំងឡាយចូរប្រុងស្តាប់នូវភាសិតដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះនឹងបានគ្រប់គ្រងទេវរាជ្យអស់ ១៤ កប្ប ផ្ទះកំពូលដ៏ធំទូលាយ របស់ទេវតានោះ ប្រក់ដោយផ្កាឈូក ។ ផ្កាឈូកទាំងឡាយនឹងបាំងឰដ៏អាកាស នេះជាផលនៃបុញ្ញកម្ម បុរសនោះនឹងអន្ទោលទៅប្រឡូកប្រឡំ ក្នុងកប្បទី ១.៤០០ ។ វិមានជាវិការៈនៃផ្កានឹងបាំងនៅឰដ៏អាកាសនោះ ទឹកនឹងមិនជាប់ក្នុងស្លឹកឈូកយ៉ាងណា កិលេសទាំងឡាយ នឹងមិនជាប់ ក្នុងញាណរបស់បុរសនោះ យ៉ាងនោះដែរ បុរសនេះ នឹងញ៉ាំងនីវរណៈទាំង ៥ ឲ្យឃ្លាតចាកចិត្ត ។ បុរសនោះ នឹងញ៉ាំងចិត្តឲ្យកើតក្នុងនេក្ខម្មៈ ហើយចេញចាកផ្ទះទៅបួស លំដាប់នោះវិមានជាវិការៈនៃផ្កាដែលកំពុងបាំង ក៏នឹងចេញទៅតាមដែរ ។

រុក្ខមូលេ វសន្តស្ស　　និបកស្ស សតីមតោ
តត្ថ បុប្ផមយំ ព្យម្ហំ　　មត្ថកេ ធារយិស្សតិ ។
ចីវរំ បិណ្ឌបាតញ្ច　　បច្ចយំ សយនាសនំ
ទទិត្វា ភិក្ខុសង្ឃស្ស　　និព្វាយិស្សតិនាសវោ ។
កូដាគារេន ចរិតេ[១]　　បព្វជំ អភិនិក្ខមិ
រុក្ខមូលេ វសន្តំបិ　　កូដាគារំ ធរីយតិ ។
ចីវរេ បិណ្ឌបាតេ ច　　ចេតនា មេ ន វិជ្ជតិ
បុញ្ញកម្មេន សំយុត្តោ　　លភាមិ បរិនិដ្ឋិតំ ។
គណនាតោ អសង្ខេយ្យា　　កប្បកោដី ពហូ មម
រិត្តកា តេ អតិក្កន្តា　　សុមុត្តា លោកនាយកា ។
អដ្ឋារសេ កប្បសតេ　　បិយទស្សី វិនាយកោ
តមហំ បយិរុបាសិត្វា　　ឥមំ យោនឹ ឧបាគតោ ។
តមទ្ទសាមិ សម្ពុទ្ធំ　　អនោមំ នាម ចក្ខុមំ
តមហំ ឧបគន្ត្វាន　　បព្វជឹ អនគារិយំ ។

---
១ ម. ចរណា ។

ភិក្ខុនោះ មានប្រាជ្ញា មានស្មារតី កាលនៅទៀបគល់ឈើ វិមានជាវិការៈនៃផ្កា នឹងមកបាំងលើព្រះកេសក្នុងទីនោះ ។ ភិក្ខុនោះ នឹងឲ្យបច្ច័យគឺចីវរ បិណ្ឌបាត និងទីដេកទីអង្គុយ ដល់ភិក្ខុសង្ឃ ជាអ្នកមិនមានអាសវៈ ហើយនឹងបរិនិព្វាន ។ បុរសនោះ ចេញទៅកាន់បព្វជ្ជា ក្នុងដំណើរជាមួយនឹងផ្ទះកំពូល ឯផ្ទះកំពូលក៏ទ្រទ្រង់បាំងភិក្ខុនោះ ដែលនៅទៀបគល់ឈើ ។

ចេតនារបស់ខ្ញុំ មិនមានក្នុងចីវរ និងចង្ហាន់បិណ្ឌបាតទេ ខ្ញុំប្រកបដោយបុញ្ញកម្ម ទើបបាននូវការសម្រេច ។ ខ្ញុំមានជាតិកំណើត រាប់ដោយកោដិនៃកប្បជាច្រើន ព្រះលោកនាយកទាំងនោះ ទ្រង់មានព្រះហឫទ័យផុតស្រឡះ និព្វានកន្លងផុតទៅទទេ ៗ ។ ក្នុងកប្បទី ១.៨០០ ព្រះលោកនាយក ព្រះនាមបិយទស្សី (ទ្រង់ត្រាស់ឡើង) ទើបខ្ញុំបានមកចាប់កំណើតជាព្រានម្រឹគ បានចូលទៅគាល់ព្រះអង្គ ។ ឥឡូវនេះខ្ញុំឃើញព្រះគោតមសម្ពុទ្ធ មានបញ្ញាចក្ខុ ទ្រង់មិនថោកទាប ខ្ញុំក៏ទៅគាល់ព្រះអង្គ ហើយចូលទៅកាន់ផ្នួស ។

១៩១

## បញ្ចមំ បទុមកូដាគារិកត្ថេរាបទានំ

ទុក្ខស្សន្តំ ករោ ពុទ្ធោ     សទ្ធម្មោ[១] ទេសយី ជិនោ
តស្ស ធម្មំ សុណិត្វាន     បត្តោម្ហិ អចលំ បទំ ។
តោសយិត្វាន សម្ពុទ្ធំ     គោតមំ សក្យបុង្គវំ
សព្វាសវេ បរិញ្ញាយ     វិហរាមិ អនាសវោ ។
អង្គារសេ កប្បសតេ     យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ     ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ     ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា     នត្ថិទានិ បុនព្ភវោ ។
ស្វាគតំ វត មេ អាសិ     មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា     កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ     វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា     កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បទុមកូដាគារិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បទុមកូដាគារិកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ម. មគ្គំ មេ ។

## បទុមកូដាគារិកត្ថេរាបទាន ទី ៥

ព្រះពុទ្ធជិនស្រី ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ បានសម្តែងនូវព្រះសទ្ធម្ម ខ្ញុំស្តាប់ធម៌របស់ព្រះអង្គ ក៏បានដល់នូវអចលបទ គឺព្រះនិព្វាន ជាឋានមិនកម្រើក ។ ខ្ញុំបានញុំាងព្រះសម្ពុទ្ធព្រះនាមគោតម ជាពូជពង្សនៃសក្យៈ ឲ្យទ្រង់ត្រេកអរហើយកំណាត់ដឹង នូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ១.៨០០ ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះសម្ពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំង-ឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ! ដំណើរដែលមកក្នុងសម្នាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះសម្ពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបទុមកូដាគារិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បទុមកូដាគារិកត្ថេរាបទាន ។

# ឆដ្ឋំ ពក្កុលត្ថេរាបទានំ

[៩៦] ហិមវន្តស្សាវិទូរេ សោភិតោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ សកសិស្សេហិ មាបិតោ ។
មណ្ឌបា ច ពហូ តត្ថ បុប្ផិតា សិន្ទុវារិតា
កបិដ្ឋា ច ពហូ តត្ថ ចម្បកា នាគកេតកា[១] ។
និគុណ្ឌិយោ ពហូ តត្ថ ពទរាមលកានិ ច
ផារុសកា អលាពូ[២] ច បុណ្ឌរីកា ច បុប្ផិតា ។
អឡក្កា ពេលុវា[៣] តត្ថ កទលី មាតុលុង្គកា[៤]
មហានាមា ពហូ តត្ថ អជ្ជុនា ច បិយង្គុកា ។
កោសុម្ភា សលឡា នីបា និគ្រោធា ច កបិត្ថនា
ឯទិសោ អស្សមោ មយ្ហំ សសិស្សោហំ តហឹ វសឹ ។
អនោមទស្សី ភគវា សយម្ភូ លោកនាយកោ
គវេសំ បដិសល្លានំ មមស្សមំ ឧបាគមិ ។

១ ម. បុប្ផិកា ជីវជីវកា ។ ២ ម. អលាមិ ។ ៣ ម. អឡាកា ពេលិកា ។
៤ ម. មាតុលុង្គិកា ។

# ពក្កុលត្ថេរាបទាន ទី ៦

[៩៦] ភ្នំឈ្មោះសោភិតៈ នៅក្នុងទីជិតនៃព្រៃហិមពាន្ត អាស្រមដ៏ល្អរបស់ខ្ញុំ គឺពួកសិស្សរបស់ខ្ញុំកសាងហើយ ។ មណ្ឌបទាំងឡាយជាច្រើន ដើមឈើភ្ញើងមានផ្ការីក ក៏មានក្នុងទីនោះ ដើមខ្ទិត ដើមច្បា ដើមខ្នឹង ដើមរំចេក ក៏មានក្នុងទីនោះ ជាច្រើន ដើមចង្កើរទ្រាយ ដើមពុទ្រា ដើមកន្ទួតព្រៃ ដើមម៉ាក់ប្រាង វល្លិឃ្លោក ដើមស្វាយសមានផ្ការីក ក៏មានក្នុងទីនោះ ជាច្រើន ដើមរាក់ស ដើមល្ពៅ ដើមចេក ដើមក្រូចថ្លុង ក៏មានក្នុងទីនោះ ដើមជន្ទាត់ដៃ ដើមអង្រ្គង ដើមប្រិយង្គ ក៏មានច្រើនក្នុងទីនោះ ។ ដើមស្រូល ដើមស្រល់ ដើមកទម្ព ដើមជ្រៃក្រឹម ដើមក្រសាំង (ក៏មានក្នុងទីនោះ) អាស្រមរបស់ខ្ញុំប្រាកដយ៉ាងនេះ ខ្ញុំព្រមទាំងពួកសិស្ស ក៏នៅក្នុងអាស្រមនោះ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាសយម្ភូលោកនាយក ទ្រង់ស្វែងរកទីសម្រាប់ពួនសម្ងំ ស្តេចបានចូលមកកាន់អាស្រមរបស់ខ្ញុំ ។

១៩៣

## ឆដ្ឋំ ពក្កុលត្ថេរាបទានំ

ឧបេតញ្ច មហាវីរំ អនោមទស្សឹ មហាយសំ
ខណេន លោកនាថស្ស វាតាពាធោ សមុដ្ឋហិ ។
វិចរន្តោ អរញ្ញម្ហិ អទ្ទសំ លោកនាយកំ
ឧបគន្ត្វាន សម្ពុទ្ធំ ចក្ខុមន្តំ មហាយសំ ។
ឥរិយាបថញ្ច ទិស្វាន ឧបលក្ខេសហំ តទា
និស្សំសយំ ហិ ពុទ្ធស្ស ព្យាធិនោ ឧបបជ្ជថ ។
ខិប្បំ អស្សមមាគញ្ឆឹ មម សិស្សាន សន្តិកេ
ភេសជ្ជំ កត្តុកាមោហំ សិស្សំ អាមន្តយឹ តទា ។
បដិសុណិត្វាន មេ វាក្យំ សិស្សា សព្វេ សគារវា
ឯកជ្ឈំ សន្និបតឹសុ សត្ថុ គារវតា មម ។
ខិប្បំ បព្វតមារុយ្ហ សព្វោសថមកាសហំ
បានីយយោគំ កត្វាន ពុទ្ធសេដ្ឋស្សទាសហំ ។
បរិភុត្តេ មហាវីរេ សព្វញ្ញុលោកនាយកេ
ខិប្បំ វាតោ វូបសមិ សុគតស្ស មហេសិនោ ។

## ពក្កុលត្ថេរាបទាន ទី ៦

លុះព្រះអនោមទស្សី ព្រះអង្គមានព្យាយាមច្រើន មានយសធំ កំពុងស្ដេចចូលមក អាពាធបណ្ដាលអំពីខ្យល់ ក៏បានតាំងឡើងដល់ព្រះលោកនាថ ក្នុងមួយរំពេច ។ ខ្ញុំកាលត្រាច់ទៅក្នុងព្រៃ បានឃើញព្រះលោកនាយក ក៏ចូលមកជិតព្រះសម្ពុទ្ធទ្រង់មានចក្ខុ មានយសច្រើន ។ លុះខ្ញុំបានឃើញឥរិយាបថក៏កំណត់ទុកក្នុងកាលនោះថា ព្យាធិទាំងឡាយ ពិតជានឹងកើតដល់ព្រះពុទ្ធ ដោយឥតសង្ស័យ ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយប្រញាប់ប្រញាល់ ខ្ញុំមានបំណងនឹងធ្វើថ្នាំ ក្នុងសម្នាក់ពួកសិស្សរបស់ខ្ញុំ ខ្ញុំបានហៅពួកសិស្សក្នុងកាលនោះ ។ ពួកសិស្សទាំងអស់ ជាអ្នកមានសេចក្ដីគោរពបានទទួលស្ដាប់ពាក្យរបស់ខ្ញុំ ហើយមកប្រជុំ ក្នុងទីជាមួយគ្នា ព្រោះពួកសិស្សទាំងនោះ ជាអ្នកមានសេចក្ដីគោរពដល់ខ្ញុំជាគ្រូ ។ ខ្ញុំបានឡើងភ្នំជាប្រញាប់ ហើយបានធ្វើនូវឱសថទាំងអស់ ខ្ញុំធ្វើផ្សំនឹងទឹកសម្រាប់ផឹក បានថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ កាលព្រះសព្វញ្ញូ លោកនាយកមានព្យាយាមធំ កាលទ្រង់សោយហើយ រោគខ្យល់នៃព្រះសុគតទ្រង់ស្វែងរកគុណដ៏ធំ ក៏បានស្ងប់រម្ងាប់យ៉ាងឆាប់ ។

បស្សន្តំ ទវចំ ទិស្វា អនោមទស្សី មហាយសោ
សកាសនេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ អទាសិ ភេសជ្ជំ ព្យាធិញ្ច សមយី មម
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
កប្បសតសហស្សានិ ទេវលោកេ រមិស្សតិ
វាទិតេ តូរិយេ តត្ថ មោទិស្សតិ សទា អយំ ។
មនុស្សលោកមាគន្ត្វា សុក្កមូលេន ចោទិតោ
សហស្សក្ខត្តុំ រាជាបិ ចក្កវត្តិ ភវិស្សតិ ។
បញ្ចបញ្ញាសកប្បម្ហិ អនោមិ នាម ខត្តិយោ
ចាតុរន្តោ វិជិតាវី ជម្ពុទីបស្ស[១] ឥស្សរោ ។
សត្តរតនសម្បន្នោ ចក្កវត្តិ មហព្ពលោ
តាវត្តឹសេហិ ខោភេត្វា ឥស្សរំ ការយិស្សតិ ។
ទេវភូតោ មនុស្សោ វា អប្បាពាធោ ភវិស្សតិ
បរិទាហំ វិវជ្ជេត្វា ព្យាធឹ លោកេ តរិស្សតិ ។

---

១ ម. ជម្ពុមណ្ឌស្ស ។

ព្រះអនោមទស្សី មានយសច្រើន ទ្រង់ឃើញសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ទ្រង់គង់លើអាសនៈ របស់ព្រះអង្គ រួចទ្រង់ពោលនូវគាថាទាំងនេះថា បុរសណា បានប្រគេនភេសជ្ជៈ ដល់តថាគតផង បានរម្ងាប់ព្យាធិរបស់តថាគតផង តថាគតនឹងសរសើរបុរសនោះ អ្នកទាំងឡាយចូរស្តាប់ភាសិត ដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះនឹងត្រេកអរក្នុងទេវលោក អស់មួយសែនកប្ប នឹងរីករាយក្នុងការប្រគំតន្ត្រីក្នុងទេវលោកនោះ សព្វកាល ។ លុះត្រឡប់មកកាន់មនុស្សលោកវិញ ត្រូវកុសលមូលដាស់តឿន នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ។ ក្នុងកប្បទី ៥៥ បុរសនេះនឹងបានកើតជាក្សត្រសោយរាជ្យ ព្រះនាមអនោមិ ជាធំក្នុងជម្ពូទ្វីប ជាធំលើផែនដី ឈ្នះសង្គ្រាម មានសមុទ្រទាំង ៤ ជាទីបំផុត ។ នឹងបានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ញុំាងទេវតាក្នុងឋានតាវត្តិង្សឲ្យកម្រើក ហើយនឹងសោយនូវឥស្សរភាព ។ បុរសនេះ ទោះនឹងកើតជាទេវតាក្តី ជាមនុស្សក្តី នឹងមិនមានអាពាធ នឹងវៀរបង់នូវព្យាធិ ជាគ្រឿងក្តៅក្រហាយ ក្នុងលោក ។

## ឆដ្ឋំ ពក្កុលត្ថេរាបទានំ

អបរិមេយ្យេ ឥតោ កប្បេ  ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន  សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ  ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ  និព្វាយិស្សតិនាសវោ ។
កិលេសេ ឈាបយិត្វាន  តណ្ហាសោតំ តរិស្សតិ
ពក្កុលោ នាម នាមេន  ហេស្សតិ សត្ថុសាវកោ ។
ឥទំ សព្វំ អភិញ្ញាយ  គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា  ឯតទគ្គេ ឋបេស្សតិ ។
អនោមទស្សី ភគវា  សយម្ភូ លោកនាយកោ
វិវេកមនុលោមេន្តោ  មមស្សមំ ឧបាគមិ ។
ឧបាគតំ មហាវីរំ  សព្វញ្ញុំ លោកនាយកំ
សព្វោសថេន តប្បេសឹ  បសន្នោ សេហិ បាណិភិ ។

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះសាស្តាព្រះនាម គោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ ទ្រង់ត្រាស់ ឡើងក្នុងលោក ។ ឯបុរសនេះ នឹងបានជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះសាស្តានោះ ជាឱរសដែលធម៌និម្មិតហើយ ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈនឹង បរិនិព្វាន ។ បុរសនេះ នឹងជុតនូវកិលេសទាំងឡាយ ហើយ ធ្វើនូវខ្សែនៃតណ្ហា នឹងបានទីជាសាវ័កនៃព្រះសាស្តា ឈ្មោះ ពក្កុលៈ ។ ព្រះមានព្រះភាគ ព្រះនាមគោតម ជាសក្យៈប្រ- សើរ ទ្រង់បានជ្រាបនូវដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួក ភិក្ខុ នឹងតាំងពក្កុលភិក្ខុក្នុងទីជាឯតទគ្គៈ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាសយម្ភូ លោកនាយក ទ្រង់ប្រមើល មើលសេចក្តីស្ងប់ស្ងាត់ ក៏បានស្តេចចូលមកអាស្រម របស់ ខ្ញុំ ។ លុះព្រះសព្វញ្ញូ ជាលោកនាយក ទ្រង់មានព្យាយាមធំ ស្តេចចូលមកដល់ហើយ ខ្ញុំក៏ជ្រះថ្លាបានញុំាងព្រះអង្គឲ្យធាន់ ធ្អេតស្កប់ស្កល់ ដោយឱសថទាំងពួង ដោយដៃរបស់ខ្លួន ។

តស្ស មេ សុកតំ កម្មំ    សុខេត្តេ ពីជសម្បទា
ខេបេតុំ នេវ សក្កោមិ    តទា ហិ សុកតំ មម ។
លាភា មម សុលទ្ធំ មេ    យោហំ អទ្ទក្ខិំ នាយកំ
តេន កម្មវិសេសេន    បត្តោម្ហិ អចលំ បទំ ។
សព្វមេតំ អភិញ្ញាយ    គោតមោ សក្យបុង្គវោ
ភិក្ខុសង្ឃេ និសីទិត្វា    ឯតគ្គេ ឋបេសិ មំ ។
អបរិមេយ្យេ ឥតោ កប្បេ    យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ    ភេសជ្ជស្ស ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា    នត្ថិ ទានិ បុនព្ភវោ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

ខ្ញុំនោះបានធ្វើអំពើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ល្អ ខ្ញុំមិនអាច ញុំាងអំពើដែលខ្ញុំធ្វើល្អហើយ ក្នុងកាលនោះ ឲ្យអស់ទៅបាន ព្រោះការដល់ព្រមដោយពូជ ។ ខ្ញុំឈ្មោះថាមានលាភ អត្ត-ភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ត្បិតខ្ញុំបានឃើញ ព្រះនាយក ខ្ញុំក៏បានដល់នូវអចលបទគឺព្រះនិព្វាន ដោយសំ-ណល់នៃកម្មនោះឯង ។ ព្រះគោតមជាសក្យៈដ៏ប្រសើរ ទ្រង់ បានជ្រាបដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយ តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្ប នេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេស ទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោល ហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុង សម្នាក់នៃព្រះសម្ពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំ បានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

១៩៧

សត្តមំ គិរិមានន្ទត្ថេរាបទានំ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា ពក្កុលោ[១] ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ពក្កុលត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ គិរិមានន្ទត្ថេរាបទានំ

[៩៧] ភរិយា មេ កាលំ កតា បុត្តោ សីវថិកំ គតោ
មាតា បិតា ច ភាតា ច ឯកចិតម្ហិ ឌយ្ហរេ ។
តេន សោកេន សន្តត្តោ កិសោ បណ្ឌុ អហោសហំ
ចិត្តក្ខេបញ្ច មេ អាសិ តេន សោកេន អដ្ដិតោ ។
សោកសល្លបរេតោបិ វនន្តំ ឧបសង្កមឹ
បវត្តផលំ ភុញ្ជិត្វា រុក្ខមូលេ វសាមហំ ។
សុមេធោ នាម សម្ពុទ្ធោ ទុក្ខស្សន្តំ ករោ ជិនោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ មម សន្តិកេ ។

១ ម. ពាកុលោ ។

*បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះពក្កុលត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ ពក្កុលត្ថេរាបទាន ។

# គិរិមានន្ទត្ថេរាបទាន ទី ៧

[៩៧] *ភរិយារបស់ខ្ញុំ ធ្វើមរណកាលហើយ កូនប្រុសរបស់ខ្ញុំ ទៅកាន់ព្រៃស្មសានហើយ មាតា បិតា និងបងប្រុស គេដុតលើជើងថ្ករតែមួយ ។ ខ្ញុំមានខ្លួនក្តៅសព្វ ស្គមស្ញេកស្ញាំង ព្រោះតែសេចក្តីសោកនោះ មិនតែប៉ុណ្ណោះ ចិត្តរបស់ខ្ញុំ ក៏ក្រឡុកច្នួត ខ្ញុំត្រូវសេចក្តីសោកនោះ គ្របសង្កត់ហើយ ។ ខ្ញុំលុះត្រូវសរ គឺសេចក្តីសោកគ្របសង្កត់ហើយ ក៏បានចូលទៅកាន់ទីជាយព្រៃ បរិភោគតែផ្លែឈើដែលជ្រុះ ហើយនៅទៀបគល់ឈើ ។ ព្រះសម្ពុទ្ធជិនស្រី ព្រះនាមសុមេធៈ ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ ព្រះអង្គមានប្រាថ្នានឹងស្រង់ខ្ញុំ ទើបស្តេចមក ក្នុងសម្នាក់របស់ខ្ញុំ ។*

បទសទ្ទំ សុណិត្វាន សុមេធស្ស មហេសិនោ
បគ្គហេត្វានហំ សីសំ ឱលោកេសឹ មហាមុនឹ ។
ឧបគញ្ឆិ មហាវីរោ[១] បីតិ មេ ឧបបជ្ជថ
តទាសិ មេកគ្គមនោ ទិស្វា តំ លោកនាយកំ ។
សតឹ បដិលភិត្វាន បណ្ណមុដ្ឋឹ អទាសហំ
និសីទិ ភគវា តត្ថ អនុកម្បាយ ចក្ខុមា ។
និសជ្ជ តត្ថ ភគវា សុមេធោ លោកនាយកោ
ធម្មំ មេ កថយិ ពុទ្ធោ សោកសល្លវិនោទនំ ។
អនវ្ហាតា តតោ អាគា នានុញ្ញាតា ឥតោ គតា
យថា គតា តថា គតា តត្ថ កា បរិទេវនា ។
យថាបិ បត្តិកា សត្តា វស្សមានាយ វុដ្ឋិយា
សភត្តេ[២] ឧបគច្ឆន្តិ វស្សាយ បតនាយ តេ ។

---

១ ម. ឧបាគតេ មហាវីរេតិ ទិស្សន្តិ ។ ២ ម. សភណ្ឌា ។

ខ្ញុំលុះឮសូរព្រះបាទ នៃព្រះសុមេធសម្ពុទ្ធជាមហេសី ក៏បាន ងើកក្បាលរមិលមើលព្រះមហាមុនី ។ ព្រះសម្មាសម្ពុទ្ធទ្រង់ មានព្យាយាមធំ ស្តេចបានចូលមកជិតខ្ញុំ ខ្ញុំក៏មានបីតិកើត ឡើង គ្រានោះ ខ្ញុំឃើញព្រះលោកនាយកនោះហើយ ជា អ្នកមានចិត្តតាំងនៅ ក្នុងអារម្មណ៍តែមួយ ។ ខ្ញុំត្រឡប់បាន ស្មារតីវិញ បានប្រគេនស្លឹកឈើមួយក្តាប់ ព្រះមានព្រះភាគ មានបញ្ញាចក្ខុ ទ្រង់គង់ក្នុងទីនោះ ដោយសេចក្តីអនុគ្រោះ ។

ព្រះសុមេធសម្ពុទ្ធមានជោគ ជាលោកនាយក លុះគង់ ក្នុងទីនោះហើយ ទ្រង់សម្តែងធម៌ជាគ្រឿងបន្ទោបង់នូវសរ គឺ សេចក្តីសោករបស់ខ្ញុំថា សត្វទាំងឡាយមកអំពីភពនោះ ក៏អ្នក មិនបានហៅមក ដល់ទៅអំពីភពនេះវិញ ក៏អ្នកមិនបានអនុ-ញ្ញាតឲ្យទៅ គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ការខ្សឹក ខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកសត្វស្វាបទាំងឡាយ កាលភ្លៀងបង្អុរចុះ ក៏នាំគ្នាហើរចូល ព្រោះចំណីរបស់ខ្លួន សត្វទាំងនោះ ហើរចូលទៅ ត្រឹមតែភ្លៀងកំពុងធ្លាក់ចុះ ។

១៩៩

## សត្តមំ គិរិមានន្ទត្ថេរាបទានំ

វស្សេរ តេ ឱរមិតេ សម្បយន្តិ យថិច្ឆកំ
ឯវំ មាតាបិតា តុយ្ហំ តត្ថ កា បរិទេវនា ។
អាគន្តុកា បាហុនកា ចលិតេជិតកម្បិតា
ឯវំ តាមាបិតា តុយ្ហំ តត្ថ កា បរិទេវនា ។
យថាបិ ឧរគោ ជិណ្ណំ ហិត្វា គច្ឆតិ សន្តនុំ
ឯវំ មាតាបិតា តុយ្ហំ សន្តនុំ ឥធ ហិយ្យរេ ។
ពុទ្ធស្ស គិរមញ្ញាយ សោកសល្លំ វិវជ្ជយឹ
បាមុជ្ជំ ជនយិត្វាន ពុទ្ធសេដ្ឋំ អវន្ទហំ ។
វន្ទិត្វាន មហានាគំ គិរិមញ្ញវិ បូជយឹ
និព្វតគ្គេន សម្ពុទ្ធំ សុមេធំ លោកនាយកំ ។
បូជយិត្វាន សម្ពុទ្ធំ សិរេ កត្វាន អញ្ជលឹ
អនុស្សរំ គុណគ្គានិ សន្ថវឹ លោកនាយកំ ។
វិតិណ្ណោសិ មហាវីរ សព្វញ្ញូ លោកនាយកោ
សព្វេ សត្តេ ឧទ្ធរេសិ ញាណេន ត្វំ មហាមុនេ ។

គិរិមានន្ទត្ថេរាបទាន ទី ៧

កាលភ្លៀងរាំងហើយ សត្វទាំងឡាយនោះ ក៏ហើរទៅកាន់ទីតាមប្រាថ្នា យ៉ាងណាមិញ មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពួកភ្ញៀវដែលទើបមកដល់ថ្មី ៗ រមែងកម្រើកញាប់ញ័រ ក្នុងកាលទៅវិញយ៉ាងណា មាតាបិតារបស់អ្នក ក៏យ៉ាងនោះដែរ ការខ្សឹកខ្សួលទៅរកជនទាំងនោះធ្វើអ្វី ។ ពស់សកសំណកចាស់ចោលហើយលូនទៅ យ៉ាងណា មាតាបិតារបស់អ្នក តែងតែលះបង់រាងកាយចោលក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

ខ្ញុំកាលបានដឹងព្រះវាចានៃព្រះពុទ្ធ ក៏លះបង់នូវសរ គឺសេចក្តីសោកបាន ហើយញ៉ាំងប្រាមោទ្យឲ្យកើត បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ លុះខ្ញុំថ្វាយបង្គំព្រះមហានាគ ហើយបូជានូវផ្កាឈើក្អិ ដ៏បរិបូណ៌ដោយក្លិនជាទិព្វ ចំពោះព្រះលោកនាយក ព្រះនាមសុមេធៈ ។ ខ្ញុំបូជាព្រះសម្ពុទ្ធរួចធ្វើអញ្ជលីលើត្បូង រលឹកនូវគុណដ៏ប្រសើរ សរសើរព្រះលោកនាយកថា បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាសព្វញ្ញូលោកនាយក ទ្រង់ឆ្លងនូវវាលវដ្តសង្សារហើយ បពិត្រមហាមុនី ព្រះអង្គទ្រង់ស្រង់សត្វទាំងពួង ដោយញាណ ។

វិមតឹ ទ្វេឡ្ហកំ វាបិ សញ្ឆិន្ទសិ មហាមុនេ
បដិបាទេសិ មេ មគ្គំ តវ ញាណេន ចក្ខុម ។
អរហា សិទ្ធិបត្តា ច ឆឡភិញ្ញា មហិទ្ធិកា
អន្តលិក្ខចរា ធីរា បរិវារេន្តិ តាវទេ ។
បដិបន្នា ច សេខា ច ផលដ្ឋា សន្តិ សាវកា
សូរោទយេវ បទុមា បុប្ផន្តិ តវ សាវកា[១] ។
មហាសមុទ្ទោ វក្ខោភោ អតុលោបិ ទុរុត្តរោ
ឯវំ ញាណេន សម្បន្នោ អប្បមេយ្យោសិ ចក្ខុម ។
វន្ទិត្វាហំ លោកជិនំ ចក្ខុមន្តំ មហាយសំ
ចតុទ្ទិសា នមស្សន្តោ បដិកុដិកោ អគញ្ឆហំ ។
ទេវលោកា ចវិត្វាន សម្បជានោ បដិស្សតោ
ឱក្កមឹ មាតុយា កុច្ឆឹ សន្ធារេន្តោ ភវាភវេ ។

---
១ ម. សន្តិកេ ។

បពិត្រព្រះមុនី ព្រះអង្គទ្រង់ផ្តាច់បង់នូវសេចក្តីងឿងឆ្ងល់ និង សេចក្តីសង្ស័យ បពិត្រព្រះអង្គមានចក្ខុ ព្រះអង្គទ្រង់ញុំាង មគ្គផលឲ្យសម្រេចដល់ខ្ញុំ ដោយញាណ របស់ព្រះអង្គ ។ ព្រះអរហន្តទាំងឡាយ ដែលដល់នូវសេចក្តីសម្រេច បាន អភិញ្ញា ៦ មានឫទ្ធិច្រើន ត្រាច់ទៅក្នុងអាកាសបាន ជា អ្នកប្រាជ្ញ តែងចោមរោម ក្នុងខណៈនោះ ។ សាវ័កទាំង-ឡាយ កំពុងប្រតិបត្តិក្តី ជាសេក្ខបុគ្គលក្តី ឋិតនៅក្នុងផលក្តី សាវ័ករបស់ព្រះអង្គទាំងនោះ បែកផ្កាហើយ ដូចផ្កាឈូក ក្នុងពេលព្រះអាទិត្យទើបនឹងរះ ។ មហាសមុទ្រមិនកម្រើក ជ្រៅថ្លឹងមិនបាន កម្របុគ្គលឆ្លងបាន យ៉ាងណា បពិត្រព្រះ អង្គមានចក្ខុ ព្រះអង្គបរិបូណ៌ដោយញាណ ប្រមាណមិន បាន ក៏យ៉ាងនោះ ។ ខ្ញុំថ្វាយបង្គំព្រះជិនស្រីមានចក្ខុ មាន យសច្រើន ហើយនមស្ការទិសទាំង ៤ ក៏ដើរថយក្រោយ ទៅ ។ កាលខ្ញុំច្យុតចាកទេវលោក អន្ទោលទៅក្នុងភពតូច ភពធំ ចុះមកចាប់ផ្ទៃនៃមាតា ជាអ្នកដឹងខ្លួន មានស្មារតី ។

២០១

## សត្តមំ គិរិមានន្ទត្ថេរាបទានំ

អគារា អភិនិក្ខម្ម បព្វជឹ អនគារិយំ
អាតាបី និបកោ ចាបិ បដិសល្លានគោចរោ ។
បធានំ បទហិត្វាន តោសយិត្វា មហាមុនឹ
ចង្កោរព្គយធា មុត្តោ វិចរាមិ អហំ សធា ។
វិវេកមនុយុត្តោម្ហិ ឧបសន្តោ និរូបធិ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
តីសកប្បសហស្សម្ហិ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
សព្វាសវា បរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

គិរិមាននន្ទត្ថេរាបទាន ទី ៧

ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស មានព្យាយាមកម្ចាត់បង់ កិលេស មានប្រាជ្ញាចាស់ មានការពួនសម្ងំជាគោចរ ។ ក្នុងកាលនោះ ខ្ញុំតាំងសេចក្ដីព្យាយាម ញុំាងព្រះមហាមុនីឲ្យត្រេកអរ ហើយប្រព្រឹត្តទៅ ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។ ខ្ញុំជាអ្នកប្រកបរឿយ ៗ នូវវិវេក ស្ងប់ស្ងាត់ ឥតមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៣ ម៉ឺន ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធ-បូជា ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះសម្ពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំបានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា គិរិមានន្ទោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

គិរិមានន្ទត្ថេរស្ស អបទានំ សមត្តំ ។

# អដ្ឋមំ សលឡមណ្ឌបិយត្ថេរាបទានំ

[៩៨] និព្វុតេ កកុសន្ធម្ហិ ព្រាហ្មណម្ហិ វុសីមតេ
គហេត្វា សលឡំ មាលំ មណ្ឌបំ ការយឹ អហំ ។
តាវតឹសំ គតោ សន្តោ លភាមិ ព្យម្ហមុត្តមំ
អញ្ញេ ទេវេ អភិភោមិ[១] បុញ្ញកម្មស្សិទំ ផលំ ។
ទិវា វា យទិ វា រត្តឹ ចង្កមន្តោ ឋិតោ ចហំ
ឆន្នោ សលឡបុប្ផេហិ បុញ្ញកម្មស្សិទំ ផលំ ។
ឥមស្មឹយេវ កប្បម្ហិ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ម. ទេវេតិរោចាមិ ។

បានឮថា ព្រះគិរិមានន្ទត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ គិរិមានន្ទត្ថេរាបទាន ។

# សលឡមណ្ឌបិយត្ថេរាបទាន ទី ៨

[៩៨] កាលព្រះកកុសន្ធៈ ទ្រង់បានបន្សាត់បាប បានអប់រំព្រហ្មចរិយធម៌ ហើយទ្រង់បរិនិព្វានទៅ ខ្ញុំបានយកកម្រងផ្កាស្រល់មកធ្វើជាមណ្ឌប ។ ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្សបាននូវវិមានដ៏ឧត្តម គ្របសង្កត់នូវទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ខ្ញុំកាលដើរទៅមកក្តី ឈរក្តី ក្នុងវេលាថ្ងៃឬក្នុងវេលាយប់ ផ្កាស្រល់តែងគ្របបិទបាំងខ្ញុំ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បនេះឯង ព្រោះហេតុដែលខ្ញុំបានបូជានូវព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្ទឹង ។

២០៣

នវមំ សព្វទាយកត្ថេរាបទានំ

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា សលឡមណ្ឌបិយោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

សលឡមណ្ឌបិយត្ថេរស្ស អបទានំ សមត្តំ ។

# នវមំ សព្វទាយកត្ថេរាបទានំ

[៩៩] មហាសមុទ្ទមោគយ្ហ ភវនំ មេ សុនិម្មិតំ
សុនិម្មិតា បោក្ខរណី ចក្កវាកុបកូជិតា ។
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
នទី ច សន្ទតេ តត្ថ សុបតិត្ថា មនោរមា ។

ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡមណ្ឌបិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សលឡមណ្ឌបិយត្ថេរាបទាន ។

# សព្វទាយកត្ថេរាបទាន ទី ៩

[៩៩] លំនៅរបស់ខ្ញុំលយចូលទៅក្នុងមហាសមុទ្រ ដែលបុញ្ញកម្មនិម្មិតល្អ ហើយស្រះបោក្ខរណី ដែលបុញ្ញកម្មនិម្មិតល្អហើយ ជាស្រះមានពួកសត្វចាក្រពាកយាសយំ ដេរដាសដោយដើមចន្ទុលណីផង ដោយផ្កាឈូកនិងផ្កាឧប្បលផង ស្ទឹងតាំងនៅដ៏ល្អ ជាទីរីករាយនៃចិត្ត តែងហូរចុះក្នុងស្រះបោក្ខរណីនោះ ។

មច្ឆកច្ឆបសញ្ឆន្នា នានាមិគសមោត្ថតា[១]
មយូរកោញ្ចាភិរុទា កោកិលាទីហិ វគ្គុហិ ។
ចារេវតា រវិហំសា ចក្កវាកា នទីចរា
ទិន្ទិភា សាលិកា ចេត្ថ ចប្បកា ជីវជីវកា ។
ហំសា កោញ្ចាភិនទិកា កោសិយា សិង្គលា ពហូ
សត្តរតនសម្បន្នា មណិមុត្តិកវាលុកា ។
សព្វសោណ្ណមយា រុក្ខា នានាគន្ធសមេរិតា
ឧជ្ជោតេន្តិ ទិវា រត្តឹ ភវនំ សព្វកាលិកំ ។
សដ្ឋី តុរិយសហស្សានិ សាយំ ចាតោ បវជ្ជរេ
សោឡសិត្ថីសហស្សានិ បរិវារេន្តិ មំ សទា ។
អភិនិក្ខម្ម ភវនា សុមេធំ លោកនាយកំ
បសន្នចិត្តោ សុមនោ វន្ទិយ[២] តំ មហាយសំ ។

---

១ ម. នានាទិជសមោត្ថតា ។ ២ ម. វន្ទិយឹ ។

ស្រះនោះ ដេរដាសដោយត្រីនិងអណ្តើក ជាទីប្រជុំនៃម្រឹគផ្សេង ៗ គឹកកងដោយសំឡេង នៃក្ងោកនិងក្រៀល មួយអន្ទើដោយសត្វទាំងឡាយ មានសត្វតាវៅជាដើម ដែលមានសំឡេងពីរោះ ។ ពួកសត្វ ព្រាប ប្រវឹក ចាក្រពាកក្អែកទឹក ត្រដេវរ៉ិច សាលិកា ចង្អៀលខ្យង ប៉ោលតោក (មានកុះករ) ក្នុងស្រះនោះ ។ ពួកសត្វហង្ស ក្រៀល ខ្វែងស្រាក គ្រលេងគ្រលោង ដ៏ច្រើន តែងបន្លឺសូរស័ព្ទកងរំពងស្រះនោះបរិបូណ៌ដោយកែវ ៧ ប្រការ មានដីខ្សាច់ជាវិការៈនៃកែវមណី និងកែវមុក្តា ។ ពួកដើមឈើជាវិការៈនៃមាសទាំងអស់ មានក្លិនផ្សេង ៗ ផ្សាយចេញទៅ ញុំាងលំនៅ (របស់ខ្ញុំ) ឲ្យរុងរឿង ទាំងថ្ងៃទាំងយប់ សព្វ ៗ កាល ។ តូរ្យតន្ត្រី ៦ ម៉ឺន មកប្រគំរាល់វេលាល្ងាចព្រឹក ស្រី ៗ ១ ម៉ឺន ៦ ពាន់ តែងមកចោមរោមខ្ញុំសព្វ ៗ កាល ។ ខ្ញុំចេញអំពីលំនៅ មានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះសុមេធៈ ជាលោកនាយក ដ៏មានយសធំអង្គនោះ ។

២០៨

## នវមំ សព្វទាយកត្ថេរាបទានំ

សម្ពុទ្ធំ អភិវាទេត្វា    សសិស្សន្តំ[១] និមន្តយឹ
អធិវាសេសិ សោ ធីរោ    សុមេធោ លោកនាយកោ ។
មម ធម្មកថំ កត្វា    ឧយ្យោជេសិ មហាមុនិ
សម្ពុទ្ធំ អភិវាទេត្វា    ភវនំ មេ ឧបាគមឹ ។
អាមន្តយឹ បរិជនំ    សព្វេ សន្និបតាថ ភោ
បុព្វណ្ហសមយំ ពុទ្ធោ    ភវនំ អាគមិស្សតិ ។
លាភា អម្ហំ សុលទ្ធា នោ    យេ វសាម តវន្តិកេ
មយំបិ ពុទ្ធសេដ្ឋស្ស    បូជំ កស្សាម សត្ថុនោ ។
អន្នបានំ បដ្ឋបេត្វា    កាលំ អារោចយឹ អហំ
វសីសតសហស្សេហិ    ឧបេសិ លោកនាយកោ ។
សង្គីតេហិ[២] តុរិយេហិ    បច្ចុគ្គមនកាសហំ
សព្វសោណ្ណមយេ បីឋេ    និសីទិ បុរិសុត្តមោ ។
ឧបរិច្ឆទនំ អាសិ    សព្វសោណ្ណមយំ តទា
វីជនិយោ បវាយន្តិ    ភិក្ខុសង្ឃស្ស អន្តរេ ។

---

១ ម. សសង្ឃំ តំ ។ ២ ម. បញ្ចង្គិកេហិ ។

លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយ និមន្តព្រះអង្គព្រមទាំងសិស្ស ព្រះសុមេធៈជាលោកនាយក ជាអ្នកប្រាជ្ញអង្គនោះ ទ្រង់បានទទួលនិមន្តន៍ ។ ព្រះមហាមុនី ទ្រង់ធ្វើធម្មកថាដល់ខ្ញុំ ហើយបញ្ជូនខ្ញុំទៅ ខ្ញុំក៏បានថ្វាយបង្គំព្រះសម្ពុទ្ធ ចូលទៅឯលំនៅរបស់ខ្ញុំ ។ ខ្ញុំបានហៅជនជាបរិស័ទមកថា អ្នកទាំងអស់គ្នាចូរប្រជុំគ្នា ព្រះសម្ពុទ្ធទ្រង់នឹងយាងមកកាន់លំនៅ (របស់យើង) ក្នុងបុព្វណ្ហសម័យ យើងឈ្មោះថាមានលាភហើយ អត្តភាពជាមនុស្ស ឈ្មោះថាយើងបានល្អហើយ ព្រោះយើងនៅរួមគ្នាយ៉ាងនេះ យើងនឹងធ្វើការបូជាដល់ព្រះពុទ្ធដ៏ប្រសើរជាសាស្តា ខ្ញុំនឹងតម្កល់បាយនិងទឹក ហើយក្រាបទូលនូវកត្តកាល ។ ព្រះលោកនាយក បាននិមន្តចូលទៅជាមួយនឹងភិក្ខុមួយសែនអង្គ ជាអ្នកស្ងាត់ក្នុងឈាន ។ ខ្ញុំបានធ្វើនូវការក្រោកទទួល ព្រមទាំងមានតូរ្យតន្ត្រីនិងចម្រៀង ប្រគំជាកិត្តិយសផង ព្រះពុទ្ធជាបុរសឧត្តម ទ្រង់គង់លើតាំង ជាវិការៈនៃមាសទាំងអស់ ។ ដំបូលខាងលើ ជាវិការនៃមាសទាំងអស់ក្នុងកាលនោះ ផ្ចិតទាំងឡាយ ក៏បក់ក្នុងចន្លោះនៃភិក្ខុសង្ឃ ។

បហូតេនន្នបានេន ភិក្ខុសង្ឃំ អតប្បយឹ
បច្ចេកទុស្សយុគលេ ភិក្ខុសង្ឃស្សទាសហំ ។
យំ វទន្តិ សុមេធោតិ លោកាហុតិបដិគ្គហោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ អន្នញ្ច បានញ្ច សព្វមេតេន តប្បយិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
អដ្ឋារសេ កប្បសតេ ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
ឧបបជ្ជតិ យំ យោនឹ ទេវត្តំ អថ មានុសំ
សព្វទា សព្វសោវណ្ណំ ឆទនំ ធារយិស្សតិ ។
តឹសកប្បសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។

ខ្ញុំបានញ៉ាំងភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹកដ៏ច្រើន ខ្ញុំបានប្រគេនសំពត់មួយគូ ៗ ផ្សេង ៗ គ្នា ដល់ភិក្ខុសង្ឃ ។ ជនទាំងឡាយ ហៅព្រះពុទ្ធអង្គណាថា សុមេធៈ ព្រះពុទ្ធអង្គនោះ ទ្រង់ទទួលការបូជារបស់សត្វលោក ទ្រង់គង់ក្នុងកណ្តាលភិក្ខុសង្ឃ បានពោលគាថាទាំងនេះថា

បុរសណា បានឲ្យតថាគតឆាន់កត្តស្កប់ស្កល់ ដោយបាយនិងទឹកទាំងអស់នេះ តថាគតនឹងសរសើរនូវបុរសនោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ នូវពាក្យរបស់តថាគត ដែលនឹងសម្តែងចុះ ។ ក្នុងកប្បទី ១.៨០០ បុរសនេះ នឹងរីករាយក្នុងទេវលោក នឹងបានជាស្តេចចក្រពត្តិ មួយពាន់ជាតិ ។ នឹងកើតក្នុងកំណើតណា ទោះជាទេវតាឬជាមនុស្ស នឹងមានដំបូល ជាវិការៈនៃមាសទាំងអស់បិទបាំង សព្វ ៗ កាល ។ កន្លងពីនេះទៅ ៣ ម៉ឺនកប្បទៀត ព្រះសាស្តា ទ្រង់ព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលនៃឱក្កាករាជ នឹងត្រាស់ឡើងក្នុងលោក ។ បុរសនេះ ជាអ្នកទទួលមត៌ក ក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ បានកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

## នវមំ សព្វទាយកត្ថេរាបទានំ

ភិក្ខុសង្ឃេ និសីទិត្វា សីហនាទំ នទិស្សតិ
ចិតកេ ឆត្តំ ធារេន្តិ ហេដ្ឋាឆត្តម្ហិ ឌយ្ហថ ។
សាមញ្ញំ មេ អនុប្បត្តំ កិលេសា ឈាបិតា មយា
មណ្ឌបេ រុក្ខមូលេ វា សន្តាចា មេ ន វិជ្ជតិ ។
តឹសកប្បសហស្សម្ហិ យំ ទានមទទិន្តទា
ទុគ្គតឹ នាភិជានាមិ សព្វទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សព្វទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

សព្វទាយកត្ថេរស្ស អបទានំ សមត្តំ ។

សព្វទាយកត្ថេរាបទាន ទី ៩

បុរសនេះ នឹងអង្គុយកណ្តាលភិក្ខុសង្ឃហើយ បន្លឺនូវសីហនាទថា ជនទាំងឡាយតែងបាំងឆត្រលើជើងថ្ករ អ្នកទាំងឡាយ ចូរដុតក្នុងខាងក្រោមនៃឆត្រចុះ ។

សាមញ្ញគុណ ខ្ញុំបានដល់ហើយ កិលេសទាំងឡាយខ្ញុំដុតចោលហើយ ខ្ញុំមិនមានសេចក្តីក្តៅក្រហាយក្នុងមណ្ឌប ឬទៀបគល់ឈើឡើយ ។ ក្នុងកប្បទី ៣ ម៉ឺន ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសព្វទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីកាត់ទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសព្វទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សព្វទាយកត្ថេរាបទាន ។

# ទសមំ អជិតត្ថេរាបទានំ

[១០០] បទុមុត្តរោ នាម ជិនោ    សព្វធម្មាន បារគូ
អជ្ឈោគហេត្វា ហិមវន្តំ    និសីទិ លោកនាយកោ ។
នាហំ អទ្ទក្ខិំ សម្ពុទ្ធំ    នាបិ សទ្ទំ សុណោមហំ
មម ភិក្ខំ គវេសន្តោ    អាហិណ្ឌាមិ វនេ អហំ ។
តត្ថទ្ទសាមិ សម្ពុទ្ធំ    ទ្វត្តឹសវរលក្ខណំ
ទិស្វាន ចិត្តមាបជ្ជឹ[១]    សត្តោ កោ នាមយំ ភវេ ។
លក្ខណានិ វិលោកេត្វា    មម វិជ្ជំ អនុស្សរឹ
សុតំ ហិ មេតំ ពុទ្ធានំ    បណ្ឌិតានំ សុភាសិតំ ។
តេសំ យថា តំ វចនំ    អយំ ពុទ្ធោ ភវិស្សតិ
យន្នូន តំ សក្ករេយ្យំ    គតឹ មេ សោធយិស្សតិ ។
ខិប្បំ អស្សមមាគន្ត្វា    មធុតេលំ គហឹ អហំ
កោលម្ពកំ គហេត្វាន    ឧបគញ្ឆឹ វិនាយកំ ។

---
១ ម. វិត្តិមាបជ្ជឹ ។

# អជិតត្ថេរាបទាន ទី ១០

[១០០] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាលោកនាយក ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ស្តេចចូលទៅក្នុងព្រៃហិមពាន្ត ហើយគង់នៅ ។ ខ្ញុំមិនធ្លាប់ស្គាល់ព្រះសម្ពុទ្ធ ទាំងមិនធ្លាប់ឮសូរស័ព្ទគេប្រាប់អំពីព្រះអង្គ ខ្ញុំកំពុងដើរស្វែងរកភិក្ខាក្នុងព្រៃដើម្បីខ្លួនខ្ញុំ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ក្នុងព្រៃនោះ លុះឃើញហើយក៏មានសេចក្តីត្រិះរិះថា សត្វនេះ ជាអ្វីហ្ន៎ ។ ខ្ញុំខំពិនិត្យមើលលក្ខណៈទាំងឡាយ ក៏បាននឹកឃើញ នូវវិជ្ជារបស់ខ្ញុំថា សុភាសិតនេះ ខ្ញុំបានឮមកអំពីសម្នាក់ នៃព្រះពុទ្ធជាអ្នកប្រាជ្ញ ។ បុរសនេះ ជាក់ជាព្រះពុទ្ធ សមដូចពាក្យនៃព្រះពុទ្ធទាំងនោះ បើដូច្នោះ អាត្មាអញគប្បីធ្វើសក្ការៈចំពោះព្រះអង្គ ព្រះអង្គនឹងញ៉ាំងគតិរបស់អញឲ្យស្អាត ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយរួសរាន់ ហើយកាន់យកទឹក-ឃ្មុំ ប្រេង និងថ្លាង ដើរចូលទៅជិតព្រះលោកនាយក ។

២០៩

## ទសមំ អជិតត្ថេរាបទានំ

តិទណ្ឌកេ គហេត្វាន  អញ្ញោកាសេ ឋបេសហំ
បទីបំ បជ្ជលិត្វាន  អដ្ឋក្ខត្តុំ អវន្ទហំ ។
សត្តរត្តិន្ទិវំ ពុទ្ធោ  និសីទិ បុរិសុត្តមោ
តតោ រត្យា វិវសនេ  វុដ្ឋាសិ លោកនាយកោ ។
បសន្នចិត្តោ សុមនោ  សព្វរត្តិន្ទិវំ អហំ
ទីបំ ពុទ្ធស្ស បាទាសឹ  បសន្នោ សេហិ បាណិភិ ។
សព្វេ គន្ធា វនមយា  បព្វតេ គន្ធមាទនេ
ពុទ្ធស្ស អានុភាវេន  អាគច្ឆុំ ពុទ្ធសន្តិកេ ។
យេ កេចិ បុប្ផគន្ធា សេ  បុប្ផិតា ធរណីរុហា
ពុទ្ធស្ស អានុភាវេន  សព្វេ សន្និបតុំ តទា ។
យាវតា ហិមវន្តម្ហិ  នាគា ច គរុឡា ឧភោ
ធម្មញ្ច សោតុកាមា តេ  អាគច្ឆុំ ពុទ្ធសន្តិកេ ។
ទេវលោ នាម សមណោ  ពុទ្ធស្ស អគ្គសាវកោ
វសីសតសហស្សេហិ  ពុទ្ធសន្តិកុបាគមិ ។

អជិតត្ថេរាបទាន ទី ១០

ខ្ញុំបានកាន់យកឈើ ៣ កំណាត់ មកតម្កល់ទុកក្នុងទីវាល ហើយអុជប្រទីប ថ្វាយបង្គំអស់ ៨ លើក ។ ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម ជាលោកនាយក ទ្រង់គង់អស់ ៧ យប់ ៧ ថ្ងៃ លំដាប់តអំពីនោះមក ទ្រង់ក្រោកចាកអាសនៈ ក្នុងវេលាជាទីអស់នៃរាត្រី ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ អស់យប់និងថ្ងៃទាំងអស់ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយប្រទីបដល់ព្រះពុទ្ធដោយដៃរបស់ខ្លួន ។ គ្រឿងក្រអូបទាំងពួង ដែលកើតក្នុងព្រៃ មាននៅលើភ្នំគន្ធមាទន៍ ក៏មកក្នុងសម្នាក់នៃព្រះពុទ្ធដោយអានុភាពនៃព្រះពុទ្ធ ។ ឈើណាមួយ ដែលមានផ្ការីក ហើយមានផ្កាក្រអូប ឈើទាំងអស់នោះ ប្រជុំគ្នាហើយក្នុងកាលនោះ ដោយអានុភាពនៃព្រះពុទ្ធ ។ នាគនិងគ្រុឌទាំងឡាយ ទាំងអម្បាលម៉ាន (ដែលនៅ) ក្នុងព្រៃហិមពាន្តសត្វទាំងពីរពួកនោះ មានប្រាថ្នាដើម្បីស្តាប់ធម៌ បាននាំគ្នាមកក្នុងសម្នាក់នៃព្រះពុទ្ធ ។ សមណៈឈ្មោះទេវលៈ ជាអគ្គសាវ័កនៃព្រះពុទ្ធ បានចូលមកកាន់សម្នាក់ នៃព្រះពុទ្ធជាមួយនឹងភិក្ខុមួយសែនអង្គ ដែលជាអ្នកស្ទាត់ក្នុងឈាន ។

បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ ទីបំ បទីបេសិ បសន្នោ សេហិ បាណិភិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
សដ្ឋី កប្បសហស្សានិ ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។

សោឡសមំ ភាណវារំ ។

ឆត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
បឋវិយំ សត្តសតំ វិបុលំ រជ្ជំ ករិស្សតិ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ឥមិនា ទីបទានេន ទិព្វចក្ខុ ភវិស្សតិ ។
សមន្តតោ អឌ្ឍកោសំ បស្សិស្សតិ អយំ សទា
ទេវលោកា ចវន្តស្ស និព្វត្តន្តស្ស ជន្តុនោ ។
ទិវា វា យទិ វា រត្តឹ បទីបំ ធារយិស្សតិ

ព្រះបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់គង់នៅក្នុងកណ្ដាលនៃពួកភិក្ខុ ហើយបានត្រាស់គាថាទាំងនេះថា

បុរសណាជ្រះថ្លា ហើយញុំាងប្រទីបឲ្យភ្លឺ ដោយដៃរបស់ខ្លួន ដើម្បីតថាគត តថាគតនឹងសរសើរ នូវបុរសនោះ អ្នកទាំងឡាយ ចូរប្រុងស្ដាប់នូវពាក្យរបស់តថាគតដែលនឹងសម្ដែងចុះ ។ បុរសនេះ នឹងរីករាយក្នុងទេវលោក អស់ ៦ ម៉ឺនកប្ប នឹងបានសោយរាជ្យ ជាស្ដេចចក្រពត្តិ អស់មួយពាន់ដង ។

ចប់ ភាណវារៈ ទី ១៦ ។

បុរសនេះនឹងបានជាធំជាងទេវតា នឹងសោយរាជ្យ ក្នុងទេវលោក អស់ ៣៦ ដង នឹងសោយរាជ្យដ៏ធំទូលាយ លើផែនដី អស់ ៧០០ ដង ។ នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប នឹងបានជាអ្នកមានចក្ខុជាទិព្វ ដោយផលនៃទីបទាននេះ ។ បុរសនេះ នឹងមើលឃើញ អស់ទីកន្ទះក្រោសជុំវិញ សព្វកាល កាលបើបុរសនេះ ច្យុតចាកទេវលោក ហើយមកកើត (ក្នុងមនុស្សលោក) នឹងមានគេទ្រទ្រង់ប្រទីបឲ្យ ទាំងយប់ទាំងថ្ងៃ ។

២១១

ទសមំ អជិតត្ថេរាបទានំ

ជាយមានស្ស សន្តស្ស បុញ្ញកម្មស្សមត្តោ ។
យាវតា នគរំ អាសិ តាវតា ជោតយិស្សតិ
ឧបបជ្ជតិ យំ យោនឹ ទេវត្តំ អថ មានុសំ ។
អស្សេវ ទីបទានស្ស អដ្ឋទីបផលេន ច
ឧបដ្ឋិស្សន្តិមំ ជន្តុំ ទីបទានស្សិទំ ផលំ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
តោសយិត្វាន សម្ពុទ្ធំ គោតមំ សក្យបុង្គវំ
អជិតោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
សដ្ឋិកប្បសហស្សានិ ទេវលោកេ រមឹ អហំ
តត្រាបិ មេ ទីបសតំ ជោតតេ និច្ចកាលិកំ ។
ទេវលោកេ មនុស្សេ វា និទ្ធាវន្តិ បភា មម
ពុទ្ធសេដ្ឋំ សរិត្វាន ភិយ្យោ ហាសំ ជនេសហំ ។

អជិតត្ថេរាបទាន ទី ១០

កាលបើបុរសអ្នកប្រកបដោយបុញ្ញកម្មនេះ កើតឡើង ទីក្រុង ត្រឹមណា នឹងភ្លឺរន្ទាលត្រឹមនោះ ។ បុរសនេះ ចាប់កំណើត ណា ទោះជាទេវតា ឬជាមនុស្ស ជនទាំងឡាយ នឹងបម្រើ បុរសនេះ ដោយអំណាចនៃទីបទាននោះផង ដោយផលនៃ ប្រទីប ៨ ផង នេះជាផលនៃទីបទាន ។ កន្លងទៅមួយសែន កប្បទៀត ព្រះសាស្តា ព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុង ត្រកូលនៃស្តេចឱក្កាកៈ នឹងត្រាស់ក្នុងលោក ។ បុរសនេះ ជាអ្នកទទួលមត៌កក្នុងធម៌ របស់ព្រះគោតមនោះ ជាឱរស ដែលធម៌និម្មិត នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិន មានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងបានជាសាវ័ក នៃព្រះសាស្តា ឈ្មោះអជិត នឹងញ៉ាំងព្រះសម្ពុទ្ធ ព្រះនាម គោតម ជាសក្យៈដ៏ប្រសើរ ឲ្យត្រេកអរ ។

ខ្ញុំត្រេកអរហើយ ក្នុងទេវលោក អស់ ៦ ម៉ឺនកប្ប ខ្ញុំមានប្រទីបចំនួនមួយរយ តែងភ្លឺរុងរឿង អស់កាលជានិច្ច ក្នុងទីនោះ ។ រស្មីរបស់ខ្ញុំ តែងផ្សាយទៅ ក្នុងទេវ-លោក ឬក្នុងមនុស្សលោក ខ្ញុំរលឹកឃើញ នូវព្រះពុទ្ធដ៏ ប្រសើរ ហើយញ៉ាំងសេចក្តីរីករាយក្រៃពេកឲ្យកើតឡើង ។

តុសិតាហំ ចវិត្វាន ឱក្កមឹ មាតុកុច្ឆិយា
ជាយមានស្ស សន្តស្ស អាលោកោ វិបុលោ អហុ ។
អគារា អភិនិក្ខម្ម បព្វជឹ អនគារិយំ
ពារឹ ឧបសង្កម្ម សិស្សត្តំ អជ្ឈុបាគមឹ ។
ហិមវន្តេ វសន្តោហំ អស្សោសឹ លោកនាយកំ
ឧត្តមត្ថំ គវេសន្តោ ឧបគញ្ឆឹ វិនាយកំ ។
ទន្តោ ពុទ្ធោ ទមេតាបិ ឱឃតិណ្ណោ និរូបធិ
និព្វានំ កថយិ ពុទ្ធោ សព្វទុក្ខា បមោចនំ ។
តម្ហេ អាគមនំ សិទ្ធំ តោសិតោហំ មហាមុនឹ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
សតសហស្សេ ឥតោ កប្បេ យំ ទីបំ អទទិន្តទា
ទុគ្គតឹ នាភិជានាមិ ទីបទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ខ្ញុំច្យុតចាកឋានតុសិត មកចាប់ផ្ទៃនៃមាតា កាលខ្ញុំកំពុងកើត ពន្លឺដ៏ធំទូលាយកើតប្រាកដឡើង ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស រួចចូលទៅរកពាវរីព្រាហ្មណ៍ ហើយដល់នូវភាពជាសិស្សនៃព្រាហ្មណ៍នោះ ។ កាលខ្ញុំនៅក្នុងព្រៃហិមពាន្ត បានឮនូវព្រះលោកនាយក កាលខ្ញុំស្វែងរកប្រយោជន៍ដ៏ឧត្តម បានចូលទៅគាល់ព្រះលោកនាយក ។ ព្រះសម្ពុទ្ធទ្រង់ជាអ្នកទូន្មាន បានទូន្មានខ្ញុំហើយ ទ្រង់ធ្វើឱ្យៈ មិនមានឧបធិក្កិលេស ព្រះសម្ពុទ្ធទ្រង់សម្តែងព្រះនិព្វាន ជាធម៌ញុំាងសត្វឲ្យរួចចាកទុក្ខទាំងពួង ។ ដំណើរមករបស់ខ្ញុំនោះ សម្រេចហើយ ខ្ញុំបានញុំាងព្រះមហាមុនី ឲ្យត្រេកអរហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យប្រទីប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលទីបទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្លីង ។

២១៣

ឧទ្ទានំ

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អជិតោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

អជិតត្ថេរស្ស អបទានំ សមត្តំ ។

# ឧទ្ទានំ

បិលិន្ទវច្ឆោ សេលោ ច សព្ពកិត្តមជ្ជនោ
កុដាគារី ពក្កុលោ ច គិរិសលឡស្សវ្ហយោ ។
សព្ពោ អជិតោ ចេវ គាថាយោ គណិតា វិសា
សតានិ បញ្ច គាថានំ វីសតិ ច តទុត្តរិ ។

បិលិន្ទវគ្គោ ចត្តាឡីសោ ។

ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអជិតត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អជិតត្ថេរាបទាន ។

# ឧទ្ទាន

បិលិន្ទវច្ឆត្ថេរាបទាន ១ សេលត្ថេរាបទាន ១ សព្វកិត្តិកត្ថេរាបទាន ១ មធុទាយកត្ថេរាបទាន ១ បទុមកូដាគារិកត្ថេរាបទាន ១ ពក្កុលត្ថេរាបទាន ១ គិរិមានន្ទត្ថេរាបទាន ១ សលឡមណ្ឌបិយត្ថេរាបទាន ១ សព្វទាយកត្ថេរាបទាន ១ អជិតត្ថេរាបទាន ១ ឯគាថា លោករាប់ឃើញ បាន ៥២៥ គាថា ។

ចប់ បិលិន្ទវគ្គ ទី ៤០ ។

# អថ វគ្គុទ្ទានំ

បទុមារក្ខទោ ចេវ ឧម្មា តណ្ហោងកោឯ ច
ឯកប្បុងសទ្ទសញ្ញី មន្ទារំ ពោធិវន្ទកោ ។
អម្ពជញ្ចា បិលិន្ទី ច គាថាយោ គណិតាបិច
ចតុសត្តតិ គាថាយោ ឯកាឯសសតានិ ច ។

បទុមវគ្គទសកំ ។

ចតុត្ថំ សតកំ សមត្តំ ។

---

# មួយទៀត ឧទ្ទាននៃវគ្គ

*បទុមកេសរិយវគ្គ ១ អារក្ខទាយកវគ្គ ១ ឧម្មាបុប្ផិយវគ្គ ១ គន្ធោទកវគ្គ ១ ឯកបទុមវគ្គ ១ សទ្ទសញ្ញិកវគ្គ ១ មន្ទារវ-បុប្ផិយវគ្គ ១ ពោធិវន្ទនវគ្គ ១ អម្ពដផលវគ្គ ១ បិលិន្ទវគ្គ ១ ចំណែកគាថា លោករាប់ឃើញបាន ១.១៧៤ គាថា ។*

ចប់ បទុមវគ្គទសកៈ ។

ចប់ សតកៈ ទី ៤ ។

---

# ឯកចត្តាឡីសមោ មេត្តេយ្យវគ្គោ

## បឋមំ តិស្សមេត្តេយ្យត្ថេរាបទានំ

[១០១] បព្ភារកូដំ និស្សាយ សោភិតោ នាម តាបសោ
បវត្តផលំ ភុញ្ជិត្វា វសតិ[១] បព្វតន្តរេ ។
អគ្គិទារុំ អាហរិត្វា ឧជ្ជលេសឹ អហំ តទា
ឧត្តមត្ថំ គវេសន្តោ ព្រហ្មលោកូបបត្តិយា ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
មមុទ្ធរិតុកាមោ សោ អាគញ្ឆិ មម សន្តិកេ ។
កឹ ករោសិ មហាបុញ្ញ ទេហិ មេ អគ្គិទារុកំ
អហំ អគ្គឹ បរិចរេ តតោ មេ សុទ្ធិ ហោហិតិ ។
សុភទ្ទកោ ត្វំ មនុជ[២] ទេវតេ ត្វំ បជានសិ[៣]
តុវំ អគ្គឹ បរិចរ ហន្ទ តេ អគ្គិ ទារុកំ ។

---
១ វសាមីតិ ភវិតព្វំ ។ ២ ម. មុនុជេ ។ ៣ ម. បជានាតិ ។

# មេត្តេយ្យវគ្គ ទី ៥១

## តិស្សមេត្តេយ្យត្ថេរាបទាន ទី ១

[១០១] ខ្ញុំជាតាបសឈ្មោះសោភិតៈ អាស្រ័យនៅចុងញកភ្នំ បរិភោគតែផ្លែឈើដែលជ្រុះឯង នៅក្នុងចន្លោះភ្នំ ។ កាលនោះ ខ្ញុំកំពុងស្វែងរកប្រយោជន៍ដ៏ឧត្តម ដើម្បីនឹងឲ្យបានកើតក្នុងព្រហ្មលោក ខ្ញុំបាននាំយកឧសសម្រាប់ដុតភ្លើងមកដុតឲ្យឆេះ ។ ព្រះបទុមុត្តរៈ ជាលោកវិទូ ទ្រង់គួរទទួលនូវគ្រឿងបូជា ព្រះអង្គមានបំណងនឹងស្រោចស្រង់ខ្ញុំ ស្តេចពុទ្ធដំណើរ មកក្នុងសម្នាក់ខ្ញុំ (ទើបត្រាស់សួរថា)

ម្នាលអ្នកមានបុណ្យធំ អ្នកធ្វើអ្វី អ្នកចូរឲ្យឧសសម្រាប់ដុតភ្លើងមកតថាគត តថាគតនឹងបម្រើភ្លើង សេចក្តីស្អាតនឹងមានដល់តថាគត ព្រោះការបម្រើភ្លើងនោះ ។ ម្នាលអ្នកជាមនុស្ស អ្នកជាមនុស្សល្អ ម្នាលទេវតា អ្នកចូរស្គាល់ចុះ អ្នកចូរបង្កាត់ភ្លើងចុះ ហ៏! នេះឧសសម្រាប់បង្កាត់ភ្លើងរបស់អ្នក ។

តតោ កដ្ឋំ គហេត្វាន អគ្គឹ ឧជ្ជាលយី ជិនោ
ន តត្ថ កដ្ឋំ បជ្ជាយិ ចាជិហោរំ មហេសិនោ ។
ន តេ អគ្គិ បជ្ជលតិ អាហុតិ តេ ន វិជ្ជតិ
និរត្ថកំ ច តំ តុយ្ហំ អគ្គឹ បរិចរស្សុ មេ ។
កីទិសោ តេ មហាវីរ អគ្គិ តវ បរុច្ចតិ
មយ្ហំបិ កថយស្សេតំ ឧភោ បរិចរាមសេ ។
ហេតុធម្មនិរោធាយ កិលេសឈាបនាយ ច[1]
ឥស្សាមច្ឆរិយំ ហិត្វា តយោ ឯតេ មមាហុតី ។
កីទិសោ តុំ មហាវីរ កថំគោត្តោសិ មារិស
អាចារប្បដិបត្តិ តេ ពាឡ្ហំ ខោ មម រុច្ចតិ ។
ខត្តិយម្ហិ កុលេ ជាតោ អភិញ្ញាបារមី គតោ
សព្វាសវបរិក្ខីណោ នត្ថិទានិ បុនព្ភវោ ។

---

១ ម. កិលេសសមណាយ ច ។

បន្ទាប់មក ព្រះជិនស្រី ទ្រង់កាន់យកឧស ហើយបង្កាត់ភ្លើងឲ្យឆេះឡើង ឯឧសក៏មិនឆេះក្នុងទិនោះ ព្រោះអាស្រ័យបាដិហារ្យរបស់ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទើបទ្រង់ត្រាស់ថា ភ្លើងរបស់អ្នកក៏មិនឆេះ គ្រឿងបូជារបស់អ្នកក៏មិនមានដែរ អំពើរបស់អ្នកនោះ ជារបស់ឥតប្រយោជន៍ អ្នកចូរបម្រើភ្លើង របស់តថាគតវិញចុះ ។

បពិត្រព្រះអង្គជាមហាវីរបុរស សភាវៈអ្វី ដែលព្រះអង្គហៅថាភ្លើង របស់ព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់នូវសភាវៈនុ៎ះ ដល់ខ្ញុំ យើងទាំងពីរនាក់ នឹងបម្រើភ្លើង ។

ការរលត់ធម៌ដែលជាហេតុ ១ ការដុតបំផ្លាញកិលេស ១ ការលះបង់ឥស្សានិងមច្ឆរិយៈ ១ ទាំង ៣ នេះ ឈ្មោះថាភ្លើងជាគ្រឿងបូជា របស់តថាគត ។

បពិត្រព្រះអង្គជាមហាវីរបុរស ព្រះអង្គជាអ្វី បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាគោត្រអ្វី អាចារៈ និងសេចក្តីប្រតិបត្តិ របស់ព្រះអង្គ ខ្ញុំគាប់ចិត្តពេកណាស់ ។

តថាគតកើត ក្នុងត្រកូលក្សត្រ ដល់នូវត្រៃយអភិញ្ញា អស់អាសវៈទាំងពួងហើយ ឥឡូវនេះ មិនមានភពថ្មីទេ ។

២១៧

## បឋមំ តិស្សមេត្តេយ្យត្ថេរាបទានំ

យទិ ពុទ្ធោសិ សព្វញ្ញូ  បភង្ករ តមោនុទ
នមស្សិស្សាមិ តំ ទេវ  ទុក្ខស្សន្តំ ករោ តុវំ ។
បត្ថរិត្វា ជិនចម្មំ  និសីទនមទាសហំ
និសីទ តត្ថ សព្វញ្ញូ  ឧបដ្ឋិស្សាមហំ តុវំ ។
និសីទិ ភគវា តត្ថ  អជិនម្ហិ សុវិត្ថតេ
និមន្តយិត្វា សម្ពុទ្ធំ  បព្វតំ អគមាសហំ ។
ខារិភារញ្ច បូរេត្វា  តិន្ទុកផលមាហរឹ
មធុនា យោជយិត្វាន  ផលំ ពុទ្ធស្សទាសហំ ។
មម និជ្ឈាយមានស្ស  បរិភុញ្ជិ តទា ជិនោ
តត្ថ ចិត្តំ បសាទេសិ  បេក្ខន្តោ លោកនាយកំ ។
បទុមុត្តរោ លោកវិទូ  អាហុតីនំ បដិគ្គហោ
មមស្សមេ និសីទិត្វា  ឥមា គាថា អភាសថ ។
យោ មេ ផលេន តប្បេសិ  បសន្នោ សេហិ បាណិភិ
តមហំ កិត្តយិស្សាមិ  សុណាថ មម ភាសតោ ។

តិស្សមេត្តេយ្យត្ថេរាបទាន ទី ១

បពិត្រព្រះអង្គទ្រង់ធ្វើនូវពន្លឺ ទ្រង់កម្ចាត់បង់ងងឹត បើព្រះអង្គ ជាព្រះពុទ្ធមែន បពិត្រព្រះអង្គ ជាទេវតា ខ្ញុំនឹងនមស្ការព្រះអង្គ ព្រះអង្គធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ។

ទើបខ្ញុំក្រាលស្បែកខ្លាជាកម្រាល ហើយអារាធនាថា បពិត្រព្រះអង្គជាសព្វញ្ញូ សូមព្រះអង្គគង់លើកម្រាលនោះចុះ ខ្ញុំនឹងបម្រើព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់គង់លើស្បែកខ្លានោះ ដែលខ្ញុំក្រាលល្អហើយ ខ្ញុំនិមន្តព្រះសម្ពុទ្ធរួចហើយក៏ដើរចូលទៅក្នុងព្រៃភ្នំ ។ ខ្ញុំញ៉ាំងភារៈគឺអម្រែកឲ្យពេញហើយទៅនាំយកផ្លែទន្លាប់ ថ្វាយផ្លែទន្លាប់ចំពោះព្រះសម្ពុទ្ធ លាយដោយទឹកឃ្មុំ ។ គ្រានោះ កាលខ្ញុំសម្លឹងមើល ព្រះជិនសិរីក៏ទ្រង់សោយ ខ្ញុំកំពុងសម្លឹងមើលព្រះលោកនាយក ញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះលោកនាយកនោះ ។

ព្រះបទុមុត្តរៈ ជាលោកវិទូ ទ្រង់គួរទទួលនូវគ្រឿងបូជា ស្តេចគង់នៅនាអាស្រមរបស់ខ្ញុំ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណា ជ្រះថ្លា ឲ្យតថាគតឆាន់ផ្លែឈើដោយដៃ របស់ខ្លួន តថាគត នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់ តថាគតនឹងសម្តែងចុះ ។

បញ្ចវីសតិក្ខត្តុំ សោ ទេវរជ្ជំ ករិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
តស្ស សង្កប្បមញ្ញាយ បុព្វកម្មសមង្គិនោ
អន្នចានញ្ច វត្ថញ្ច សយនញ្ច មហារហំ ។
បុញ្ញកម្មេន សំយុត្តា និព្វត្តិស្សន្តិ តាវទេ
សទា សម្មុទិតោ[១] ចាយំ ភវិស្សតិ អនាមយោ ។
ឧបបជ្ជតិ យំ យោនឹ ទេវត្តំ អថ មានុសំ
សព្វត្ថ សុខិតោ ហុត្វា មនុស្សត្តំ ភវិស្សតិ ។
អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន ចារគូ
សម្ពុទ្ធំ ឧបគន្ត្វាន អរហា សោ ភវិស្សតិ ។
យតោ សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
ភោគេ មេ ឩនតា នត្ថិ ផលទានស្សិទំ ផលំ ។
រាគទោសេ សមូហនឹ
វជេម្មមនុប្បត្តោ
សព្វាសវបរិក្ខីណោ នត្ថិ ទានិ បុនព្ភវោ ។

---

១ ម. បមោទិតោ ។

បុគ្គលនោះ នឹងបានសោយរាជ្យ ជាស្តេចទេវតា អស់ ២៥ ដង នឹងបានជាស្តេចចក្រពត្តិ មួយពាន់ដង ។ បាយទឹក សំពត់ និងទីដេក ដ៏មានថ្លៃច្រើន ប្រកបហើយដោយបុញ្ញកម្ម ហាក់ដូចដឹងបំណងរបស់បុគ្គល អ្នកប្រកបដោយបុញ្ញកម្ម នឹងកើតឡើង ក្នុងខណៈនោះ ។ បុគ្គលនេះ នឹងរីករាយ ជាអ្នកមិនមានរោគ សព្វ ៗ កាល ។ បុគ្គលនេះ បើទៅកាន់កំណើតណា ទោះជាទេវតា ឬជាមនុស្ស នឹងជាអ្នកដល់នូវសេចក្តីសុខ ក្នុងទីទាំងពួង ។ បុគ្គលនោះ នឹងជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ដល់នូវត្រើយនៃត្រៃវេទ នឹងបានចូលទៅគាល់ព្រះសម្ពុទ្ធហើយ នឹងបានជាព្រះអរហន្ត ។

ខ្ញុំរលឹកឃើញនូវខ្លួនក្នុងកាលណា ដល់នូវភាពជាអ្នកដឹងក្តីក្នុងកាលណា កាលនោះ ខ្ញុំមិនមានសេចក្តីខ្វះខាត ដោយភោគៈឡើយ នេះជាផលនៃការថ្វាយផ្ទៃទន្ទាប់ ។ ខ្ញុំបានដល់នូវធម៌ដ៏ប្រសើរ គាស់រំលើងនូវរាគៈ ទោសៈ មោហៈហើយ អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតទេ ។

២១៩



កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិស្សមេត្តេយ្យោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិស្សមេត្តេយ្យត្ថេរស្ស អបទានំ សមត្តំ ។

# ទុតិយំ បុណ្ណកត្ថេរាបទានំ

[១០២] បព្ភារកូដំ និស្សាយ សយម្ភូ អបរាជិតោ
អាពាធិកោ ច សោ ពុទ្ធោ វសតិ បព្វតន្តរេ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិស្សមេត្តេយ្យត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិស្សមេត្តេយ្យត្ថេរាបទាន ទី ១ ។

# បុណ្ណកត្ថេរាបទាន ទី ២

[១០២] ព្រះពុទ្ធជាសយម្ភូ ទ្រង់ឈ្នះមារ គង់នៅក្នុងចន្លោះភ្នំដែលនៅអែបចុងញក ព្រះអង្គមានអាពាធ ក្នុងទីនោះ ។

មម អស្សមសាមន្តា បជាយោ អាសិ តាវទេ
ពុទ្ធេ និព្វាយមានម្ហិ អាលោកោ អាសិ តាវទេ ។
យាវតា វនសណ្ឌាស្មឹ អច្ឆកោកតរច្ឆយោ
ពាឡា ច កេសរី សព្វេ អភិកុជ្ជឹសុ[១] តាវទេ ។
ឧប្បាតំ តមហំ ទិស្វា បព្ភារំ អគមាសហំ
តត្ថទ្ទសាសឹ សម្ពុទ្ធំ និព្វុតំ អបរាជិតំ ។
សុផុល្លំ សាលរាជំវ សតរំសីវ ឧគ្គតំ
វីតច្ចិតំវ អង្គារំ និព្វុតំ អបរាជិតំ ។
តិណំ កដ្ឋញ្ច បូរេត្វា ចិតកំ តត្ថកាសហំ
ចិតកំ សុកតំ កត្វា សរីរំ ឈាបយឹ អហំ ។
សរីរំ ឈាបយិត្វាន គន្ធតោយំ សមោកិរឹ
អន្តលិក្ខេ ឋិតោ យក្ខោ នាមំ អគ្គហិ តាវទេ ។

១ ម. អភិគជ្ជឹសុ ។

កាលព្រះពុទ្ធស្តេចបរិនិព្វានហើយ សំឡេងគឹកកង កើតមាន ជុំវិញអាស្រមរបស់ខ្ញុំ ក្នុងខណៈនោះ ពន្លឺក៏កើតឡើងក្នុង វេលានោះដែរ ។ ពួកសត្វសាហាវទាំងពួង គឺខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន និងកេសររាជសីហ៍ ក្នុងដងព្រៃទាំងអម្បាលម៉ាន ក៏បន្លឺសំឡេងឡើង ក្នុងខណៈនោះដែរ ។ ខ្ញុំបានឃើញ សេចក្តីអស្ចារ្យនោះកើតហើយ ក៏ចូលទៅកាន់ញកភ្នំ បាន ឃើញព្រះសម្ពុទ្ធ ទ្រង់ឈ្មោះមារ ស្តេចបរិនិព្វានហើយ ត្រង់ ញកភ្នំនោះ ។ (លុះខ្ញុំឃើញ) នូវព្រះសម្ពុទ្ធ ទ្រង់ឈ្មោះមារ ដែលបរិនិព្វានហើយ ទ្រង់ដូចជាសាលរាជព្រឹក្ស ដែលមាន ផ្ការីក ឬដូចជាព្រះអាទិត្យ ដែលទើបនឹងរះឡើង ពុំនោះ សោត ដូចជារងើកភ្លើង ដែលឥតមានអណ្តាត ។ ខ្ញុំបាន ធ្វើជើងថ្ករ បំពេញស្មៅនិងឧស ក្នុងទីនោះ លុះខ្ញុំធ្វើជើងថ្ករ ដ៏វិចិត្ររួចហើយ ក៏បូជាសរីរសព ។ លុះខ្ញុំបូជាសរីរសព រួចហើយ ក៏ស្រោចស្រពនូវទឹកអប់លើព្រះធាតុ ខណៈនោះ ទេវតា ដែលឋិតនៅឰដ៏អាកាស កាន់យកនូវឈ្មោះ(ខ្ញុំ) ថា

២២១

## ទុតិយំ បុណ្ណកត្ថេរាបទានំ

តំ បូរិតំ[១] តយា កិច្ចំ សយម្ភុស្ស មហេសិនោ
បុណ្ណកោ នាម នាមេន យថា ហោសិ តុវំ មុនេ ។
តស្មា កាយា ចវិត្វាន ទេវលោកំ អគច្ឆហំ
តត្ថ ទិព្វមយោ គន្ធោ អន្តលិក្ខា បវស្សតិ ។
តត្រាបិ នាមធេយ្យំ មេ បុណ្ណកោតិ អហូ តទា
ទេវភូតោ មនុស្សោ វា សង្កប្បំ បូរយាមហំ ។
ឥទំ បច្ឆិមកំ មយ្ហំ ចរិមោ វត្តតី ភវោ
ឥធាបិ បុណ្ណកោ នាម នាមធេយ្យំ បកាសតិ ។
តោសយិត្វាន សម្ពុទ្ធំ គោតមំ សក្យបុង្គវំ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ កិត្តនាយ ឥទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

១ ម. សប្បុរិស ។

## បុណ្ណកត្ថេរាបទាន ទី ២

អ្នកបំពេញកិច្ចនោះ ចំពោះព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ អ្នកនៅក្នុងសម្នាក់នៃព្រះមុនី ក្នុងកាលណា អ្នកនឹងបានឈ្មោះថា បុណ្ណកៈ ក្នុងកាលនោះ ។ លុះខ្ញុំច្យុតចាកកាយនោះហើយ ក៏បានទៅកើតក្នុងទេវលោក ក្លិនជាទិព្វបង្អុរចុះពីអាកាស ត្រង់កន្លែងដែលខ្ញុំនៅនោះ ។ កាលនោះ ឈ្មោះរបស់ខ្ញុំថាបុណ្ណកៈ ក្នុងទីនោះ ខ្ញុំកើតជាទេវតា ឬជាមនុស្ស តែងបំពេញសេចក្ដីបំណងបាន ។ នេះសរីរៈ ជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុត កំពុងប្រព្រឹត្តទៅ សូម្បីក្នុងអត្តភាពនេះ គង់អ្នកផងប្រកាសនាម (របស់ខ្ញុំ) ថាបុណ្ណកៈ ។ ខ្ញុំបានញ៉ាំងព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យត្រេកអរ ខ្ញុំកំណត់ដឹងអាសវៈទាំងពួងជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការបូជាសរីរសពនោះឯង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីផ្ដាច់ខ្សែទន្ទីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុណ្ណកោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

បុណ្ណកត្ថេរស្ស អបទានំ សមត្តំ ។

# តតិយំ មេត្តគុត្តេរាបទានំ

[១០៣] ហិមវន្តស្ស អវិទូរេ អសោកោ នាម បព្វតោ

តត្ថាបិ អស្សមោ មយ្ហំ វិស្សុកម្មេន មាបិតោ ។

សុមេធោ នាម សម្ពុទ្ធោ អគ្គោ ការុណិកោ មុនិ

និវាសយិត្វា បុព្វណ្ហេ បិណ្ឌាយ មេ ឧបាគមិ ។

ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុណ្ណកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុណ្ណកត្ថេរាបទាន ។

# មេត្តគុត្ថេរាបទាន ទី ៣

[១០៣] មានភ្នំមួយឈ្មោះអសោកៈ នៅជិតព្រៃហិមពាន្តឯអាស្រមរបស់ខ្ញុំ វិស្សុកម្មទេវបុត្រនិម្មិតឲ្យហើយ ជិតភ្នំនោះ ។ ព្រះសម្ពុទ្ធ ព្រះនាមសុមេធ ជាកំពូលអ្នកប្រាជ្ញទ្រង់មានសេចក្តីករុណា ទ្រង់ប្រដាប់ចីវរ ក្នុងបុព្វណ្ហសម័យហើយស្តេចពុទ្ធដំណើរ តម្រង់ទៅរកខ្ញុំដើម្បីបិណ្ឌបាត ។

២២៣

តតិយំ មេត្តគុត្តេរាបទានំ

ឧចាគតំ មហាវីរំ សុមេធំ លោកនាយកំ
បក្ខយ្ហ សុគតបត្តំ សប្បិតេលំ អបូរយឹ ។
ទត្វានាហំ ពុទ្ធសេដ្ឋេ សុមេធេ លោកនាយកេ
អញ្ជលឹ បគ្គហេត្វាន ភិយ្យោ ហាសំ ជនេសហំ ។
ឥមិនា សប្បិទានេន ចេតនាបណិធីហិ ច
ទេវភូតោ មនុស្សោ វា លភាមិ វិបុលំ សុខំ ។
វិនិបាតំ វិវជ្ជេត្វា សំសរាមិ ភវាភវេ
តត្ថ ចិត្តំ បណិធិត្វា លភាមិ អចលំ បទំ ។
លាភា តុយ្ហំ សុលទ្ធង្គេ យំ មំ អទ្ទក្ខិ ព្រាហ្មណ
មម ទស្សនមាគម្ម អរហត្តំ គមិស្សតិ[១] ។
វិស្សដ្ឋោ ហោហិ មា ភាយិ អធិគន្ត្វា មហាយសំ
មមំ ហិ សប្បឹ ទត្វាន បរិមោក្ខាសិ ជាតិយា ។

១ ម. ភវិស្សតិ ។

មេត្តគុត្ថេរាបទាន ទី ៣

ខ្ញុំ (បានឃើញ) នូវព្រះលោកនាយក ព្រះនាមសុមេធ ព្រះអង្គជាមហាវីរបុរស ស្តេចចូលមកដល់ ទើបទទួលយកបាត្រព្រះសុគត ហើយបំពេញសប្បិនិងប្រេង ។ លុះខ្ញុំថ្វាយចំពោះព្រះលោកនាយក ទ្រង់ព្រះនាមសុមេធៈ ជាព្រះពុទ្ធដ៏ប្រសើរហើយ ក៏ផ្គងអញ្ជលី ញ៉ាំងសេចក្តីរីករាយដ៏ខ្លាំងឲ្យកើតឡើង ។ ខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស តែងបាននូវសេចក្តីសុខដ៏ធំ ដោយការថ្វាយសប្បិនេះផង ដោយការតាំងចេតនានេះផង ។ ខ្ញុំវៀរកំណើតវិនិបាត តែងអន្ទោលទៅ ក្នុងភពតូចនិងភពធំ ក៏បានតាំងចិត្តប្រណិធាន ក្នុងភពនោះ ៗ ហើយឥឡូវនេះ ខ្ញុំបានដល់នូវអចលបទ គឺព្រះនិព្វាន ។

ម្នាលព្រាហ្មណ៍[១] អ្នកឈ្មោះថាមានលាភហើយ អត្តភាពជាមនុស្ស ឈ្មោះថាអ្នកបានល្អហើយ ព្រោះអ្នកបានឃើញតថាគត ឯបុគ្គលនឹងដល់នូវអរហត្តផល ក៏ព្រោះអាស្រ័យការឃើញតថាគត ។ អ្នកត្រូវស្និទ្ធស្នាលចុះ កុំខ្លាចឡើយ អ្នកនឹងបានយសធំ នឹងរួចចាកជាតិ ព្រោះបានឲ្យសប្បិដល់តថាគត ។

១ តពីនេះទៅ យើងមិនយល់ មិនដឹងថា ជាពាក្យអ្នកណានិយាយ ។

ឥមិនា សប្បិទានេន ចេតនាបណិធីហិ ច
ទេវភូតោ មនុស្សោ វា លភាមិ វិបុលំ សុខំ ។
ឥមិនា អធិការេន[១] មេត្តចិត្តវតាយ ច
អដ្ឋារសេ កប្បសតេ ទេវលោកេ រមិស្សតិ ។
អដ្ឋារស ច តិក្ខត្តុំ[២] ទេវរាជា ភវិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
ឯកបញ្ញាសក្ខត្តុញ្ច ចក្កវត្តិ ភវិស្សតិ
ចាតុរន្តោ វិជិតាវី ជម្ពុមណ្ឌស្ស ឥស្សរោ ។
មហាសមុទ្ទោវក្ខោភោ ទុទ្ធរោ បថវី យថា
ឯវមេវ ច មេ[៣] ភោគា អប្បមេយ្យា ភវិស្សរេ ។
សដ្ឋិកោដី ហិរញ្ញស្ស ចជិត្វាន បព្វជឹ អហំ
កឹកុសលំ គវេសន្តោ ពាវរឹ ឧបសង្កមឹ ។
តត្ថ មន្តេ អធិយាមិ ឆឡង្គំ នាម លក្ខណំ
តមន្ធការំ វិធមំ ឧប្បជ្ជិ តុំ មហាមុនិ ។

---

១ ម. សប្បិទានេន ។ ២ ម. អដ្ឋក្ខត្តុំសតិក្ខត្តុំ ច ។ ៣ ម. តេ ។

ខ្ញុំកើតជាទេវតា ឬកើតជាមនុស្ស រមែងបាននូវសុខដ៏ធំ ដោយការថ្វាយសប្បិនេះផង ដោយការតាំងចេតនានេះផង ។

បុគ្គលនេះ នឹងរីករាយក្នុងទេវលោក ក្នុងកប្បទី ១៨ ដោយអធិការនេះផង ដោយការប្រព្រឹត្តមេត្តាចិត្តនេះផង ។ នឹងបានជាស្តេចទេវតា អស់ ៥៤ ដង នឹងបានសោយប្រទេសរាជ្យធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ នឹងបានជាស្តេចចក្រពត្តិ មានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ឈ្មោះសង្គ្រាម ជាឥស្សរៈ លើមណ្ឌលជម្ពូទ្វីប អស់ ៥១ ដង ។

មហាសមុទ្រមិនរំភើប ផែនដីធ្ងន់ គេទ្រទ្រង់បានដោយក្រ យ៉ាងណា ភោគៈទាំងឡាយរបស់ខ្ញុំ ប្រមាណមិនបាន ក៏យ៉ាងនោះដែរ ខ្ញុំឲ្យប្រាក់អស់ ៦០ កោដិ ហើយទើបចេញទៅបួស ខ្ញុំកំពុងស្វែងរកកុសល ក៏បានចូលទៅរកពាវរីព្រាហ្មណ៍ ។ ខ្ញុំបានរៀនលក្ខណមន្ត ប្រកបដោយអង្គ ៦ ក្នុងសម្នាក់ពាវរីព្រាហ្មណ៍នោះ បពិត្រព្រះមហាមុនី ព្រះអង្គកម្ចាត់បង់ នូវងងឹតអន្ធការ ហើយកើតឡើងហើយ ។

## តតិយំ មេត្តគុត្តេរាបទានំ

តវ ទស្សនកាមោហំ អាគតោម្ហិ មហាមុនិ
តវ ធម្មំ សុណិត្វាន បត្តោម្ហិ អចលំ បទំ ។
តឹសកប្បសហស្សម្ហិ សប្បឹ ពុទ្ធស្សទាសហំ
ឯត្ថន្តរេ នាភិជានេ[១] សប្បិ វិញ្ញាបិតំ មយា ។
មម សង្កប្បមញ្ញាយ ឧប្បជ្ជតិ យទិច្ឆកំ
ចិត្តមញ្ញាយ និព្វត្តិ សព្វេ សន្តប្បយាមហំ ។
អហោ ពុទ្ធា អហោ ធម្មា អហោ នោ សត្ថុសម្បទា
ជោតកញ្ហិ សប្បឹ ទត្វាន អប្បមេយ្យំ លភាមហំ ។
មហាសមុទ្ទេ ឧទកំ យាវតា នេរុបស្សតោ
មម សប្បឹ ឧបាទាយ កលភាគំ ន ហិស្សតិ ។
យាវតា ចក្កវាឡស្ស ការយន្តស្ស រាសិតោ
មម និព្វត្តវត្ថានំ ឱកាសោ សោ ន សម្មតិ ។
បព្វតរាជា ហិមវា បវរោបិ សិលុច្ចយោ
មមានុលិត្តគត្តស្ស ឧបនិធំ ន ហិស្សតិ ។

១ ម. នាភិជានាមិ ។

បពិត្រព្រះមហាមុនី ខ្ញុំមានបំណងចង់ចួបនឹងព្រះអង្គ ទើបមក ខ្ញុំបានស្តាប់ធម៌របស់ព្រះអង្គហើយ ក៏នឹងបានដល់ នូវអចលបទ គឺព្រះនិព្វាន ។

ក្នុងកប្បទី ៣០ ពាន់ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយសប្បិដល់ព្រះពុទ្ធ ខ្ញុំមិនដែលស្គាល់សប្បិដែលខ្ញុំត្រូវសូមគេទេ ។ សប្បិដូចដឹងបំណងរបស់ខ្ញុំ ហើយកើតឡើងតាមសេចក្តីប្រាថ្នា សប្បិកើតឡើងហើយ ព្រោះដឹងចិត្តខ្ញុំ ខ្ញុំញុំាងជនទាំងពួងឲ្យឆ្អែតស្កប់ស្កល់ ។ ឱ ! ព្រះពុទ្ធ ឱ ! ព្រះធម៌ ឱ ! សម្បទានៃព្រះសាស្តារបស់ខ្ញុំ ខ្ញុំគ្រាន់តែថ្វាយសប្បិបន្តិចបន្តួចសោះ ត្រឡប់ជាបានសប្បិរាប់មិនអស់ ។ ទឹកក្នុងមហាសមុទ្រ ដែលទល់នឹងភ្នំសុមេរុ ប្រៀបផ្ទឹមនឹងសប្បិរបស់ខ្ញុំ គង់មិនដល់មួយភាគនៃចំណិត ។ ឱកាសនៃចក្រវាឡទាំងប៉ុន្មាន ឱកាសនោះ គង់មិនល្មមនឹងសំពត់ទាំងឡាយ ដែលកើតឡើងសម្រាប់ខ្ញុំ ដែលឲ្យគេធ្វើជាគំនរឡើយ ។ ស្តេចភ្នំឈ្មោះហិមវន្ត ជាភ្នំដ៏ប្រសើរ គង់មិនដល់នូវការប្រៀបធៀបនឹងក្លិន ដែលជាប់នឹងកាយរបស់ខ្ញុំដែរ ។

វត្ថំ កន្ធញ្ច សប្បិញ្ច    អញ្ញំ វា ទិដ្ឋធម្មិកំ
អសង្ខតញ្ច និព្វានំ    សប្បិទានស្សិទំ ផលំ ។
សតិប្បដ្ឋានសយនោ    សមាធិជ្ឈានគោចរោ
ពោជ្ឈង្គជននោ អដ្ឋ    សប្បិទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ    មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មេត្តគូ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

មេត្តគុត្ថេរស្ស អបទានំ សមត្តំ ។

ខ្ញុំបានសំពត់ គ្រឿងក្រអូប សប្បិនិងវត្ថុដទៃ ដែលប្រព្រឹត្ត ទៅក្នុងបច្ចុប្បន្ន ទាំងបានព្រះនិព្វាន ដែលជាអសង្ខតៈ នេះ ជាផលនៃការថ្វាយសប្បិ ។ ក្នុងថ្ងៃនេះ ខ្ញុំមានសតិប្បដ្ឋាន ជាទីដេក មានសមាធិជ្ឈានជាគោចរ ញ៉ាំងពោជ្ឈង្គឲ្យកើត នេះជាផលនៃការថ្វាយសប្បិ ។ កិលេសទាំងឡាយ ខ្ញុំដុត បំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នក មិនមានអាសវៈ ដូចដំរីកាត់ខ្សែទន្ទីង ។ ឱ ! ដំណើរដែល ខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន ធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមេត្តគុត្តេរ មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មេត្តគុត្តេរាបទាន ។

# ចតុត្ថំ ធោតកត្ថេរាបទានំ

[១០៤] គង្គា ភាគីរសី នាម ហិមវន្តា បភាវិតា
ហំសវតិយា ទ្វារេន អនុសន្ទតិ តាវទេ ។
សោភិតោ នាម អារាមោ គង្គាកូលេ សុមាបិតោ
តត្ថ បទុមុត្តរោ ពុទ្ធោ វសតេ លោកនាយកោ ។
តិទសេហិ យថា ឥន្ទោ មនុជេហិ បុរក្ខតោ
និសីទិ តត្ថ ភគវា អសម្ភីតោវ កេសរី ។
នគរេ ហំសវតិយា អហោសឹ(១) ព្រាហ្មណោ អហំ
ឆឡង្គោ នាម នាមេន ឯវំ នាមោ មហាមុនិ ។
អដ្ឋារស សិស្សសតា បរិវារេន្តិ មំ តទា
តេហិ សិស្សេហិ សមិតោ គង្គាតីរំ ឧបាគមឹ ។
តត្ថទ្ទសាសឹ សមណេ និក្កុហេ ធោតបាបកេ
ភាគីរសិន្តរន្តោហំ ឯវំ ចិន្តេសិ តាវទេ ។

១ ម. វសាមិ ។

# ធោតកត្ថេរាបទាន ទី ៤

[១០៤] ទឹកស្ទឹងឈ្មោះភាគីរសី ហូរចេញមកអំពីព្រៃហិម-ពាន្ត ហើយហូរទៅតាមទ្វារក្រុងហង្សវតី ក្នុងខណៈនោះ ។ អារាមឈ្មោះសោភិត ដែលគេសាងល្អហើយ នៅក្បែរឆ្នេរស្ទឹងគង្គា ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ជាលោកនាយក ស្តេចប្រថាប់នៅក្នុងអារាមនោះ ។ ព្រះមានព្រះភាគ មានពួកមនុស្សចោមរោមហើយ ដូចជាព្រះឥន្ទ្រមានពួកទេវតាចោមរោម ស្តេចគង់នៅក្នុងអារាមនោះ ដូចកេសររាជសីហ៍ ដែលឥតមានសេចក្តីតក់ស្លុត ។ ខ្ញុំកើតជាព្រាហ្មណ៍ មាននាមថាឆឡង្គៈ នៅក្នុងនគរហង្សវតី បពិត្រព្រះមហាមុនី ឈ្មោះខ្ញុំយ៉ាងនេះ ។ កាលនោះ ពួកសិស្សចំនួន ១៨ រយនាក់ តែងចោមរោមខ្ញុំ ខ្ញុំព្រមព្រៀងដោយពួកសិស្សទាំងនោះ ក៏ចូលទៅកាន់ឆ្នេរស្ទឹងគង្គា ។ ខ្ញុំកំពុងឆ្លងស្ទឹងភាគីរសី បានឃើញពួកសមណៈ ជាបុគ្គលមិនកុហក ជាអ្នកបន្សាត់បង់នូវបាបត្រង់ឆ្នេរស្ទឹងគង្គានោះ ហើយខ្ញុំគិតយ៉ាងនេះក្នុងខណៈនោះថា

សាយំ ចាតំ តវគ្គាមេ ពុទ្ធបុត្តា មហាយសា
វិហាសយន្តិ អត្តានំ តេសំ អត្ថា វិហញ្ញតិ ។
សទេវកស្ស លោកស្ស ពុទ្ធោ អគ្គោ បវុច្ចតិ
នត្ថិ មេ ទក្ខិណោ ការំ គតិមគ្គវិសោធនំ ។
យន្នូន ពុទ្ធសេដ្ឋស្ស សេតុំ កង្កាយ ការយេ
ការាបេត្វា ឥមំ សេតុំ[១] សន្តរាមិ ឥមំ ភវំ ។
សតំ សហស្សំ ទត្វាន សេតុំ ការាបយឹ អហំ
សទ្ទហន្តោ កតំ ការំ វិបុលំ មេ ភវិស្សតិ ។
ការាបេត្វាន តំ សេតុំ ឧបេសឹ លោកនាយកំ
សិរសិ អញ្ជលឹ កត្វា ឥមំ វចនមព្រវឹ ។
សតំ សហស្សំ សវយំ ទត្វា ការាបិតោ មយា
តវត្ថាយ មហាសេតុំ បដិគ្គណ្ហ មហាមុនេ ។

---
១ ម. កម្មំ ។

ពួកសមណៈ ជាពុទ្ធបុត្រ មានយសធំទាំងនេះ ធ្វើងស៊ើងទៅ ទាំងល្ងាចទាំងព្រឹក នាំឲ្យខ្លួនលំបាក ខ្លួនសមណៈទាំងនោះ ក៏នឿយហត់ ។ ព្រះពុទ្ធអ្នកផងតែងពោលថា ជាកំពូលរបស់ សត្វលោក ព្រមទាំងទេវលោក ឯអាត្មាអញមិនទាន់មាន គ្រឿងសក្ការៈ គឺការជម្រះផ្លូវសម្រាប់ដើរទៅ ចំពោះទក្ខិ-ណេយ្យបុគ្គលនៅឡើយ ។ បើដូច្នោះ គួរតែអាត្មាអញញុំាង ជន ឲ្យធ្វើស្ពានត្រង់ស្ទឹងគង្គា ថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះអា-ត្មាអញឲ្យគេធ្វើស្ពាននេះរួចហើយ ឈ្មោះថាអាត្មាអញបាន ធ្វើងនូវភពនេះ ។ ខ្ញុំបានចំណាយទ្រព្យរាប់រយរាប់ពាន់ ឲ្យ គេធ្វើស្ពាន ខ្ញុំជឿថាសក្ការៈដែលខ្ញុំធ្វើហើយ (នេះ) នឹងមាន ផលធំទូលាយ ។ លុះខ្ញុំឲ្យគេធ្វើស្ពាននោះរួចហើយ ក៏ចូល ទៅគាល់ព្រះលោកនាយក ធ្វើអញ្ជលីលើត្បូង ហើយក្រាប បង្គំទូលពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គចំណាយ ទ្រព្យរាប់រយរាប់ពាន់ ឲ្យគេធ្វើស្ពាននេះ ដើម្បីប្រយោជន៍ ដល់ព្រះអង្គ សូមព្រះអង្គទទួលយក នូវស្ពានដ៏ធំនេះចុះ ។

## ២២៩

### ចតុត្ថំ ធោតកត្ថេរាបទានំ

បទុមុត្តរោ លោកវិទូ　　អាហុតីនំ បដិគ្គហោ
ភិក្ខុសង្ឃេ និសីទិត្វា　　ឥមា គាថា អភាសថ ។
យោ មេ សេតុំ អការេសិ　　បសន្នោ សេហិ ចាណិភិ
តមហំ កិត្តយិស្សាមិ　　សុណាថ មម ភាសតោ ។
ទរិតោ បព្វតាតោ វា　　រុក្ខតោ បតិតោបិយំ
ចុតោបិ លច្ឆតិដ្ឋានំ　　សេតុទានស្សិទំ ផលំ ។
វិរុឡ្ហមូលសន្តានំ　　និគ្រោធមិវ មាលុតោ
អមិត្តា នប្បសហន្តិ　　សេតុទានស្សិទំ ផលំ ។
នាស្ស ចោរា បសហន្តិ　　នាតិមញ្ញន្តិ ខត្តិយា
សព្វេ តរិស្សតាមិត្តេ　　សេតុទានស្សិទំ ផលំ ។
អព្ភោកាសគតំ សន្តំ　　កឋិនាតបតាបិតំ
បុញ្ញកម្មេន សំយុត្តំ　　ន ភវិស្សតិ វេទនា ។
ទេវលោកេ មនុស្សេ វា　　ហត្ថិយានំ សុនិម្មិតំ
តស្ស សង្កប្បមញ្ញាយ　　និព្វត្តិស្សតិ តាវទេ ។

ធោតកត្ថេរាបទាន ទី ៩

ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់លោក គួរទទួលគ្រឿងបូជា ស្តេចគង់នៅកណ្តាលភិក្ខុសង្ឃ ហើយត្រាស់គាថាទាំងនេះថា បុគ្គលណាជ្រះថ្លា បានឲ្យគេធ្វើស្ពានដោយដៃខ្លួនឯង ដើម្បីតថាគត ៗ នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែង ដូចតទៅនេះ

បុគ្គលនេះ បើទុកជាធ្លាក់ទៅក្នុងជ្រោះ ឬធ្លាក់ពីភ្នំឬដើមឈើក្តី ច្យុតហើយក្តី រមែងបាននូវទីឈរ នេះជាផលនៃការឲ្យស្ពាន ។ សត្រូវទាំងឡាយ មិនគ្របសង្កត់ (នូវបុគ្គលនេះបាន) ដូចជាខ្យល់ មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫសដុះមាំ នេះជាផលនៃការឲ្យស្ពាន ។ ចោរទាំងឡាយមិនអាចនឹងគ្របសង្កត់បុគ្គលនេះបានទេ ពួកក្សត្រក៏មិនមើលងាយបានដែរ (បុគ្គលនេះ) នឹងឆ្លងផុតសត្រូវទាំងពួង នេះជាផលនៃការឲ្យស្ពាន ។ បុគ្គលប្រកបដោយបុញ្ញកម្មនេះ បើទុកជានៅក្នុងទីវាល ដែលហាលដោយកម្តៅថ្ងៃដ៏ក្លាខ្លាំង ក៏នឹងមិនមានវេទនាឡើយ ។ យានដំរី ដែលជាបុញ្ញកម្មនិម្មិតល្អហើយ ក្នុងទេវលោក ឬក្នុងមនុស្សលោក នឹងកើតឡើងក្នុងខណៈនោះ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់បុគ្គលនោះ ។

សហស្សស្សា វាតជវា សិន្ធវា សីឃវាហនា
សាយំ បាតំ ឧបេស្សន្តិ សេតុបានស្សិទំ ផលំ ។
អាគន្ត្វាន មនុស្សត្តំ សុខិតោយំ ភវិស្សតិ
ឥហាបិ មនុជស្សេវ ហត្ថិយានំ ភវិស្សតិ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
អហោ មេ សុកតំ កម្មំ ជលជុត្តមនាមកេ
តត្ថ ការំ ករិត្វាន បត្តោហំ អាសវក្ខយំ ។
បធានំ បហិតត្តោម្ហិ ឧបសន្តោ និរូបធិ
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

សេះសិន្ធពមួយពាន់ មានសន្ទុះលឿនដូចខ្យល់ ជាពាហនៈ ដំរហ័ស នឹងចូលទៅបម្រើ (បុគ្គលនោះ) ទាំងល្ងាចទាំងព្រឹក នេះជាផលនៃការឲ្យស្ពាន ។ បុគ្គលនេះ លុះមកកាន់អត្តភាព ជាមនុស្ស នឹងបានសេចក្ដីសុខ មួយទៀត យានដំរីនឹង កើតដល់បុគ្គលនេះ ដែលកើតជាមនុស្ស ក្នុងលោកនេះ ។ កន្លងទៅមួយសែនកប្បទៀត នឹងមានព្រះបរមសាស្ដា ព្រះ នាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ឡើង ក្នុងលោក ។ បុគ្គលនេះ នឹងបានទទួលមត៌កក្នុងធម៌របស់ ព្រះពុទ្ធអង្គនោះ ជាឱរសដែលធម៌និម្មិតហើយ នឹងកំណត់ ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ឱហ្ន៎ ! អំពើដែលខ្ញុំធ្វើល្អហើយ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ខ្ញុំធ្វើគ្រឿងសក្ការៈ ចំពោះព្រះពុទ្ធអង្គ នោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំមាន ចិត្តបញ្ជូនទៅកាន់សេចក្ដីព្យាយាម ជាអ្នកស្ងប់រម្ងាប់ មិនមាន ឧបក្កិលេស មិនមានអាសវៈ ដូចដំរីកាត់ផ្ដាច់នូវទន្លីង ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ជោតកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជោតកត្ថេរស្ស អបទានំ សត្តមំ ។

# បញ្ចមំ ឧបសីវត្ថេរាបទានំ

[១០៨] ហិមវន្តស្ស អវិទូរេ អនោមោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។

កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំង-ពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីកាត់ផ្ដាច់នូវទន្ទីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជាទាំង ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធោតកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធោតកត្ថេរាបទាន ។

# ឧបសីវត្ថេរាបទាន ទី ៥

[១០៥] មានភ្នំមួយឈ្មោះអនោមៈ នៅជិតព្រៃហេមពាន្ត អាស្រមរបស់ខ្ញុំធ្វើល្អហើយ បណ្ណសាលា ខ្ញុំក៏បានកសាងល្អហើយដែរ ។

នទី ច សន្ទតិ តត្ថ សុបតិត្ថា មនោរមា
អនូបតិត្ថេ ជាយន្តិ បទុមុប្បលកា ពហូ ។
បាឋីនា បាវុសា មច្ឆា ពលជា មុញ្ជរោហិតា
មច្ឆកច្ឆបសញ្ឆន្នា នទិកា សន្ទតេ តទា ។
តិមិរា បុប្ផិតា តត្ថ អសោកា ខុទ្ទមាលកា
បុណ្ណា គា គិរិបុណ្ណា គា សម្បវន្តិ មមស្សមំ ។
កុដជា បុប្ផិតា តត្ថ តិណសូលវនានិ ច
សាលា ច សលឡា តត្ថ ចម្បកា បុប្ផិតា ពហូ ។
អជ្ជុនា អតិមុត្តា ច មហានាមា ច បុប្ផិតា
អសនា មធុគន្ធី ច បុប្ផិតា តេ មមស្សមេ ។
ឧទាលកា បាដលិកា យូថិកា ច បិយង្គុកា
ពិម្ពិជាលកសញ្ឆន្នា សមន្តា អឌ្ឍយោជនំ ។

មានស្ទឹងមួយ មានកំពង់រាបល្អ គួរជាទីរីករាយនៃចិត្ត តែង ហូរចុះទៅក្នុងទីនោះ មានឈូកនិងឧប្បលជាច្រើន ដុះនៅ តាមកំពង់ ជាលំដាប់ ។ ឯត្រីស្វាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីឆ្ពិន (មានក្នុងកំពង់នោះ) ទឹកស្ទឹងដ៏ដេរ-ដាសដោយត្រីនិងអណ្តើក រមែងហូរទៅ ក្នុងកាលនោះ ។ ក្នុងទីនោះ មានតិមិរព្រឹក្ស មានផ្ការីក ដើមអសោកមាន ផ្កាតូច ៗ ទាំងក្រូចឆ្មារ និងក្រូចភ្លា ទោរទៅកាន់អាស្រម របស់ខ្ញុំ ។ ក្នុងទីនោះ មានដើមខ្ទឹងគង់ និងព្រៃ ម្ទិះរួត មានផ្ការីក ដើមរាំង ដើមស្រល់ និងដើមចម្បាជាច្រើន មានផ្ការីកក្នុងទីនោះដែរ ។ ដើមអង្រ្គង ដើមរំដួល ដើម ចម្បក់ ដើមធ្នង់ និងដើមបេកទុំ មានផ្ការីក ពួកឈើទាំង នោះ សុទ្ធតែមានផ្ការីកហើយ នៅជិតអាស្រមរបស់ខ្ញុំ ។ ដើមរាជព្រឹក្ស ដើមច្រនៀង ដើមយុថ្កា និងដើមប្រយង្គុ សឹងដ៏ដេរដាសដោយរល្វិបាស អស់កន្ទះយោជន៍ជុំវិញ ។

## បញ្ចមំ ឧបសីវត្ថេរាបទានំ

មាតការា(១) សត្តលិយោ ចាដលី សិន្ទុវារិតា
អង្កោលកា ពហុ តត្ថ តាលកុដា ច បុប្ផិតា ។
សេលេយ្យកា ពហូ តត្ថ បុប្ផិតា មម អស្សមេ
ឯតេសុ បុប្ផជាតេសុ សោភន្តិ ចាទចា ពហូ ។
សមន្តា តេន គន្ធេន វាយតេ មម អស្សមេ
ហរីតកា អាមលកា អម្ពជម្ពូ វិភេទកា ។
កោលា ភល្លាតកា ពេល្លា ផារុសកផលានិ ច
តិន្ទុកា ច បិយាលា ច មធុកា កាសមារិយោ ។
លពុជា បនសា តត្ថ កទលី ចន្ទរីផលា
អម្ពាដកា ពហូ តត្ថ វល្លិការផលានិ ច ។
ចិរសំរសចាកា ច(២) ផលិតា មម អស្សមេ
អាឡកា ឥសិមុគ្គា ច តតោ សោរផលា(៣) ពហូ ។
អវដា បក្កភរិតា មិលក្ខុទុម្ពរានិ ច
បិប្ផលី មរិចា តត្ថ និគ្រោធា ច កបិដ្ឋនា ។
ឧទុម្ពរកា ពហវោ កណ្ឌបក្កា ច ចារិយោ(៤)
ឯតេ ចញ្ញេ ច ពហវោ ផលិតា អស្សមេ មម ។

១ ម. មាតគ្គារា ។ ២ ម. វិទបរបទានយោ ។ ៣ ម. មោទផលា ។ ម. កណ្ឌបណ្ណា ច ហារិយោ ។

ឧបសីវត្ថេរាបទាន ទី ៥

ដើមមាតករព្រឹក្ស ម្ទិះរួត ប្រទៀង ឈើភ្ញើង អង្កោលនិង តាលកុដព្រឹក្ស ជាច្រើនក្នុងទីនោះ សុទ្ធតែជាឈើ មានផ្កា រីក ។ ស្មៅក្រវាញជ្រូកជាច្រើន សុទ្ធតែជាស្មៅមានផ្ការីក ក្បែរអាស្រមរបស់ខ្ញុំនោះ បណ្តាឈើមានផ្កាទាំងនុ៎ះ ពួក ឈើច្រើន សុទ្ធតែល្អ ៗ ។ ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង និងសម៉ពិភេទក៏ ផ្សាយក្លិននោះ ជុំវិញអាស្រមខ្ញុំ ។ ដើម ពុទ្រា ដើមរាក់ខ្មៅ ដើមញ្ញោ មាក់ប្រ៉ាង ទន្ទាប់ ទ្រយឹង ស្រគំ ពង្រ ។ ដើមខ្នុរសម្ង ខ្នុរណាំង បេក ដើមច័ន្ទ ក៏មានក្នុង ទីនោះ ដើមម្កាក់ និងដើមគុយ ក៏មានច្រើនក្នុងទីនោះដែរ ។ ដើមគូលែន អាលកព្រឹក្ស និងសណ្តែកព្រៃ សុទ្ធតែជាឈើ មានផ្លែ នៅជិតអាស្រមរបស់ខ្ញុំ តពីនោះទៅ មានផ្លែសាវ- ម៉ាវជាច្រើន ។ អវជព្រឹក្ស ពេញដោយផ្លែទុំ ដើមមិលក្ខុ- ព្រឹក្ស ដើមឧទុម្ពរ ដីប្លី ម្រេច ជ្រៃ និងដើមក្រសាំង មានក្នុងទី នោះ ។ ដើមឧទុម្ពរជាច្រើន ខ្លះផ្លែទុំ ខ្លះផ្លែខ្ចី ដើមឈើក្រៅពី នេះជាច្រើន សុទ្ធតែជាឈើមានផ្លែ ជិតអាស្រមរបស់ខ្ញុំ ។

បុប្ផរុក្ខាបិ ពហវោ    បុប្ផិតា មម អស្សមេ
អាលវា ច កាឯម្ពា ច    ពិឡាលិតក្កលានិ ច ។
អាលកា តាលកា ចេវ    វិជ្ជន្តិ មម អស្សមេ
អស្សមស្សាវិទូរេ មេ    មហាជាតស្សរោ អហុ ។
អច្ឆោទកោ សីតជលោ    សុបតិត្ថោ មនោរមោ
បទុមុប្បលា ពហូ តត្ថ    បុណ្ឌរិកសមាយុតា ។
មន្ទាលកេហិ សញ្ឆន្នា    នានាគន្ធសមីរិតា[១]
គព្ភំ គណ្ហន្តិ បទុមា    អញ្ញេ បុប្ផន្តិ កេសរី ។
ឱបុប្ផបត្តា តិដ្ឋន្តិ    បទុមា កណ្ណិកា ពហូ
មធុ ភិសម្ហា សវតិ    ខីរសប្បិ មុឡាលិភិ ។
សមន្តា តេន តង្វេន    នានាគន្ធសមោហិតា[២]
កុមុទា អម្ពគន្ធី ច    នយិតា ទិស្សរេ ពហូ ។
ជាតស្សរស្សានុកូលំ    កេតកា បុប្ផិតា ពហូ
សុផុល្លា ពន្ធុជីវា ច    សេតវារី សុគន្ធិកា ។

១ ម. សញ្ឆន្នោ នានាគន្ធសមេរិតោ ។ ២ ម. នានាគន្ធសមេរិតា ។

សូម្បីឈើមានផ្កាច្រើន គឺដើមកន្ទ្រំ ដើមក្ទម្ព និងដើមពុកឆ្មា មានផ្ការីក នៅជិតអាស្រមរបស់ខ្ញុំ ។ អាលកព្រឹក្សនិងតាលកព្រឹក្ស មាននៅជិតអាស្រមរបស់ខ្ញុំ មានជាតស្រះធំមួយ នៅជិតអាស្រមរបស់ខ្ញុំ ។ ស្រះនោះ មានទឹកថ្លាមានទឹកត្រជាក់ មានកំពង់ល្អ គួរជាទីរីករាយនៃចិត្ត មានទាំងឈូកក្រហម និងឧប្បលជាច្រើន លាយចម្រុះដោយឈូកសនៅក្នុងស្រះនោះ ទាំងដេរដាសដោយព្រលិត សាយភាយដោយក្លិនផ្សេង ៗ ដើមឈូកកំពុងចាប់ផ្ទៃ (ក្រពុំ) ពួកដើមកេសរឯទៀត ៗ កំពុងរីកផ្កា ឈូកនិងផ្កាកណិការជាច្រើនមានត្របកផ្កាសំយុងចុះក្រោម មានទឹកហូរចេញអំពីក្រអៅឈូកផ្អែមដូចទឹកឃ្មុំ មានទឹកហូរចេញអំពីមើមឈូក ឆ្ងាញ់ដូចទឹកដោះស្រស់និងទឹកដោះថ្លា ផ្កាកុមុទ ស្វាយក្រអូប ផ្កានយិតា-ព្រឹក្សជាច្រើន ប្រកបដោយក្លិនផ្សេង ៗ រមែងប្រាកដដោយក្លិននោះជុំវិញ ។ ឆ្នេរជាតស្រះ មានដើមកាកេតជាច្រើនមានផ្ការីក ដើមកុឡាបមានផ្កាល្អ ឈូកសមានក្លិនក្រអូប ។

២៣៨

### បញ្ចមំ ឧបសីវត្ថេរាបទានំ

កុម្ភីលា សុំសុមារា ច  គហកា តត្ថ ជាយរេ
ឧគ្គាហកា អជគរា  តត្ថ ជាតស្សរេ ពហូ ។
បាឋីនា បាវុសា មច្ឆា  ពលជា មុញ្ជរោហិតា
មច្ឆកច្ឆបសញ្ឆន្នា  អថោ សបជកោហិ ច ។
បារេវតា រវិហំសា  កុក្កុត្ថកា នទីចរា
ជិន្ទិភា ចក្កវាកា ច  ចប្បកា[១] ជីវជីវកា ។
កលន្ទកា ឧក្កុសា ច  សេនកា ឧទ្ធរា ពហូ
កោត្ថកា សុកបោតា ច  កុឡីរា[២] ចមរា ពហូ ។
កាសេនិយា[៣] ច តិលកា  ឧបជីវន្តិ តំ សរំ
សីហា ព្យគ្ឃា ច ទីបិ ច  អច្ឆ កោកតរច្ឆយោ ។
វានរា កិន្នរា ចេវ  ទិស្សន្តិ មម អស្សមេ
តានិ គន្ធានិ ឃាយន្តោ  ភក្ខយន្តោ ផលានហំ ។
គន្ធោទកំ បិវន្តោ ច  វសាមិ មម អស្សមេ
ឯណិមិគា វរាហា ច  បសទា ខុទ្ទរូបកា ។

---

១ ម. ចម្បកា ។ ២ ម. គុលិយា ។ ៣ ម. ការេនិយោ ។

ឧបសីវត្ថេរាបទាន ទី ៥

ក្រពើ ក្រពា ជាសត្វចាប់គេស៊ី ក៏កើតនៅក្នុងស្រះនោះ ពស់ថ្លាន់ជាសត្វរួបរឹត ក៏មានច្រើន ក្នុងស្រះនោះដែរ ។ មានត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ និងត្រីឆ្ពិន ដ៏ដេរដាស ដោយត្រីនិងអណ្តើក ដោយកន្ធែងដែលធ្លាប់អាស្រ័យនៅ ។ ព្រាប ប្រវឹក ខ្វែក ក្អែកទឹក ត្រដេវរិច ចាក្រពាក ចង្កៀលខ្យង ព្រហីត ។ មានពួកសត្វកង្វែន លលក ខ្វែង ជាសត្វហើរដ៏ច្រើន ឆ្កែចចក កូនសេក ក្តាន់ ទ្រាយ ជាច្រើន ។ ពួកម្រឹគ គឺកាសេនិយម្រឹគ និង តិលកម្រឹគ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ចូលទៅអាស្រ័យនឹងស្រះនោះ ។ ពួកស្វា ពួកកិន្នរ ក៏ ប្រាកដជិតអាស្រមខ្ញុំ ខ្ញុំស្រង់ក្លិនទាំងនោះ ហើយបរិភោគ ផ្លែឈើទាំងឡាយ ។ ខ្ញុំផឹកទឹកក្រអូប នៅក្នុងអាស្រមរបស់ ខ្ញុំ មានម្រឹគទ្រាយ ជ្រូក ប្រើស និងពួកសត្វមានរូបតូច ៗ ។

អក្កិកា ជោតិកា ចេវ វសន្តិ មម អស្សមេ
ហំសា កោញ្ចា មយូរា ច សហិតាបិច[១] កោកិលា ។
មញ្ជរិកា[២] ពហូ តត្ថ កោសិកា ចោត្ថសីសកា
បិសាចា ទានវា ចេវ កុម្ភណ្ឌា រក្ខសា ពហូ ។
គរុឡា បន្នគា ចេវ វសន្តិ មម អស្សមេ
មហានុភាវា ឥសយោ[៣] សន្តចិត្តា សមាហិតា ។
កមណ្ឌលុធរា សព្វេ អជិនុត្តរវាសិនោ
ជដាភារភរិតា ច វសន្តិ មម អស្សមេ ។
យុគមត្តញ្ច បេក្ខន្តា និបកា សន្តវុត្តិនោ
លាភាលាភេន សន្តុដ្ឋា វសន្តិ មម អស្សមេ ។
វាកចីរំ ធុនន្តា តេ ផោដេន្តាជិនចម្មកំ
សពលេហិ ឧបត្ថទ្ធា គច្ឆន្តិ អម្ពរេ តទា ។
ឧទកំ អាហរន្តិ កដ្ឋំ វា អគ្គិទារុកំ
សយញ្ច ឧបសម្បន្នា សប្បាដិហិរស្សិធំ ផលំ ។

---

១ ម. បហីនាបិច ។ ២ ម. មជ្ជារិកា ។ ៣ ម. ឥស្សរា ។

ក្រើនមានពន្លឺដ៏រុងរឿង នៅជិតអាស្រមរបស់ខ្ញុំ ពួកសត្វហង្ស ក្រៀល ក្ងោក និង តាវៅ ជាសត្វមានប្រយោជន៍ តែង អាស្រ័យនៅក្បែរអាស្រមរបស់ខ្ញុំដែរ ។ ក្នុងទីននោះ មានថ្នា ខ្ញៃងស្រោក កេងកង ជាច្រើន និងបិសាច អសុរ កុម្ភណ្ឌ និងអារក្ស ជាច្រើន ។ ពួកគ្រុឌ នាគ និងពួកឥសីមាន អានុភាពច្រើន មានចិត្តស្ងាប់ តម្កល់មាំ នៅជិតអាស្រម របស់ខ្ញុំ ។ ពួកឥសីទាំងអស់ ទ្រទ្រង់នូវកន្ធីទឹក ស្លៀក សំពត់ ស្បែកខ្លា ពេញដោយភារៈគឺផ្នួងសក់ នៅជិតអាស្រម របស់ខ្ញុំ ។ ពួកឥសីទាំងនោះ ក្រឡេកមើលប្រមាណមួយជួរ នឹម ជាបុគ្គលមានប្រាជ្ញា មានកិរិយាប្រព្រឹត្តស្ងប់ជាប្រក្រតី ជាអ្នកត្រេកអរតាមមានតាមបាន នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះ រលាស់សំពត់សម្បកឈើ ដំនូវស្បែកខ្លា ជាអ្នករឹងប៉ឹងដោយកម្លាំងរបស់ខ្លួន ទៅឰដ៏អាកាស ក្នុងកាល នោះ ។ ពួកឥសីទាំងនោះ នាំមកនូវទឹកថ្មីៗ ឈើនិង ឧស ចូលទៅប្រកបដោយខ្លួនឯង នេះជាផលនៃសប្បាយជិហារិយៈ ។

២៣៧

## បញ្ចមំ ឧបសីវត្ថេរាបទានំ

លោហតោណិំ គហេត្វាន វនមជ្ឈេ វសន្តិ តេ
កុញ្ជរា មហានាគា អឆម្ភិតា កេសរី ។
អញ្ញេ គច្ឆន្តិ គោយានំ អញ្ញេ បុព្វវិទេហកំ
អញ្ញេ ច ឧត្តរកុរុំ សកម្ពលមបស្សិតា ។
តតោ បិណ្ឌំ អាហរិត្វា បរិភុញ្ជន្តិ ឯកតោ
សព្វេសំ បក្កមន្តានំ ឧគ្គតេជាន តាទិនំ ។
អជិនចម្មសទ្ទេន វនំ សទ្ទាយតេ តទា
ឯទិសា តេ មហាវីរ សិស្សា ឧគ្គតបា មម ។
បរិវុតោ អហំ តេហិ វសាមិ មម អស្សមេ
តោសិតា សកកម្មេន វិនីតាបិ សមាគតា ។
អារាធយឹសុ មំ ឯតេ សកកម្មាភិលាសិនោ
សីលវន្តោ ច និបកា អប្បមញ្ញាសុ កោវិទា ។

ឧបសីវត្ថេរាបទាន ទី ៥

ពួកឥសីទាំងនោះ កាន់យកស្នូកលោហជាតិ នៅក្នុងកណ្ដាលព្រៃ ដូចជាដំរីដ៏ប្រសើរ ឬដូចជាកេសររាជសីហ៍ មិនមានសេចក្ដីតក់ស្លុតឡើយ ។ ពួកឥសីខ្លះ ទៅកាន់គោយានទ្វីប ខ្លះទៅកាន់បុព្វវិទេហទ្វីប ខ្លះទៅកាន់ឧត្តរកុរុទ្វីប ដោយមិនអើពើនឹងសំពត់កម្ពលរបស់ខ្លួន ។ ពួកឥសីទាំងនោះ នាំយកបិណ្ឌបាតអំពីទ្វីបនោះ ៗ មកឆាន់ជាមួយគ្នា កាលបើពួកឥសីទាំងអស់ មានតេជះដ៏ខ្ពង់ខ្ពស់ ប្រកបដោយតាទិគុណចៀសចេញទៅហើយ ព្រៃក៏លាន់ឮកងរំពងឡើង ដោយសំឡេងនៃស្បែកខ្លា ក្នុងកាលនោះ ។ បពិត្រព្រះអង្គមានព្យាយាមធំ ពួកសិស្សរបស់ខ្ញុំទាំងនោះ ប្រាកដបែបនេះ សុទ្ធតែជាអ្នកមានតបៈដ៏ខ្ពង់ខ្ពស់ ខ្ញុំមានពួកសិស្សទាំងនោះចោមរោមហើយ នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកសិស្សទាំងនុ៎ះ ដែលមកប្រជុំគ្នា ជាអ្នកត្រេកអរដោយកុសលកម្មរបស់ខ្លួន មានខ្លួនទូន្មានហើយ ជាអ្នកមានសេចក្ដីប្រាថ្នា ចំពោះកុសលកម្មរបស់ខ្លួន មានសីល មានប្រាជ្ញាចាស់ ជាអ្នកឈ្លាសវៃ ក្នុងអប្បមញ្ញាទាំងឡាយ ធ្វើឲ្យខ្ញុំរីករាយ ។

បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
សមយំ សំវិជិត្វាន ឧបគញ្ឆិ វិនាយកោ ។
ឧបគន្ត្វាន សម្ពុទ្ធោ អាតាបី និបកោ មុនិ
បត្តំ បគ្គយ្ហ សម្ពុទ្ធោ ភិក្ខាយ សមុចាគមិ ។
ឧបាគតំ មហាវីរំ ជលជុត្តមនាមកំ
តិណត្ថរំ បញ្ញាបេត្វា សាលបុប្ផេហិ ឱកិរឹ ។
និសីទិត្វាន[១] សម្ពុទ្ធំ អដ្ឋោ សំវិគ្គមានសោ
ទិប្បំ បព្វតមារុយ្ហ អគច្ឆុំ អគ្គហឹ អហំ ។
កុម្ភមត្តំ គហេត្វាន បនសំ ទេវគន្ធិកំ
ខន្ធេ អារោបយិត្វាន ឧបគញ្ឆឹ វិនាយកំ ។
ផលំ ពុទ្ធស្ស ទត្វាន អគច្ឆុំ អនុលិម្បហំ
បសន្នចិត្តោ សុមនោ ពុទ្ធសេដ្ឋំ អវន្ទិហំ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ឥសិមជ្ឈេ និសីទិត្វា ឥមា គាថា អភាសថ ។

---

១ ម. និសាទេត្វាន ។

ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់ត្រៃលោក គួរទទួលនូវគ្រឿងបូជា ជាអ្នកដឹកនាំសត្វលោក មានព្យាយាម មានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ទ្រង់ជ្រាបច្បាស់នូវសម័យ ស្តេចយាងចូលមកជិត ព្រះសម្ពុទ្ធទ្រង់កាន់បាត្រស្តេចចូលមកដើម្បីភិក្ខា ។ (ខ្ញុំបានឃើញ) នូវព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ មានព្យាយាមធំ ទ្រង់ស្តេចចូលមកហើយ ក៏ក្រាលកម្រាលស្មៅ ហើយរោយរាយដោយផ្កាឈើ ។ ខ្ញុំមានចិត្តតក់ស្លុត មិនអាចតាំងនៅបាន ក៏និមន្តព្រះសម្ពុទ្ធឲ្យគង់ ហើយឡើងភ្នំយ៉ាងឆាប់ កាន់យកនូវខ្លឹមក្រឹស្នា ។ ខ្ញុំបានបេះយកផ្លែខ្នុរប៉ុនឆ្នាំង មានក្លិនក្រអូប ជាទីរីករាយនៃទេវតា ហើយលើកលី នាំចូលទៅថ្វាយព្រះលោកនាយក ។ លុះខ្ញុំថ្វាយផ្លែខ្នុរ ចំពោះព្រះពុទ្ធរួចហើយ លាបនូវខ្លឹមក្រឹស្នា ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់ត្រៃលោក គួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្តាលពួកឥសី ហើយត្រាស់គាថាទាំងនេះថា

២៣៩

### បញ្ចមំ ឧបសីវត្ថេរាបទានំ

យោ ច មេ ផលមគ្ឃំ អាសនញ្ច អទាសិ មេ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
កាមេ វា យទិ វារញ្ញេ បព្ពតេសុ គុហាសុ វា
តមស្ស ចិត្តមញ្ញាយ និព្វត្តិស្សតិ ភោជនំ ។
ទេវលោកេ មនុស្សេ វា ឧបបន្នោ អយំ នរោ
ភោជនេហិ ច វត្ថេហិ បរិសន្តប្បយិស្សតិ ។
ឧបបជ្ជតិ យំ យោនឹ ទេវត្តំ អថ មានុសំ
អក្ខោភភោគោ ហុត្វាន សំសរិស្សតិយំ នរោ ។
តឹសកប្បសហស្សានិ ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
ឯកសត្តតិក្ខត្តុញ្ច ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
កប្បសតសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
ឧបសីវោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។

ឧបសីវត្ថេរាបទាន ទី ៥

បុគ្គលណាបានឲ្យផ្លែខ្នុរ ខ្ញីមក្រីស្មា និងអាសនៈដល់តថាគត ។ នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតនឹងសម្តែង ដូចតទៅនេះ បុគ្គលនេះ កាលនៅក្នុងស្រុកក្តី ក្នុងព្រៃក្តី ក្នុងញកភ្នំក្តី ក្នុងគុហាក្តី ភោជននឹងកើតឡើង ព្រោះដឹងចិត្តរបស់បុគ្គលនេះ នរៈនេះ បើទៅកើតក្នុងទេវលោកឬមនុស្សលោក នឹងឆ្អែតស្កប់ស្កល់ ដោយភោជនផង ដោយសំពត់ផង នរៈនេះ បើអន្ទោលទៅកាន់កំណើតណា ទោះជាទេវតា ឬជាមនុស្ស នឹងជាអ្នកមានភោគៈមិនរំភើបញាប់ញ័រ ។ នឹងត្រេកអរក្នុងទេវលោក អស់ ៣ ម៉ឺនកប្ប នឹងបានជាស្តេចចក្រពត្តិមួយពាន់ដង ។ នឹងបានសោយរាជ្យជាស្តេចទេវតា ៧១ ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក នរៈនេះ នឹងបានទទួលមត៌កក្នុងធម៌របស់ព្រះពុទ្ធនោះ ជាឱរសដែលធម៌និម្មិតហើយ មាននាមឧបសីវៈ នឹងបានជាសាវ័កនៃព្រះសាស្តា ។

សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ
សុលទ្ធលាភោ លទ្ធោ មេ យោហំ អទ្ទក្ខឹ ជាយកំ ។
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ
កាមេ វា យទិ វារញ្ញេ បព្ភារេសុ គុហាសុ វា
មម សង្កប្បមញ្ញាយ ភោជនំ ហោតិ មេ សទា ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧបសីវោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧបសីវត្ថេរស្ស អបទានំ សមត្តំ ។

នរៈនេះនឹងមិនមានអាសវៈ ព្រោះកំណត់ដឹងអាសវៈទាំងពួង ។ លាភដែលត្រូវបានដោយល្អ ខ្ញុំបានហើយ ព្រោះខ្ញុំបានជួបនឹងព្រះលោកនាយក ។ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ ខ្ញុំ (កាលទៅ) ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក្នុងញកភ្នំក្តី ក្នុងគុហាក្តី ភោជនរមែងកើតឡើងដល់ខ្ញុំ ព្រោះដឹងនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបសីវត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧបសីវត្ថេរាបទាន ។

២៤១

# ឆដ្ឋំ នន្ទកត្ថេរាបទានំ

[១០៦] មិគលុទ្ទោ បុរេ អាសឹ អរញ្ញេ កាននេ អហំ
បសទំ មិគមេសន្តោ សយម្ភុំ អទ្ទសំ អហំ ។
អនុរុទ្ធោ នាម សម្ពុទ្ធោ សយម្ភូ អបរាជិតោ
វិវេកកាមោ សោ ធីរោ វនំ អជ្ឈោគហិ តទា ។
ចតុទ្ទណ្ឌេ គហេត្វាន ចតុដ្ឋានេ ឋបេសហំ
មណ្ឌបំ សុកតំ កត្វា បទុមបុប្ផេហិ ឆាទយិ ។
មណ្ឌបំ ឆាទយិត្វាន សយម្ភុំ អភិវាទយឹ
ធនុំ តត្ថេវ និក្ខិប្ប បព្វជឹ អនគារិយំ ។
ន ចិរំ បព្វជិតស្ស ព្យាធិ មេ ឧបបជ្ជថ
បុព្វកម្មំ សរិត្វាន តត្ថ កាលំ កតោ អហំ ។
បុព្វកម្មេន សំយុត្តោ តុសិតំ អគមាសហំ
តត្ថ សោណ្ណមយំ ព្យម្ហំ និព្វត្តតិ យទិច្ឆកំ ។

# នន្ទកត្ថេរាបទាន ទី ៦

[១០៦] ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ កំពុងស្វែងរកម្រឹគប្រើស ស្រាប់តែបានជួបព្រះសយម្ភូ ។ គ្រានោះ ព្រះសយម្ភូសម្ពុទ្ធ ព្រះនាមអនុរុទ្ធ ទ្រង់ឈ្នះមារ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ប្រាថ្នានូវទីដ៏ស្ងប់ស្ងាត់ ស្តេចយាងចូលទៅក្នុងព្រៃ ។ ខ្ញុំយកឈើ ៤ កំណាត់ មកបញ្ឈរទុកក្នុងទីជា ៤ ធ្វើបារាំដ៏វិចិត្រយ៉ាងល្អ ប្រក់ដោយផ្កាឈូកទាំងឡាយ ។ ខ្ញុំប្រក់បារាំរួចហើយ ក៏ថ្វាយបង្គំព្រះសយម្ភូ ត្រវែងធ្នូចោលក្នុងទីនោះ ហើយចូលទៅកាន់ផ្នួស ។ កាលខ្ញុំទើបតែនឹងបួស ខ្ញុំក៏មានព្យាធិកើតឡើង ខ្ញុំនឹកឃើញនូវបុព្វកម្ម ហើយធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំប្រកបដោយបុព្វកម្ម បានទៅកើតក្នុងឋានតុសិត វិមានជាវិការៈនៃមាស កើតឡើងតាមសេចក្តីប្រាថ្នា ក្នុងទីនោះ ។

សហស្សយុត្តំ ហយវាហឹ ទិព្វយានមធិដ្ឋិតោ
អារោហិត្វាន តំ យានំ គច្ឆាមហំ យទិច្ឆកំ ។
តតោ មេ ធីយមានស្ស ទេវភូតស្ស មេ សតោ
សមន្តា យោជនសតំ មណ្ឌបោ មេ ធរីយតិ ។
សយនេ សោ តុវដ្ដាមិ អច្ឆន្នេ បុប្ផសន្ថតេ
អន្តលិក្ខា ច បទុមា វស្សន្តេ និច្ចកាលិកំ ។
មរីចិកេ ផន្ទមានេ តប្បមានេ ច អាតបេ
ន មំ តបតិ អាតប្បោ មណ្ឌបស្ស ឥទំ ផលំ ។
ទុគ្គតឹ សមតិក្កន្តោ អបាយា បិហិតា មម
មណ្ឌបេ រុក្ខមូលេ វា សន្តាបោ មេ ន វិជ្ជតិ ។
មហិសញ្ញំ អធិដ្ឋាយ លោណតោយំ តរាមហំ
តស្ស មេ សុកតំ កម្មំ ពុទ្ធបូជាយិទំ ផលំ ។
អព្ភម្ហិ បថំ កត្វាន គច្ឆាមិ អនិលញ្ជសេ
អហោ មេ សុកតំ កម្មំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំអធិដ្ឋាននូវវាហនៈ ដែលទឹមដោយសេះមួយពាន់ ជាយានទិព្វ ខ្ញុំឡើងកាន់យាននោះ ហើយទៅតាមសេចក្តីប្រាថ្នា ។ កាលបើខ្ញុំ ដែលបុញ្ញកម្មនាំអំពីទីនោះមក ខ្ញុំបានកើតជាទេវតា បារាំបិទបាំងខ្ញុំ អស់ទីមួយរយយោជន៍ជុំវិញ ។ ខ្ញុំនោះ ដេកលើដំណេកដោយរូសរាន់ ដែលគេមិនបានប្រក់ហើយ គ្រាន់តែក្រាលដោយផ្កា ស្រាប់តែផ្កាឈូកធ្លាក់ចុះអំពីអាកាស មកបិទបាំងអស់កាលជានិច្ច ។ កាលថ្ងៃបណ្តើរកូនកំពុងញាប់ញ័រ កាលកម្តៅថ្ងៃកំពុងក្តៅ កម្តៅឥតក្តៅដល់ខ្ញុំឡើយ នេះជាផលនៃការឲ្យបារាំ ។ ខ្ញុំបានកន្លងផុតទុគ្គតិ អបាយទាំងឡាយ ខ្ញុំបានបិទហើយ កម្តៅក្នុងបារាំក្តី ទៀបគល់នៃឈើក្តី ឥតមានដល់ខ្ញុំឡើយ ។ ខ្ញុំអធិដ្ឋានទឹកសមុទ្រ ឲ្យទៅជាផែនដី ហើយឆ្លងនូវទឹកប្រៃព្រោះអំពើដែលខ្ញុំ បានធ្វើល្អហើយនោះ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំធ្វើផ្លូវឰដ៏អាកាស ហើយទៅឰដ៏អាកាសបាន ឱហ្ន៎ ! អំពើដែលខ្ញុំធ្វើល្អហើយ នេះជាផលនៃពុទ្ធបូជា ។

## ២៤៣

### ឆដ្ឋំ នន្ទកត្ថេរាបទានំ

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
អាសវា មេ បរិក្ខីណា ពុទ្ធបូជាយិទំ ផលំ ។
ជហិតា បុរិមា ជាតិ ពុទ្ធស្ស ឱរសោ អហំ
ទាយាទោម្ហិ ច សទ្ធម្មេ ពុទ្ធបូជាយិទំ ផលំ ។
អារាធិតោម្ហិ សុគតំ គោតមំ សក្យបុង្គវំ
ធម្មធជោ ធម្មទាយាទោ[១] ពុទ្ធបូជាយិទំ ផលំ ។
ឧបដ្ឋិត្វាន សម្ពុទ្ធំ គោតមំ សក្យបុង្គវំ
ចារំ គមនីយំ មគ្គំ អបុច្ឆឹ លោកនាយកំ ។
អជ្ឈិដ្ឋោ កថយិ ពុទ្ធោ គម្ភីរំ និបុណំ បទំ
តស្សាហំ ធម្មំ សុត្វាន បត្តោម្ហិ អាសវក្ខយំ ។
អហោ មេ សុកតំ កម្មំ បរិមុត្តោម្ហិ ជាតិយា
សព្វាសវបរិក្ខីណោ នត្ថិទានិ បុនព្ភវោ ។

---

១ ម. ធម្មធជោ ធម្មទាសោតិ ទិស្សន្តិ ។

## នន្ទកត្ថេរាបទាន ទី ៦

ខ្ញុំដឹងខន្ធរបស់ខ្លួននិងសត្វដទៃ ដែលអាស្រ័យនៅក្នុងកាលមុន ទិព្វចក្ខុ ខ្ញុំបានជម្រះហើយ អាសវៈទាំងឡាយរបស់ខ្ញុំអស់រលីងហើយ នេះជាផលនៃពុទ្ធបូជា ។ ជាតិខាងមុខខ្ញុំបានលះបង់ហើយ ខ្ញុំបានជាឱរសនៃព្រះពុទ្ធ ជាអ្នកទទួលមត៌ក ក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានញ៉ាំងព្រះសុគត ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យប្រោសប្រាណ ជាអ្នកទ្រទ្រង់ធម៌ ជាអ្នកទទួលមត៌កក្នុងធម៌ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានបម្រើព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ហើយបានក្រាបទូលសួរផ្លូវដែលគប្បីទៅកាន់ត្រើយ គឺព្រះនិព្វាន ចំពោះព្រះលោកនាយក ។ ព្រះពុទ្ធដែលខ្ញុំអារាធនាហើយ ទ្រង់សម្តែងនូវបទ គឺព្រះនិព្វាន ជាគុណជាតដ៏ល្អិតជ្រាលជ្រៅ ខ្ញុំលុះបានស្តាប់ធម៌ របស់ព្រះពុទ្ធនោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ឱហ្ន៎ ! អំពើល្អ ខ្ញុំបានធ្វើហើយ ខ្ញុំបានរួចស្រឡះ ចាកជាតិហើយ មានអាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នន្ទកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

នន្ទកត្ថេរស្ស អបទានំ សមត្តំ ។

## សត្តមំ ហេមកត្ថេរាបទានំ

[១០៧] បព្ភារកូដំ និស្សាយ អនោមោ នាម តាបសោ
អស្សមំ សុកតំ កត្វា បណ្ណសាលេ វសី តទា ។

*កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។*

*បានឮថា ព្រះនន្ទកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់ នន្ទកត្ថេរាបទាន ។

## ហេមកត្ថេរាបទាន ទី ៧

[១០៧] *កាលនោះ ខ្ញុំជាតាបសឈ្មោះអនោមៈ បានធ្វើអាស្រម បណ្ណសាលាដ៏វិចិត្រល្អ នៅអែបនឹងចុងញកភ្នំ ។*

## សត្តមំ ហេមកត្ថេរាបទានំ

សិទ្ធំ តស្ស តបោកម្មំ    សិទ្ធិប្បត្តោ សកេ ពលេ
សកំសាមញ្ញវិក្កន្តោ    អាតាបី និបកោ មុនិ ។
វិសារទោ សសមយេ    បរវាទេ ច កោវិទោ
បដ្ឋោ ភូមន្តលិក្ខស្មឹ    ឧបាទម្ហិ(១) ច កោវិទោ ។
វីតសោកោ និរារម្ភោ    អប្បាហារោ អលោលុបោ
លាភាលាភេន សន្តុដ្ឋោ    ឈាយី ញាណរតោ មុនិ ។
បិយទស្សី នាម សម្ពុទ្ធោ    អគ្គោ ការុណិកោ មុនិ
សត្តេ តារេតុកាមោ សោ    ករុណាយ ផរិ តទា ។
ពោធនីយំ ជនំ ទិស្វា    បិយទស្សី មហាមុនិ
ចក្កវាឡសហស្សម្ហិ    គន្ត្វា ឱវាទកោ មុនិ ។
មមុទ្ធរិតុកាមោ សោ    មមស្សមមុបាគមិ
ន ទិដ្ឋោ មេ ជិនោ បុព្វេ    ន សុតោបិ ច កស្សចិ ។

---
១ ម. ឧបាតម្ហិ ។

ហេមកត្ថេរាបទាន ទី ៧

ខ្ញុំនោះ បានសម្រេចនូវតបកម្ម ខ្ញុំដល់នូវការសម្រេច ក្នុងកម្លាំងរបស់ខ្លួន ជាអ្នកក្លាហាន ក្នុងភាពនៃខ្លួនជាសមណៈ ជាអ្នកមានព្យាយាមដុតបំផ្លាញកិលេស មានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ជាអ្នកក្លៀវក្លាក្នុងលទ្ធិរបស់ខ្លួន វាងវៃក្នុងវាទៈរបស់បុគ្គលដទៃ មួយទៀត ជាអ្នកតាំងនៅលើផែនដី និងអាកាសបាន វាងវៃក្នុងឧបាទវយធម៌ ។ ខ្ញុំប្រាសចាកសេចក្ដីសោក មិនមានការប្រណាំងប្រជែង មានអាហារតិច មិនមានសេចក្ដីប្រាថ្នា ជាអ្នកត្រេកអរ ដោយលាភនិងអលាភ មានឈាន ត្រេកអរក្នុងឈាន ជាអ្នកប្រាជ្ញ ។ កាលនោះ ព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ព្រះអង្គប្រាថ្នាដើម្បីចម្លង នូវសត្វទាំងឡាយ ទ្រង់ផ្សាយព្រះទ័យករុណា ។ ព្រះមហាមុនី ព្រះនាមបិយ-ទស្សី ទ្រង់ឃើញនូវជនដែលគួរឲ្យត្រាស់ដឹង ព្រះអង្គជាអ្នកប្រាជ្ញ ជាអ្នកឲ្យឱវាទ ស្ដេចទៅក្នុងចក្រវាឡមួយពាន់ ។ ព្រះអង្គមានប្រាថ្នាស្រោចស្រង់ខ្ញុំ ស្ដេចយាងចូលទៅកាន់អាស្រមរបស់ខ្ញុំ ព្រះជិនស្រី ខ្ញុំមិនដែលឃើញទាំងមិនធ្លាប់បានឮ អំពីសម្នាក់អ្នកណាមួយ ក្នុងកាលមុនឡើយ ។

ឧប្បាជា[១] សុបិនា មយ្ហំ  លក្ខណា សុប្បកាសិតា
បជ្ជោ ភូមន្តលិក្ខស្មឹ  នក្ខត្តបទកោវិទោ ។
សោហំ ពុទ្ធស្ស សុត្វាន  តត្ថ ចិត្តំ បសាទយឹ
តិដ្ឋន្តោ[២] វា និសិន្នោ វា  សរាមិ និច្ចកាលិកំ ។
មម ឯវំ សរន្តស្ស  ភគវាបិ អនុស្សរិ
ពុទ្ធំ អនុស្សរន្តស្ស  បីតិ មេ ហោតិ តាវទេ ។
កាលញ្ច បុនរាគម្ម  មំ ឧបេសិ មហាមុនិ
សម្បត្តេបិ ន ជានាមិ  អយំ ពុទ្ធោ មហាមុនិ ។
អនុកម្បកោ ការុណិកោ  បិយទស្សី មហាមុនិ
សញ្ជានាបេសិ អត្តានំ  អហំ ពុទ្ធោ សទេវកេ ។
សញ្ជានិត្វាន សម្ពុទ្ធំ  បិយទស្សឹ មហាមុនឹ
សកំ ចិត្តំ បសាទេត្វា  ឥទំ វចនមព្រវឹ ។

---
១ ម. ឧប្បាតា ។ ២ ម. ភុញ្ជន្តោ វា ។

ខ្ញុំបានសុបិននិម្មិតកើតឡើង លក្ខណៈទាំងឡាយ បានប្រកាសល្អហើយ ខ្ញុំជាអ្នកបិតនៅលើផែនដី និងអាកាសឈ្លាសវៃ ក្នុងបទនៃនក្ខត្តឫក្ស ។ ខ្ញុំនោះ បានស្តាប់ធម៌របស់ព្រះពុទ្ធហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ខ្ញុំទោះឈរ ឬអង្គុយ តែងនឹកឃើញព្រះអង្គជានិច្ច ។ កាលខ្ញុំកំពុងនឹកយ៉ាងនេះ ព្រះមានព្រះភាគ ក៏ទ្រង់នឹកដល់ខ្ញុំដែរ ខ្ញុំកំពុងតែនឹកព្រះពុទ្ធ បីតិក៏កើតមាន ដល់ខ្ញុំ ក្នុងខណៈនោះ ។ ព្រះមហាមុនី ទ្រង់ស្តេចចូលមករកខ្ញុំ អស់កាលម្តងទៀត កាលបើព្រះអង្គស្តេចមកដល់ហើយ ខ្ញុំឥតស្គាល់ថា នោះជាព្រះពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរឡើយ ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ប្រកបដោយករុណា ទ្រង់អនុគ្រោះខ្ញុំ បានញុំាងខ្ញុំឲ្យស្គាល់ព្រះអង្គថា តថាគត ជាព្រះពុទ្ធក្នុងលោក ព្រមទាំងទេវលោក ។ ខ្ញុំបានស្គាល់ច្បាស់ នូវព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ជាមហាមុនី ហើយក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ក្រាបទូលពាក្យនេះថា

២៤៧

## សត្តមំ ហោមកត្ថេរាបទានំ

សព្វេ(១) បីឋេ ច បល្លង្កេ អាសន្ទីសុ និសីទរេ
តុវំបិ សព្វទយាវី(២) និសីទ រុចិរាសនេ(៣) ។
សព្វរតនមយំ បីឋំ និម្មិនិត្វាន តាវទេ
បិយទស្សិស្ស មុនិនោ អាសនំ(៤) ឥទ្ធិនិម្មិតំ ។
រតនេវ និសិន្នស្ស បីឋកោ ឥទ្ធិនិម្មិតេ
កុម្ភមត្តំ ជម្ពុផលំ អទាសឹ តាវទេ អហំ ។
មម ហាសំ ជនេត្វាន បរិភុញ្ជិ មហាមុនិ
តទា ចិត្តំ បសាទេត្វា សត្ថារំ អភិវាទយឹ ។
បិយទស្សី តុ ភគវា លោកជេដ្ឋោ នរាសភោ
រតនាសនមាសិន្នោ ឥមា គាថា អភាសថ ។
យោ មេ រតនមយំ បីឋំ អមតញ្ច ផលំ តទា
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

---

១ ម. អញ្ញេ ។ ២ ម. សព្វទស្សាវី ។ ៣ ម. រតនាសនេ ។ ៤ ម. អទាសឹ ។

ហេមកត្ថេរាបទាន ទី ៧

ពួកជនទាំងអស់ តែងអង្គុយលើតាំងក្តី លើបល្ល័ង្កក្តី លើតាំងវែងក្តី ព្រះអង្គមានសេចក្តីអាណិតអាសូរ ដល់សត្វទាំង-ពួង សូមគង់លើអាសនៈដ៏រុងរឿង ។ ខ្ញុំបាននិម្មិតតាំងជាវិការៈនៃកែវទាំងពួង ជាអាសនៈដែលខ្ញុំនិម្មិតដោយឫទ្ធិ ថ្វាយព្រះមហាមុនី ព្រះនាមបិយទស្សី ក្នុងខណៈនោះ ។ កាលព្រះអង្គគង់លើតាំងកែវដែលនិម្មិតដោយឫទ្ធិ ខ្ញុំបានថ្វាយផ្លែព្រីងប៉ុនក្អម ក្នុងខណៈនោះ ។ ព្រះមហាមុនី ទ្រង់ញ៉ាំងសេចក្តីរីករាយឲ្យកើតដល់ខ្ញុំ ហើយទ្រង់សោយ (ផ្លែព្រីងនោះ) គ្រានោះ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសាស្តា ។ ចំណែកព្រះមានព្រះភាគ ព្រះនាមបិយទស្សី ព្រះអង្គប្រសើរបំផុតក្នុងលោក ប្រសើរជាងនរៈ ទ្រង់គង់លើអាសនៈកែវ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានថ្វាយតាំងជាវិការៈនៃកែវ និងផ្លែព្រីងទិព្វដល់តថាគត ក្នុងកាលនោះ តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតនឹងសម្តែង ដូចតទៅនេះ

សត្តសត្តតិ កប្បានិ ទេវលោកេ រមិស្សតិ
បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តិ ភវិស្សតិ ។
ទ្វត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
សោវណ្ណមយំ រុចិមយំ បល្លង្កំ សុកតំ ពហុំ
លោហិតង្គមយញ្ចេវ លព្ភតិ រតនាមយំ ។
ចង្កមន្តំបិ មនុញ្ញំ[១] បុញ្ញកម្មសមង្គិនំ
បល្លង្កានិ អនេកានិ បរិវារិស្សរេ សទា ។
កូដាគារា ច បាសាទា សយនញ្ច មហារហំ
ឥមស្ស ចិត្តមញ្ញាយ និព្វត្តិស្សន្តិ តាវទេ ។
សដ្ឋី នាគសហស្សានិ សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា ហេមកប្បនិវាសសា ។
អារុឡ្ហា គាមណិយេភិ តោមរង្កុសបាណិភិ
តេបិមំ បរិចរិស្សន្តិ រតនបីឋស្សិទំ ផលំ ។

---
១ ម. មន្ទជំ ។

បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។ នឹងបានជាព្រះឥន្ទ្រសោយទេវរាជ្យ អស់ ៣២ ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ បុគ្គលនោះ នឹងបាននូវបល្ល័ង្កជាវិការៈនៃមាស ជាវិការៈនៃវត្ថុជាទីគាប់ចិត្ត ជាវិការៈនៃកែវទទឹម ជាវិការៈនៃកែវជាច្រើន ដែលបុញ្ញកម្មបានតាក់តែងល្អហើយ ។ បល្ល័ង្កទាំងឡាយជាច្រើន ចោមរោមបុគ្គល អ្នកប្រកបដោយបុញ្ញកម្មនោះ សូម្បីកាលដើរទៅដើរមក សព្វ ៗ កាល ។ ផ្ទះមានកំពូលប្រាសាទនិងទីសម្រាប់ដេក មានតម្លៃច្រើន នឹងកើតក្នុងខណៈនោះ ព្រោះដឹងចិត្តរបស់បុគ្គលនេះ ។ ដំរី ៦០ ពាន់ ដែលគេស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាដំរីដ៏ប្រសើរ មានខ្សែដង្កន់មាស ប្រកបដោយគ្រឿងតាក់តែងក្បាលជាវិការៈនៃមាស ។ ដំរីទាំងនោះ ដែលពួកហ្មមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំងជាវិការៈនៃកែវ ។

២៤៩

## សត្តមំ ហេមកត្តោរាបទានំ

សដ្ឋី អស្សសហស្សានិ សព្វាលង្ការភូសិតា
អាជានិយា ច ជាតិយា សិន្ធវា សីឃពាហនា ។
អារុឡ្ហា គាមណិយេភិ ចាបហត្ថេហិ ចម្មិភិ[១]
តេបិមំ បរិចរិស្សន្តិ រតនបីឋស្សិទំ ផលំ ។
សដ្ឋី រថសហស្សានិ សព្វាលង្ការភូសិតា
ទីបា អថោបិ វេយ្យគ្ឃា សន្នទ្ធា ឧស្សិតទ្ធជា ។
អារុឡ្ហា គាមណិយេភិ ចាបហត្ថេហិ ចម្មិភិ
បរិវារេស្សន្តិមំ និច្ចំ រតនបីឋស្សិទំ ផលំ ។
សដ្ឋី ធេនុសហស្សានិ គាវី សុបុង្គវុសភា
វច្ឆកេ ជនយិស្សន្តិ រតនបីឋស្សិទំ ផលំ ។
សោឡសិត្ថីសហស្សានិ សព្វាលង្ការភូសិតា
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា ។
អាឡារមុខា ហសុលា សុសញ្ញា តនុមជ្ឈិមា
បរិវារេស្សន្តិមំ និច្ចំ រតនបីឋស្សិទំ ផលំ ។

១ ម. ឥទ្ធិយា ចាបធារិភីតិ ខាយតិ ។

សេះ ៦០ ពាន់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ជាអាជានេយ្យ អំពីកំណើត ជាសេះសិន្ធព ជាពាហនៈដ៏លឿន ។ សេះទាំងនោះ ដែលនាយសារថី មានដៃកាន់ធ្នូនិងខែលឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំង ជាវិការៈនៃកែវ ។ រថទាំង ៦០ ពាន់ ដែលតាក់តែងដោយគ្រឿងប្រដាប់គ្រប់យ៉ាង បិទបាំងដោយស្បែកខ្លាដំបង ខ្លាធំ ដែលគេប្រដាប់ហើយ លើកទង់ជ័យ មានពួកនាយសារថី មានដៃកាន់ធ្នូនិងខែល ឡើងជិះហើយ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំង ជាវិការៈនៃកែវ ។ ពួកមេគោមានទឹកដោះ ៦០ ពាន់ មេគោនិងពួកគោឧសភដ៏ប្រសើរ នឹងញុំាងកូនទាំងឡាយ ឲ្យកើត នេះជាផលនៃការថ្វាយតាំង ជាវិការៈនៃកែវ ។ ពួកស្ត្រី ១៦ ពាន់ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមុក្តា កែវមណីនិងកណ្ឌល ទាំងមានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ ទាំងមានចង្កេះរៀវ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំង ជាវិការៈនៃកែវ ។

អដ្ឋារសេ កប្បសតេ គោតមោ នាម ចក្ខុមា
តមន្ធការំ វិធំសេត្វា ពុទ្ធោ លោកេ ភវិស្សតិ ។
តស្ស ទស្សនមាគម្ម បព្វជិស្សតិ កិញ្ចនោ
តោសយិត្វាន សត្ថារំ សាសនេភិរមិស្សតិ ។
តស្ស ធម្មំ សុណិត្វាន កិលេសេ ឈាបយិស្សតិ
សព្វាសវេ បរិញ្ញាយ និព្វាយិស្សតិនាសវោ ។
វីរិយំ មេ ធុរធោរយ្ហំ យោគក្ខេមាធិវាហនំ
ឧត្តមត្ថំ បត្ថយានោ សាសនេ វិហរាមហំ ។
ឥទំ បច្ឆិមកំ មយ្ហំ ចរិមោ វត្តតេ ភវោ
សព្វាសវបរិក្ខីណោ នត្ថិទានិ បុនព្ភវោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

ក្នុងកប្ប ទី ១.៨០០ នឹងមានព្រះពុទ្ធ ព្រះនាមគោតម មានបញ្ញាចក្ខុ ទ្រង់កម្ចាត់បង់ នូវងងឹតអន្ធការ ត្រាស់ដឹងក្នុងលោក ។ បុគ្គលនេះ មានសេចក្តីខ្វល់ខ្វាយ នឹងបួសព្រោះអាស្រ័យការឃើញ នូវព្រះពុទ្ធអង្គនោះ បានញុំាងព្រះសាស្តាឲ្យត្រេកអរ នឹងរីករាយក្នុងសាសនា ។ បុគ្គលនេះបានស្តាប់ធម៌របស់ព្រះពុទ្ធអង្គនោះហើយ នឹងដុតបំផ្លាញនូវកិលេសទាំងឡាយ កំណត់ដឹងនូវអាសវៈទាំងពួង ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

សេចក្តីព្យាយាមរបស់ខ្ញុំ គួរនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ ដ៏ក្សេមចាកយោគៈ ខ្ញុំប្រាថ្នានូវប្រយោជន៍ដ៏ឧត្តមក្នុងសាសនា ។ នេះជារាងកាយ ខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ខ្ញុំមានអាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្ទីង ។

## ២៤១

អដ្ឋមំ តោទេយ្យត្ថេរាបទានំ

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ហេមកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ហេមកត្ថេរស្ស អបទានំ សមត្តំ ។

អដ្ឋារសមំ ភាណវារំ ។

# អដ្ឋមំ តោទេយ្យត្ថេរាបទានំ

[១០៨] រាជា វិជិតជយោ នាម កេតុមតិបុរុត្តមេ
សុរោ វិក្កមសម្បន្នោ បុរមជ្ឈាវសី តទា ។
តស្ស រញ្ញោ បមត្តស្ស រដ្ឋវិសា[១] សមុដ្ឋហុំ
ឧត្តរា តុណ្ឌិកា ចេវ រដ្ឋំ វិទ្ធំសយុំ តទា ។

១ ម. អដ្ដវិយោ ។

ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់តាមលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះហេមកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ហេមកត្ថេរាបទាន ។

ចប់ ភាណវារៈ ទី ១៨ ។

# តោទេយ្យត្ថេរាបទាន ទី ៨

[១០៨] គ្រានោះ ក្នុងកេតុមតីបុរីដ៏ឧត្តម ព្រះរាជាព្រះនាមវិជិតជ័យ ជាស្តេចក្លៀវក្លា បរិបូណ៌ដោយព្យាយាម នៅគ្រប់គ្រងបុរី ។ កាលព្រះរាជាអង្គនោះ ធ្វេសប្រហែសហើយ ពួកជនជាសត្រូវ នៅក្នុងដែនឧត្តរៈនិងតុណ្ឌិកៈ បង្កគ្នាឡើង លុកលុយដែន ក្នុងកាលនោះ ។

បច្ចន្តេ កុប្បិតេ ខិប្បំ  សន្និចាតេសិរិន្ទមោ
ភដេ ចេវ ពលត្ថេ ច  អរី និក្កាហយិ តទា ។
ហត្ថារោហា អនីកត្ថា  សូរា ច វម្មយោធិនោ[១]
ធនុគ្គហា ច រថិកា[២]  សព្វេ សន្និបតុំ តទា ។
អាឡារិកា កប្បកា ច  ន្ហាបកា មាលការកា
សូរា វិជិតសង្គាមា  សព្វេ សន្និបតុំ តទា ។
ខគ្គហត្ថា ច បុរិសា  ចាបហត្ថា ច ចម្មិនោ[៣]
លុទ្ធា វិជិតសង្គាមា  សព្វេ សន្និបតុំ តទា ។
តិធប្បភិន្នា មាតង្គា  កុញ្ជរា សដ្ឋិហាយនា
សុវណ្ណកច្ឆាលង្ការា  សព្វេ សន្និបតុំ តទា ។
ខមា សីតស្ស ឧណ្ហស្ស  ឧក្ការុហរណស្ស ច
យោធាជីវា កតកម្មា  សព្វេ សន្និបតុំ តទា ។
សង្ខសទ្ទំ ភេរិសទ្ទំ  អថោ ឧទ្ធជសទ្ទកំ[៤]
ឯតេហិ តេ ហាសយន្តា  សព្វេ សន្និបតុំ តទា ។

---

១ ម. ចម្មយោធិនោ ។ ២ ម. ឧគ្គា ច ។ ៣ ម. វម្មិនោ ។ ៤ ម. ឧតុជសទ្ទកំ ។

កាលអ្នកបច្ចន្តគ្រាមបះបោរឡើងហើយ ព្រះរាជាទ្រង់ឲ្យប្រជុំគ្នាយ៉ាងប្រញាប់ គឺទ្រង់ញ៉ាំងអាមាត្យនិងរាជទូតទាំងឡាយឲ្យសង្កត់សង្កិនសត្រូវ ក្នុងកាលនោះ ។ ពលដំរី ពលសេះពលពាក់គ្រឿងក្រោះ ពលកាន់ធ្នូ និងពលរថទាំងអស់សុទ្ធតែជាអ្នកក្លៀវក្លា មកប្រជុំគ្នា ក្នុងកាលនោះ ។ ពួកអ្នកគ្រួ ពួកអ្នកខ្មាន់ព្រះកេស ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើផ្កាកម្រងទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏ក្លាហាន មកប្រជុំគ្នា ក្នុងកាលនោះ ។ ពួកបុរស មានដាវក្នុងដៃ មានធ្នូ និងខែលក្នុងដៃ ទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏កាច មកប្រជុំគ្នា ក្នុងកាលនោះ ។ ពួកដំរីដ៏ប្រសើរ មានអាយុ ៦០ ឆ្នាំ មានខ្សែដង្កន់ និងគ្រឿងប្រដាប់ជាវិការៈនៃមាស សុទ្ធតែជាដំរីចុះប្រេង ៣ អន្លើ ទាំងអស់ មកប្រជុំគ្នាក្នុងទីនោះ ។ ក្រុមយុទ្ធនាធិការទាំងអស់ ដែលមានការផ្សារធ្វើហើយ ជាអ្នកអត់ធ្មត់ចំពោះត្រជាក់ ក្តៅ និងការបន្ទោបង់នូវលាមក មកប្រជុំគ្នា ក្នុងកាលនោះ ។ សំឡេងស័ង្ខសំឡេងស្គរ ជាសំឡេងលាន់ឮឡើង ពួកជនទាំងអស់នោះរីករាយដោយសំឡេងទ៊ុះ មកប្រជុំគ្នា ក្នុងកាលនោះ ។

២៤៣

អដ្ឋមំ តោទេយ្យត្ថេរាបទានំ

តិសូលកោន្តិមន្តេហិ ជនូហិ តោមរេហិ[១] ច
កោដ្ដយន្តា និវត្តេន្តា[២] សព្វេ សន្និបតុំ តទា ។
ការចានិ និភាសេត្វា[៣] សរាជា អជិតញ្ជយោ
សជ្ជីចាណសហស្សានិ សូលេ ឧត្តាសយឹ តទា ។
សត្វំ មានុសកាកំសុ អហោ រាជា អធម្មិកោ
និរយេ បច្ចមានស្ស តទា អន្តោ ភវិស្សតិ ។
សយនេហំ តុវដ្ដេន្តោ បស្សាមិ និរយេ តទា
ន សុចាមិ ទិវារត្តឹ សូលេន តជ្ជយន្តិ មំ ។
កឹ បមាទេន រជ្ជេន ពាហនេន ពលេន ច
ន តេ បហោន្តិ ធារេតុំ តាសយន្តិ មមំ សទា ។
កឹ មេ បុត្តេហិ ទារេហិ រជ្ជេន សកលេន ច
យន្នូន បព្វជេយ្យាហំ គតិមគ្គំ វិសោធយេ ។

១ ម. កវចតោមរេហិ ច ។ ២ ម. កោដេន្តានំ និបាតេន្តាតិ ទិស្សន្តិ ។ ៣ ម. កិមេវាតិ និយាមេត្វាតិ ខាយតិ ។

## តោទេយ្យត្ថេរាបទាន ទី ៨

ពួកជនទាំងអស់ ចាក់ផ្លូលដោយច្បូក កាំបិតចៀស្បែក ផ្នូ និងលំពែងស្នែងក្របី មកប្រជុំគ្នា ក្នុងកាលនោះ ។ កាលនោះ ខ្ញុំហ្នឹងឯង ជាស្តេចឈ្នះសង្គ្រាមដែលគេមិនធ្លាប់ឈ្នះ ពាក់គ្រឿងក្រោះ បានយកដែកស្រួចចាក់សត្វ ៦០ ពាន់ឲ្យតក់ស្លុត ។ ពួកមនុស្សបានស្រែកកងរំពងថា ឱហ្ន៎ ស្តេចនេះ មិនប្រកបដោយធម៌ទេ កាលបើស្តេចនេះ ទៅឆេះក្នុងនរក កាលណា កាលនោះ យើងទើបនឹងមានទីបំផុតនៃទុក្ខ ។ កាលនោះ ខ្ញុំដេកលើដំណាក់ ស្រាប់តែឃើញសត្វនរក ខ្ញុំដេកឥតលក់ទាំងថ្ងៃទាំងយប់ ពួកនិរយបាលទាំងនោះ គំរាមខ្ញុំដោយដែកស្រួច ។ ខ្ញុំគិតថា ប្រយោជន៍អ្វីដោយរាជ្យ ពាហនៈ និងពល ដែលអញប្រមាទហើយ រាជ្យ និងពលទាំងនោះ មិនអាចទ្រទ្រង់អញបានឡើយ មានតែញុាំងអញឲ្យតក់ស្លុត សព្វ ៗ កាល ។ ប្រយោជន៍អ្វីដោយកូនប្រពន្ធ និងរាជ្យទាំងអស់របស់អញ បើដូច្នោះ អាត្មាអញគួរតែបួស នឹងជម្រះផ្លូវសម្រាប់ទៅកាន់ (ព្រះនិព្វាន) ។

សដ្ឋីនាគសហស្សានិ សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ ហេមកប្បនិវាសសេ ។
អារុឡ្ហេ គាមណីយេភិ តោមរង្កុសបាណិភិ
សង្គាមាវចរេ ហានេ អនបេក្ខោ វិហាយហំ ។
សកកម្មេន សន្តុដ្ឋោ និក្ខមឹ អនគារិយំ
សដ្ឋីអស្សសហស្សានិ សព្វាលង្ការភូសិតេ ។
អាជានីយេ ច ជាតិយា សិន្ធវា សីឃពាហនេ
អារុឡ្ហេ គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ[១] ។
ឆឌ្ឌយិត្វាន សព្វេ តេ និក្ខមំ អនគារិយំ
សដ្ឋីរថសហស្សានិ សព្វាលង្ការភូសិតេ ។
ទីបេ អថោបិ វេយ្យគ្ឃេ សន្នទ្ធេ ឧស្សិតទ្ធជេ
សព្វេ តេ បរិវជ្ជេត្វា បព្វជឹ អនគារិយំ ។

---

១ ម. វម្មិភិ ។

ខ្ញុំឥតអាឡោះអាល័យ បានលះបង់ពួកដំរី ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការ គ្រប់យ៉ាង ជាដំរីដ៏ប្រសើរ មានខ្សែរដង្គន់មាស ប្រកបដោយគ្រឿងតាក់តែងក្បាល ជាវិការៈនៃមាស ដែលពួកហ្មដំរីមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយ ក្នុងទីសមរភូមិ ខ្ញុំក្តៅក្រហាយសព្វ ដោយកម្មរបស់ខ្លួន ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំលះចោលនូវសេះ ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង នូវសេះអាជានេយ្យអំពីកំណើត និងសេះសិន្ធវៈ ជាពាហនៈដ៏លឿន ដែលពួកនាយសារថីមានធ្នូក្នុងដៃ និងពាក់គ្រឿងក្រោះឡើងជិះហើយ ទាំងអស់នោះ ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំបានលះបង់ នូវរាជរថ ចំនួន ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដែលប្រកបស្រោបបិទបាំង ដោយស្បែកខ្លាដំបង និងខ្លាធំ មានទង់ជ័យលើកឡើង ទាំងអស់នោះ ហើយចេញទៅកាន់ផ្នួស ។

២៨៨

## អដ្ឋមំ តោទេយ្យត្ថេរាបទានំ

សដ្ឋីធេនុសហស្សានិ សព្វា កំសុបធារណា
ការិយោ ឆឌ្ឌយិត្វាន បព្វជឹ អនគារិយំ ។
សដ្ឋីឥត្ថីសហស្សានិ សព្វាលង្ការភូសិតា
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា ។
អាឡារមុខា[១] ហសុលា សុសញ្ញា តនុមជ្ឈិមា
តា ហិត្វា កន្ទមានាយោ បព្វជឹ អនគារិយំ ។
សដ្ឋីគាមសហស្សានិ បរិបុណ្ណានិ សព្វសោ
ឆឌ្ឌយិត្វាន តំ រជ្ជំ បព្វជឹ អនគារិយំ ។
នគរា និក្ខមិត្វាន ហិមវន្តំ ឧបាគមឹ
ភាគីរសីនទីតីរេ អស្សមំ មាបយឹ អហំ ។
បណ្ណសាលំ ករិត្វាន អគ្យាគារំ អកាសហំ
អារទ្ធវីរិយោ បហិតត្តោ វសាមិ អស្សមេ អហំ ។
មណ្ឌបេ រុក្ខមូលេ វា សុញ្ញាគារេ វ ឈាយតោ
ន តុ វិជ្ជតិ តាសោ មេ ន បស្សេ ភយភេរវំ ។
សុមេធោ នាម សម្ពុទ្ធោ អគ្គោ ការុណិកោ មុនិ
ញាណាលោកេន ជោតេន្តោ លោកេ ឧប្បជ្ជិ តាវទេ ។

---
១ ម. អាឡារបម្ហា ។

## គោទេយ្យត្ថេរាបទាន ទី ៨

ខ្ញុំលះបង់នូវមេគោ ដែលមានទឹកដោះ ៦០ ពាន់ និងគ្រឿងសម្រាប់ទ្រភាជន៍ទាំងអស់ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំលះបង់ពួកស្រី ៦០ ពាន់ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់យ៉ាង មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្ត ពាក់កែវមណីនិងកណ្ឌល មានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានចង្កេះមូលរៀវ កំពុងកន្ទក់កន្ទេញទាំងនោះ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំលះបង់ស្រុក ៦០ ពាន់ បរិបូណ៌ដោយវត្ថុគ្រប់យ៉ាង និងរាជ្យនោះ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំចេញចាកនគរហើយ ចូលទៅកាន់ព្រៃហេមពាន្ត សាងអាស្រមមួយទៀបឆ្នេរស្ទឹងភាគីរសី ។ ខ្ញុំធ្វើបណ្ណសាលា រួចហើយធ្វើរោងភ្លើង ខ្ញុំមានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅហើយ ក្នុងអាស្រម ។ កាលខ្ញុំចម្រើនឈាននៅក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ខ្ញុំមិនមានសេចក្តីតក់ស្លុតឡើយ ខ្ញុំមិនដែលជួបប្រទះភ័យដែលគួរឲ្យខ្លាចឡើយ ។ ព្រះសម្ពុទ្ធ ព្រះនាមសុមេធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ទ្រង់រុងរឿងដោយពន្លឺគឺញាណ កើតឡើងក្នុងលោក ក្នុងខណៈនោះឯង ។

មម អស្សមសាមន្តា យក្ខោ អាសិ មហិទ្ធិកោ
ពុទ្ធសេដ្ឋម្ហិ ឧប្បន្នេ អារោចេសិ មមំ តទា ។
ពុទ្ធោ លោកេ សមុប្បន្នោ សុមេធោ នាម ចក្ខុមា
តារេសិ ជនតំ សព្វំ តម្បិ សោ តារយិស្សតិ ។
យក្ខស្ស វចនំ សុត្វា សំវិគ្គោ អាសិ តាវទេ
ពុទ្ធោ ពុទ្ធោតិ ចិន្តេន្តោ អស្សមំ បដិសាមយឹ ។
អគ្គិទារុញ្ច ឆឌ្ឌេត្វា សំសាមេត្វាន សន្ថតំ
អស្សមំ អភិវន្ទិត្វា និក្ខមឹ បវនា អហំ ។
តតោ ចន្ទនមាទាយ គាមា គាមំ បុរា បុរំ
ទេវទេវំ គវេសន្តោ ឧបគញ្ឆឹ វិនាយកំ ។
ភគវា តម្ហិ សមយេ សុមេធោ លោកនាយកោ
ចតុសច្ចំ បកាសេន្តោ ពោធេតិ ជនតំ ពហុំ ។
អញ្ជលឹ បគ្គហេត្វាន សីសេ កត្វាន វន្ទនំ
សម្ពុទ្ធំ អភិវាទេត្វា ឥមា គាថា អភាសថ ។

យក្សមួយមានឫទ្ធិច្រើន នៅជិតអាស្រមរបស់ខ្ញុំ កាលព្រះពុទ្ធដ៏ប្រសើរកើតឡើងហើយ ក៏ប្រាប់ខ្ញុំក្នុងកាលនោះថា ព្រះពុទ្ធព្រះនាមសុមេធ មានបញ្ញាចក្ខុ កើតហើយ ក្នុងលោក ទ្រង់ញុំាងប្រជុំជនទាំងអស់ឲ្យឆ្លងហើយ ទ្រង់មុខជាចម្លងអ្នកដែរ ។ ខ្ញុំមានសេចក្តីស្ងប់ស្ងែងកើតឡើង ក្នុងខណៈនោះ ព្រោះឮពាក្យយក្សនោះ ខ្ញុំគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ហើយរៀបចំនូវអាស្រម ។ ខ្ញុំលះបង់ឧសសម្រាប់ដុតភ្លើង រៀបក្រាលកម្រាល រួចថ្វាយបង្គំអាស្រមហើយចេញអំពីព្រៃធំ ។ ខ្ញុំកាន់យកខ្លឹមចន្ទន៍ អំពីព្រៃធំនោះ ហើយចេញពីស្រុកមួយចូលទៅកាន់ស្រុកមួយ ចេញពីបុរីមួយ ចូលទៅកាន់បុរីមួយស្វែងរកព្រះពុទ្ធ ជាទេវតាដ៏ប្រសើរជាងទេវតា ហើយចូលគាល់ព្រះលោកនាយក ។

សម័យនោះឯង ព្រះមានព្រះភាគ ព្រះនាមសុមេធជាលោកនាយក ទ្រង់កំពុងប្រកាសនូវសច្ចៈ ៤ ញុំាងប្រជុំជនដ៏ច្រើននាក់ឲ្យត្រាស់ដឹង ។ ខ្ញុំផ្គងអញ្ជលីប្រណម្យលើក្បាល ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយពោលនូវគាថាទាំងនេះថា

២៤៧

### អដ្ឋមំ តោទេយ្យត្ថេរាបទានំ

វស្សិកោ បុប្ផមានស្មឹ សន្តិកេ ឧបវាយតិ
ត្វំ វីរ គុណគន្ធេន ទិសា សព្វា បវាយសិ
ចម្បកេ នាគមលិកេ អតិមុត្តកកេតកេ
សាលេសុ បុប្ផមានេសុ អនុវាតំ បវាយតិ ។
តវ គន្ធំ ឃាយិត្វាន(១) ហិមវន្តា ឥធាគមឹ
បូជេមិ តំ មហាវីរ លោកជេដ្ឋ មហាយស ។
វរចន្ទនេនានុលិម្បឹ សុមេធំ លោកនាយកំ
សកំ ចិត្តំ បសាទេត្វា តុណ្ហី អដ្ឋាសិ តាវទេ ។
សុមេធោ នាម ភគវា លោកជេដ្ឋោ នរាសភោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ គុណំ បកិត្តេសិ ចន្ទនញ្ច អបូជយិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

---
១ ម. សុណិត្វាន ។

តោទេយ្យត្ថេរាបទាន ទី ៨

កាលបើផ្កាម្ទិះកំពុងរីក ក្លិននោះ ក៏ផ្សាយទៅបានតែក្នុងទីជិត កាលបើផ្កាចម្បា ផ្កាខ្ទឹង ផ្កាម្ទិះ ផ្ការំដួល ផ្កាការកេត និង ផ្ការាំងកំពុងរីក ក្លិនក៏ផ្សាយទៅបានតែក្នុងទីបណ្តោយខ្យល់ បពិត្រព្រះអង្គជាមហាវីរបុរស ព្រះអង្គតែងផ្សាយដោយក្លិន គឺគុណធម៌ សព្វទិសទី ។ ខ្ញុំព្រះអង្គចេញចាកព្រៃហិមពាន្ត មកក្នុងទីនេះ ព្រោះបានធុំក្លិនព្រះអង្គ បពិត្រព្រះអង្គជាមហា-វីរបុរស ទ្រង់ប្រសើរបំផុតក្នុងលោក មានយសច្រើន ខ្ញុំព្រះ អង្គសូមបូជាចំពោះព្រះអង្គ ។ ខ្ញុំបានលាបលាបព្រះសុមេធ ជាលោកនាយក ដោយខ្លឹមចន្ទន៍ដ៏ប្រសើរ រួចហើយញុំាង ចិត្តរបស់ខ្លួនឲ្យជ្រះថ្លា អង្គុយនៅស្ងៀមក្នុងខណៈនោះ ។

ព្រះមានព្រះភាគ ព្រះនាមសុមេធ ប្រសើរបំផុតក្នុង លោក ប្រសើរជាងពួកនរៈ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយ ត្រាស់គាថាទាំងនេះថា បុគ្គលណា បានសរសើរគុណតថា-គត ទាំងបានបូជាខ្លឹមចន្ទន៍ដល់តថាគត តថាគតនឹងសរសើរ បុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងចុះ ។

អាទេយ្យវាក្យវចនោ ព្រហ្មា ឧជុ បតាបវា
បញ្ចវីសតិកប្បានិ សប្បភាសោ ភវិស្សតិ ។
ឆព្វីសតិកប្បសតេ ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
តេត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
តតោ ចុតោយំ មនុជោ មនុស្សត្តំ គមិស្សតិ
បុញ្ញកម្មេន សំយុត្តោ ព្រហ្មពន្ធុ ភវិស្សតិ ។
អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ
តីណិលក្ខណសម្បន្នោ ពាវរី នាម ព្រាហ្មណោ ។
តស្ស សិស្សោ ភវិត្វាន ហេស្សតិ មន្តបារគូ
ឧបគន្ត្វាន សម្ពុទ្ធំ គោតមំ សក្យបុង្គវំ ។
បុច្ឆិត្វា និបុណេ បញ្ហេ ហាសយិត្វាន មានសំ[១]
សព្វាសវេ បរិញ្ញាយ វិហារាមិ អនាសវោ ។

---
១ ម. ភាវយិត្វាន សព្វាយន្តិ ទិស្សន្តិ ។

បុគ្គលនេះ នឹងមានពាក្យសម្តីគេគួរជឿ ជាបុគ្គលប្រសើរ មានចិត្តត្រង់ មានព្យាយាមដុតកម្តៅកិលេស មានពន្លឺ អស់ ២៥ កប្ប ។ បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ២៦ រយកប្ប នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ ដង នឹងបានជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចទេវតា អស់ ៣៣ ដង នឹងបានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ មនុស្សនេះឯង លុះច្យុតចាកទីនោះមក នឹងបានទៅកើតជាមនុស្ស ប្រកបដោយបុញ្ញកម្ម នឹងមានផៅពង្សដ៏ប្រសើរ ។ ព្រាហ្មណ៍ម្នាក់ ឈ្មោះពាវរី ជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ដល់នូវត្រើយវេទទាំង ៣ បរិបូណ៌ដោយលក្ខណៈ ៣ យ៉ាង ។ បុគ្គលនេះនឹងបានជាសិស្សពាវរីព្រាហ្មណ៍នោះ ជាអ្នកដល់ត្រើយនៃមន្ត បានចូលគាល់ព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ។

ខ្ញុំបានទូលសួរនូវប្រស្នាដ៏ល្អិត ហើយញុំាងចិត្តឲ្យរីករាយ កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។

២៤៩

## អដ្ឋមំ តោទេយ្យត្ថេរាបទានំ

តិវិធគ្គិ និព្វុតា មយ្ហំ ភវា សព្វេ សមូហតា
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តោទេយ្យោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តោទេយ្យត្ថេរស្ស អបទានំ សមត្តំ ។

តោទេយ្យត្ថេរាបទាន ទី ៨

ភ្លើង ៣ យ៉ាង របស់ខ្ញុំ បានរលត់ហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ កិលេសទាំងពួង ខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតោទេយ្យត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តោទេយ្យត្ថេរាបទាន ។

# នវមំ ជតុកណ្ណិកត្ថេរាបទានំ

[១០៩] នគរេ ហំសវតិយា សេដ្ឋិបុត្តោ អហោសហំ
សមប្បិតោ កាមគុណេហិ បរិវារេមហំ តទា ។
តយោ បាសាទមារុយ្ហ មហាភោគេ វលញ្ជកោ[១]
តត្ថ នច្ចេហិ គីតេហិ បរិវារេមហំ តទា ។
តុរិយា អាហតា មយ្ហំ សម្មតាលសមាហិតា
រញ្ជន្តី ឥត្ថិយោ សព្វា ហរន្តិយេវ មេ មនោ ។
ចេលាវកា វាមនិកា[២] កុញ្ជវា សីហិមជ្ឈិតា[៣]
លង្ឃិកា[៤] សោកជ្ឈាយី ច បរិវារេន្តិ មំ សទា ។
វេតាលិនោ កុម្ភថូនិ នដា ច នច្ចកា ពហូ
នដកា នាដកា ចេវ បរិវារេន្តិ មំ សទា ។
កប្បកា ន្ហាបកា សូទា មាលាការា សុបាសកា
ជល្លា មល្លា ច តេ សព្វេ បរិវារេន្តិ មំ សទា ។

---

១ ម. ឧព្វិទ្ធា គេហលុញ្ចកាតិ ទិស្សន្តិ ។ ២ ម. ចេលាបិកា លាមណិកាតិ ខាយតិ ។ ៣ ម. សិតិមជ្ឈិកា ។ ៤ ម. លង្ឃីកា ។

# ជតុកណ្ណិកត្ថេរាបទាន ទី ៩

[១០៩] កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្រ នៅក្នុងនគរហង្សវតី ជាអ្នកឆ្អែតស្កប់ស្កល់ ដោយកាមគុណទាំងឡាយ ញុំាងគេឲ្យចោមរោម ។ កាលនោះ ខ្ញុំឡើងកាន់ប្រាសាទទាំង ៣ ប្រើប្រាស់ភោគៈច្រើន ញុំាងគេឲ្យចោមរោមដោយការរាំច្រៀង ក្នុងប្រាសាទនោះ ។ តូរ្យតន្ត្រី ប្រកបដោយការប្រគំដ៏ពីរោះ ដែលគេនាំមកដើម្បីខ្ញុំ ពួកស្រីទាំងអស់កាលត្រេកអរ រមែងដឹកនាំនូវចិត្តខ្ញុំ ។ ពួកស្រីកំពុងពេញល្បែង ពួកស្រីតឿ ពួកស្រីពេញរូបរាង ពួកស្រីចំទង់ ពួកស្រីឡើងរាំរ៉ាវ និងពួកស្រីត្លុក តែងចោមរោមខ្ញុំ សព្វ ៗ កាល ។ ពួកអ្នកប្រគំ ពួកអ្នកជំស្គរ ពួកអ្នករបាំ ជាច្រើនគ្នា ពួករបាំប្រុសស្រី តែងចោមរោមខ្ញុំ សព្វ ៗ កាល ។ ពួកជាងកំណោរ ពួកអ្នកផ្ងូតទឹក ពួកអ្នកដាំស្ល ពួកអ្នកធ្វើផ្កាកម្រង ពួកសុបាសកជន ពួកអ្នកប្រដាល់ ពួកអ្នកចំបាប់ទាំងអស់នោះ តែងចោមរោមខ្ញុំ សព្វ ៗ កាល ។

២៦១

## នវមំ ជតុកណ្ណិកត្ថេរាបទានំ

ឯតេសុ កីឡមានេសុ    សិក្ខិតេ កតុចាសនេ
រត្តិន្ទិវំ ន ជានាមិ    ឥន្ទោវ តិទសេ បុរេ(១) ។
អទ្ធិកា កបណា(២) សព្វេ    យាចកា ចរកា(៣) ពហូ
ឧបគច្ឆន្តិ តេ និច្ចំ    ភិក្ខយន្តា មមំ ឃរំ ។
សមណា ព្រាហ្មណា ចេវ    បុញ្ញក្ខេត្តា អនុត្តរា
វឌ្ឍយន្តា មមំ បុញ្ញំ    អាគច្ឆន្តិ មមំ ឃរំ ។
បដកា(៤) លដុកា សព្វេ    និគន្ថា បុប្ផសាដកា
តេ ទណ្ឌិកា ឯកសិខា    អាគច្ឆន្តិ មមំ ឃរំ ។
អាជីវិកា វិលុត្តាវី    គោតមា(៥) ទេវធម្មិកា
រជោជល្លធរា ឯតេ    អាគច្ឆន្តិ មមំ ឃរំ ។
បរិវត្តកា សិទ្ធិបត្តា(៦)    កោដបុក្កនិកា ពហូ
តបសី វនចារី ច    អាគច្ឆន្តិ មមំ ឃរំ ។
អន្ធកា ទមិលា ចេវ    សាកុលា មលយាលកា
សវរា យោនកា ចេវ    អាគច្ឆន្តិ មមំ ឃរំ ។

---

១ ម. តិទសង្គណេ ។ ២ ម. បថិកា ។ ៣ ម. វរកា ។ ៤ ម. បដគា ។ ៥ ម. គោធម្មា ។ ៦ ម. បរិត្តកា សន្តិបត្តា ។

ជតុកណ្ណិកត្ថេរាបទាន ទី ៩

កាលពួកជនទាំងនុ៎ះ កំពុងលេង ក្នុងការបាញ់ធ្នូដែលសិក្សាស្ទាត់ហើយ ខ្ញុំឥតស្គាល់យប់និងថ្ងៃឡើយ ដូចជាព្រះឥន្ទ្រ ឋិតនៅក្នុងតាវត្តិង្សបុរី ។ ពួកអ្នកដើរផ្លូវ ពួកអ្នកកំព្រា ពួកយាចក ពួកអ្នកដើរជាច្រើនគ្នា អ្នកទាំងអស់នោះ តែងចូលទៅសុំទាន ក្នុងផ្ទះខ្ញុំជានិច្ច ។ ពួកសមណៈនិងព្រាហ្មណ៍ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ញ៉ាំងបុណ្យឲ្យចម្រើនដល់ខ្ញុំ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកនិគ្រន្ថទាំងអស់នោះ គឺពួកបជកៈ លដុកៈ បុប្ផសាដកៈ ទណ្ឌិកៈ ឯកសិខៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកប្រព្រឹត្តចិញ្ចឹមជីវិតដោយប្រពៃ ពួកអ្នកបួន់ដណ្ដើមទ្រព្យគេ ពួកអ្នកប្រព្រឹត្តធម៌ដូចគោ ពួកអ្នកប្រព្រឹត្តធម៌ដូចទេវតា ពួកអ្នកទ្រទ្រង់ល្អងធូលី ទាំងនុ៎ះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកប្រព្រឹត្តធម៌ ពួកអ្នកដល់នូវការសម្រេចហេតុផ្សេង ៗ ពួកអ្នកប្រជុំគ្នារម្ងាប់ការក្រោធ ពួកអ្នកមានតបៈ និងពួកអ្នកប្រព្រឹត្តនៅក្នុងព្រៃ ជាច្រើន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនខ្វាក់ ពួកទមិឡ ពួកអ្នកដែនសាកុឡៈ ពួកអ្នកដែនមលយាលកៈ ពួកអ្នកដែនសវរៈ និងពួកអ្នកដែនយោនកៈ តែងមកកាន់ផ្ទះខ្ញុំ ។

គន្ធកា មុណ្ឌកា សព្វេ កុដ្ឋលា សានុវិន្ទកា
អាភវ ចីនវដ្ឋា ច[១] អាគច្ឆន្តិ មមំ ឃរំ ។
អលសន្ទកា បល្ហវកា បព្វតានគ្គមារុហា
ពាហិកា[២] ចេតបុត្តា ច អាគច្ឆន្តិ មមំ ឃរំ ។
មធុរកា កោសលកា កាសិកា[៣] ហត្ថិចោរិកា
ឥសិន្ទា មក្កលា ចេវ អាគច្ឆន្តិ មមំ ឃរំ ។
ចេលាវកា អារម្ពា ច ឱភាសា មេឃលា ពហូ
ខុទ្ទកា សុទ្ទកា ចេវ អាគច្ឆន្តិ មមំ ឃរំ ។
រោហកា សិន្ធវា ចេវ ចិត្តកា ឯកកណ្ណិកា
សុរដ្ឋា អបរន្តា ច អាគច្ឆន្តិ មមំ ឃរំ ។

---

១ ម. អារាគចិនត្ថា ចាតិ ទិស្សន្តិ ។ ២ ម. អលសន្ទា បសំវកា ធម្មទា និគ្គមានុសា គាហិកាតិ ឥមេ បាឋា ទិស្សន្តិ ។ ៣ ម. កលិង្គា ។

ពួកអ្នកដែនគន្ធកៈ ពួកអ្នកដែនមុណ្ឌកៈ ពួកអ្នកដែនកុដ្ឋលៈ ពួកអ្នកដែនសានុវិន្ទកៈ ពួកអ្នកដែលអារាព និងពួកអ្នកដែនចិន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកអាស្រ័យនៅភ្នំអលសន្ទកៈ ពួកអ្នកអាស្រ័យនៅភ្នំបល្លវៈ ពួកអ្នកឡើងកំពូលភ្នំ និងពួកបេតបុត្ត អ្នកនៅក្រៅដែន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនមធុរៈ ពួកជនអ្នកនៅ ក្នុងដែនកោសល ពួកជនអ្នកនៅក្នុងដែនកាសី ពួកជនអ្នកនៅ ក្នុងដែនហត្ថិបុរី ពួកជនអ្នកនៅក្នុងដែនឥសិន្ទៈ និងពួកជនអ្នកនៅក្នុងដែនមក្កលៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនចេលាវកៈ ពួកជនអ្នកនៅក្នុងដែនអារម្ពៈ ពួកជនអ្នកនៅក្នុងដែនឱភាសៈ ពួកជនអ្នកនៅ ក្នុងដែនមេឃលៈ ពួកជនអ្នកនៅក្នុងដែនខុទ្ទកៈ និងពួកជនអ្នកនៅក្នុងដែនសុទ្ទកៈ ជាច្រើន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនរោហកៈ ពួកជនអ្នកនៅក្នុងដែនសិន្ធវៈ ពួកជនអ្នកនៅ ក្នុងដែនចិត្តកៈ ពួកជនអ្នកនៅ ក្នុងដែនឯកកណ្ណិកៈ ពួកជនអ្នកនៅក្នុងដែនសុរដ្ឋៈ និងពួកជនអ្នកនៅក្នុងដែនអបរន្តៈ តែងមកកាន់ផ្ទះខ្ញុំ ។

២៦៣

នវមំ ជតុកណ្ណិកត្ថេរាបទានំ

សុចារកា កុមារា ច មលយា សោណកូមិកា
វឌ្ឍិហារា[(១)] ច តេ សព្វេ អាគច្ឆន្តិ មមំ ឃរំ ។
មលការា បេសការា ចម្មការា ច តច្ឆកា
កម្មការា កុម្ភការា អាគច្ឆន្តិ មមំ ឃរំ ។
មណិការា លោហការា សោណ្ណការា ច ទុស្សិកា
តិបុការា ច តេ សព្វេ អាគច្ឆន្តិ មមំ ឃរំ ។
ឧសុការា ភមការា បេសការា ច គន្ធិកា
រជកា តុន្នវាយា ច អាគច្ឆន្តិ មមំ ឃរំ ។
តេលិកា កដ្ឋហារា ច ឧទហារា ច បេសិកា
សុបិកា សរក្ខា ច[(២)] អាគច្ឆន្តិ មមំ ឃរំ ។
ទោវារិកា អនីកដ្ឋា គន្ថិកា បុប្ផឆឌ្ឌកា
ហត្ថារោហា ហត្ថិបាលា អាគច្ឆន្តិ មមំ ឃរំ ។
អានន្ទស្ស នាម រញ្ញោ សមគ្គស្ស អទាសហំ
សត្តវណ្ណេន រតនេន ឩនត្ថំ បូរយាមហំ ។

---

១ ៣ ម. វឌ្ឍិគង្គា ។ ២ ម. សុបិការា បរក្ខា ច ។

ពួកកុមារ នៅក្នុងដែនសុបារកៈ នៅក្នុងដែនមលយៈ នៅក្នុងសោណភូមិ នៅក្នុងដែនវិជ្ជហារ ពួកជនទាំងអស់នោះតែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងផ្កាកម្រង ពួកជាងតម្បាញ ពួកជាងធ្វើស្បែក ពួកជាងចាំងឈើ ពួកអ្នកធ្វើការងារ និងពួកស្មូនឆ្នាំង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកែវមណី ពួកជាងលោហៈ ពួកជាងមាស ពួកជាងត្បាញសំពត់ និងពួកជាងសំណ ទាំងអស់នោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកូនសរ ពួកជាងក្រឡឹង ពួកជាងតម្បាញ ពួកអ្នកធ្វើទឹកអប់ ពួកជាងជ្រលក់ និងពួកជាងជុល តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកស្ងប្រេង ពួកអ្នកនាំឧស ពួកអ្នកដងទឹក ពួកអ្នកចិញ្ច្រាំសាច់ ពួកអ្នកដាំស្ល និងពួកអ្នកឃ្លាសវៃក្នុងសំឡេង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកចាំទ្វារ ពួកអ្នករក្សាអង្គ ពួកអ្នកក្រងផ្កា ពួកអ្នកចាក់ចោលផ្កា ពួកអ្នកជិះដំរី និងពួកគង្វាលដំរី តែងមកកាន់ផ្ទះខ្ញុំ ។ ខ្ញុំបានឲ្យសាមគ្គី ដល់ស្តេចឈ្មោះអានន្ទៈ ខ្ញុំបំពេញសេចក្តីខ្វះខាតដោយរតនៈ មានពណ៌ ៧ ។

យេ មយា កិត្តិតា សព្វេ ជាតាវណ្ណា ពហូ ជនា
តេសាហំ ចិត្តមញ្ញាយ តប្បយឹ រតនេនបិ ។
វត្ថេសុ កាសមានេសុ វជ្ជមានាសុ ភេរិសុ
សង្ខេសុ ធមយន្តេសុ សកកេហេ រមាមហំ ។
ភគវា តម្ហិ សមយេ បទុមុត្តរនាមកោ
សហ សតសហស្សេហិ បរិក្ខីណាសវេហិ សោ ។
ភិក្ខូហិ សហិតោ វីថឹ បដិបជ្ជិត្ថ ចក្ខុមា
ឱភាសេន្តោ ទិសា សព្វា ទីបរុក្ខោវ ជោតតិ ។
វជ្ជន្តិ ភេរិយោ សព្វា គច្ឆន្តេ លោកនាយកេ
បភា និទ្ធាវតេ តស្ស សតរំសីវ ឧគ្គតោ ។
កវាដន្តរិកាយាបិ បវិដ្ឋេន ច រស្មិនា
អន្តោឃរេសុ វិបុលោ អាលោកោ អាសិ តាវទេ ។
បភំ ទិស្វាន ពុទ្ធស្ស អាវិសជ្ជេ អហោចហំ
និស្សំសយំ ពុទ្ធសេដ្ឋោ ឥមំ វីថិមុបាគតោ ។

ពួកជនជាច្រើនទាំងអស់ណា មានវណ្ណៈផ្សេង ៗ គ្នា ដែលខ្ញុំបានពណ៌នារួចហើយ ខ្ញុំដឹងចិត្តនៃជននោះ ហើយឲ្យឆ្អែតស្កប់ស្កល់ដោយរតនវត្ថុ ។ កាលបើគេនិយាយពាក្យពីរោះ កាលបើគេទួងស្គរឡើង កាលបើគេផ្លុំស័ង្ខឡើង ខ្ញុំត្រេកអរតែក្នុងផ្ទះរបស់ខ្លួន ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ព្រមទាំងព្រះខីណាស្រពមួយសែនអង្គ កើតមានឡើងហើយ ។ ព្រះសម្ពុទ្ធមានចក្ខុ ព្រមដោយភិក្ខុទាំងឡាយទ្រង់ស្តេចទៅតាមថ្នល់ រុងរឿងដូចជាដើមទីបព្រឹក្ស ដែលញុំាំងទិសទាំងពួងឲ្យភ្លឺ ។ កាលបើព្រះលោកនាយក ស្តេចយាងទៅ ស្គរទាំងពួង ក៏លាន់ឮឡើង រស្មីរបស់ព្រះពុទ្ធក៏ផ្សាយចេញទៅ ហាក់ដូចព្រះអាទិត្យទើបនឹងរះ ។ ខណៈនោះ ពន្លឺដ៏ធំទូលាយ ចាំងចូលទៅក្នុងផ្ទះទាំងឡាយ ដោយរស្មី ផ្សាយចូលទៅតាមចន្លោះសន្ទះទ្វារ ។ ខ្ញុំបានឃើញរស្មីរបស់ព្រះពុទ្ធហើយ បានប្រាប់បរិស័ទខ្ញុំថា ព្រះពុទ្ធដ៏ប្រសើរ ស្តេចយាងមកតាមថ្នល់នេះ ដោយឥតសង្ស័យ ។

# ២៦៨

## នវមំ ជតុកណ្ណិកត្ថេរាបទានំ

ខិប្បំ ឱរុយ្ហ បាសាទា អគមឹ អន្តរាបថំ[១]
សម្ពុទ្ធំ អភិវាទេន្តោ ឥទំ វចនមព្រវឹ ។
អនុកម្បតុ មេ ពុទ្ធោ ជលជុត្តមនាមកោ
វសីសតសហស្សេហិ អធិវាសេសិ សោ មុនិ ។
និមន្តយិត្វាន សម្ពុទ្ធំ អភិនេសឹ សកំ ឃរំ
តត្ថ អន្នេន បានេន សន្តប្បេសឹ មហាមុនឹ ។
ភុត្តាវិកាលមញ្ញាយ ពុទ្ធសេដ្ឋស្ស តាទិនោ
សង្គីតេន តុរិយេន ពុទ្ធសេដ្ឋំ ឧបដ្ឋហឹ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
អន្តោឃរេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មំ តុរិយេនុបដ្ឋាសិ អន្នបានញ្ចទាសិ មេ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
បហូតភក្ខោ ហុត្វាន សហិរញ្ញោ សភោជនោ
ចតុទ្ទីបេ ឯករជ្ជំ ការយិស្សតិយំ នរោ ។

---

១ ម. អន្តរាបណំ ។

## ជតុកណ្ណិកត្ថេរាបទាន ទី ៩

ខ្ញុំបានចុះអំពីប្រាសាទដោយរហ័ស ទៅរង់ចាំពាក់កណ្ដាលផ្លូវ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយក្រាបបង្គំទូលថា សូមព្រះពុទ្ធព្រះនាមបទុមុត្តរៈ អនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះពុទ្ធជាអ្នកប្រាជ្ញអង្គនោះ ទ្រង់ទទួលនិមន្តន៍ មួយអន្លើដោយពួកភិក្ខុមួយសែនអង្គ ។ លុះខ្ញុំនិមន្តព្រះសម្ពុទ្ធរួចហើយ នាំព្រះអង្គទៅឯផ្ទះរបស់ខ្ញុំ ញុំាងព្រះមហាមុនី ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ក្នុងផ្ទះនោះ ។ ខ្ញុំបានដឹងកាលដ៏គួរនៃព្រះពុទ្ធដ៏ប្រសើរ ជាតាទិបុគ្គល ទ្រង់ឆាន់រួចហើយ ក៏បម្រើព្រះពុទ្ធដ៏ប្រសើរ ដោយតូរ្យតន្ត្រីព្រមទាំងចម្រៀង ។ ព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោកគួរទទួលគ្រឿងបូជា ទ្រង់គង់នៅខាងក្នុងផ្ទះ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណាបានបម្រើតថាគត ដោយតូរ្យតន្ត្រីផង បានថ្វាយបាយនិងទឹកផង ដល់តថាគត តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្ដាប់ តថាគតនឹងសម្ដែង ដូចតទៅនេះ នរៈនេះ នឹងមានគ្រឿងបរិភោគច្រើន ព្រមទាំងមាសប្រាក់ ភោជន នឹងបានសោយឯករាជ្យ ក្នុងទ្វីប ៤ ។

បញ្ចសីលេ សមាទាយ     ទសកម្មបថេ តតោ
សមាទាយ បវត្តេន្តោ     បរិសំ សិក្ខាបេស្សតិ[១] ។
តុរិយសតសហស្សានិ     ភេរិយោ សមលង្កតា
វជ្ជយិស្សន្តិមំ និច្ចំ     ឧបដ្ឋានស្សិទំ ផលំ ។
តឹសកប្បសហស្សានិ     ទេវលោកេ រមិស្សតិ
ចតុសដ្ឋិក្ខត្តុំ ទេវិន្ទោ     ទេវរជ្ជំ ករិស្សតិ ។
ចតុសត្តតិក្ខត្តុំ ច     ចក្កវត្តី ភវិស្សតិ
បទេសរជ្ជំ វិបុលំ     គណនាតោ អសង្ខិយំ ។
កប្បសតសហស្សម្ហិ     ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន     សត្ថា លោកេ ភវិស្សតិ ។
ឧបបជ្ជតិ យំ យោនឹ     ទេវត្តំ អថ មានុសំ
អនូនភោគោ ហុត្វាន     មនុស្សត្តំ គមិស្សតិ ។
អជ្ឈាយកោ ភវិត្វាន     តិណ្ណំ វេទាន បារគូ
ឧត្តមត្ថំ គវេសន្តោ     ចរិស្សតិ មហឹ តទា[២] ។
សោ ច បច្ឆា បព្វជិត្វា     សុក្កមូលេន ចោទិតោ
គោតមស្ស ភគវតោ     សាសនេភិរមិស្សតិ ។

---
១ ម. បរិសិក្ខាបយិស្សតិ ។ ២ ម. ឥមំ ។

នរៈនេះ នឹងសមាទានសីល ៥ ត្រេកអរក្នុងកុសលកម្មបថ ១០ ប្រព្រឹត្តសមាទានកុសលធម៌ ហើយនឹងញុំាងបរិស័ទឲ្យសិក្សា ។ តួរ្យតន្ត្រីមួយសែន និងពួកនារីមានខ្លួនប្រដាប់ប្រពៃ តែងគាល់បម្រើនរៈនេះជានិច្ច នេះជាផលនៃការបម្រើ ។ នរៈនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាព្រះឥន្ទ្រសោយរាជ្យ ជាស្តេចទេវតា អស់ ៦៤ ដង ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៤ ដង បានសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូល ព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក ។ នរៈនេះ បើចូលទៅកាន់កំណើតណា ទោះជាទេវតា ឬជាមនុស្ស នឹងជាអ្នកមានភោគៈមិនខ្វះខាត ក្នុងបច្ឆិមជាតិ នឹងបាននូវភាពជាមនុស្ស ។ ក្នុងកាលនោះ នរៈនេះ ជាអ្នកស្វាធ្យាយមន្ត ដល់នូវត្រើយ នៃវេទទាំង ៣ កាលស្វែងរកប្រយោជន៍ដ៏ឧត្តម នឹងត្រាច់ទៅតាមផែនដី ។ នរៈនោះ លុះកាលជាខាងក្រោយ ក៏ចេញបួស ត្រូវកុសលមូលដាស់តឿន នឹងត្រេកអរក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមគោតម ។

២៦៧

នវមំ ជតុកណ្ណិកត្ថេរាបទានំ

អារាធយិត្វាន សម្ពុទ្ធំ   គោតមំ សក្យបុង្គវំ
កិលេសេ ឈាបយិត្វាន   អរហាយំ ភវិស្សតិ ។
បវនេ ព្យគ្ឃរាជាវ   មិគរាជាវ កេសរី
អភីតោ វិហរាមជ្ជ   សក្យបុត្តស្ស សាសនេ ។
ទេវលោកេ មនុស្សេ វា   ទលិទ្ទេ ទុគ្គតិម្ហិ វា
និព្វត្តឹ មេ ន បស្សាមិ   ឧបដ្ឋានស្សិទំ ផលំ ។
វិវេកមនុយុត្តោម្ហិ   ឧបសន្តោ និរូបធិ
ណាគោវ ពន្ធំ ឆេត្វា   វិហរាមិ អណាសវោ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
ណាគោវ ពន្ធំ ឆេត្វា   វិហរាមិ អណាសវោ ។
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ជតុកណ្ណិកត្ថេរាបទាន ទី ៩

នរៈនេះ នឹងញុំាងព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យត្រេកអរ នឹងដុតកម្តៅនូវកិលេសទាំង-ឡាយ ហើយបានជាព្រះអរហន្ត ។

ថ្ងៃនេះ ខ្ញុំនៅក្នុងសាសនា នៃព្រះពុទ្ធជាសក្យបុត្រ ខ្ញុំឥតភ័យ ដូចជាស្តេចខ្លាធំ ឬដូចជាកេសររាជសីហ៍ ជាស្តេចម្រឹគនៅក្នុងព្រៃ ។ ខ្ញុំមិនដែលឃើញនូវកំណើតរបស់ខ្ញុំ ក្នុងទេវលោកកម្សត់ ឬក្នុងកំណើតមនុស្សកម្សត់ ឬក៏ក្នុងទុគ្គតិឡើយ នេះជាផលនៃការបម្រើ ។ ខ្ញុំជាអ្នកប្រកបក្នុងវិវេក ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិ មិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្នឹង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្នឹង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ជតុកណ្ណិកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ជតុកណ្ណិកត្ថេរស្ស អបទានំ សមត្តំ ។

# ទសមំ ឧទេនត្ថេរាបទានំ

[១១០] ហិមវន្តស្ស អវិទូរេ បទុមោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។
នទិយោ សន្ទរេ តត្ថ សុបតិត្ថា មនោរមា
អច្ឆោទកា សីតជលា សន្ទរេ នទិយោ សទា ។
បាឋីនា បាវុសា មច្ឆា វលជា[១] មុញ្ជរោហិតា
សោភេន្តិ នទិយោ ឯតេ វសេន្តិ នទិយា តទា ។
អម្ពជម្ពូហិ សញ្ឆន្នា ការេរិតិលកា តថា
ឧទ្ទាលកា បាដលិយោ សោភេន្តិ មម អស្សមំ ។
អង្កោលកា ពិម្ពិជាលា មាយាហារា[២] ច បុប្ផិតា
គន្ធេន ឧបវាយន្តា សោភេន្តិ មម អស្សមំ ។
អតិមុត្តា សត្តលិកា នាគា សាលា ច បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភេន្តិ មម អស្សមំ ។
កោសុម្ភា[៣] សលឡា នីបា ហត្ថបាតា ច បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភេន្តិ មម អស្សមំ ។

---
១ ម. ជលជា ។ ២ ម. មាយាការី ។ ៣ ម. កោសម្ភា ។

បានឮថា ព្រះជតុកណ្ណិកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ជតុកណ្ណិកត្ថេរាបទាន ។

# ឧទេនត្ថេរាបទាន ទី ១០

[១១០] មានភ្នំមួយឈ្មោះបទុមៈ នៅជិតព្រៃហិមពាន្ត ខ្ញុំបានធ្វើអាស្រមមួយយ៉ាងល្អ ទាំងសាងបណ្ណសាលាមួយដ៏ល្អដែរ ។ នៅជិតអាស្រមនោះ មានស្ទឹង ដែលមានកំពង់ល្អ ជាទីរីករាយនៃចិត្ត ស្ទឹងទាំងនោះ មានទឹកថ្លា មានទឹកត្រជាក់ តែងហូរទៅ សព្វ ។ កាល ។ កាលនោះ ពួកត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីឆ្ពិន ត្រីទាំងនុ៎ះ នៅក្នុងស្ទឹង នាំឲ្យល្អស្ទឹង ។ ស្ទឹងនោះ ដ៏ដេរដាសដោយដើមស្វាយ ដើមព្រីង ដើមថ្ងាន់ ដើមដង្កៀបក្តាម ដើមរាជព្រឹក្ស និងដើមប្រទៀង នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមអង្កោល វល្លិបាស មានផ្ការីកជាឈើធ្វើដូចជាមានកិច្ចកល មានក្លិនផ្សព្វផ្សាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមរំដួល ម្ទិះរួត ខ្ទឹង រាំងភ្នំ មានផ្ការីកមានក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមស្រូល ដើមស្រល់ ដើមក្តួល មានផ្ការីក ដូចជាធ្លាក់មកក្នុងដៃមានក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។

២៦៩

## ទសមំ ឧទេនត្ថេរាបទានំ

ហរីតកា អាមលកា អម្ពា ជម្ពូ វិភេទកា
កោលា ភល្លាតកា ពេល្លា ផលានិ ពហុ អស្សមេ ។
កលម្ពា កទលី តត្ថ បុប្ផន្តិ មម អស្សមេ
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមំ ។
អសោកបិណ្ឌី ច វរី[១] និម្ពរុក្ខា ច បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមំ ។
បុន្នាគា គិរិបុន្នាគា[២] តិមិរា តត្ថ បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមំ ។
និគ្គុណ្ឌី សិរិនិគ្គុណ្ឌី ចម្បរុក្ខេត្ថ បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមំ ។
អវិទូរេ បោក្ខរណី ចក្កវាកូបកូជិតា
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច ។
អច្ឆោទកា សីតជលា សុបតិត្ថា មនោរមា
អច្ឆា ផលិកសមានា សោភន្តិ មម អស្សមំ ។
បទុមា បុប្ផរេ តត្ថ បុណ្ឌរីកា ច ឧប្បលា
មន្ទាលកេហិ សញ្ឆន្នា សោភន្តិ មម អស្សមំ ។

---

១ ម. អសោកបិណ្ឌិបារី ច ។ ២ ម. បុន្នាគា គិរិបុន្នាគាតិ ទិស្សន្តិ ។

ឧទេនត្ថេរាបទាន ទី ១០

ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង សម៉ពិភេទក៍ ពុទ្រា រាក់ខ្មៅ ល្មៀ ជាឈើមានផ្លែច្រើន នៅជិតអាស្រមរបស់ខ្ញុំ ។ ដើមក្ទាំពាក់ និងដើមចេក បញ្ចេញផ្កា ជិតអាស្រមរបស់ខ្ញុំនោះ ក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមអសោក វីរព្រឹក្ស និងដើមស្តៅ ជាឈើមានផ្ការីក ក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ដើមក្រូចឆ្មារ ក្រូចភ្វា និងតិមិរព្រឹក្ស មានផ្ការីក ក្នុងទីនោះ ក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ និគ្គុណ្ឋិព្រឹក្ស សរិនិគ្គុណ្ឋីព្រឹក្ស និងដើមចម្បា មានផ្ការីកក្នុងទីនោះ ក្លិនជាទិព្វសាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ស្រះបោក្ខរណីនៅជិត (អាស្រមនោះ) មានពួកសត្វចាក្រពាកឃុំគឹកកង ដេរដាសដោយផ្កាលំចង់ ផ្កាឈូកនិងផ្កាឧប្បល ។ (ស្រះបោក្ខរណីនោះ) មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់ល្អ ជាទីរីករាយនៃចិត្ត មានទឹកថ្លា ដូចជាកែវផលិក នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ឈូកក្រហម ឈូកស និងឧប្បល បញ្ចេញផ្កាក្នុងស្រះនោះ ដេរដាសដោយផ្កាលំចង់ទាំងឡាយ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។

បាឋីនា បាវុសា មច្ឆា ពលជា មុញ្ជរោហិតា
វិចរន្តារ តេ តត្ថ សោភន្តិ មម អស្សមំ ។
កុម្ភីលា សុំសុមារា ច កច្ឆបា ច គហា ពហូ
ឱគហា អជគរា ច សោភន្តិ មម អស្សមំ ។
បារេវតា រវិហំសា ចក្កវាកា នទីចរា
ទិន្ទិភា សាលិកា ចេវ[១] សោភន្តិ មម អស្សមំ ។
នយិតា[២] អម្ពគន្ធី ច កេតកា តត្ថ បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមំ ។
សីហា ព្យគ្ឃា ច ទីបី ច អច្ឆកោកតរច្ឆយោ
អនុសញ្ចរន្តា បវនេ សោភន្តិ មម អស្សមំ ។
ជដាភារេន ភរិតា អជិនុត្តរវាសិនោ
អនុសញ្ចរន្តា បវនេ សោភន្តិ មម អស្សមំ ។
អជិនានិ ធរា ឯកេ និបកា សន្តវុត្តិនោ
អប្បាហារា ច តេ សព្វេ សោភន្តិ មម អស្សមំ ។
ខារិកាជំ[៣] គហេត្វាន អជ្ឈោគយ្ហ វនំ តទា
មូលផលានិ ភុញ្ជន្តា វសន្តិ អស្សមេ តទា ។
ន តេ ទារុំ អាហរន្តិ ឧទកំ បាទធោវនំ
សព្វេសំ អានុភាវេន សយមេវាហរីយតិ ។

១ ម. ចេត្ថាតិ ទិស្សតិ ។ ២ ម. នយិកា ។ ៣ ម. ខារិភារំ ។

ពួកត្រីស្វាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីឆ្តិន ពួកត្រីទាំងនោះហែលទៅមកក្នុងស្រះនោះ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ក្រពើ ក្រពា អណ្តើកជាសត្វចាប់គេស៊ី និងពស់ថ្លាន់ ជាសត្វរួបរឹត នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ ពួកព្រាប ប្របឹក ចាក្រពាក ក្អែកទឹក ត្រដេវរិច និងសាលិកា នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ នយិតាព្រឹក្ស ស្វាយក្រអូប ដើមការកេត មានផ្ការីក ក្នុងទីនោះ ក្លិនជាទិព្វ សាយភាយទៅ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន ត្រាច់ទៅមករឿយ ៗ ក្នុងព្រៃធំ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ (ពួកតាបស) ពេញដោយភារៈគឺផ្នួងសក់ ស្លៀកពាក់សំពត់ស្បែកខ្លា ត្រាច់ទៅរឿយ ៗ ក្នុងព្រៃធំ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ តាបសពួកខ្លះ ទ្រទ្រង់ស្បែកខ្លា មានប្រាជ្ញាចាស់ ប្រព្រឹត្តស្ងប់រម្ងាប់ ជាអ្នកមានអាហារតិច តាបសទាំងអស់នោះ នាំឲ្យល្អអាស្រមរបស់ខ្ញុំ ។ គ្រានោះ តាបសទាំងនោះ កាន់យកនូវដងរែក និងសង្រែក ចូលទៅក្នុងព្រៃ បរិភោគមើមឈើនិងផ្លែឈើនៅជិតអាស្រមរបស់ខ្ញុំ ។ តាបសទាំងនោះ មិនបាននាំមកនូវឧស និងទឹកសម្រាប់លាងជើងឡើយ (វត្ថុទាំងនោះ) គឺទេវតានាំមកដោយខ្លួនឯង ដោយអានុភាព នៃតាបសទាំងអស់ ។

២៧១

ទសមំ ឧទេនត្ថេរាបទានំ

ចុល្លាសីតិសហស្សានិ ឥសយោ តត្ថ សមាគតា
សព្វេ ឈាយិនោ ឯតេ ឧត្តមត្ថំ គវេសិនោ(១) ។
តបស្សិនោ ព្រហ្មចារី ចោទេន្តា អប្បនាវ តេ
អម្ពរាវចរា សព្វេ វសន្តិ អស្សមេ តទា ។
បញ្ចាហំ សន្និបតន្តិ ឯកគ្គា សន្តវុត្តិនោ
អញ្ញមញ្ញំ អភិវាទេត្វា បក្កមន្តិ ទិសា មុខា ។
បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
តមន្ធការំ វិធមំ ឧប្បជ្ជិ តាវទេ ជិនោ ។
មម អស្សមសាមន្តា យក្ខោ អាសិ មហិទ្ធិកោ
សោ មេ សំសិត្ថ សម្ពុទ្ធំ ជលជុត្តមនាមកំ(២) ។
ឯស ពុទ្ធោ សមុប្បន្នោ បទុមុត្តរោ មហាមុនិ
ខិប្បំ គន្ត្វាន សម្ពុទ្ធំ បយិរុបាសស្សុ មារិស ។
យក្ខស្ស វចនំ សុត្វា វិប្បសន្នេន ចេតសា
អស្សមំ សំសាមេត្វាន និក្ខមឹ បវនា តទា ។

---
១ ម. គវេសកា ។ ២ ម. ជលជុត្តមនាយកំ ។

ពួកឥសី ៨៤ ពាន់រូប មកប្រជុំគ្នា ក្នុងទីនោះ ពួកឥសីទាំងអស់នុ៎ះ សុទ្ធតែជាអ្នកមានឈាន ស្វែងរកប្រយោជន៍ដ៏ឧត្តម ។ ក្នុងកាលនោះ ឥសីទាំងអស់នោះ ជាអ្នកមានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរ មានអប្បនាឈានជាស់តឿនហើយ ត្រាច់ទៅតាមអាកាស នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះ ជាអ្នកមានចិត្តនឹងធឹង មានកិរិយាប្រព្រឹត្តស្ងប់ ប្រជុំគ្នា អស់ ៥ ថ្ងៃ ថ្វាយបង្គំលាគ្នានិងគ្នា មានមុខឆ្ពោះទៅកាន់ទិស ហើយចៀសចេញទៅ ។ ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ឈ្នះសត្រូវព្រះអង្គកម្ចាត់បង់ងងឹត ទ្រង់កើតឡើង ក្នុងខណៈនោះ ។ មានយក្សមួយ មានឫទ្ធិច្រើន នៅជិតអាស្រមរបស់ខ្ញុំ យក្សនោះសរសើរព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ប្រាប់ខ្ញុំថា ព្រះពុទ្ធអង្គនុ៎ះ ជាមហាមុនី ព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងហើយ ម្នាលអ្នកនិទ៌ុក្ខ អ្នកចូរទៅគាល់ព្រះសម្ពុទ្ធ យ៉ាងឆាប់ ៗ ។ ខ្ញុំបានឮពាក្យយក្សហើយ មានចិត្តជ្រះថ្លា រៀបចំអាស្រមស្រេចហើយ ក៏ចេញអំពីព្រៃធំក្នុងកាលនោះ ។

ចេលេវ ឧយ្ហមានម្ហិ  និក្ខមិត្វាន អស្សមា
ឯការត្តឹ និវាសិត្វា  ឧបគញ្ឆឹ វិនាយកំ ។
បទុមុត្តរោ លោកវិទូ  អាហុតីនំ បដិគ្គហោ
ចតុសច្ចំ បកាសេន្តោ  ទេសេសិ អមតំ បទំ ។
សុផុល្លំ បទុមំ គយ្ហ  ឧបគន្ត្វា មហេសិនោ
បសន្នចិត្តោ សុមនោ  ពុទ្ធស្ស អភិវាទយឹ[១] ។
បូជយិត្វាន សម្ពុទ្ធំ  ជលជុត្តមនាយកំ
ឯកំសំ អជិនំ កត្វា  សន្ថវឹ លោកនាយកំ ។
យេន ញាណេន សម្ពុទ្ធោ  វសតីហ អនាសវោ
តំ ញាណំ កិត្តយិស្សាមិ  សុណាថ មម ភាសតោ ។
សំសារសោតំ ឆិន្ទិត្វា  តារេសិ សព្វបាណិនំ
តវ ធម្មំ សុណិត្វាន  តណ្ហាសោតំ តរន្តិ តេ ។
តុវំ សត្ថា ច កេតុវ  ធជោ យូបោវ បាណិនំ
បរាយនោ បតិដ្ឋាសិ  ទីបោ ច ទិបទុត្តមោ ។

១ ម. អភិរោបយឹ ។

កាលបើសំពត់ ត្រូវភ្លើងឆេះអស់ហើយ ខ្ញុំចេញអំពីអាស្រម នៅអស់មួយរាត្រី ហើយចូលទៅរកព្រះលោកនាយក ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវលោក គួរទទួលនូវគ្រឿងបូជា ទ្រង់កំពុងប្រកាសសច្ចៈ ៤ សម្តែងនូវអមតបទ គឺព្រះនិព្វាន ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ កាន់យកផ្កាឈូករីកល្អ ចូលទៅថ្វាយព្រះមហេសី ហើយថ្វាយបង្គំព្រះពុទ្ធ ។ ខ្ញុំបូជាព្រះសម្ពុទ្ធ ជាលោកនាយក ព្រះនាមបទុមុត្តរៈ រួចហើយធ្វើស្បែកខ្លាធៀងស្មាម្ខាង ហើយពោលសរសើរព្រះលោកនាយកថា ព្រះសម្ពុទ្ធ ជាបុគ្គលមិនមានអាសវៈ គង់នៅក្នុងទីនេះ ដោយញាណណា ខ្ញុំសរសើរនូវញាណនោះ អ្នកទាំងឡាយចូរស្តាប់ខ្ញុំនឹងសម្តែង ។ ព្រះអង្គកាត់នូវខ្សែសំសារវដ្តបានហើយ ទ្រង់ញុំាងសព្វសត្វទាំង-ឡាយ ឲ្យឆ្លងផុតបានទៀត ពួកសត្វទាំងនោះ ឆ្លងនូវខ្សែនៃតណ្ហាបាន ព្រោះតែបានស្តាប់ធម៌របស់ព្រះអង្គ ។ មិនតែប៉ុណ្ណោះ ព្រះអង្គជាគ្រូជាទីប្រព្រឹត្តទៅ ក្នុងលោកខាងមុខរបស់សត្វទាំងឡាយ ជាទីពឹង ជាប្រទីបដ៏ឧត្តមជាងសត្វជើងពីរ ដូចជាទង់ ឬដូចជាទង់ជ័យ ពុំនោះសោតដូចប្រាសាទ ។

២៧៣

### ទសមំ ឧទេនត្ថេរាបទានំ

យាវតា គណិនោ លោកេ សត្ថវាហា បវុច្ចរេ
តុវំ អគ្គោសិ សព្វញ្ញូ តវ អគ្គោគណាវ តេ ។
តវ ញាណេន សព្វញ្ញូ តារេសិ ជនតំ ពហុំ
តវ ទស្សនមាគម្ម ទុក្ខស្សន្តំ ករិស្សរេ ។
យេកេចិមេ គន្ធជាតា លោកេ វាយន្តិ ចក្ខុម
តវ គន្ធសមោ នត្ថិ បុញ្ញក្ខេត្តេ មហាមុនិ ។
តិរច្ឆានយោនឹ និរយំ បរិមោចេហិ ចក្ខុមា
អសង្ខតំ បទំ សន្តំ ទេសេសិ ត្វំ មហាមុនិ ។
បទុមុត្តរោ លោកវិទូ អាហុតីនំ បដិគ្គហោ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ ញាណំ អបូជេសិ បសន្នោ សេហិ ចាណិហិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

ពួកឈ្មួញជាច្រើនក្រុមទាំងប៉ុន្មានក្នុងលោក តែងពោលថា ព្រះអង្គជាបុគ្គលប្រសើរ ប្រកបដោយបញ្ញា ពួកជនទាំងនោះ សុទ្ធតែលុះក្នុងសំណាញ់ញាណ របស់ព្រះអង្គ ។ ព្រះអង្គ ប្រកបដោយបញ្ញា ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លងទុក្ខ ដោយ ញាណរបស់ព្រះអង្គ ជនទាំងឡាយ នឹងធ្វើនូវព្រះនិព្វានជា ទីបំផុតនៃទុក្ខបាន ព្រោះអាស្រ័យ នូវការឃើញព្រះអង្គ ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ក្លិនណានីមួយ តែងផ្សាយទៅ ក្នុងលោក បពិត្រព្រះមហាមុនី ក្លិននោះ ពុំស្មើដោយក្លិន របស់ព្រះអង្គជាបុញ្ញក្ខេត្តឡើយ ។ បពិត្រព្រះមហាមុនី ព្រះ អង្គមានចក្ខុ សូមញ៉ាំងពួកសត្វឲ្យរួច ចាកកំណើតតិរច្ឆាន និងនរក សូមសម្តែងនូវសន្តិបទ គឺព្រះនិព្វាន ឥតមានបច្ច័យ តាក់តែងឲ្យទាន ។

ព្រះលោកវិទូ ព្រះនាមបទុមុត្តរៈ ព្រះអង្គគួរទទួលនូវ គ្រឿងបូជា ទ្រង់គង់នៅក្នុងភិក្ខុសង្ឃ ហើយត្រាស់គាថា ទាំងនេះថា បុគ្គលណា មានចិត្តជ្រះថ្លា បានបូជាញាណ តថាគត ដោយដៃរបស់ខ្លួន តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែង ដូចតទៅនេះ

តឹសកប្បសហស្សានិ ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
សុលទ្ធលាភោ លទ្ធោម្ហិ តោសយិត្វាន សុព្វតំ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧទេនោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទេនត្ថេរស្ស អបទានំ សមត្តំ ។

បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់ កប្ប នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ។

ខ្ញុំជាអ្នកមានលាភ ដែលគេត្រូវបានដោយប្រពៃ បានហើយ ព្រោះបានញុំាងព្រះសម្ពុទ្ធ ព្រះអង្គមានវត្តដ៏ល្អឲ្យត្រេកអរ ខ្ញុំកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទេនត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទេនត្ថេរាបទាន ។

២៧៤

# ឧទ្ទានំ

មេត្តេយ្យោ បុណ្ណកោ ថេរោ មេត្តគូ ធោតកោបិ ច
ឧបសីវោ ច នន្ទោ ច ហេមកោ សត្តមោ តហឹ ។
តោទេយ្យោ ជតុកណ្ណី ច ឧទេនោ ច មហាយសោ
តីណិ គាថាសតានេត្ថ អសីតិ តីណិ ចុត្តរឹ ។

មេត្តេយ្យវគ្គោ ឯកចត្តាឡីសមោ ។

---

# ឧទ្ទាន

តិស្សមេត្តេយ្យត្ថេរាបទាន ១ បុណ្ណកត្ថេរាបទាន ១ មេត្តគុត្ថេរាបទាន ១ ធោតកត្ថេរាបទាន ១ ឧបសីវត្ថេរាបទាន ១ នន្ទកត្ថេរាបទាន ១ ហេមកត្ថេរាបទាន ១ ជាគម្រប់ ៧ ក្នុងអបទាននោះ ។ តោទេយ្យត្ថេរាបទាន ១ ជតុកណ្ណិកត្ថេរាបទាន ១ ឧទេនត្ថេរាបទាន ១ សុទ្ធតែមានយសច្រើន ក្នុងមេត្តេយ្យវគ្គនេះ មានគាថា ៣៨៣ ។

ចប់ មេត្តេយ្យវគ្គ ទី ៥១ ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស អបទានំ

# តតិយោ ភាគោ

---

## មាតិកាបត្តានិ

មាតិកា អង្កេ

### ឯកត្តឹសមោ បទុមកេសរិយវគ្គោ


បទុមកេសរិយវគ្គេ បឋមំ បទុមកេសរិយត្ថេរាបទានំ.................. ១
ទុតិយំ សព្វគន្ធិយត្ថេរាបទានំ....................... ២
តតិយំ បរមន្នទាយកត្ថេរាបទានំ.................. ៣
ចតុត្ថំ ធម្មសញ្ញកត្ថេរាបទានំ ........................ ៤
បញ្ចមំ ផលទាយកត្ថេរាបទានំ .................... ៥
ឆដ្ឋំ សម្បសាទិកត្ថេរាបទានំ........................ ៦
សត្តមំ អារាមទាយកត្ថេរាបទានំ.................. ៨
អដ្ឋមំ អនុលេបទាយកត្ថេរាបទានំ............... ៩
នវមំ ពុទ្ធសញ្ញិកត្ថេរាបទានំ ........................ ១០
ទសមំ បព្ភារទាយកត្ថេរាបទានំ .................. ១១

# សុត្តន្តបិដក
# ខុទ្ទកនិកាយ អបទាន
# តតិយភាគ

---

## សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

### បទុមកេសរិយវគ្គ ទី ៣១


*បទុមកេសរិយវគ្គ* *បទុមកេសរិយត្ថេរាបទាន ទី ១................. ១*

*សព្វគន្ធិយត្ថេរាបទាន ទី ២....................... ២*

*បរមន្នទាយកត្ថេរាបទាន ទី ៣................. ៣*

*ធម្មសញ្ញកត្ថេរាបទាន ទី ៤....................... ៤*

*ផលទាយកត្ថេរាបទាន ទី ៥...................... ៥*

*សម្បសាទិកត្ថេរាបទាន ទី ៦..................... ៦*

*អារាមទាយកត្ថេរាបទាន ទី ៧................. ៨*

*អនុលេបទាយកត្ថេរាបទាន ទី ៨.............. ៩*

*ពុទ្ធសញ្ញិកត្ថេរាបទាន ទី ៩....................... ១០*

*បព្ភារទាយកត្ថេរាបទាន ទី ១០ ................ ១១*

# មាតិកាបត្តានិ

មាតិកា អង្កេ

## ពត្តឹសោ អារក្ខទាយកវគ្គោ


អារក្ខទាយកវគ្គេ បឋមំ អារក្ខទាយកត្ថេរាបទានំ........................ ១៣
ទុតិយំ ភោជនទាយកត្ថេរាបទានំ...................... ១៤
តតិយំ គតសញ្ញកត្ថេរាបទានំ........................... ១៥
ចតុត្ថំ សត្តបទុមិយត្ថេរាបទានំ.......................... ១៦
បញ្ចមំ បុប្ផាសនទាយកត្ថេរាបទានំ.................... ១៧
ឆដ្ឋំ អាសនត្ថវិកត្ថេរាបទានំ.............................. ១៨
សត្តមំ សទ្ទសញ្ញកត្ថេរាបទានំ.......................... ២០
អដ្ឋមំ តិរំសិយត្ថេរាបទានំ................................. ២១
នវមំ នាលិបុប្ផិយត្ថេរាបទានំ............................. ២២
ទសមំ កុមុទមាលិយត្ថេរាបទានំ........................ ២៣


## តេត្តឹសោ ឧម្មាបុប្ផិយវគ្គោ


ឧម្មាបុប្ផិយវគ្គេ បឋមំ ឧម្មាបុប្ផិយត្ថេរាបទានំ............................ ២៥
ទុតិយំ បុឡិនបូជកត្ថេរាបទានំ.......................... ២៦
តតិយំ ហាសជនកត្ថេរាបទានំ.......................... ២៧

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

## អារក្ខទាយកវគ្គ ទី ៣២

អារក្ខទាយកវគ្គ អារក្ខទាយកត្ថេរាបទាន ទី ១........................ ១៣
ភោជនទាយកត្ថេរាបទាន ទី ២...................... ១៤
គតសញ្ញកត្ថេរាបទាន ទី ៣.......................... ១៥
សត្តបទុមិយត្ថេរាបទាន ទី ៤......................... ១៦
បុប្ផាសនទាយកត្ថេរាបទាន ទី ៥.................... ១៧
អាសនត្ថវិកត្ថេរាបទាន ទី ៦.......................... ១៨
សទ្ទសញ្ញកត្ថេរាបទាន ទី ៧.......................... ២០
តិរំសិយត្ថេរាបទាន ទី ៨................................ ២១
នាលិបុប្ផិយត្ថេរាបទាន ទី ៩.......................... ២២
កុមុទមាលិយត្ថេរាបទាន ទី ១០...................... ២៣

## ឧម្មាបុប្ផិយវគ្គ ទី ៣៣

ឧម្មាបុប្ផិយវគ្គ ឧម្មាបុប្ផិយត្ថេរាបទាន ទី ១............................ ២៥
បុឡិនបូជកត្ថេរាបទាន ទី ២.......................... ២៦
ហាសជនកត្ថេរាបទាន ទី ៣.......................... ២៧

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| ឱម្មាបុប្ផិយវគ្គេ | ចតុត្ថំ យញ្ញសាមិកត្ថេរាបទានំ | ២៨ |
| | បញ្ចមំ និមិត្តសញ្ញកត្ថេរាបទានំ | ៣០ |
| | ឆដ្ឋំ អន្នសំសាវកត្ថេរាបទានំ | ៣១ |
| | សត្តមំ និគ្គុណ្ឌិបុប្ផិយត្ថេរាបទានំ | ៣២ |
| | អដ្ឋមំ សុមនាវេឡិយត្ថេរាបទានំ | ៣៦ |
| | នវមំ បុប្ផច្ឆត្តិយត្ថេរាបទានំ | ៣៨ |
| | ទសមំ សបរិវារច្ឆត្តទាយកត្ថេរាបទានំ | ៣៩ |


## ចតុត្តឹសោ គន្ធោទកវគ្គោ


| | | |
|---|---|---|
| គន្ធោទកវគ្គេ | បឋមំ គន្ធធូបិយត្ថេរាបទានំ | ៤៤ |
| | ទុតិយំ ឧទកបូជកត្ថេរាបទានំ | ៤៥ |
| | តតិយំ បុន្នាគបុប្ផិយត្ថេរាបទានំ | ៤៦ |
| | ចតុត្ថំ ឯកទុស្សទាយកត្ថេរាបទានំ | ៤៧ |
| | បញ្ចមំ ផុសិតកម្មិយត្ថេរាបទានំ | ៥១ |
| | ឆដ្ឋំ បភង្ករត្ថេរាបទានំ | ៥៣ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| ឧម្មាបុប្ផិយវគ្គ | យញ្ញសាមិកត្ថេរាបទាន ទី ៤.......................... | ២៨ |
| | និមិត្តសញ្ញកត្ថេរាបទាន ទី ៥.......................... | ៣០ |
| | អន្នសំសាវកត្ថេរាបទាន ទី ៦.......................... | ៣១ |
| | និគ្គុណ្ឌិបុប្ផិយត្ថេរាបទាន ទី ៧....................... | ៣២ |
| | សុមនាវេឡិយត្ថេរាបទាន ទី ៨....................... | ៣៦ |
| | បុប្ផច្ឆត្តិយត្ថេរាបទាន ទី ៩.............................. | ៣៨ |
| | សបរិវារច្ឆត្តទាយកត្ថេរាបទាន ទី ១០............ | ៣៩ |

## គន្ធោទកវគ្គ ទី ៣៤

| | | |
|---|---|---|
| គន្ធោទកវគ្គ | គន្ធធូបិយត្ថេរាបទាន ទី ១.............................. | ៤៤ |
| | ឧទកបូជកត្ថេរាបទាន ទី ២.............................. | ៤៥ |
| | បុន្នាគបុប្ផិយត្ថេរាបទាន ទី ៣......................... | ៤៦ |
| | ឯកទុស្សទាយកត្ថេរាបទាន ទី ៤..................... | ៤៧ |
| | ផុស្សិតកម្មិយត្ថេរាបទាន ទី ៥......................... | ៥១ |
| | បភង្ករត្ថេរាបទាន ទី ៦................................... | ៥៣ |

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| គន្ធោទកវគ្គេ | សត្តមំ តិណកុដិទាយកត្ថេរាបទានំ................... | ៥៦ |
| | អដ្ឋមំ ឧត្តរេយ្យទាយកត្ថេរាបទានំ..................... | ៥៨ |
| | នវមំ ធម្មស្សវនិយត្ថេរាបទានំ........................... | ៦២ |
| | ទសមំ ឧក្ខិត្តបទុមិយត្ថេរាបទានំ........................ | ៦៥ |

## បញ្ចត្តឹសោ ឯកបទុមវគ្គោ

| | | |
|---|---|---|
| ឯកបទុមវគ្គេ | បឋមំ ឯកបទុមិយត្ថេរាបទានំ........................... | ៦៨ |
| | ទុតិយំ តិណុប្បលមាលិយត្ថេរាបទានំ.............. | ៦៩ |
| | តតិយំ ធជទាយកត្ថេរាបទានំ........................... | ៧១ |
| | ចតុត្ថំ តីណិកិង្កណិបូជកត្ថេរាបទានំ................ | ៧២ |
| | បញ្ចមំ នឡាគារិកត្ថេរាបទានំ........................... | ៧៣ |
| | ឆដ្ឋំ ចម្បកបុប្ផិយត្ថេរាបទានំ............................ | ៧៤ |
| | សត្តមំ បទុមបូជកត្ថេរាបទានំ........................... | ៧៥ |
| | អដ្ឋមំ តិណមុដ្ឋិទាយកត្ថេរាបទានំ.................... | ៧៦ |
| | នវមំ តិន្ទុកផលទាយកត្ថេរាបទានំ................... | ៧៨ |
| | ទសមំ ឯកញ្ជលិយត្ថេរាបទានំ.......................... | ៧៩ |

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ


គន្ធោទកវគ្គ តិណកុដិទាយកត្ថេរាបទាន ទី ៧.................... ៥៦
ឧត្តរេយ្យទាយកត្ថេរាបទាន ទី ៨.................... ៥៨
ធម្មស្សវនិយត្ថេរាបទាន ទី ៩.......................... ៦២
ឧក្ខិត្តបទុមិយត្ថេរាបទាន ទី ១០...................... ៦៥

## ឯកបទុមវគ្គ ទី ៣៥

ឯកបទុមវគ្គ ឯកបទុមិយត្ថេរាបទាន ទី ១........................... ៦៨
តិណុប្បលមាលិយត្ថេរាបទាន ទី ២............... ៦៩
ធជទាយកត្ថេរាបទាន ទី ៣........................... ៧១
តីណិកិង្កណិបូជកត្ថេរាបទាន ទី ៤................ ៧២
នឡាគារិកត្ថេរាបទាន ទី ៥............................ ៧៣
ចម្បកបុប្ផិយត្ថេរាបទាន ទី ៦.......................... ៧៤
បទុមបូជកត្ថេរាបទាន ទី ៧............................ ៧៥
តិណមុដ្ឋិទាយកត្ថេរាបទាន ទី ៨.................... ៧៦
តិន្ទុកផលទាយកត្ថេរាបទាន ទី ៩.................. ៧៨
ឯកញ្ជលិយត្ថេរាបទាន ទី ១០........................ ៧៩

# មាតិកាបត្តានិ

## មាតិកា អង្កេ

## ឆត្តឹសោ សទ្ធសញ្ញិកវគ្គោ


*សទ្ធសញ្ញិកវគ្គេ បឋមំ សទ្ធសញ្ញិកត្ថេរាបទានំ............................ ៨១*

*ទុតិយំ យវកលាបិយត្ថេរាបទានំ....................... ៨២*

*តតិយំ កឹសុកបូជកត្ថេរាបទានំ.......................... ៨៣*

*ចតុត្ថំ សកោដកកោរណ្ឌទាយកត្ថេរាបទានំ....... ៨៤*

*បញ្ចមំ ទណ្ឌទាយកត្ថេរាបទានំ........................ ៨៥*

*ឆដ្ឋំ អម្ពយាគុទាយកត្ថេរាបទានំ....................... ៨៦*

*សត្តមំ បុដកបូជកត្ថេរាបទានំ........................... ៨៧*

*អដ្ឋមំ វច្ឆទាយកត្ថេរាបទានំ............................. ៨៨*

*នវមំ សរណាគមនិយត្ថេរាបទានំ...................... ៨៩*

*ទសមំ បិណ្ឌបាតិកត្ថេរាបទានំ.......................... ៨៩*


## សត្តត្តឹសោ មន្ទារវបុប្ផិយវគ្គោ


*មន្ទារវបុប្ផិយវគ្គេ បឋមំ មន្ទារវិយត្ថេរាបទានំ............................... ៩១*

*ទុតិយំ កក្ការុបុប្ផិយត្ថេរាបទានំ.......................... ៩២*

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## សទ្ទសញ្ញិកវគ្គ ទី ៣៦

សទ្ទសញ្ញិកវគ្គ សទ្ទសញ្ញិកត្ថេរាបទាន ទី ១ ........................... ៨១
យវកលាបិយត្ថេរាបទាន ទី ២ ........................ ៨២
កឹសុកបូជកត្ថេរាបទាន ទី ៣ .......................... ៨៣
សកោដកកោរណ្ឌទាយកត្ថេរាបទាន ទី ៤ ...... ៨៤
ទណ្ឌទាយកត្ថេរាបទាន ទី ៥.......................... ៨៥
អម្ពយាគុទាយកត្ថេរាបទាន ទី ៦ .................... ៨៦
បុដកបូជកត្ថេរាបទាន ទី ៧ ............................ ៨៧
វច្ឆទាយកត្ថេរាបទាន ទី ៨ .............................. ៨៨
សរណាគមនិយត្ថេរាបទាន ទី ៩ .................... ៨៩
បិណ្ឌបាតិកត្ថេរាបទាន ទី ១០ ........................ ៨៩

## មន្ទារវបុប្ផិយវគ្គ ទី ៣៧

មន្ទារវបុប្ផិយវគ្គ មន្ទារវិយត្ថេរាបទាន ទី ១ ............................... ៩១
កក្ការុបុប្ផិយត្ថេរាបទាន ទី ២ .......................... ៩២

# មាតិកាបត្តានិ

| មាតិកា | | អង្កេ |
|---|---|---|

មន្ទារវបុប្ផិយវគ្គេ តតិយំ ភិសមុឡាលទាយកត្ថេរាបទានំ............. ៩២
ចតុត្ថំ កេសរបុប្ផិយត្ថេរាបទានំ......................... ៩៣
បញ្ចមំ អង្កោលបុប្ផិយត្ថេរាបទានំ ..................... ៩៤
ឆដ្ឋំ កទម្ពបុប្ផិយត្ថេរាបទានំ ............................ ៩៥
សត្តមំ ឧទ្ទាលកបុប្ផិយត្ថេរាបទានំ..................... ៩៦
អដ្ឋមំ ឯកចម្បកបុប្ផិយត្ថេរាបទានំ .................... ៩៦
នវមំ តិមិរបុប្ផិយត្ថេរាបទានំ.............................. ៩៧
ទសមំ សលឡបុប្ផិយត្ថេរាបទានំ....................... ៩៨

## អដ្ឋត្តឹសោ ពោធិវន្ទនវគ្គោ

ពោធិវន្ទនវគ្គេ បឋមំ ពោធិវន្ទកត្ថេរាបទានំ.............................. ១០០
ទុតិយំ បាដលិបុប្ផិយត្ថេរាបទានំ ....................... ១០១
តតិយំ តីណុប្បលមាលិយត្ថេរាបទានំ.............. ១០២
ចតុត្ថំ បត្តិបុប្ផិយត្ថេរាបទានំ.............................. ១០៤
បញ្ចមំ សត្តបណ្ណិយត្ថេរាបទានំ ........................ ១០៥

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

មន្ទារវបុប្ផិយវគ្គ ភិសមុឡាលទាយកត្ថេរាបទាន ទី ៣............. ៩២
កេសរបុប្ផិយត្ថេរាបទាន ទី ៤.......................... ៩៣
អង្កោលបុប្ផិយត្ថេរាបទាន ទី ៥...................... ៩៤
កទម្ពបុប្ផិយត្ថេរាបទាន ទី ៦ .......................... ៩៥
ឧទ្ទាលកបុប្ផិយត្ថេរាបទាន ទី ៧..................... ៩៦
ឯកចម្បកបុប្ផិយត្ថេរាបទាន ទី ៨.................... ៩៦
តិមិរបុប្ផិយត្ថេរាបទាន ទី ៩............................ ៩៧
សលឡបុប្ផិយត្ថេរាបទាន ទី ១០..................... ៩៨

## ពោធិវន្ទនវគ្គ ទី ៣៨

ពោធិវន្ទនវគ្គ ពោធិវន្ទកត្ថេរាបទាន ទី ១.............................. ១០០
បាដលិបុប្ផិយត្ថេរាបទាន ទី ២ ........................ ១០១
តីណុប្បលមាលិយត្ថេរាបទាន ទី ៣.............. ១០២
បត្តិបុប្ផិយត្ថេរាបទាន ទី ៤.............................. ១០៤
សត្តបណ្ណិយត្ថេរាបទាន ទី ៥.......................... ១០៥

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| ពោធិវន្ទនវគ្គេ | ឆដ្ឋំ គន្ធមុដ្ឋិយត្ថេរាបទានំ | ១០៦ |
| | សត្តមំ ចិតកបូជកត្ថេរាបទានំ | ១០៧ |
| | អដ្ឋមំ សុមនតាលវណ្ដិយត្ថេរាបទានំ | ១០៨ |
| | នវមំ សុមនទាមិយត្ថេរាបទានំ | ១០៩ |
| | ទសមំ កាសុមារិផលទាយកត្ថេរាបទានំ | ១១០ |


## ឯកូនចត្តាឡីសោ អម្ពដផលវគ្គោ


| | | |
|---|---|---|
| អម្ពដផលវគ្គេ | បឋមំ អម្ពដផលទាយកត្ថេរាបទានំ | ១១២ |
| | ទុតិយំ លពុជទាយកត្ថេរាបទានំ | ១១៣ |
| | តតិយំ ឧទុម្ពរផលទាយកត្ថេរាបទានំ | ១១៤ |
| | ចតុត្ថំ មិលក្ខុផលទាយកត្ថេរាបទានំ | ១១៦ |
| | បញ្ចមំ ផារុសផលទាយកត្ថេរាបទានំ | ១១៧ |
| | ឆដ្ឋំ វល្លិផលទាយកត្ថេរាបទានំ | ១១៨ |
| | សត្តមំ កទលិផលទាយកត្ថេរាបទានំ | ១១៩ |
| | អដ្ឋមំ បនសផលទាយកត្ថេរាបទានំ | ១២០ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ


ពោធិវន្ទនវគ្គ គន្ធមុដ្ឋិយត្ថេរាបទាន ទី ៦.............................. ១០៦
ចិតកបូជកត្ថេរាបទាន ទី ៧............................ ១០៧
សុមនតាលវណ្ដិយត្ថេរាបទាន ទី ៨............... ១០៨
សុមនទាមិយត្ថេរាបទាន ទី ៩ ........................ ១០៩
កាសុមារិផលទាយកត្ថេរាបទាន ទី ១០.......... ១១០


## អម្ពដផលវគ្គ ទី ៣៩


អម្ពដផលវគ្គ អម្ពដផលទាយកត្ថេរាបទាន ទី ១.................. ១១២
លពុជទាយកត្ថេរាបទាន ទី ២........................១១៣
ឧទុម្ពរផលទាយកត្ថេរាបទាន ទី ៣ ............... ១១៤
មិលក្ខុផលទាយកត្ថេរាបទាន ទី ៤ ................ ១១៦
ផារុសផលទាយកត្ថេរាបទាន ទី ៥................. ១១៧
វល្លិផលទាយកត្ថេរាបទាន ទី ៦...................... ១១៨
កទលិផលទាយកត្ថេរាបទាន ទី ៧ ................ ១១៩
បនសផលទាយកត្ថេរាបទាន ទី ៨................. ១២០

# មាតិកាបត្តានិ

មាតិកា អង្កេ

*អម្ពជផលវគ្គេ នវមំ សោណកោដិវីសត្ថេរាបទានំ.................... ១២១*

*ទសមំ បុព្វកម្មបិលោតិ នាម ពុទ្ធាបទានំ ....... ១២៤*

## ចត្តាឡីសោ បិលិន្ទវគ្គោ

*បិលិន្ទវគ្គេ បឋមំ បិលិន្ទវច្ឆត្ថេរាបទានំ............................... ១៣០*

*ទុតិយំ សេលត្ថេរាបទានំ.................................. ១៦៣*

*តតិយំ សព្វកិត្តិកត្ថេរាបទានំ............................ ១៧៩*

*ចតុត្ថំ មធុទាយកត្ថេរាបទានំ............................ ១៨៣*

*បញ្ចមំ បទុមកូដាគារិកត្ថេរាបទានំ .................... ១៨៧*

*ឆដ្ឋំ ពក្កុលត្ថេរាបទានំ ...................................... ១៩២*

*សត្តមំ គិរិមានន្ទត្ថេរាបទានំ .............................. ១៩៧*

*អដ្ឋមំ សលឡមណ្ឌបិយត្ថេរាបទានំ.................. ២០២*

*នវមំ សព្វទាយកត្ថេរាបទានំ............................ ២០៣*

*ទសមំ អជិតត្ថេរាបទានំ .................................... ២០៨*

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

អម្ពជផលវគ្គ សោណកោដិវីសត្ថេរាបទាន ទី ៩................... ១២១
បុព្វកម្មបិលោតិ នាម ពុទ្ធាបទាន ទី ១០...... ១២៤

## បិលិន្ទវគ្គ ទី ៤០

បិលិន្ទវគ្គ បិលិន្ទវច្ឆត្ថេរាបទាន ទី ១ ................................ ១៣០
សេលត្ថេរាបទាន ទី ២...................................១៦៣
សព្វកិត្តិកត្ថេរាបទាន ទី ៣.............................១៧៩
មធុទាយកត្ថេរាបទាន ទី ៤.............................១៨៣
បទុមកូដាគារិកត្ថេរាបទាន ទី ៥ ......................១៨៧
ពក្កុលត្ថេរាបទាន ទី ៦ .................................... ១៩២
គិរិមានន្ទត្ថេរាបទាន ទី ៧ ...............................១៩៧
សលឡមណ្ឌបិយត្ថេរាបទាន ទី ៨ ................. ២០២
សព្វទាយកត្ថេរាបទាន ទី ៩............................២០៣
អជិតត្ថេរាបទាន ទី ១០ .................................. ២០៨

# មាតិកាបត្ថានិ

## មាតិកា អង្កេ

## ឯកចត្តាឡីសមោ មេត្តេយ្យវគ្គោ


*មេត្តេយ្យវគ្គេ បឋមំ តិស្សមេត្តេយ្យត្ថេរាបទានំ........................ ២១៥*

*ទុតិយំ បុណ្ណកត្ថេរាបទានំ................................ ២១៩*

*តតិយំ មេត្តគុត្ថេរាបទានំ .................................. ២២២*

*ចតុត្ថំ ធោតកត្ថេរាបទានំ ..................................២២៧*

*បញ្ចមំ ឧបសីវត្ថេរាបទានំ.................................២៣១*

*ឆដ្ឋំ នន្ទកត្ថេរាបទានំ......................................... ២៤១*

*សត្តមំ ហេមកត្ថេរាបទានំ ................................ ២៤៤*

*អដ្ឋមំ តោទេយ្យត្ថេរាបទានំ .............................. ២៥១*

*នវមំ ជតុកណ្ណិកត្ថេរាបទានំ.............................. ២៦០*

*ទសមំ ឧទេនត្ថេរាបទានំ.................................. ២៦៨*

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

## មេត្តេយ្យវគ្គ ទី ៩១


មេត្តេយ្យវគ្គ តិស្សមេត្តេយ្យត្ថេរាបទាន ទី ១ ........................ ២១៥

បុណ្ណកត្ថេរាបទាន ទី ២ .................................. ២១៩

មេត្តគុត្ថេរាបទាន ទី ៣ .................................. ២២២

ធោតកត្ថេរាបទាន ទី ៤ .................................. ២២៧

ឧបសីវត្ថេរាបទាន ទី ៥ .................................. ២៣១

នន្ទកត្ថេរាបទាន ទី ៦ ...................................... ២៤១

ហេមកត្ថេរាបទាន ទី ៧ .................................. ២៤៤

តោទេយ្យត្ថេរាបទាន ទី ៨ .............................. ២៥១

ជតុកណ្ណិកត្ថេរាបទាន ទី ៩ ............................ ២៦០

ឧទេនត្ថេរាបទាន ទី ១០ .................................. ២៦៨

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៨៨៧ ៩៦១ ៩២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

***"Wherever the Buddha's teachings have flourished,***

***either in cities or countrysides,***

***people would gain inconceivable benefits.***

***The land and people would be enveloped in peace.***

***The sun and moon will shine clear and bright.***

***Wind and rain would appear accordingly,***

***and there will be no disasters.***

***Nations would be prosperous***

***and there would be no use for soldiers or weapons.***

***People would abide by morality and accord with laws.***

***They would be courteous and humble,***

***and everyone would be content without injustices.***

***There would be no thefts or violence.***

***The strong would not dominate the weak***

***and everyone would get their fair share."***

**~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~**

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**